# ការស្វែងយល់
# អំពីរបត់ព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរ
## The understanding of Buddhism Khmer society
## ភាគ ២



រៀបចំសម្រិតសម្រាំង និងបោះពុម្ពដោយ បណ្ឌិត ខ្លូត ធីតា
Selected Reading by Dr. KHLOT THYDA

រក្សាសិទ្ធ

ព.ស.២៥៤៧ គ.ស.២០០៣

# ការស្វែងយល់
# អំពីរបត់ព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរ

The understanding of Buddhism Khmer society

បោះពុម្ពចំនួន ៥០០ ច្បាប់
រោងពុម្ព វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

រៀបចំសម្រិតសម្រាំង និងបោះពុម្ព ដោយបណ្ឌិត ខ្លូត ធីតា
Selected Reading by Dr. KHLOT THYDA

00009602
បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ភាគ ទី២

រក្សាសិទ្ធិ

ព.ស.២៥៤៧ គ.ស.២០០៣

# ការស្វែងយល់អ័ពីរបត់ព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរ

## The understanding of Buddhism in Khmer Society


រៀបចំសម្រិតសម្រាំង និងបោះពុម្ពដោយ ខ្លូត ធីតា

(បណ្ឌិតវិទ្យាសាស្ត្រទស្សនវិជ្ជា)

Selected reading by Dr. KHLOT THYDA

អនុប្រធានវិទ្យាស្ថានសង្គមសាស្ត្រ

និងមនុស្សសាស្ត្រនៃរាជបណ្ឌិតសភាកម្ពុជា

សមាជិកពេញសិទ្ធនៃរាជបណ្ឌិតសភាកម្ពុជា

សាស្ត្រាចារ្យ វិទ្យាសាស្ត្រ ទស្សនវិជ្ជា


- ពិនិត្យអក្ខរាវិរុទ្ធដោយៈ

  លោក **ម៉ន សម្បត្តិ** : មន្ត្រីក្រសួងសាធារណការ

- កុំព្យូទ័រដោយ :

  អ្នកស្រី **មុត សៅរ៉េត្ន័** : បរិញ្ញាប័ត្រពិតមានវិទ្យា( រាជបណ្ឌិតសភាកម្ពុជា)،

  ក. **កែវ ខេមរា** : និស្សិតទស្សនវិជ្ជា ជំនាន់ទី២១ (២000-0៤)

  សកលវិទ្យាល័យភូមិភ្នំពេញមណ្ឌល២


**រក្សាសិទ្ធិ**



**រាជបណ្ឌិតសភាកម្ពុជា ព.ស.២៥៤៧ គ.ស. ២០០៣**

# មាតិកា

ទំព័រ


ឧបត្ថម្ភកថា

សេចក្តីថ្លែងអំណរគុណ

អារម្ភកថា

សេចក្តីផ្តើម............................................................................................................១

**I.** ពុទ្ធសាសនា និងប្រជាជនខ្មែរ..................................................................១០

**II.** វត្តអារាមក្លាយជាមជ្ឈមណ្ឌលវប្បធម៌ជាតិខ្មែរ.......................................២៦

-ជំពូកទី២: អំពីបុណ្យ.................................................................................៣៣

I. បំភ្លឺបុណ្យ....................................................................................................៣៤

- រូបភាព

II. ព្រះរាជពិធីទ្វាទសមាស..................................................................................៤៦

III. សង្ខេបបុណ្យ បែបព្រះពុទ្ធសាសនាក្នុងជំនឿទំនៀមទម្លាប់ខ្មែរ.................៥៣

១-ពិធីបុណ្យ ព.ស ២៥០០ នៃប្រទេសកម្ពុជា...................................៥៣

២-ពិធីច្រៀងបទ លើកទង់ជ័យព្រះពុទ្ធសាសនា...................................៥៤

៣-បុណ្យក្នុងគ្រួសារលោកម្ចាស់ និង អភិជន.......................................៥៥

៤-ពិធីបំបួសនាគ.................................................................................៦៤

៥-ពិធីចូលព្រះវស្សា............................................................................៦៧

៦-ទំនៀមរាស្ត្រ.....................................................................................៦៩

៧-បវារណាចេញវស្សា..........................................................................៧២

៨-បុណ្យនៅរដូវអស់ទឹកភ្លៀង................................................................៧៣

៩-កឋិនទានានិសង្សកថា.....................................................................៧៨

១០-អំពីសេនាសនទាន...........................................................................៧៨

១១-បុណ្យកតញ្ញូកតវេទី.........................................................................៨១

១២-បុណ្យបញ្ចុះសីមា.............................................................................៨៣

១៣-ពិធីបុណ្យផ្លូវផ្សេងៗ..........................................................................៨៧

១៤-ប្រវត្តិលោកអភិធម្ម និងលោកមាតិកានៅពេលដង្ហែសព.....................៨៨

១៥-ប្រវត្តិទាក់ទងនិងទៀនកាល្ប នៅពេលមានមនុស្សស្លាប់.............៨៩
១៦-បុណ្យភ្ជុំបិណ្ឌ..........................................................................៩១
១៧-បុណ្យពិសាខបូជា....................................................................៩៣
១៨-បុណ្យមាឃបូជា......................................................................៩៤
១៩-បុណ្យចូលឆ្នាំ..........................................................................៩៦
២០-បុណ្យទេសនាមហាជាតិ............................................................៩៨
២១-បុណ្យទេសនាភិសេក...............................................................៩៩
២២-បុណ្យចំរើនព្រះជន្ម..................................................................១០២
២៣-បុណ្យឈាបនកិច្ច.....................................................................១០៣
២៤-បុណ្យឆាកបង្សុកូល..................................................................១០៧
២៥-បុណ្យឆាកម្យ៉ាងទៀត................................................................១១០
២៦-អំពីបុណ្យអុំទូក អកអំបុក សំពះព្រះខែ បណ្តែតប្រទីប...............១១២
២៧-បុណ្យភេសជ្ជទាន....................................................................១១៦
២៨-បុណ្យសលាភត្ត.......................................................................១១៧
២៩-បុណ្យសង្ឃភត្ត........................................................................១១៨
៣០-បុណ្យឆ្លង................................................................................១១៩
៣១-ព្រះរាជពិធីច្រត់ព្រះនង្គ័ល.............................................................១២១
៣២-បុណ្យអ្នកតា...........................................................................១២៤
៣៣-បុណ្យសង្ឃទាន.......................................................................១២៧
៣៤-បុណ្យបច្ច័យបួន.......................................................................១៣១
៣៥-ពិធីត្រិស្តសង្ក្រាន.......................................................................១៣៣
៣៦-បុណ្យផ្កា..................................................................................១៣៥
៣៧-បុណ្យមតកភត្ត........................................................................១៣៧
៣៨-បុណ្យវេរសាដកនៅរដូវចូលឆ្នាំ......................................................១៣៨
៣៩-អំពីសង្ឃកម្ម...........................................................................១៣៩
៤០-ឧបោសថកម្ម...........................................................................១៤២

* វណ្ណកម្ម

* ឯកសារពិគ្រោះ

# ឧបត្ថម្ភកថា

នាងខ្ញុំ មហាឧបាសិកា **ញឹក ប៊ុនថា** ជាអនុប្រធានក្រុមប្រឹក្សាភិបាលសមាពន្ធ័យុវពុទ្ធសាសនិក ជាសមាជិកនាយក ជាព្រធានគណកម្មការប្រជាសង្គ្រោះ សមាគមពុទ្ធកកម្ពុជា នឹងជាអ្នកឧបត្ថម្ភ កម្មវិធីស្វែងយល់ព្រះពុទ្ធសាសនា ព្រមទាំងឧបាសិកា **ម៉ែន សុភាវី** និងក្រុមគ្រួសារ បានមានសទ្ធាជ្រះថ្លាផ្តល់វិភាគទានជាបច្ច័យបោះពុម្ពសៀវភៅ "ការស្វែងយល់អំពីរបត់ព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរ "ភាគទី២" **ចំនួន ៤០០ ក្បាល** ដែលសរសេរដោយលោកស្រី បណ្ឌិត **ខ្លូត ធីតា** ដើម្បីចែកជាធម្មទានដល់សង្ឃសាសនិក ពុទ្ធសាសនិក អ្នកអានអ្នកស្រាវជ្រាវ ជាទីគោរពរាប់អាន ។

ដោយអំណាចនៃបុញ្ញកម្មនេះ សូមឧទ្ទិសកុសលមានដូចតទៅ :

- សូមឱ្យប្រទេសកម្ពុជា បានសុខសន្តិភាពជានិរន្តរ៍ ។
- សូមឱ្យព្រះពុទ្ធសាសនា បានរុងរឿងនិងស្ថិតស្ថេរក្នុងលោកអស់កាលជាយូរអង្វែង ។
- សូមឱ្យសត្វលោកទូទៅទាំងអស់ បានសេចក្តីចម្រើនគ្រប់ប្រការ ។
- សូមឱ្យខ្ញុំបានជាព្រះអរហន្តសម្មាសម្ពុទ្ធ ១ព្រះអង្គ ទៅក្នុងអនាគតជាតិ ដើម្បីជួយចម្លងសត្វលោកឱ្យរួចចាកសេចក្តីទុក្ខ ។

ពុទ្ធសាសនបណ្ឌិត្យ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៣

មហាឧបាសិកា **ញឹក ប៊ុនថា**

# សេចក្ដីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណដល់មហាឧបាសិកា **ញ៉ឹក ម៉ុនថា** ព្រមទាំងគ្រួសារ
និងប្អូនឈ្មោះឧបាសិកា **ម៉ែន សុភារី** ដែលមានសទ្ធាជ្រះថ្លា
ផ្ដល់វិភាគទានជាបច្ច័យបោះពុម្ពសៀវភៅ "ការស្វែងយល់ អំពីរបត់ព្រះពុទ្ធសាសនា
នៅក្នុងសង្គមខ្មែរ " ភាគទី២ ចំនួន ៤០០ ក្បាល និងលោក **ម៉ែន សម្បត្តិ** ចំនួន ១០០ ក្បាល
សំរាប់ចែកជូនធម្មទាន ( សរុប ៥០០ ក្បាល )

រាជបណ្ឌិតសភា ថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៣ ព.ស. ២៥៤៧

បណ្ឌិត **ខ្លូត ធីតា**

# អារម្ភកថា

សៀវភៅ "ការស្វែងយល់អំពីព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ ភាគទី២ សង្កត់ទៅលើវត្តអារាម និងបុណ្យ " ត្រូវបានបោះពុម្ពផ្សាយឆ្នាំ ២០០៣ ក្រោយពេលសន្និសិទកំពូល ពុទ្ធសាសនាលើកទី៣ ដែលបានប្រារព្ធឡើងនៅទីក្រុងភ្នំពេញ មានប្រទេសគោរពព្រះពុទ្ធសាសនា លើសកលលោក ចំនួន ១៥ប្រទេស ដើម្បីឆ្លុះបញ្ចាំងនូវកង្វះខាត ខាងអ្វីដែលហួសសម័យ (យឺត) អ្វីដែលលឿនជ្រុល (បរទេស) អ្វីជាយើង អ្វីមិនមែនយើង។ ក្រោយពេលខ្ញុំបោះពុម្ពលើកទី១ ទី២ ភាគទី១ ខ្ញុំគិតថា ការរួមចំណែករបស់ខ្ញុំហាក់ដូចជានៅខ្វះអ្វីទៀត ប៉ុន្តែនិយាយបែបនេះ មិនមែនមានន័យថាគ្រប់សព្វជ្រុងជ្រោយទេ ។ សៀវភៅទាំងភាគទី១ ទី២នេះ គ្រាន់តែអ្នកនិពន្ធខិតខំ នាំអ្នកអានអ្នកស្រាវជ្រាវជំនាន់ក្រោយ ពិចារណារួមគ្នានូវអ្វី ដែលកប់បាត់ក្នុងស្រទាប់នៃការប្រតិបត្តិជាយូរលង់ហើយ ហើយយើងចេះតែស្រែកដាក់គ្នា ថាក្រុមនេះខុស ក្រុមនោះត្រូវតាមពិត ក្នុងបញ្ហានេះ យើងខ្វះខាតទាំងអស់គ្នា ។ ដូនតាយើងគាត់បានរៀបចំផ្លូវ ជាច្រើនមកហើយ សម្រាប់អ្នកមិនចេះ គាត់អប់រំយ៉ាងណា អ្នកចេះតិចអប់រំត្រឹមណា អ្នកចេះច្រើនអប់រំដល់កំរិតណា ។ ប៉ុន្តែយើងជំនាន់ក្រោយ មិនទាន់បានបំពេញលក្ខណ្ឌនេះបានល្អ។ កត្តាសំខាន់ជាងនេះគឺ យល់ស្គាល់ឱកាស ស្គាល់ខ្លួនឯង ស្គាល់បញ្ញត្តិ ស្គាល់ឫស្សព្រះធម៌ ឱ្យបានច្បាស់ ។ កំហុសនេះ គេមិនអាចទម្លាក់ទៅលើពុទ្ធសាសនាខ្មែរណាមួយឡើយ។ គួរកាត់បន្ថយការធ្វើពិធីអ្វីមួយគ្មានច្បាស់លាស់ គឺ ធ្វើទៅតាមតែទឹកប្រាក់។ ព្រោះវត្តអារាមនិងបុណ្យ សុទ្ធតែឫសគល់នៃវប្បធម៌ជាតិទាំងអស់ ។

ខ្ញុំមានជំនឿថា ក្នុងពេលណា កាលៈទេសៈណាដែលពុទ្ធសាសនិកខ្មែរបានចេះចងចាំខ្លឹមសារពិត នៃវត្ត នៃបុណ្យ នៃព្រះពុទ្ធសាសនា ពេលនោះខ្មែរមុខជាមានជំនឿជឿលើខ្លួនឯងជាងជឿជំនឿក្រៅខ្លួន ខ្មែរពិតជាដឹងថាកុសលល្អនឹងបានមកពីណា ? ហើយខ្មែរកាន់តែមានមោទនភាព និងមហិច្ឆតា ក្នុងការកសាងប្រទេសជាតិឱ្យបានរីកចំរើនលូតលាស់ ដូចប្រទេសជឿនលឿនឯទៀតជាមិនខាន ។

រាជបណ្ឌិតសភាកម្ពុជា

ថ្ងៃចន្ទ ទី៣ ខែមិនា ឆ្នាំ ២០០៣

**ខួត ធីតា**

បណ្ឌិតផ្នែកវិទ្យាសាស្ត្រទស្សនវិជ្ជាពុទ្ធសាសនា

# សេចក្តីផ្តើម

សតវត្សទី២១នេះ គឺជាសម័យមួយ ដែលចរន្តសាកលភាវូបនីកម្ម កំពុងមានសន្ទុះយ៉ាងខ្លាំងក្លាគួរឱ្យកត់សំគាល់ ។ ចរន្តសាកលភាវូបនីកម្មនេះ បានជំរុញឱ្យពិភពលោកស្ថិតក្នុងសភាពប្រកួតប្រជែងស្ទើរគ្រប់វិស័យ ។ ការប្រកួតប្រជែងនេះ មានលក្ខណៈទូលំទូលាយ ហើយអាចរាលដាលចេញពីប្រទេសមួយទៅប្រទេសមួយទៀត និង រីករាលដាលពាសពេញពិភពលោកទាំងមូល ។ ជាធម្មតា ដើម្បីទទួលបានជោគជ័យលើការប្រកយតប្រជែង គូប្រកួតខ្លះបានរិះរកគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន ទាំងមធ្យោបាយស្របច្បាប់ ស្របគោលការណ៍សីលធម៌ ផ្អែកលើសិទ្ធិមនុស្ស ទាំងមធ្យោបាយមិនស្របច្បាប់ មិនស្របគោលការណ៍សីលធម៌ និងផ្អែកលើគោលការណ៍សិទ្ធិមនុស្ស ។ ការប្រកួតប្រជែងទាំងឡាយណា ដែលធ្វើឡើងដោយស្របច្បាប់រដ្ឋ ស្របគោលការណ៍សិទ្ធិមនុស្ស និងស្របគោលការណ៍សីលធម៌ អាចធ្វើឱ្យក្រុមមួយ សង្គមមួយ ប្រទេសមួយ ឬពិភពលោកទាំងមូលឈានទៅរកវឌ្ឍនភាព សុភមង្គល និងសន្តិភាព ។ ផ្ទុយទៅវិញ ការប្រកួតប្រជែងទាំងឡាយណា ដែលធ្វើឡេងដោយមិនស្របច្បាប់រដ្ឋ មិនស្របគោលការណសិទ្ធមនុស្ស មិនស្របនឹងគោលការណ៍សីលធម៌ អាចធ្វើឱ្យក្រុមមួយ សង្គមមួយ ប្រទេសមួយនិងពិភពលោកទាំងមូលកើតឡើងនូវភាពអនាធិបតេយ្យ អំពើហឹង្សា អំពើរអសីលធម៌ ដែលអាចនាំសង្គមមនុស្សទាំងមូលឆ្ពោះទៅរកភាពក្តៅក្រហាយ សង្គ្រាម អស្ថេរភាព ហាយនភាព អពមង្គល និង អសន្តិសុខ ។

១ នៅក្នុងពិភពលោកសម័យយើងនេះ មរតកនៃសីលធម៌កំពុងតែមានភាស្វិតស្រពោន ដោយការបំផ្លិចបំផ្លាញ និងការរីកចម្រើននៃអរិយធម៌សម្ភារនិយម ដោយប្រកាន់យកជំនឿសុខៈក្លែងក្លាយ និងការពេញចិត្តចំពោះសេចក្តីត្រេត្រអាលភផ្ទាល់ខ្លួនក្នុងជីវភាពលោកីយ៍នេះ ។ អរិយធម៌សម្ភារនិយម ដែលសង្ឃឹមថានឹងធ្វើឱ្យសម្បូរបែបនូវឧបករណ៍វិទ្យាសាស្ត្រ និងបច្ចេកវិជ្ជាទំនើបនោះ បានបង្កឱ្យមានបញ្ហាជាច្រើននៅក្នុងវិស័យផ្សេងៗដូចជា សេដ្ឋកិច្ច សង្គមកិច្ច ការអប់រំសិក្សា ការធ្វើឱ្យវិនាសអន្តរាយដល់បរិស្ថាន និងការធ្វើឱ្យកាន់តែខ្សត់នូវធនធាន ព្រមទាំងការបំផ្លិចបំផ្លាញនូវធនធានធម្មជាតិ និងការបង្កឱ្យមានភាពច្របូកច្របល់

ថែមទាំងជះឥទ្ធិពលអាក្រក់គំរាមកំហែងដល់ពិភពលោក នៃសតវត្សទី២០ នេះ ។ សព្វថ្ងៃនេះ គេឃើញថា មនុស្សអាចយកជ័យជំនះលើអ្វីៗជាច្រើនផ្នែកសម្ភារៈ ។ ក៏ប៉ុន្តែ ក្នុងដំណើរការនៃទំនើបឧបនីយកម្ម និងការយកឈ្នះលើធម្មជាតិនេះ យើងបានបាត់បង់នូវគុណធម៌ល្អៗជាច្រើនរបស់មនុស្សជាតិ ដូចជា សីលធម៌ មេត្តាធម៌សុភាវធម៌ និងគតិបណ្ឌិត ទៅវិញ ។ ដើម្បីតម្រង់ទិសមនុស្សធម៌ ឱ្យចូលក្នុងគន្លងដ៏ត្រឹមត្រូវវិញនោះ វាទាមទារឱ្យយើងរួបរួមកម្លាំងគ្នា នាំយកព្រះធម៌ដ៏ល្អថ្លៃថ្លារបស់ព្រះសាម្មាសាម្ពុទ្ធ ទៅផ្សព្វផ្សាយឱ្យបានជ្រួតជ្រាបដល់ដួងចិត្តមនុស្សគ្រប់រូប ឆ្ពោះទៅដល់ការលើកកំពស់សុខសន្តិភាព សុខុមាលភាព និងការយោគយល់គ្នាទៅវិញទៅមក ក្នុងចំណោមប្រជាជនពិភពលោក តាមរយៈសកម្មភាពធម្មទូត ។ ការលើកកំពស់ដល់ការប្រតិបត្តិជាប្រចាំ តាមអរិយមគ្គទាំង ៨ ប្រការគឺ : សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សាម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ និង សម្មាសមាធិ ត្រូវអនុវត្តក្នុងចំណោមសាធារណជន ជាពិសេសក្នុងមជ្ឈដ្ឋានយុវជន ដែលនឹងត្រូវទទួលខុសត្រូវជាចម្បង[១] ។

២ ជាងម្ភៃប្រាំសតវត្សកន្លងទៅហើយ ពុទ្ធសាសនាបានជះឥទ្ធិពលដ៏ធំសម្បើមមកលើវប្បធម៌ និងអារ្យធម៌នៃតំបន់ដ៏ធំទូលាយនៃទ្វីបអាស៊ី ។ ដោយការផ្សព្វផ្សាយទៅ បីដូចជាខ្យល់ជំនោរដ៏ស្រទន់មកលើទ្វីបអាស៊ី សាសនាប្រកបដោយសន្តិភាព និងករុណាធម៌នេះ បានធ្វើឱ្យជីវភាពនៃមនុស្សច្រើនលានរាប់មិនអស់ ក្នុងដែនដីជាច្រើនសម្បូរសប្បាយ ដោយផ្តល់ដល់មនុស្សទាំងនោះ មិនគ្រាន់តែមាគ៌ានៃជីវិតដទន់ភ្លន់ និងសុខដុមប៉ុណ្ណោះទេ ប៉ុន្តែដោយលើទឹកចិត្តដល់ពួកគេឱ្យចេះច្នៃប្រឌិតបង្កើតទម្រង់វប្បធម៌ប្លែកៗ មានគំនូរ ចម្លាក់ ដន្ត្រី និងស្ថាបត្យកម្ម ថែមទៀត ។ សាសនានេះ បានបង្រៀនមនុស្សឱ្យចេះរស់នៅក្នុងសន្តិភាពជាមួយគ្នាទៅវិញទៅមក ឱ្យចេះផ្តល់កិត្តិយសដល់ឪពុកម្តាយ និងរៀមច្បង ឱ្យចេះថែរក្សាបរិស្ថាន ។ ប៉ុន្តែសព្វថ្ងៃនេះ មាគ៌ានៃជីវិតពីបុរាណដ៏ប្រសើរនេះ កំពុងទទួលរងការគម្រាមកំហែង ហើយរបៀបរបបវប្បធម៌ និងសង្គម កំពុងតែស្រុតចុះ តាមរយៈការបញ្ចូលគំនិត និងជំនឿទាំងឡាយដែលចម្លែក ក្រៅពីមាគ៌ាវប្បធម៌ផ្ទាល់នៃជីវិតយើង ។ ក្នុងពេលថ្មីៗនេះ ពុទ្ធសាសនិកជនអ្នកយល់ដឹង បានកត់សម្គាល់ឃើញដោយសេចក្តីព្រួយបារម្ភថា ចំនួនពុទ្ធសាសនិកជនក្នុងទ្វីបអាស៊ី បានថយចុះក្នុងកម្រិតអត្រាដ៏គួរឱ្យព្រួយ ជាពិសេស ក្នុងចំណោមជំនាន់មនុស្សក្មេងៗ ។ មនហេតុ-

---

[១] ដេម បេរ៉ែល ឆយដាម ម៉ុងហ្គោលី សន្និសីទ ពុទ្ធសាសនាកំពូលលើកទី៣ ភ្នំពេញ ធ្នូ ២០០២

ផលជាច្រើនចំពោះរឿងនេះ គឺមានហេតុ-ផលទាំងខាងក្នុង និងទាំងខាងក្រៅ ។ ពុទ្ធសាសនាកំពុងទទួលរងការគម្រាមកំហែង ដោយការបញ្ចូលទស្សនៈសាសនា ច្រើនតែធ្វើឡើងតាមរយៈមធ្យោបាយមិនសូវស្មោះត្រង់ ដែលជាទស្សនៈសាសនាកំពុងត្រូវបានបដិសេធច្រើនឡើងៗ ដោយពពួកមនុស្សលោកខាងលិច ជាមនុស្សមានចំណេះដឹង និងមានការអភិវឌ្ឍន៍ខាងសម្ភារៈ[២] ។

៣ -នៅទីបំផុត យើងត្រូវរំលឹកបន្ទូលរបស់មហាអធិរាជអសោក ដែលបានត្រាស់ថាៈ "អ្នកណាដែលរំលោភបំពានលើជំនឿរបស់អ្នកដទៃទន្ទឹមនឹងអួតសសើរជំនឿផ្ទាល់របស់ខ្លួនគ្រាន់តែបានទទួលជោគជ័យ ក្នុងការផ្តន្ទាទោសសាសនាផ្ទាល់របស់ខ្លួនប៉ុណ្ណោះ"[៣] ។

យោងតាមស្ថានភាព សង្គម បរិយាកាសពុទ្ធសាសនា លើពិភពលោក នៅអាស៊ីអាគ្នេយ៍ ពិសេសជាងនេះទៅទៀត នៅប្រទេសកម្ពុជាយើងតែម្តង ទើបជំរុញឱ្យអ្នកនិពន្ធមាន បំណងលើកនូវ បញ្ហា២ធំៗ (វត្ត និង បុណ្យ) នេះមកបំភ្លឺក្នុងសៀវភៅភាគទី២ "ការស្វែង យល់អំពីរបត់ព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរ" ដល់ពុទ្ធសាសនិកជនខ្មែរ ។

កត្តាសំខាន់នៅពេលនេះ គឺអ្នកចង់នាំពុទ្ធសាសនិកជនខ្មែរក្នុងស្វែងយល់បន្ថែមចំពោះវត្តអារាម និងបុណ្យនានា នៅប្រទេសយើង។ មូលហេតុអ្វី ដែលនាំឱ្យខ្មែរស្រឡាញ់វត្តអារាម ? ស្រឡាញ់ការធ្វើបុណ្យ ? រហូតដល់មួយឆ្នាំមានបុណ្យសឹងគ្រប់ខែទាំងអស់ ("បុណ្យទ្វារទស មាស" "បុណ្យ១២ ខែ") ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏មិនទាន់គ្រប់ជ្រុងជ្រោយទេ ព្រោះវត្តអារាមក្តីបុណ្យក្តី។ សុទ្ធតែមានអត្ថន័យបែបសង្គម-វប្បធម៌ ទូលំទូលាយណាស់ ហើយសមស្របទៅតាមសម័យកាលបំផុត ដែលក្នុងនោះទាមទាការបកស្រាយមិនចេះចប់ ។

---

[២] - ស្រី ធម្មានន្ទ ពុទ្ធសាសនានៅក្នុងអាស៊ីបច្ចុប្បន្ន សន្និសីទពុទ្ធសាសនាលើកទី៣ ភ្នំពេញ ២០០២ ទំព័រទី ៣៨

[៣] -ដ- ទំព័រទី ៣៩

# ១

# វត្តអារាម
# ជាមជ្ឈមណ្ឌលវប្បធម៌របស់ប្រជារាស្ត្រខ្មែរ

(សូមមើលឯកសារធម្មការ ឆ្នាំ ១៩៩៤)

ប្រជារាស្ត្រខ្មែរជាង៩៥% ជាអ្នកគោរពព្រះពុទ្ធសាសនា។ ជីវិតរបស់គេ បានផ្សារភ្ជាប់ទៅនឹងវត្តអារាមតាំងពីកើតរហូតដល់ស្លាប់។ ដោយសារប្រជារាស្ត្រខ្មែរទាំងអស់គ្នា ផ្តោតចិត្តគំនិតនិងសកម្មភាពទៅលើតែចំណុចរួមមួយគឺវត្តអារាម ដូច្នេះ ទើបវត្តអារាមបានក្លាយទៅជាមជ្ឈមណ្ឌលវប្បធម៌របស់គេ។

តាមរយៈឯកសាររបស់ឥណ្ឌា ចិន និងការស្រាវជ្រាវខាងបុរាណវិទ្យាបញ្ជាក់ថា មនុស្សខ្មែរបានរស់នៅលើទឹកដីសុវណ្ណភូមិនេះ តាំងតែរាប់ពាន់ឆ្នាំមកហើយ។ គឺប្រជាជាតិដែលមានចំណាស់ជាងគេមួយ ក្នុងចំណោមប្រជាជាតិនៅអាស៊ីអាគ្នេយ៍។ ប្រជាជាតិខ្មែរបានស្ថាបនាប្រព័ន្ធគ្រប់គ្រងរបស់ខ្លួន មានការរីកចម្រើនគ្រប់វិស័យ តាំងពីមុនពេលដែលព្រះពុទ្ធសាសនា និងសាសនាព្រាហ្មណ៍ចូលមកដល់។ ខ្មែរមានភាសាដោយឡែករបស់ខ្លួន មានជំនឿសំរាប់គោរពបូជារបស់ខ្លួន។ រីឯវប្បធម៌ដែលចូលពីក្រៅ មានវប្បធម៌ឥណ្ឌា និងចិន គឺគ្រាន់តែជាការផ្តល់កំលាំងឬជាពន្លឺជួយជំរុញឱ្យវប្បធម៌ខ្មែរបានរីកចម្រើន និងអភិវឌ្ឍន៍បានយ៉ាងឆាប់រហ័សតែប៉ុណ្ណោះ។ ដោយហេតុភាពរលាយនៃវប្បធម៌បរទេស មកជាវប្បធម៌ខ្មែរនេះហើយ ទើបប្រទេសដែលជាម្ចាស់ដើមនៃវប្បធម៌នោះ ពុំអាចរកភស្តុតាងនូវវប្បធម៌របស់ខ្លួនឃើញនូវប្រទេសខ្មែរយើង។ ដូនតាខ្មែរ ជាអ្នកមានទេពកោសល្យខាងច្នៃប្រឌិត មានកំលាំងខាងបញ្ញាដ៏អស្ចារ្យណាស់ខាងការបង្កើតថ្មី។ ការណ៍ដែលលោកមិនចេះចម្លងតាមគ្នានេះហើយបានជា វិស័យសិល្បៈ វប្បធម៌ខ្មែរមានខ្លឹមសារ និងមានរូបភាពយ៉ាងសម្បូណ៌បែប។ សិល្បៈវប្បធម៌ដ៏សម្បូរនោះ មាន

មជ្ឈមណ្ឌលដោយឡែកពីគ្នា ប៉ុន្តែទាំងអស់គ្នា ដើរតាមក្បួនខ្នាតជាមូលដ្ឋានរួមមួយ ដែលជាអត្តសញ្ញាណរបស់ជាតិ ។

ក្នុងពេលដែលសាសនាព្រាហ្មណ៍ ជាសាសនារបស់ប្រទេសនោះ ព្រះមហាក្សត្រ និងរាជបណ្ឌិតបានកសាងប្រាសាទជាច្រើន( រាប់ពាន់ប្រាសាទ ) ។ ប្រាសាទទាំងនោះទោះបីស្ថិតក្នុងរចនាបថជាមួយគ្នា ក៏លក្ខណៈពិសេសពុំដូចគ្នាទេ :ទំហំ កំពស់ ទីតាំងតុបតែងលំអរក្បូរក្បាច់ខុសគ្នា។ ប៉ុន្តែដែលដូចគ្នានោះគឺប្រាសាទទាំងអស់នោះគឺជាទីគោរពសក្ការបូជា និងជាកន្លែងរក្សាទុកឯកសារដូចគ្នា ។

លុះដល់ពេលដែលពុទ្ធសាសនាមហាយានមកជំនួសសាសនាព្រាហ្មណ៍វិញ ប្រាសាទទាំងឡាយនោះ មិនគ្រាន់តែជាទីសក្ការបូជា ជាបណ្ណាល័យប៉ុណ្ណោះទេប៉ុន្តែថែមទាំងជាសាលារៀនជាមហាវិទ្យាល័យរបស់ជាតិទៀតផង ។

ឧទាហរណ៍- ប្រាសាទព្រះខ័ន ប្រាសាទតាព្រហ្ម ជាដើម ។ សិលាចារឹក( តាព្រហ្ម សៀមរាប អង្គរ) ឬ "បុរីរាជវិហារ" បញ្ជាក់ថា បុរីរាជវិហារនេះ មានការជួយឧបត្ថម្ភដោយស្រុកចំនួន៣.១៤០ សំរាប់ឧបត្ថម្ភចំពោះបុរស៤០០នាក់ មានអធិការ( មហាថេរ) ១៨អង្គ មានអធិការរង( អនុថេរ)២.៧៤០ អង្គ អ្នកបំរើ ២.២៣២នាក់ រួមទាំងបរិចារិការ( ស្រីរបាំ) ៦១៥ នាក់ រីឯអ្នកបំរើមាន ៦៦.៦២៥ សរុបទាំងអស់មានមាន៧៩.២៦៥នាក់ រួមទាំងជាតិភូមា និងចាមផង ។ នៅទីនេះមាន:

- លំនៅថ្ម ៥៦៦ កន្លែង
- លំនៅឥដ្ឋ ២៨៨ កន្លែង
- ស្រះទទឹង ៧៦ ព្យាម បណ្តោយ១១៥០ព្យាម ។
- ភិក្ខុសង្ឃ៤៣៩ អង្គ ទទួលភត្តរាល់ថ្ងៃ ក្នុងព្រះរាជមន្ទីរ ។ សិស្សមាន ៩៧០ នាក់ ។ សរុបទាំងអស់មាន ១.៤០៩ នាក់ ។

នៅក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ដែលជាព្រះរាជាគោរពពុទ្ធសាសនា ព្រះអង្គបានកសាងអរោគ្យសាលា ( មន្ទីរពេទ្យ) ចំនួន១០២ កន្លែង-មានទេវរូប ៧៩៨ អង្គ តម្កល់នៅទូទាំងប្រទេស ។

ដើម្បីព្យាបាលអ្នកជំងឺនៅគ្រប់មន្ទីរពេទ្យទាំងនោះ គេត្រូវចំណាយអង្ករចំនួន១១៧.២០០ ខារីកា។ អង្ករនោះបានមកពីស្រុកចំនួន ៨៣៨។ បុគ្គលិកអ្នកបំរើនៅមន្ទីរពេទ្យ មាន៨១.៦៤០ នាក់។

(ដល់មកក្រោយសម័យអង្គរ ពុទ្ធសាសនាហីនយាន បានចូលមកជំនួសពុទ្ធសាសនាមហាយាន ពេលនោះវត្តអារាម ក៏មានតួនាទីដូចប្រាសាទសិលាពីបុរាណ ដូច្នេះដែរ ។តាមពិតទៅ ពុទ្ធសាសនា និង សាសនាព្រហ្មណ៍មកដល់ប្រទេសខ្មែរ ក្នុងពេលប្រហាក់ ប្រហែលគ្នា។ គម្ពីរពុទ្ធសាសនា បានផ្តល់ពតិមានថា ក្រោយពេលធ្វើតតិយសង្គាយនារួច ក្នុងវង្សពុទ្ធសតវត្សទី៣ ព្រះមហាថេរមួយអង្គ ព្រះនាម មហាមោគ្គល្លីបុត្តតិស្សៈ បានចាត់ចែងបញ្ជូប ព្រះថេរ ២អង្គ គឺព្រះសោណត្ថេរ និង ព្រះឧត្តរត្ថេរ អោយចេញពីជម្ពូទ្វីប "ឥណ្ឌា " មកផ្សាយពុទ្ធសាសនានៅសុវណ្ណភូមិយើងនេះ ។)

តាមប្រភពឯកសារចិនថា ប្រទេសខ្មែរនិងប្រទេសចិន មានទំនាក់ទំនងជាមួយគ្នាតាំងពីរមុនគ.ស ច្រើនរយឆ្នាំ។ ប៉ុន្តែឯកសារជាភស្តុតាង ទុកជាផ្លូវការនោះគឺ ចាប់តាំងពីគ្រឹស្តតវត្សទី៣ រហូតមក។ តាមរយៈឯកសាររបស់ចិនដដែលនោះ យើងអាចដឹងបាន ថា : ចិនមកដល់ប្រទេសខ្មែរយើង ( ដែលកាលណោះ មានឈ្មោះថា Founan ) តាំងពីមុន២៣១ នៃគ.ស។ នៅក្នុងរជ្ជកាល ព្រះចៅក្រុងចិន នាម វូ (២២០-២៨០ គ.ស)ចិនបានបញ្ជូនទូត ២ រូប មកកម្ពុជាគឺ កាំង ថៃ និង ជូ យីង។ ទូតទាំងពីររូបនេះបានជួបទូតមកពីឥណ្ឌា នៅក្នុងស្រុកខ្មែរយើង។ ទូតឥណ្ឌាឈ្មោះចិន ស៊ុន។ តាមឯកសារដែលទូតចិនឈ្មោះ ជូ យីង សរសេរ គេអាចដឹងថា ព្រះរាជានៅនគរភ្នំ ព្រះនាម ហ្វាម័ន ឬ ហ្វាន់ចេម៉ុន ( ស្រីមារៈ ? )។ ព្រះអង្គជាព្រះរាជាកាន់ពុទ្ធសាសនា មានកិត្យានុភាព ដ៏ល្បីល្បាញ។

ជូ យីង រៀបរាប់ថា ប្រជាជននៅនគរភ្នំមានសម្បុរខ្មៅ សក់រួញ នៅក្នុងប្រជុំភូមិមួយមានអណ្តូងមួយគេរកស៊ីធ្វើស្រែចំការ ចេះត្បាញរវៃអម្បោះ សូត្រ ចេះសិល្បៈឆ្លាក់ក្បាច់រចនា ធ្វើចិញ្ចៀន កងដៃ កងជើង កងក ប្រើចានប្រាក់ យកពន្ធ ដារជាមាស ប្រាក់ គុជ និងមានក្បួនតម្រា មានមន្ទីរឯកសារ អក្សរសរសេរតាមអក្សរឥណ្ឌា ទំនៀមការកូនចៅ បុណ្យខ្មោចដូចនៅប្រទេសចាមដែរ ។ ប្រជាជនកាន់សាសនាព្រាហ្មណ៏ និងកាន់ពុទ្ធសាសនា ។

ឯកសារចិក៏បានបញ្ជាក់ថា : ក្នុង ព.ស ១០៤៦ (គ.ស៥០៣) ព្រះបាទកៅណ្ឌិន្យជ័យ វរ្ម័ន បានបញ្ជូនរាជទូតម្នាក់ទៅប្រទេសចិន។ នៅចុងគ្រឹស្តសតវត្សទី៥ ដើមគ្រឹស្តសតវត្សទី៦ ព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន បានបញ្ជូនព្រះថេរ ២ អង្គ ១ អង្គ នាម សេងគា ប៉ូឡូ(សង្ឃបាលោ) ដែលចេះច្រើនភាសា ឱ្យទៅជួយបកប្រែគម្ពីរបិដក អស់១៦ឆ្នាំ នៅការិយាល័យនគរភ្នំ ឯប្រទេសចិន។ ព្រះថេរៈនេះ បានសុគតនៅទីនេះក្នុងគ.ស ៥២៤។ព្រះថេរៈ ១ អង្គទៀតនាម ម័ត្តូឡូ(និមន្តទៅដល់ប្រទេសចិន ក្នុងឆ្នាំ ៥០៣ ក៏បានទៅ បកប្រែគម្ពីរព្រះត្រៃបិដកដែរ។ ព្រះនាមនៃព្រះថេរៈទាំងពីរអង្គចារក្នុងឯកសារនេះរហូតដល់ សព្វថ្ងៃ។ កាលពីឆ្នាំ ១៩៥៦ ពេល ព្រះសម្តេចព្រះ ន.សីហនុវរ្ម័ន ស្តេចយាងទៅប្រទេសចិន គេបាន ថ្វាយព្រះអង្គទតនូវស្នាដៃនោះ។

ចំពោះភស្តុតាងនៅក្នុងប្រទេសយើងវិញ គេបានរកឃើញសិលាចារឹកមួយផ្ទាំង នៅវ៉ូកាញ នៅតំបន់ញ៉ាត្រាង(សព្វថ្ងៃនៅប្រទេសវៀតណាម)ចារជាអក្សរខ្មែរបុរាណដ៏មានចំ ណាស់បំផុត សរសេរជាភាសាសំស្ក្រឹតដែលក្នុងនោះមានពាក្យ"គតាគតិ"និងពាក្យ"ប្រជានំ ករុណា" ដែលជា ពាក្យឧទ្ទិសរបស់ព្រះបាទស្រីមារៈដែលសោយរាជ្យនៅនគរភ្នំ ក្នុងសតវត្សទី៣ នៃមហាសករាជ (គ្រឹស្តសតវត្សទី២)។

អត្ថបទសិលាចារឹកបានឱ្យដឹងថាៈ ព្រះរាជវង្សស្រីមារៈ បានត្រាស់បង្គាប់ឱ្យចារឹកទុក ដើម្បីជាអនុស្សាវរីយ៍ ចំពោះព្រះបាទស្រីមារៈថា :រាជកុលៈគឺ បឋមវង្សជ្រះថ្លាចំពោះព្រះពុទ្ធ សាសនា ដោយត្រាស់យល់ច្បាស់នូវ គតាគតិដំណើរអន្ទោលស្លាប់កើតនៃសត្វលោក ក្នុងវាលវដ្ត សង្សារ ទ្រង់ប្រកបដោយមេត្តាករុណាដល់សព្វសត្វ ហើយទ្រង់ត្រាស់បង្គាប់ឱ្យបរិច្ចាកព្រះរាជ ទ្រព្យព្រះអង្គ ធ្វើជាទានទុកជាសាធារណៈប្រយោជន៍។ ទ្រង់ផ្តាំ "ឱ្យព្រះរាជាសោយរាជាសោយ រាជ្យជាតំណទៅអនាគតឱ្យប្រតិបត្តិតាមព្រះរាជប្រកាសនេះដើម្បីជាប្រយោជន៍ដល់សត្វលោក។

សិលាចារឹកប្រាសាទតាព្រហ្ម ទន្លេបាទី (គ្រឹស្តសតវត្សទី៦)ថា ព្រះបាទរុទ្រវរ្ម័ន ជាព្រះ រាជបុត្រព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន ទ្រង់កាន់ពុទ្ធសាសនា ហើយគោរពព្រះបរមសារីរិកធាតុ នៃ អង្គព្រះសម្មាសម្ពុទ្ធ។ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី១(ព.ស ១២០០-១២២៣) (គ.ស ៦៥៧-៦៨១)មានសិលាចារឹកមួយនៅវត្តព្រៃវៀរ រៀបរាប់ថា មានភិក្ខុពីរអង្គ ជាបងប្អូនបង្កើតជាតិ ជាក្សត្រចេញទៅបួស ហើយគង់នៅវត្តព្រៃវៀរ។ ទាំងពីរអង្គមានសីលជាពហុស្សូត្រ សុភាព ខន្តី

មានករុណា មានសមា ធិជាអរិយទ្រព្យនាមខាងដើមដូចគ្នាថា "រតនៈ"គឺរតនៈភាណុ និង រតនៈសិង្ហ។ ព្រះថេរទាំងពីរ អង្គនេះបានហាមប្រាមមិនឱ្យគេកាប់ព្រៃក្នុងវត្ត ទើបមានឈ្មោះថា វត្តព្រៃវៀររហូតមក។

តាមពតិមានឥណ្ឌា-ចិន និងខ្មែរ យើងឃើញមានចំណុចត្រូវគ្នាច្រើនល្មមសន្និដ្ឋាន បាន ថា ព្រះពុទ្ធសាសនា បានចូលដល់ប្រទេសកម្ពុជាយើង តាំងពីមុនគ្រឹស្តសករាជ ព្រមទាំងមានការ រីកចម្រើនយ៉ាងខ្លាំង តាំងពីសម័យនគរភ្នំមកម្ល៉េះ។ភស្តុតាងខាងលើនេះបញ្ជាក់ថា ពុទ្ធសាសនា ត្រូវបានគេគោរពនៅ កម្ពុជាតាំងពីរាប់ពាន់ឆ្នាំមកហើយ។ ទន្ទឹមនឹងការគោរពពុទ្ធសាសនាគេក៏ គោរពសាសនាព្រាហ្មណ៍ដែរ។ ការគោរពសាសនា ធំពីរទន្ទឹមគ្នាយ៉ាងនេះបង្កើតជាចរន្តធំៗរបស់ វប្បធម៌។ ចរន្តមួយចេញពីសាសនាព្រាហ្មណ៍ដែលជាសាសនារបស់ស្រទាប់វណ្ណៈខ្ពស់នៅសម័យ នោះនិងចរន្តមួយទៀតចេញពីវត្តអារាមនៃពុទ្ធសាសនា។ ចរន្តទាំងពីរនេះមិនដែលប្រឆាំងគ្នាទេ ផ្ទុយទៅវិញបានរស់នៅជាសហវិជ្ជមានជាមួយគ្នា និងបង្កើតជាធ្លុងពីរនៃវប្បធម៌របស់ជាតិ។ ឯធ្លុងចរន្តទីបីនោះគឺ គតិបណ្ឌិតប្រជាប្រិយ៍ និងជំនឿអ្នកស្រុកដើម។

ក្នុងប្រវត្តិសាស្ត្ររបស់ខ្មែរ គេមិនដែលឃើញមានសង្គ្រាមសាសនារវាងពុទ្ធសាសនា និង សាសនាដទៃទៀតទេ។ ផ្ទុយទៅវិញគេឃើញមានការរួមរស់ជាមួយយ៉ាងសុខសាន្ត រវាង សាសនាទាំងឡាយទៅវិញ។ ពិតមែនហើយពេលដែលផ្លាស់ប្តូរការគោរពសាសនាម្តង តែងតែ មានការកែច្នៃខ្លះមិនខានឡើយ។ ប៉ុន្តែគួរឱ្យស្តាយសង្គ្រាមពីខាងក្រៅ និងការបែកបាក់សាមគ្គី ផ្ទៃក្នុង បានធ្វើឱ្យខូចខាតដល់សមិទ្ធិផលខាងវប្បធម៌យ៉ាងសម្បើមឥតគណនា។ ប៉ុន្តែ ទោះបី យ៉ាងណា ក៏យើងនៅតែឃើញមាននិរន្តរភាពរបស់ចរន្តវប្បធម៌នេះរបន្តរហូត តាំងពីបុរាណដល់ សព្វថ្ងៃ។ យើងបានសង្កេតឃើញថា វត្តអារាម និងប្រាសាទបុរាណ នៅតែមាន ទំនាក់ទំនងគ្នាជា និច្ច ។ វត្តអារាមដែលសង់ថ្មី ច្រើននៅក្បែរបុរាណដ្ឋានចាស់ ឬនៅចំពីលើកន្លែង ដែលបែកបាក់ អស់ទៅ ។ ដូចជានៅទន្លេបាទីជាឧទាហរណ៍ស្រាប់។ ការសង់បែបនេះគឺជាបំណងរបស់ប្រជា រាស្ត្រខ្មែរ ដែលចង់រក្សាកេរដំណែលបុរាណឱ្យគង់វង្ស ចង់បន្តការគោរពបូជាចំពោះបុព្វបុរស របស់ខ្លួនចាប់ពីឪពុកម្តាយឡើងទៅ។ ដូច្នេះ ហើយយើងឃើញថាវត្តអារាមយើងសព្វថ្ងៃ មាន ឈ្មោះតាមប្រាសាទ ឬទីតាំងបុរាណដូចជា វត្តអង្គរ វត្តព្រះធាតុ វត្តអង្គរតាសូរ វត្តអង្គរស្នួល

ជាដើម។ រីឯវត្តជាច្រើនទៀត ពិតមែនតែដាក់ ឈ្មោះថ្មី ប៉ុន្តែសង់ក្បែរបុរាណដ្ឋានដដែល ដូចជា វត្តបាទី វត្តភ្នំជីសូរ វត្តអាធ្វារ វត្តបាគង...។ ត្រង់នេះបញ្ជាក់ថា ប្រាសាទក្តី វត្តក្តី សុទ្ធតែមានតួនាទីជាមជ្ឈមណ្ឌលវប្បធម៌ដូចគ្នា។ ដូច្នេះ វត្តបានបន្តតួនាទីវប្បធម៌ តាំងពីសម័យបុរាណ ពិសេស ពីសម័យអង្គរមក។

## I-ពុទ្ធសាសនា និងប្រជាជនខ្មែរ

ដូចបានបញ្ជាក់ពីខាងដើមមកហើយ ប្រជារាស្ត្រខ្មែរ ៩៥% ជាអ្នកកាន់ពុទ្ធសាសនា។ ការគោរពពុទ្ធសាសនានេះ មានតាំងពីសម័យបុរាណ គឺ មានតាំងពីមុនសម័យអង្គរទៅទៀត ។ ការគោរពពុទ្ធសាសនាត។គ្នាទៅ រាប់សតវត្សបែបនេះបានធ្វើឱ្យទស្សនវិជ្ជាពុទ្ធសាសនាជ្រួតជ្រាប ជឹតជាប់ក្នុងផ្នត់គំនិតរបស់ ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស។ ផ្នត់ចិត្តគំនិតនេះ បានក្លាយទៅជា"ទស្សនៈរួមរបស់ជាតិ" ដែលមនុស្សខ្មែរសព្វថ្ងៃមានកំណើត។ ទោះអ្នកនោះមិនបានទៅរៀនធម៌អាថ៌ក៏ដោយ ក៏ទស្សនៈ របស់ព្រះពុទ្ធដែលបន្តពីឪពុកម្តាយ បានជ្រាបចូលទៅដល់បុត្រធីតារួចស្រេចទៅហើយ ហើយដែលមិនអាចប្តូរផ្លាស់ដោយងាយ។ឡើយ ។ ជាពិសេស ប្រជាពលករជាកសិកររស់នៅតាមជនបទ រមែងផ្សារភ្ជាប់ខ្លួនគេទៅនឹងវត្តអារាម និងជួយទ្រទ្រង់វត្តឱ្យមានជីវិតជានិច្ចនិរន្តរ៍រហូតមក។ ទីណាមានប្រជារាស្ត្រខ្មែររស់នៅ ទីនោះមានវត្ត។ តាមទូរលេខក្នុងឆ្នាំ ១៩១៦ នៅក្នុងទូទាំង ប្រទេស មានវត្តអារាមចំនួន២.៥០៥ វត្តដែលក្នុងនោះមាន ២១ វត្តនៅក្នុងរាជធានីភ្នំពេញ ។ ព្រះសង្ឃមានចំនួន ៣០.០០០អង្គ។ បើប្រៀបទៅនឹងប្រជាពលរដ្ឋប្រហែល ២លាននាក់ គឺថា វត្តមួយសំរាប់ប្រជាជនខ្មែរចំនួន ៨០០នាក់ និងក្នុងចំណោមមនុស្ស ៦៦នាក់ មានព្រះសង្ឃ ១អង្គ។ មកដល់ឆ្នាំ១៩៦៩ វត្តបានកើនរហូតដល់ ៣.៣៦៩ ក្នុងនោះ វត្តធម្មយុត្តិកនិកាយមាន ១៣៩ វត្ត។ ព្រះសង្ឃមានចំនួន ៦៥.០៦២ អង្គ ក្នុងនោះព្រះសង្ឃធម្មយុត្តមាន ២.៣៨៤ អង្គ។ បើធៀបនឹងចំនួនប្រជាជនប្រហែល ៧ លាននាក់ ឃើញថា វត្តមួយសំរាប់ប្រជាជន ១.៧៨០នាក់ និងសង មួយសំរាប់ប្រជាជន ៩២ នាក់។ បច្ចុប្បន្ននេះនៅទូទាំងប្រទេស មានវត្តចំនួន ៣.០៨៧ វត្ត ព្រះសង្ឃមាន ២៧.៣៥៩ អង្គ(ស្ថិតិ ១៩៩៤) បើធៀបនឹងប្រជាជន ឃើញថា វត្តមួយ សំរាប់ប្រជាជន ២៥៤ នាក់។ គិត

តាមចំនួនប្រជាជន ៧.០០០.០០០នាក់។ ដូច្នេះបានជាគេនិយម ពោលថា វត្តជាជីវិតរបស់ខ្មែរ និងតំណាងនៃអត្តិភាពរបស់ខ្មែរ។

**១. តើគេច្រើនសង់វត្តអារាមនៅកន្លែងណា ?**

វត្តអារាម ទោះបីជាកន្លែងស្ងប់ សំរាប់អ្នកបួសសំងំបន្ទំចិត្តជំរះកិលេសតណ្ហា កាត់ផ្តាច់ការជាប់ជំពាក់នឹងជីវភាពរស់នៅសាមញ្ញរបស់មនុស្ស ក៏ដោយក៏វត្តនៅតែមានទំនាក់ទំនងជាប្រចាំ ជាមួយសង្គម ផ្សារភ្ជាប់នឹងសង្គមជានិច្ចកាល។

ដូច្នេះបានជាគេឃើញវត្តអារាម ច្រើនស្ថិតនៅកណ្តាលចំណោមភូមិ។ វត្តទាំងឡាយច្រើនសង់នៅលើទីទួលខ្ពស់មិនលិចទឹកនៅរដូវវស្សា ឬនៅលើកំពូលភ្នំ។ នេះជាលក្ខណៈមួយបង្ហាញថា វត្តជាទីសការៈត្រូវស្ថិតនៅខ្ពស់ជាងលំនៅរបស់ប្រជារាស្ត្រ ប្រហាក់ប្រហែលនឹងបុរាណប្រាសាទ ដែលគេសាងនៅលើកំពូលភ្នំ ដូច្នេះដែរ។

-វត្តសង់លើភ្នំណា យកឈ្មោះតាមភ្នំនោះ ដូចជាភ្នំស្រង់ ភ្នំសន្ទុក ភ្នំជីល ភ្នំជីល ភ្នំបាឆាយ ភ្នំស្អាង ភ្នំធន់មន់ ភ្នំសំពៅ ភ្នំតាម៉ៅ ។ល។

-វត្តសង់លើទួលណា គេដាក់ឈ្មោះតាមទួលនោះ

ឧទាហរណ៍: វត្តទួលព្រេច -វត្តទួលរកា -វត្តទួលស្គី ជាដើម។

-វត្តមួយចំនួនសង់លើទីតាំងរបស់អង្គចាស់ៗ ពីបុរាណ ដូចបានរៀបរាប់ដូចខាងលើ ហើយយកឈ្មោះតាមអង្គនោះ ឬព្រះធាតុនោះ ឬតាំងនោះ។

ឧ. វត្តអង្គប្រួច - វត្តតាសូរ វត្តព្រះធាតុ ។ល។

-វត្តតាំងក្រសាំង -វត្តតាំងផ្លោត ។ល។

** តាំង គឺទួលក្នុងដងព្រៃ ដែលគេកាប់ឆ្ការកសាងជាភូមិ ឬកសាងជាវត្ត។ ក្រៅពីទួល-អង្គ-ព្រះធាតុ-តាំង វត្តអារាមត្រូវបានគេកសាងនៅកន្លែងផ្សេងៗទៀតជិតៗភូមិ ដូចជាកន្លែងរំលិច។ រំលិចជាអន្លង់ទឹកមានសណ្ឋានទ្រវែង ទាល់ចុងដើម គ្មានផ្លូវទឹកហូរចេញចូល ច្រើននៅជិតស្ទឹង ជិតព្រែក។ នៅខាងខ្ពស់ គេហៅក្បាលរំលិច ខាងទាប គេហៅចុងរំលិច។ រំលិចជាប្រភពទឹកមួយដែរ។

កន្លែងមានក្រាំង មានខ្នារ មានព្នៀត មានរលាំង...។ ឧ. វត្តក្រាំងយ៉ូវ វត្តរលាំងកែន ឬឃុំរលាំងកែន។

**ក្រាំង គឺជាទួលដែលមានទីវាល គេដាក់ឈ្មោះក្រាំងទៅតាមដើមឈើដែលដុះនៅលើដីក្រាំងនោះដូចជា : ក្រាំងធ្នង់ ក្រាំងព្នៅ ក្រាំងចេក ... ។

**ខ្នារ : គឺដីទួលខ្ពស់ព័ទ្ធជុំវិញត្រពាំង ឬស្រះដែលកើតឯងដោយធម្មជាតិ ឥតមានអ្នកណាជីក។ បើកគេកសាងវត្តនៅលើទីទួលនោះ។ ឧ. វត្តខ្នារ នៅឃុំស្រឡប់ជាដើម។ រីឯត្រពាំង ដែលនៅជិតនោះ ក៏ឱ្យឈ្មោះហៅថា ត្រពាំងខ្នារក៏មាន។

**ព្នៀត : គឺដីទួលទាបៗ នៅជាប់ពីមាត់បឹងប៉ាចហាច ឬមាត់បឹងមានស្រែមានព្រៃរបោះ។ ជួនកាលគេកសាងភូមិ កសាងវត្តនៅលើទីទួលនោះឈ្មោះថា វត្តព្នៀត ឬភូមិព្នៀត...។ល។

**រលាំង : គឺទួលប៉ែកខាងខ្ពស់ជិតរំលិច ឬក្បាលរំលិច ពេលគេកសាងជាវត្ត ជាភូមិនៅទីនោះ គេឱ្យឈ្មោះភូមិ វត្តតាមឈ្មោះរលាំងនោះដែរ។ ឧ. រលាំងគ្រិល រលាំងចេក រលាំងឈូក ជាដើម។

**គោក : គឺទួលកណ្ដាលវាល ឬកណ្ដាលវាលស្រែ ឬក៏នៅកណ្ដាលទីដែលមានទឹកលិច បើគេកសាងភូមិ ឬវត្តនៅទីនោះ គេក៏ដាក់ឈ្មោះតាមឈ្មោះគោកនោះទៅ។ ឧ.វត្តគោកព្រីង -គោកសណ្ដែក -គោកត្រប់ -គោកគង់ ។ល។ គេសាងវត្តនៅទីកន្លែងផ្សេងទៀតដែលមានប្រភពទឹក ដូចជា លំហាច របាល បារាយណ៍ ស្ពុក ជាដើម។

## ២.ហេតុអ្វីបានជាគេនិយាយមកកសាងវត្តនៅទីទាំងឡាយនោះ ?

- ប្រទេសកម្ពុជាយើង ជាប្រទេសទំនាប ភ្លៀងច្រើន មានទឹកលិចច្រើន នៅរដូវវស្សា។ ភូមិសាស្ត្របែបនេះ តម្រូវឱ្យគេជ្រើសរើសរកកន្លែងខ្ពស់ មិនលិចទឹកកសាងវត្តអារាមដើម្បីងាយដល់ការធ្វើបុណ្យសុន្ទរ៍ទានផងទាំងឡាយ។ គេអាចធ្វើដំណើរទៅកាន់ទីនោះបានតាមផ្លូវគោកនៅរដូវប្រាំង។

ទីពីរ ទីកន្លែងនោះ ច្រើនមានប្រភពទឹកនៅក្បែរ ជាទីប្រជុំនៃមនុស្ស សត្វផងទាំងឡាយនៅរដូវរាំងស្ងួត។ គេនាំគ្នាទៅទីនោះបានផលប្រយោជន៍យ៉ាងច្រើនគឺ ទៅវត្តផង យកសត្វទៅឱ្យទឹកផង ងូតខ្លួនឯងផងដងទឹកយកទៅបរិភោគផង បេះបន្លែវារីជាតិ មានឈូកព្រលិត លំចង់ ស្បង្កើជ ទៅបរិភោគផង។

-ទីបី គឺជាកន្លែងដែលធ្លាប់គោរពបូជា តាំងពីបុរាណកាលត១មក។ យើងសង្កេតឃើញថា មានវត្តជាច្រើន ដែលកសាងជាឡើងលើដីណែលចាស់ពីបុរាណ។

ឧ. វត្តនៅទន្លេបាទី វត្តនៅក្នុងបរិវេណប្រាសាទអង្គរវត្ត ។ល។

- ទីបួន វត្តជាទីកន្លែងស្ងប់-ស្ងាត់ ត្រជាក់ត្រជុំ មានព្រៃឈើ ដែលគេហៅថាអារាម-ដូច្នេះ ទីទួលដែលមានព្រៃស្រោប់ នោះជាកន្លែងសមស្របមុនគេ។

- ទីប្រាំ វត្តអារាម ជាកន្លែងដែលមានបារមីនៃព្រះពុទ្ធជាព្រះបរមគ្រូ ជាឃ្លាំងនៃធម៌វិន័យ ដែលប្រជាជនខ្មែរមានជំនឿថាអាចកំចាត់ បីសាច ខ្មោច ព្រាយ អសុរកាយបាន។

រីឯទីទួលព្រៃស្មសាន ច្រើនជាកន្លែងដែលប្រជាជនខ្លាចរអែង ធ្វើឱ្យអារម្មណ៍របស់ប្រជាជន មិនស្ងប់។ ដូច្នេះ ព្រះសង្ឃដែលតំណាងនូវសេចក្ដីលះបង់ តំណាងនៃសេចក្ដីពិតសច្ចៈ ដែលមិនចេះខ្លាចខ្មោច ព្រាយ បីសាច លោកតែងទៅតាំងទីធ្វើសំណាក់កម្មដ្ឋានធុតង្គទុក្ខមូល ដើម្បីកំចាត់ពួកព្រាយ អសុរកាយទាំងនោះ។ ក្រោយមក គេក៏នាំគ្នាកសាងវត្តនៅទីនោះទៅ។ វត្តបានទៅជាការធានារ៉ាប់រង ជាទីពំនាក់ខាងសតិអារម្មណ៍ ខាងផ្លូវចិត្តរបស់ប្រជាជន។

**៣-តើអ្នកណាជាអ្នកកសាងវត្តអារាម ?**

ដូចបានបញ្ជាក់ស្រាប់រួចមកហើយថា ប្រជាជនខ្មែរបានផ្សារភ្ជាប់ខ្លួនទៅនឹងវត្តអារាម តាំងពីកំណើត។ ទំនាក់ទំនងរវាងវត្តអារាម និងជីវភាពរស់នៅរបស់ប្រជាជនខ្មែរ មានភាពរឹងមាំណាស់ មិនអាចកាត់ផ្ដាច់បានឡើយ។

ដូច្នេះ បើមានការតាំងទីលំនៅកន្លែងណាមួយហើយ គេតែងនិមន្តព្រះសង្ឃ១អង្គ ពីវត្តណាមួយឱ្យទៅគង់នៅកន្លែងតាំងលំនៅថ្មីនោះ ដើម្បីបង្កើតជាវត្ត។

វត្តជារបស់ឧបាសកពុទ្ធបរិស័ទ ពោលគឺ ប្រជាជនក្នុងភូមិស្រុកនៅជុំវិញវត្តនោះ។ ប្រជាជនជាអ្នកកសាងវត្តគេចាត់ទុកវត្តជាសម្បត្តិរួមរបស់គេ។ ព្រះសង្ឃជាអ្នកទ្រទ្រង់ថែរក្សាវត្តអារាម។

នៅសម័យបុរាណ ពេលដែលដីធ្លីនៅទូលាយ គេនាំគ្នាជ្រើសរើសរកដីទួលខ្ពស់ មានព្រៃ មានទឹកនៅជិតធ្វើជាវត្ត ឬគេតាំងវត្តនៅកន្លែងដែលប្រជាជនថាមានខ្មោច ព្រាយ បិសាចដែលតែងតែមកយាយីដល់ជីវភាពរស់នៅរបស់ប្រជាជន។

ប៉ុន្តែក្រោយមក ពេលដែលដីធ្លីកាន់តែចង្អៀត ប្រជាជនកាន់តែច្រើន វត្តអារាមក៏បំបែកខ្លួនទៅតាមកំណើនប្រជាជនដែរ។ គឺប្រជាជនដែលចង់បានវត្តសំរាប់ប្រតិបត្តិនៅជិតផ្ទះរបស់ខ្លួន នាំគ្នាកសាងវត្តថ្មីឡើង។

គេអាចកសាងវត្ត ដោយសារមានសប្បុរសជនធ្វើអំណោយ ដីធ្លី ឬប្រាក់កាស ឬទ្រព្យសម្បត្តិ ដើម្បីទិញដីធ្លី ទិញសម្ភារៈសំណង់ផ្សេងៗ។

ជួនកាល អំណោយរបស់សប្បុរសជនម្នាក់ ក៏ល្មមអាចសាងសង់វត្តមួយបាន ជួនកាលគេនាំគ្នាកាត់ដីធ្លីដែលនៅជាប់គ្នា ឬផ្លាស់ប្តូរដីគ្នា រួមបញ្ចូលគ្នាឱ្យបានធំទូលាយល្មមនឹងកសាងវត្តបាន។

ចំពោះការសាងកុដិវិញ វិហារ សាលាបុណ្យ សាលាបាលី... និយាយរួម គឺសំណង់ស្ថាបត្យកម្មក្នុងវត្តទាំងមូល គឺពុទ្ធបរិស័ទចំណុះជើងវត្តជាអ្នកជួយឧបត្ថម្ភ និងរ៉ាប់រង។

ពេលសង់បានអាគារហើយ គឺប្រជាជនជាអ្នកសម្រេចថា ត្រូវនិមន្តព្រះសង្ឃណាមកធ្វើជាចៅអធិការ ។ គណៈអាចារ្យវត្ត ក៏ត្រូវបង្កើតឡើងដែរ ដើម្បីបន្តទ្រទ្រង់វត្តជួយមើលដំណើរការរបស់វត្ត និងការដឹកនាំវត្តរបស់ចៅអធិការ។ ភារកិច្ចរបស់អាចារ្យ និងគណៈកម្មការវត្ត គឺបន្តជួយសាងសង់សំណង់ទាំងឡាយរបស់វត្ត កែលំអរ ជួយជួសជុលសំណង់ចាស់ សាងសង់សំណង់ថ្មី ។

ភារកិច្ចទីពីររបស់ឧបាសកជើងវត្ត គឺការឃ្លាំមើលការគោរពប្រតិបត្តិ ធម៌វិន័យរបស់សង្ឃក្នុងវត្តរបស់ចៅអធិការៈ

- តើមានភាពបរិសុទ្ធល្អ ឬទេ ?
- តើត្រឹមត្រូវតាមធម៌វិន័យ និងសិក្ខាបទ ឬទេ ?
- តើវត្តបំរើផលប្រយោជន៍រួមរបស់ពុទ្ធបរិស័ទជើងវត្តបាន សមតាមសេចក្តីប្រាថ្នាដែរ ឬទេ ?

ប្រសិនបើមានរឿងអាស្រូវណាមួយកើតឡើងនោះ មិនអាចបំបាំងនឹងភ្នែករបស់មហាជនបានទេ។ ព្រោះវត្ត ជាវត្តរបស់គេ គេមានសិទ្ធិនិងភារកិច្ចនឹងរក្សាភាពថ្លៃថ្នូរ និងកិត្យានុភាពរបស់វត្តគេ។

ដើម្បីឱ្យវត្តនៅក្នុងភូមិរបស់គេរស់រាន រីកចម្រើន ស្ថិតស្ថេរ ប្រជាជនតែងបរិច្ចាគកូនចៅរបស់គេឱ្យបួសជាសង្ឃ ដើម្បីបន្តដឹកនាំវត្ត ពីជំនាន់មួយទៅជំនាន់មួយ។

**៤.តើវត្តអារាមផ្តល់អ្វីខ្លះឱ្យប្រជាជនវិញ ?**

ក / វត្តអារាមជាទីតាំងនៃព្រះពុទ្ធសាសនា ដែលជាទីពឹងពំនាក់ របស់ប្រជាជនគ្រប់ៗរូប។

- សង្ឃជួយប្រជាជន ឱ្យរំដោះផុតពីការភ័យខ្លាច -តាមរយៈកាសូត្រមន្តផ្សេងៗ
- ព្រះធម៌ធ្វើឱ្យស្ងប់ចិត្តរំងាប់ រំដោះខ្លួនចេញពីសេចក្តីទុក្ខសោក ទាំងឡាយ
- ព្រះធម៌នាំបរិស័ទឱ្យដើរតាមផ្លូវត្រូវ-មជ្ឈឹមបដិបទា-មានសីល(មានទាន) -បញ្ញាសមាធិមានអដ្ឋង្គិកមគ្គ ជាអាទិ៍។

- វត្តអារាម ជាកន្លែងស្ងប់រំងាប់ចិត្ត ឱ្យផុតកង្វល់ក្នុងជីវិត ដែលពោរពេញទៅដោយអវិជ្ជា តណ្ហាសេចក្តីលោភ ហិង្សា សេចក្តីច្រណែនឈ្នានីស អំពើពាល អំពើឃោរឃៅការជិះជាន់កេងប្រវ័ញ្ច កាប់សម្លាប់ពោលគឺ សង្គ្រាម និងអសន្តិសុខ។ មនុស្សយើង ដើម្បីរស់នៅត្រូវតែតស៊ូក្នុងជីវិតរបស់ខ្លួន។ ការតស៊ូតែងតែប៉ះទង្គិច ការប៉ះទង្គិចនាំឱ្យមានទំនាស់មិនចេះចប់។ ទំនាស់នេះនាំឱ្យមានវិបត្តិ ទាំងខាងផ្លូវកាយ ទាំងខាងផ្លូវចិត្ត។ ម្យ៉ាងទៀត មនុស្សកើតមកមាន "កម្ម" មកជាមួយ កម្មនេះអាចផ្តល់សេចក្តីសុខ ឬទុក្ខ។ ប៉ុន្តែសេចក្តីទុក្ខជាមរតក ជាសច្ចធម៌ដែលមនុស្សគ្រប់រូបត្រូវទទួល ពិសេសគឺ ទុក្ខដែលកើតមកពីសេចក្តីកើតស្លាប់។ មនុស្សភ័យខ្លាចសេចក្តីស្លាប់ណាស់ តែមនុស្សមិនខ្លាចប្រព្រឹត្តអំពើដែលនាំឱ្យទៅរកសេចក្តីស្លាប់ទេ។

អ្នកភ័យខ្លាចនឹងសេចក្តីស្លាប់ អ្នកស្អប់ខ្ពើមអំពើបាប អ្នកចង់សាងអំពើល្អ តែងតែទៅពឹងវត្ត។

ខ / វត្តអារាមជាមន្ទីរពេទ្យខាងផ្លូវចិត្ត របស់បរិស័ទជើងវត្ត ។

-ព្រះសង្ឃនិងព្រះធម៌អាចជួយព្យាបាល ជួយពន្យល់ឱ្យបរិស័ទអ្នកមានទុក្ខ មានកង្វល់ រំលត់ទុក្ខព្រួយបាន ។ ពេលមានកើតហេតុមិនល្អ នៅតាមគ្រួសារក្តី នៅភូមិក្តី គេតែងនិមន្តព្រះសង្ឃទៅជួយដោះស្រាយ ។

-គ្រប់ពិធីទាំងអស់នៅក្នុងគ្រួសារ តាំងពីកើតកូនរហូតដល់ស្លាប់ គេមិនដែលចោលព្រះសង្ឃទេ ។

-ព្រះសង្ឃជួយអប់រំជនពាល ជនប្រមឹកឱ្យស្គាល់ផ្លូវត្រូវវិញបាន ។

គ / វត្តជាកន្លែងជ្រកកោនរបស់អ្នកកំសត់ទុរគត ។

គ្រប់វត្តអារាម តែងទទួលចិញ្ចឹមកុមារកំព្រាឥតទីពឹង ព្រមទាំងសិស្សានុសិស្ស ជាកូនចៅរបស់ប្រជាជនដែលនៅទីឆ្ងាយ ខ្វះជំរក ខ្វះទីសំណាក់ ដើម្បីបន្តការសិក្សា ។

ជនពនេចរ ចាស់ជរា ជនអភ័ព្វឥតសំណាង គ្មានកូនចៅទំនុកបំរុង តែងទៅជ្រកនៅក្នុងវត្ត ដើម្បីរៀនធម៌អាថ៌ នៅក្នុងសំណាក់ចុងក្រោយនៃជីវិតរបស់ខ្លួន ។

ឃ / វត្តជាជម្រកនិរភ័យរបស់សត្វម្រឹគីម្រឹគា បក្សាបក្សី និងមច្ឆាជាតិ និងជាកន្លែងរក្សា ការពារពូជឈើព្រៃឱ្យគង់វង្ស ។ វត្តជាសួនច្បារ ជាអារម ជារមណីយដ្ឋាន អាចលំហែអារម្មណ៍បាន ។

ការបំផ្លាញព្រៃឈើរបស់វត្តអារាម ធ្វើឱ្យបក្សាបក្សីបាត់ជម្រក ហើយក៏ហើរទៅរកកន្លែងផ្សេងៗ ។ ការបំផ្លាញវត្ត ធ្វើឱ្យមច្ឆាជាតិ ព្រៃឈើ និងបក្សាបក្សីដែលជាសម្បត្តិធម្មជាតិមានតម្លៃសម្រាប់ទ្រទ្រង់ជីវិតមនុស្សវិនាសសាបសូន្យ ឬក៏ផុតពូជតែម្តង ។

ង / វត្តជារណ្តៅដែលគេកប់ចោលនូវទំនាស់ទាស់ទែងគ្នា ជាកន្លែងដែលមនុស្សទាំងអស់មានភាពស្មើរគ្នា ។

ពេលចូលទៅដល់ក្នុងវត្ត ទាំងអស់គ្នាមានឈ្មោះថាឧបាសក ពេលនោះ ទោះបីជាមន្ត្រីរាជការមានឋានៈណាក៏ដោយ ក៏ត្រូវថ្វាយបង្គំព្រះពុទ្ធបដិមា ថ្វាយបង្គំព្រះសង្ឃដូចគ្នា ។ ហើយបើចូលបព្វជា ជាសង្ឃ ក៏រឹតតែមានសមត្ថភាពនឹងគ្នាទៅទៀត ។ វត្តជាកន្លែងដែលមានឋានៈសង្គមទាំងឡាយត្រូវរលាយចូលគ្នា ។ វត្តជាកន្លែងដែលធ្វើឱ្យមនុស្សគ្រប់ស្រទាប់ខិតចូល ជិតគ្នា

យល់អធ្យាស្រ័យគ្នា អនុគ្រោះឱ្យគ្នា ដោយអំណាចនៃព្រះធម៌ នៃធម៌អហឹង្សាវីរយៈ ខន្តី និងភាពទន់ភ្លន់ ... ។

ហេតុនេះ ព្រះសង្ឃត្រូវប្រកាន់ទសពិធរាជធម៌ និងព្រហ្មវិហារធម៌ឱ្យបាន ដើម្បីជួយពុទ្ធបរិសទ័ឱ្យបានស្មើៗគ្នា ដោយឥតរើសអើង ឥតប្រកាន់និន្នាការនយោបាយ ប្រកាន់ពណ៌សម្បុរ ប្រកាន់វណ្ណភាពឡើយ ។

ច / វត្តជាចំណុចកណ្តាលនៃផ្លូងសាមគ្គីភាពជាតិ និងប្រជាធិបតេយ្យ ។

គ្មានកន្លែងដែលនាំប្រជាជនខ្មែរ ទៅរកសាមគ្គីភាព និងប្រជាធិបតេយ្យបានល្អ ដូចវត្តអារាមទេ ។ ព្រះសង្ឃបានធ្វើគំរូមុនគេក្នុងការរក្សាសាមគ្គីភាព និងប្រជាធិបតេយ្យ ។ រីឯប្រជាជន ក៏រៀនសូត្រធម៌ទាំងពីរនេះ ពីវត្តអារាមដែរ ។

ឆ / វត្តក៏ជាកន្លែងការពារសិទ្ធិរបស់ប្រជាជនដែរ ។

នៅសម័យអាណានិគមបារាំង វត្តបានជួយលាក់បំពួនជនអ្នកស្នេហាជាតិ ដែលបះបោរប្រឆាំងបារាំង និងមនុស្សដែលត្រូវរដ្ឋការបារាំងចោទថាជាអ្នកមានទោស ។

ក្រោយមក ចៅអធិការវត្ត អាចមានសិទ្ធិបិណ្ឌបាតយកអ្នកមានទោស ទៅអប់រំឱ្យកែប្រែអត្តចរិកសីលធម៌អ្នកទោសទាំងនោះបាន ។ ដូច្នេះ វត្តក្លាយទៅជា មណ្ឌលកែប្រែ និងអប់រំឡើងវិញរបស់ប្រជាជន ។

គេតែងយកជនខិលខូច ជនប្រមឹក ជនពាលាអាវ៉ាសែ ទៅប្រគេនព្រហសង្ឃជួយអប់រំ ។

ជ / វត្តជាមជ្ឈមណ្ឌលវប្បធម៌របស់ប្រជាជន ។

-វត្តជាសាលារៀន ខាងលេខនព្វន្ត និងអក្សរសាស្ត្ររបស់ប្រជាជន ។ រហូតមកដល់ចុងសតវត្សរ៍ទី ១៩ ឬដើមសតវត្សរ៍ទី ២០ វត្តជាមជ្ឈមណ្ឌលតែមួយគត់នៃការអប់រំ និងការសិក្សានៅជនបទ ។

បុរសស្ទើរតែ ១០០% សុទ្ធតែបានបួសរៀននៅក្នុងវត្ត យ៉ាងហោចណាស់ ក៏មួយវស្សាដែរ ។ ចំណុចនេះបញ្ជាក់ថា មនុស្សប្រុសទាំងអស់ សុទ្ធតែបានឆ្លងផុតគ្រោះមិនចេះអក្សរ ។ រីឯផ្នែកនារីវិញ ទោះបីមិនបានរៀនសូត្រនៅវត្ត ប៉ុន្តែក៏មានស្ត្រីចេះអក្សរដោយសាររៀនពីឪពុក

និងបងៗ ដែលធ្លាប់បានបួសរៀននៅវត្តដែរ យ៉ាងហោចណាស់ ក៏កូនស្រីបានទទួលការអប់រំខាងច្បាប់សីលធម៌ ក្នុងពេលចូលម្លប់ដែរ ។

– វត្តជាកន្លែងអប់រំសីលធម៌របស់ខ្មែរ ។

វត្តជាកន្លែងទ្រទ្រង់សីលធម៌សង្គម ធ្វើឱ្យសង្គមខ្មែរមានរបៀបរបបខាងសីលធម៌មួយដែលមានច្បាប់ជាមូលដ្ឋាន ។ អ្នកដែលបានបួសរៀននៅវត្ត គេចាត់ទុកថាជាអ្នកចេះដឹងខាងសីលធម៌ មានកិត្តិយស មានឋានៈមុខមាត់ស្មើគេឯងនៅក្នុងភូមិ ក្នុងសង្គម។ ពុទ្ធសាសនាជាលទ្ធិ "សង្គ្រោះខ្លួនឯង" ឱ្យមានតម្លៃគួរដល់ការគោរពពីអ្នកដទៃ ។

ក្បួនខ្នាត ទំនៀមទម្លាប់ ប្រពៃណី ពិធីការផ្សេងៗ ត្រូវគេបង្រៀននៅក្នុងវត្ត ។ ដូចជាសាស្ត្រាច្បាប់ប្រុស ច្បាប់ស្រីច្បាប់កេរកាល ច្បាប់ត្រីនេតី ច្បាប់ក្រម ច្បាប់ពាក្យចាស់ ។ល។ នេះជាច្បាប់សំរាប់គ្រហស្ថ ហៅថាអាគារិយវិន័យ ។ ឯអានាគារិយវិន័យ ក៏វត្តរឹតតែយកចិត្តទុកដាក់បង្ហាត់បង្រៀន ថែបំប៉នណាស់ទៅទៀត ។ គឺលោកមេវត្តជាអ្នកបង្ខំឱ្យព្រះសង្ឃរៀនច្បាប់ទាំងនេះ ។ ច្បាប់ សីលធម៌ វិន័យរបស់ពុទ្ធសាសនានេះហើយដែលជាគ្រឹះមូលដ្ឋាននៃសីលធម៌ខ្មែរ ។

-វត្តជាកន្លែងអប់រំវិជ្ជាជីវៈ ។

មុខវិជ្ជាជាច្រើន ត្រូវបានគេបង្រៀននៅក្នុងវត្ត គឺការបង្រៀនដោយ អនុវត្តផ្ទាល់ ដូចជា មុខរបរជំនាញចម្លាក់ សិល្បៈ សិប្បកម្មសម្រាប់បម្រើជីវភាពរស់របស់ប្រជាជន ។

ការទៅវត្តបួសរៀនសម្រាប់កូនចៅប្រជាជនខ្មែរ មិនមែនដើម្បីស្វែងរកសួគ៌និព្វានទេ គឺគ្រាន់តែបំពេញលក្ខណៈសម្បត្តិជាមនុស្សប្រុស ដែលសមល្មមអាចប្រកបរបរចិញ្ចឹមជីវិត និងរស់នៅក្នុងសង្គមដោយថ្លៃថ្នូរ ស្មើមុខស្មើមាត់នឹងគេ ពេលដែលខ្លួនលាចាកសិក្ខាបទមកជាគ្រហស្ថវិញ តែប៉ុណ្ណោះ ។ នៅវត្ត គេមិនគ្រាន់តែរៀនវិជ្ជាខាងជំនាញ ដូចជាជាងទង ជាងឈើ ជាងសំណង់ធ្វើផ្ទះសំបែង ប៉ុណ្ណោះទេ ។ ប៉ុន្តែ គេអាចរៀនខាងវិជ្ជាផ្សំថ្នាំបុរាណ វិជ្ជាខាងតន្ត្រីបុរាណ ដូចភ្លេងពិណពាទ្យ និងល្បែងប្រជាប្រិយផ្សេងទៀត ដូចជា ធ្វើខ្លែង ធ្វើកាំជ្រួច ធ្វើទូកង ធ្វើគោមបង្ហោះ ព្រមទាំងរៀនដឹកនាំពិធីការផ្សេងៗ ក្នុងបុណ្យទានផ្សេងៗ ពេលរៀបពិធីជា

មង្គលធំៗ ដូចជា ពិធីរៀបការ ពិធីបូជាសព ការធ្វើមេរុ ការធ្វើមឈូស ការរក្សាសពទុកឱ្យបាន យូរ ។ល។

– វត្តជាបណ្ណាល័យរបស់ប្រជាជន ។

គ្រប់វត្តពីបុរាណ សុទ្ធតែមានបណ្ណាល័យ មានរក្សាទុកគម្ពីរក្បួនខ្នាត និងគម្ពីរដីកា សាស្ត្រាស្លឹករឹត ។ ពេលត្រូវការផ្ទៀងផ្ទាត់អំពីព្រឹត្តិការណ៍ ឬក្បួនខ្នាតអ្វីមួយ គេតែងទៅបើក មើលក្បួននៅតាមវត្ត ដូចជាក្បួនហោរាក្បួនទំនាយផ្សេងៗ មានទំនាយព្រហ្មជាតិសម្រាប់ជ្រើស រើសគូស្រករ ឬក្បូនសំរាប់ប្រារព្ធពិធីផ្សេងៗ ។ល។

ព្រះសង្ឃជាអ្នកចារចម្លងសាស្ត្រា គម្ពីរនានា ទាំងខាងធម៌អាថ៌អក្សរសាស្ត្រ ប្រវត្តិ សាស្ត្រ និង ជាអ្នកថែរក្សាសម្បត្តិវប្បធម៌ អក្សរសាស្ត្រ និងសិល្បៈរបស់ជាតិ ។

– វត្តជាកន្លែងបង្កើតស្នាដៃនិពន្ធ ។

ព្រះសង្ឃ មិនគ្រាន់តែជាអ្នកថែរក្សាក្បួនខ្នាតខាងអក្សរសាស្ត្រ សីលធម៌ ធម៌អាថ៌ របស់ព្រះពុទ្ធ ប៉ុណ្ណោះទេ ។ ប៉ុន្តែ លោកជាអ្នកបង្កើតស្នាដៃដោយផ្ទាល់ផង ជាអ្នកបណ្តុះ បណ្តាលកវីនិពន្ធខ្មែរផង ។ ព្រះសង្ឃដែលបានរៀនសូត្រភាសាបាលីជ្រៅជ្រះ បានបកប្រែគម្ពីរ ពីភាសាបាលីមកជាភាសាខ្មែរ និងបាននិពន្ធសៀវភៅធម៌អាថ៌ ជាច្រើនសម្រាប់ព្រះសង្ឃក្មេងៗ និងពុទ្ធបរិស័ទរៀនសូត្រ ។ ព្រះសង្ឃអង្គខ្លះទៀត មានថ្វីមាត់អាចនិយាយជាកាព្យ សរសេរជា កាព្យ អាចនិពន្ធទាំងរឿងបែបអក្សរសាស្ត្រទៀតផង ។ បើនៅពេលគង់ក្នុងផ្នួស លោកមិនបាន តែងនិពន្ធ ក៏ដល់ពេលលោកលាសិក្ខាបទមកវិញ ក៏លោកក្លាយទៅជាអ្នកនិពន្ធដែរ ។

អ្នកនិពន្ធនិងកវីខ្មែរ សុទ្ធតែចេញមកពីវត្តអារាមទាំងអស់ ដូចជា:

ព្រះនាងឥន្ទ្រទេវី នៅសម័យអង្គរ (សតវត្សរ៍ទី ១២)

| | |
|---|---|
| ១- បណ្ឌិត្យ ជ័យនន្ទ | -សិលាចារឹកនគរវត្ត |
| ២- អ្នកប៉ាង | -ល្បើកអង្គរវត្ត |
| ៣- ព្រះឃ្លាំងនង | -លោកនេយ្យជាតក |
| ៤- ម៉ឺនភក្តីអក្សរតន់ | -រឿងសព្វសិទ្ធ |
| ៥- ព្រះរិយគមនី ហ៊ឹង | -រឿងព្រះជិនវង្ស |

៦- សន្ធរម៉ុក -រឿងទេវន្ទ

៧- ព្រះបុទុមថេរ -រឿងទុំទាវ

៨- សុត្តន្តប្រីជាឥន្ទ -គតិលោក និរាសនគរវត្ត

៩- អ្នកព្រះភិរម្យភាសា អ៊ូ -ច្បាប់ល្បើកថ្មី

១០- សម្តេចព្រះសង្ឃរាជ ជួន ណាត -វចនានុក្រមខ្មែរ ។ល។

ដូច្នេះយើងឃើញថាវត្តអារាមនេះហើយជាកន្លែងថែរក្សាទ្រទ្រង់វប្បធម៌ខ្មែរឱ្យគង់វង្ស និងរីកចម្រើនរៀងរហូតមកដល់សតវត្សរ៍ទី២០នេះ ។

-វត្តអារាមជាមណ្ឌលផ្សព្វផ្សាយវប្បធម៌ខ្មែរ និងផ្តល់ពត៌មានដល់រាស្ត្រ ។.

ពុទ្ធសាសនានៅកម្ពុជាមានប្រព័ន្ធគ្រប់គ្រងដឹកនាំជាឋានានុក្រមពីថ្នាក់កំពូលរហូតដល់ជនបទគឺ វត្តអារាមនេះឯង ។ នៅថ្នាក់កំពូលមានសម្តេចព្រះសង្ឃរាជ និងមន្ត្រីសង្ឃរាជថ្នាក់រាជគណៈនិងឋានានុក្រម ។ នៅថ្នាក់ខេត្តមានមេគណៈខេត្ត នៅថ្នាក់ស្រុកមានអនុគណៈស្រុក នៅវត្តមានចៅអធិការ និងលោកគ្រូសូត្រឆ្វេង-ស្តាំជាជំនួយ ។ នៅមុនឆ្នាំ ១៨៦៤ ពុទ្ធសាសនានៅកម្ពុជាមានតែ១គណៈទេ គឺគណមហានិកាយ ។ គណៈធម្មយុត្តិកនិកាយនេះ មានកំណើតនៅប្រទេសថៃនៅក្នុង ឆ្នាំឆ្លូវឯកស័ក ច.ស ១៩១ ត្រូវនឹង ១៨២៩ គ.ស ។ នៅសម័យឧត្តុង្គ(សម្តេចព្រះសុគន្ធាធិបតី) មហាប៉ានបាននិមន្តទៅរៀននៅប្រទេសថៃ ហើយបាននិមន្តទៅគង់នៅវត្តបរមនិវ៉ាត ដែលជាវត្តធម្មយុត្តដំបូងបំផុតកសាងឡើងដោយ ព្រះចោមក្លាវ ។ ដល់ពេលត្រឡប់មកប្រទេសវិញ លោកបានសុំព្រះរាជាអនុញ្ញាតបង្កើត គណៈធម្មយុត្តិនិកាយនៅកម្ពុជាទើបបានជាមានគណៈធម្មយុត្ត តាំងពីពេលនោះមក ។

ចំពោះសមណស័ក្តិ តាមបវេណីក្នុងរដ្ឋកម្ពុជាពីបុរាណមកមាន :

-ទីសម្តេចសង្ឃ

-ទីសង្ឃនាយក

-ទីរាជាគណៈ

-ទីឋានុក្រម

-ទីមហា

ហើយចែកជាបួនថ្នាក់គឺ ឯក ទោ ត្រី ចត្វា ។ សមណស័ក្តិទីរាជគណៈមាន ៣២ គឺ :

-ថ្នាក់ឯក មាន១១ (ផ្ចិតពណ៌បៃតង)

-ថ្នាក់ទោ មាន ៧ (ផ្ចិតពណ៌បៃតង)

-ថ្នាក់ត្រី មាន (ផ្ចិតពណ៌ស្វាយ)

-ថ្នាក់ចត្វា មាន៧ (ផ្ចិតពណ៌ខៀវ)

ដល់មក គ.ស ១៩៤៣ មានការកែប្រែបន្ថែមបន្ថយខ្លះ ហើយដល់មក គ.ស ១៩៤៨ បានកែប្រែម្តងទៀតដោយចែកចេញជាពីរ គឺ :

| មហានិកាយ | ធម្មយុត្តិកនិកាយ |
|---|---|
| -ព្រះសង្ឃនាយកគណៈមហានិកាយ | -ព្រះសង្ឃនាយកគណៈធម្មយុត្តិកនិកាយ |
| ព្រះមហាសុមេធាធិបតី | ព្រះសុគន្ធាធិបតី |
| (សម្តេចព្រះសង្ឃរាជ) | (សម្តេចព្រះសង្ឃរាជ) |
| ទីរាជាគណៈមាន ៣៥ គឺ | ទីរាជាគណៈមាន២១ គឺ |
| ថ្នាក់ឯក មាន ៣ | ថ្នាក់ឯក មាន ២ |
| ថ្នាក់ទោ មាន ៦ | ថ្នាក់ទោ មាន ៣ |
| ថ្នាក់ត្រី មាន ៦ | ថ្នាក់ត្រី មាន ៤ |
| ថ្នាក់ចត្វា មាន២០ | ថ្នាក់ចត្វា មាន ១២ |

**រាជាគណៈទាំងអស់មាន ៥៦ អង្គ**

ព្រះសង្ឃនាយក (សម្តេច) ទាំងពីរព្រះអង្គ និងរាជាគណៈទាំង ៥៦ អង្គនេះ សុទ្ធតែព្រះមហាក្សត្រទ្រង់ប្រោសព្រះរាជទានតែងតាំងដោយព្រះរាជក្រឹត្យ ។

ព្រះសង្ឃទាំង ៥៦ អង្គ ព្រមទាំងព្រះឋានុក្រម រហូតដល់ព្រះចៅអធិការ មានឥទ្ធិពលខ្លាំងណាស់ក្នុងការឃោសនាផ្សព្វផ្សាយអប់រំខាងទ្រឹស្តីពុទ្ធសាសនា ខាងធម៌អាថ៌ ក៏ដូចជាពណ៌មានផ្សេងៗ ។ ដូច្នេះហើយបានជារឿងរ៉ាវច្បាប់ទម្លាប់ ក្បួនខ្នាត និងពតិមានផ្សេងៗ បានរីកសាយយ៉ាងឆាប់រហ័ស ចូលទៅដល់ភូមិ ដល់ផ្ទះប្រជាជន ។

ការចារចម្លង គម្ពីរ ពីវត្តមួយទៅវត្តមួយ ពីភូមិមួយទៅភូមិមួយ ការទេសនាពីផ្ទះមួយទៅផ្ទះមួយ គឺជាការផ្ទេរមរតកវប្បធម៌របស់ជាតិ ពីជំនាន់មួយទៅឱ្យជំនាន់មួយទៀត ។

ឧ. ដូចជានៅសម័យបុរាណ យើងមានសិលាចារឹកជិត ២.០០០ផ្ទាំង ( ទាំងភាសាខ្មែរ ទាំងភាសាសំស្ក្រឹត )

-នៅសម័យកណ្តាល មានសាស្ត្រាស្លឹករឹត រាប់ពាន់ច្បាប់មានក្រាំង មានគម្ពីរ រាប់ពាន់ច្បាប់ ។

-នៅសម័យទំនើប មានសៀវភៅរាប់ពាន់ម៉ឺនក្បាល ដែលត្រូវចារចម្លងផ្សាយ ។

ព្រះសង្ឃជាអ្នកអាន អ្នកទេសនា អ្នកសូត្រកាព្យ យ៉ាងពិរោះ ។

ខ្មែរមានក្បួនតែងកាព្យជាង ៤០ និងមានរបៀបសូត្រកាព្យជាង ៦០ បែប ។ ហើយមានតែព្រះសង្ឃទេដែលមានទេពកោសល្យក្នុងការតែងនិពន្ធ និងសូត្រកាព្យ ។

នៅសម័យបុរាណ គ្រប់វត្តសុទ្ធតែមានស្គរធំសម្រាប់ផ្តល់សញ្ញាល្អ ឬសញ្ញាអាសន្នដល់ប្រជាជន ។ ដូចជាពេលមានចោរកម្ម ពេលមានភ្លើងឆេះផ្ទះ ពេលមានបុណ្យទានត្រូវប្រមូលផ្តុំមនុស្ស ជាដើម ។

-វត្តជាកន្លែងសំរាប់ផ្តល់នូវបុណ្យកុសលគ្រប់យ៉ាងដល់ប្រជាពលរដ្ឋ ដើម្បីឱ្យពុទ្ធបរិស័ទកើតសទ្ធាជ្រះថ្លា កសាងបុណ្យ រក្សាសីល ធ្វើទានដើម្បីសេចក្តីសុខចម្រើន ។ វត្តជួយកិច្ចការសង្គមជាកុសលច្រើនទៀតដូចជា អណ្តូងទឹក ថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យ ។ល។

-វត្តអារាមជាទីប៉ាឆា សម្រាប់បូជាសពនៃប្រជាពលរដ្ឋ ។

តាមទម្លាប់ខ្មែរ ពេលស្លាប់គេតែងតែចង់ទៅជួបព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។ ហេតុនេះបានជាគេតែងយកសពទៅបូជានៅវត្ត រួចគេបញ្ចុះធាតុ ឬតម្កល់ធាតុនៅក្នុងវត្តនោះតែម្តង ។

ដោយសារធាតុរបស់មាតាបិតា ញាតិសន្តានរបស់គេនៅវត្តជាមួយគ្នា ដូច្នេះហើយបានជាវត្តក្លាយទៅជាទីជួបជុំគ្នារវាងប្រជាជនក្នុងភូមិទាំងអស់ ជាពិសេសពេលបុណ្យចូលឆ្នាំ បុណ្យភ្ជុំបិណ្ឌ ជាដើម ។

តាមប្រពៃណីរបស់ខ្មែរ ការគោរពដឹងគុណចំពោះមាតាបិតា និងគ្រូឧបជ្ឈាយាចារ្យ ឬគ្រូបាធ្យាយ ជាអំពើប្រកបដោយកតញ្ញូកតវេទី ដែលកុលបុត្រកុលធីតាត្រូវធ្វើវត្តប្រតិបត្តិជាចាំបាច់ ដោយខានពុំបានឡើយ ។ ឱ្យតែដល់រដូវទាំងពីរនេះ ទោះបីគេរស់នៅទីឆ្ងាយដល់ណាក៏ដោយ ក៏គេតែងតែឆ្លៀតពេលត្រឡប់ទៅកាន់ភូមិកំណើតវត្តកំណើតរបស់គេ ដើម្បីធ្វើកិច្ចតបស្នងសងគុណ រំឭកគុណដល់បុព្វការីជនរបស់គេ មានការជូនជំនូនជាសំពត់ អាវ សម្លៀកបំពាក់ នំចំណី ប្រាក់កាស ការបោសសំអាតធាតុចេតិយ ដែលជាកន្លែងបញ្ចុះធាតុ ការបង្សុកូលជូនអ្នកដែលលាចាកលោកនេះទៅហើយ ជាដើម ។

ចំពោះអ្នកដែលបានបួសជាព្រះសង្ឃវិញ ការគោរពគ្រូឧបជ្ឈាយ៍ និងចៅធិការ មានជម្រៅធំធេងជាងការគោរពឪពុកម្តាយបង្កើតទៅទៀត ។ ទោះបី សឹកមកជាគ្រហស្ថវិញហើយក៏ដោយ ក៏លោកគ្រូចៅអធិការ និងគ្រូឧបជ្ឈាយ៍ នៅតែមានឥទ្ធិពលដដែល ។ រីឯសិស្សានុសិស្សវិញ ក៏ខិតខំថែរក្សាលើកតម្កើងកេរ្តិ៍ឈ្មោះរបស់លោកគ្រូរបស់ខ្លួនគេដែរ ។

ទម្លាប់ល្អនេះ បានសាបរលាបបន្តិចម្តងៗ នៅពេលដែលសាលារៀនរៀបរយសាធារណៈកើនឡើង គឺក្នុងរវាងឆ្នាំ ១៩១០ ។ ពេលដែលសិស្ស ១ ភាគ បានឃ្លាតចេញពីវត្ត មករៀននៅសាលាបារាំង ដោយឆ្លងកាត់ថ្នាក់កាន់តែច្រើន ចំណេះដឹងខាងវិទ្យាសាស្ត្រសង្គមកាន់តែខ្ពស់ អរិយធម៌ និងស៊ីវីល័យសកល ក៏ចូលមកលាយឡំក្នុងការអប់រំលោកគ្រូ សាស្ត្រាចារ្យកាន់តែច្រើន ដូច្នេះសិស្សម្នាក់ៗគោរពកោតខ្លាចគ្រូតែពេលរៀនក្នុងថ្នាក់ទាប ឬក្នុងឆ្នាំដែលខ្លួនរៀនតែប៉ុណ្ណោះ និងគោរពកោតខ្លាចដូចសិស្សដែលរៀនក្នុងសំណាក់តែគ្រូមួយអង្គពុំបាន ។ ម្យ៉ាងទៀតលោកគ្រូសាស្ត្រាចារ្យនៅសាលាសធារណៈ លោកមានប្រាក់បៀវត្សរ៍ដែលរដ្ឋផ្គត់ផ្គង់ មានគ្រួសារ បុត្រ ភរិយា ជាអ្នកជួយទំនុកបំរុងរួចហើយ ដូច្នេះបានជាកម្រមានសិស្សនៅរក្សាដឹងគុណដូចព្រះសង្ឃណាស់ ។

-វត្តអារាមជាកន្លែងប្រមូលផ្តុំ នៃជំនឿរបស់ប្រជាជន ។

ដោយសារវត្តជាទីប្រជុំនៃឧបាសកបរិស័ទជើងវត្ត ដែលមានជំនឿ ទម្លាប់ ដូចគ្នាខ្លះ ខុសគ្នាខ្លះ ដូច្នេះដើម្បីឱ្យសមស្របទៅនឹងចំណង់ចំណូលចិត្តរបស់ពុទ្ធបរិស័ទដែលជាម្ចាស់របស់វត្ត គេឃើញមានលទ្ធិសាសនា និងជំនឿជាច្រើន រលាយចូលគ្នានៅក្នុងវត្តអារាម ។ ដូចជាមានអ្នកតា មានយាយទេព តាមោក មានការគោរពលឹង្គព្រះសីវៈ ។ល។

ការរលាយខាងជំនឿបែបនេះ គឺជាលក្ខណៈនៃវប្បធម៌ខ្មែរ ដែលជាវប្បធម៌កើតនិងធំធាត់ រីកចម្រើនដោយសារការរលាយចូលគ្នានៃវប្បធម៌ពីក្រៅ និងវប្បធម៌របស់ខ្មែរ ។ ប៉ុន្តែចំណុចសំខាន់ដែលត្រូវកត់សម្គាល់គឺធាតុពីក្រៅ ត្រូវតែចំណុះក្នុងក្បួនខ្នាតរបស់វប្បធម៌ខ្មែរ ហើយរលាយបាត់រូបទៅក្នុងវប្បធម៌ខ្មែរ ។ ការរលាយទៅតាមក្បួនខ្នាតខ្មែរនេះ មិនមែនមានតែក្នុងជំនឿសាសនាទេ នៅក្នុងភាសា អក្សរសាស្ត្រ សិល្បៈតូចធំ មានភ្លេងរបាំ ស្ថាបត្យកម្មក៏ដូចគ្នាដែរ ។

- វត្តអារាមជាសារមន្ទីនៃស្ថាបត្យកម្មខ្មែរ ។

សំណង់ក្នុងវត្ត ទោះបីសង់ក្នុងសម័យទំនើបហើយក្តី ក៏នៅតែរក្សាលក្ខណៈជាតិដែរ ។ គេគ្រាន់តែក្រឡេកមើលពីចម្ងាយ ក៏អាចស្គាល់បានភ្លាមថា នោះជាវត្តអារាមដោយកំពូលដំបូលវិហារប្រកបដោយក្បូរក្បាច់រចនាមានជហ្វា ដងក្តារ បៃរកា ហោជាង ។ល។ ដោយសារស្ថាបត្យកម្មនេះជារបស់ខ្មែរ បានជាខ្មែរមានពាក្យសំរាប់សម្គាល់ចំណែកផ្សេងៗនៃស្ថាបត្យកម្មនោះ ។ ពាក្យទាំងអស់នោះ ក៏រលប់បាត់ទៅដែរ នៅពេលដែលយើងលែងសង់សំណង់បែបបុរាណនោះ ។ មកដល់ពេលនេះ មានតែចាស់ៗដែលធ្លាប់បួសរៀននៅវត្តទេ ដែលអាចស្គាល់ពាក្យសម្គាល់ចំណែកផ្សេងៗនៃសំណង់ទាំងនោះ ។

ក្រៅពីព្រះវិហារ នៅមានសំណង់សំខាន់ៗដទៃទៀត ដែលប្រកបដោយលក្ខណៈជាតិដែរ ដូចជា ចេតិយ ប្រាង្គ ពុទ្ធបដិមា មេរុបូជាសព ជាដើម ។

ចំណុចទាំងអស់ខាងលើនេះ គឺជាធាតុនៃវប្បធម៌ខ្មែរ ។ ដោយសារវត្ត មានលក្ខណៈជាច្រើនទាក់ទងដល់វប្បធម៌ជាតិ ដល់ចរិតលក្ខណៈរបស់ជាតិ ទើបវត្តមានតួនាទីមួយទៀតគឺជាតំណាងអត្តសញ្ញាណរបស់ជាតិ និងជាព្រលឹងនៃវប្បធម៌ជាតិ។ មានវត្តអារាមនៅកន្លែងណា បញ្ជាក់ថាមានមនុស្សខ្មែរធ្លាប់រស់នៅ ។ ព្រោះវត្តអារាម ជារបស់ប្រជាជនខ្មែរ មានលក្ខណៈពិសេសរបស់ខ្លួន ខុសប្លែកពីវត្តអារាមរបស់ប្រជាជាតិដទៃ ។ វត្តជាភស្តុតាងបញ្ជាក់អំពីវត្តមាននៃប្រជាជនខ្មែរ នៅកន្លែងជិតៗនោះ ។

នៅសម័យមហានគរ យើងមានប្រាសាទបុរាណ មានអង្គរ មានព្រះធាតុ មានសិលាចារឹកដែលជាភស្តុតាងបញ្ជាក់ថា ប្រជាជនខ្មែរធ្លាប់បានរស់នៅទីណាខ្លះ ក្នុងឧបទ្វីបអាស៊ីអាគ្នេយ៍នេះ ។ ចាប់ពីសម័យកណ្តាល គឺវត្តអារាមដែលអាចបញ្ជាក់បន្ថែមទៀត ទៅលើប្រាសាទបុរាណទាំងនោះ ។

វត្តអារាមជារបស់ប្រជារាស្ត្រខ្មែរ កសាងឡើងដោយប្រជារាស្ត្រខ្លួនឯង និង ដើម្បីបម្រើផលប្រយោជន៍របស់ប្រជារាស្ត្រខ្លួនឯង ។ ដូច្នេះមានតែប្រជារាស្ត្រខ្មែរទេ ដែលជាអ្នកកំណត់ជោគវាសនារបស់វត្តអារាម ។

ក្នុងរយៈពេលពីរទសវត្សកន្លងទៅនេះ បុរាណស្ថាន ប្រាសាទបុរាណ និងវត្តអារាមស្ទើរតែទាំងអស់ ត្រូវទទួលរងគ្រោះមហន្តរាយដោយសារសង្គ្រាម និង របបប្រល័យពូជសាសន៍ ធ្វើឱ្យបាត់អស់នូវភស្តុតាង ជាកេរដំណែលដូនតារបស់យើង ។ ការបំផ្លិចបំផ្លាញគាស់កកាយ ជីករំលើងបុរាណស្ថាន ក៏បានន័យថា ជាការសម្លាប់ព្រលឹងជាតិ ។ ការបំផ្លាញវត្តអារាម ការដុតកំទេចគម្ពីរ ក្បួនខ្នាត ការប្រើប្រាស់ពាក្យពេចន៍ខុសក្បួនច្បាប់ ក៏ចាត់ថាជាការសម្លាប់ព្រលឹងជាតិដែរ ។

ឥឡូវនេះ ទោះបីសង្គ្រាម និងរបបប្រល័យពូជសាសន៍បានកន្លងផុតទៅហើយ តែផលវិបាកមានយ៉ាងធ្ងន់ធ្ងរមកលើវប្បធម៌ មកលើសតិបញ្ញាស្មារតី ធ្វើឱ្យប្រជាជាតិខ្មែរគ្រប់រូបមានរបួសខាងផ្លូវចិត្តមិនអាចព្យាបាលឱ្យជាសះស្បើយវិញ ក្នុងរយៈពេលដ៏ខ្លីបានឡើយ ដែលជាហេតុ

ធ្វើឱ្យខ្មែរមានវិបល្លាសខាងសតិបញ្ញា វង្វេងនៅក្នុងភាពស្មុគស្មាញ ទន់ខ្សោយបាត់ជំនឿលើខ្លួនឯង ។ ប្រជាជនខ្មែរឥឡូវ មិនទាន់ចាប់យកព្រលឹងរបស់ខ្លួនដែលលស់ទៅបានមកវិញនៅឡើយ ពោលគឺ កំពុងស្ថិតក្នុងភាព " លស់ព្រលឹងនៅឡើយ" ។

គួរឱ្យខ្មាស់ខ្លួនឯងណាស់ ដែលខ្មែរយើងពីបុរាណ ដូនតាយើងធ្លាប់តែជាគ្រូគេ ធ្លាប់តែដាក់ទានឱ្យគេ ឥឡូវខ្មែរទ្រុឌទ្រោម ក្លាយជាអ្នកសុំទានគេ ត្រូវទទួលទានឱវាទពីគេ ត្រូវគេមើលងាយ ព្រោះខ្មែរខ្សោយ ខ្មែរមិនខ្លាំងដូចពីបុរាណ ។

## II-យើងធ្វើឱ្យវត្តអារាមក្លាយជាមជ្ឈមណ្ឌលវប្បធម៌ឡើងវិញ

ហេតុនេះ ដើម្បីឱ្យព្រលឹងខ្មែរ(រស់មកវិញ) ចូលមកសណ្ឋិតក្នុងរូបរាងរបស់ខ្មែរវិញ ប្រជាជាតិខ្មែរត្រូវរួមចំណែកស្វែងរកព្រលឹងនោះគ្រប់ៗគ្នា ។ ជាមួយនឹងការកសាងវត្តអារាមខាងសម្ភារៈ របស់ពុទ្ធបរិស័ទ ព្រះសង្ឃក៏មានភារកិច្ចយ៉ាងសំខាន់ដែរនោះគឺ ការថែរក្សាវប្បធម៌ខ្មែរ ការបំប៉នពូនជ្រំឱ្យវប្បធម៌រីកចម្រើនលូតលាស់ឡើងវិញឱ្យស្មារតីជាតិ ស្មារតីថ្លៃថ្នូររបស់ខ្មែរឡើងវិញ ទប់ទល់នឹងអប្បិយជំនឿ ទប់ទល់នឹងការឈ្លានពាន និងឥទ្ធិពលនៃវប្បធម៌បរទេសឱ្យបាន ។ ត្រូវខិតខំលើកតម្កើង និងឱ្យតម្លៃ ឱ្យសារសំខាន់ដល់វប្បធម៌ខ្មែរ ។ ចំពោះមុខវត្តអារាមណាដែលបានស្តារឡើងវិញរួច គប្បីប្រែក្លាយឱ្យទៅមជ្ឈមណ្ឌលវប្បធម៌ជាតិឱ្យបានដូចពីបុរាណកាល ។

ក្នុងអនុវត្តជាក់ស្តែង ការស្តារតួនាទីរបស់វត្តឱ្យដូចពីបុរាណ ត្រូវធ្វើទៅតាមលទ្ធភាព និងស្ថានភាពជាក់ស្តែងរបស់មូលដ្ឋាននីមួយៗផង ព្រមទាំងសមស្របទៅនឹងការរីកចម្រើនរបស់សង្គមផង ។

១-ការសាងសង់សំណង់ថ្មី ត្រូវតែរក្សាឱ្យបាននូវលក្ខណៈចរិតវប្បធម៌ខ្មែរខាងស្ថាបត្យកម្ម ។ ការតុបតែងលំអក៏ត្រូវតែគោរពតាមក្បួនខ្នាតនៃសិល្បៈខ្មែរ ។

២-ស្ថាបត្យកម្មសំណង់ចាស់ក្នុងវត្តអារាមត្រូវតែខំរក្សាទុកឱ្យបានល្អ ។ ការជួសជុលត្រូវធ្វើដោយប្រយ័ត្នប្រយែង កុំឱ្យប៉ះពាល់ដល់សោភ័ណ សិល្បៈស្ថាបត្យកម្មបុរាណ ។ បើចាំបាច់ត្រូវរុះរើនោះ គប្បីរក្សាបំណែកសិល្បៈទាំងឡាយទុកធ្វើជាគំរូ ។

៣-ត្រូវខិតខំដាំដើមឈើល្អៗ ឈើកម្រៗ ឈើប្រើជាថ្នាំសង្កូវ ឈើហូបផ្លែ ឈើលំអសួន ឈើយកស្លឹក ( ម្លប់ ) ។

៤-ត្រូវជីកយកស្រះធំៗ យកទឹកប្រើប្រាស់ ស្រោចស្រពដំណាំ យកទឹកជាជម្រកត្រីនិងមច្ឆាជាតិ ។ បក្សាបក្សីខ្លះ រស់ដោយសារមច្ឆាជាតិ ក៏អាចវិលមកនៅក្នុងវត្តវិញ ។

៥-ខិតខំបង្កើតសាលារៀន ឬខិតខំបង្រៀនសង្ឃខ្ចីវស្សាឱ្យចេះធម៌ ចេះភាសាខ្មែរ ភាសាបាលី ចេះសរសេរ ចេះលេខនព្វន្ត ។

៦-បង្កើតឱ្យមានទូសៀវភៅ បណ្ណាល័យសម្រាប់ព្រះសង្ឃផង និងសម្រាប់ប្រជាជនរៀនសូត្រផង ។

៧-វត្តនីមួយៗ គប្បីបង្រៀនមុខវិជ្ជាជំនាញ ត្រូវមានរោងជាងរបស់វត្តដូចជា ជាងឈើ តុកៅអី គ្រែ ឬសិប្បកម្ម ល្អី កញ្ជើ ... ខ្សែវល្លិ ឬសិល្បៈសូន្យរូប មានចម្លាក់ គំនូរបុរាណ ជាដើម ។ វត្តក៏អាច មានលទ្ធភាពធ្វើឱ្យអ្នកដែលរៀននៅសាលាវត្តមានសមត្ថភាព ដូចជាសាលារៀនសាធារណៈដែរ ។ លើសពីនេះទៀត អ្នករៀនសាលាវត្ត អាចមានសមត្ថភាពខ្ពស់ជាងការអប់រំសីលធម៌ និងអក្សរសាស្ត្រ ។ ដូច្នេះ សិស្សសាលាវត្ត ជាមនុស្សដែលមានគុណភាពខាងសីលធម៌ផង មានសមត្ថភាពខាងវិជ្ជាជីវៈផង និងខាងវប្បធម៌អក្សរសាស្ត្រផង ។

បើធ្វើបានយ៉ាងនេះ នោះវត្តអារាមរបស់យើង ប្រាកដជាបំពេញបាននូវភារកិច្ចដែលវត្តធ្លាប់មានពីបុរាណមក ។

៨-តាមដំណើរប្រព្រឹត្តទៅជាលំដាប់លំដោយ វត្តអារាមបានក្លាយទៅជាស្ថាប័នសម្រាប់ការអប់រំជាប្រពៃណី ដែលត្រូវបានគេរក្សាទុករហូតមកដល់បច្ចុប្បន្ន សូម្បីវត្តអារាមមួយយ៉ាងតូច តាំងនៅក្បែរកោះដាច់ស្រយាលមួយនៃប្រទេសពុទ្ធសាសនា ក៏គង់បានទៅជាមណ្ឌលរៀនសូត្រមួយដ៏សំខាន់ដែរ ។ នៅក្នុងការរីកដុះដាលនៃប្រព័ន្ធអប់រំរបស់វត្ត កើតមានគោលការណ៍ដ៏មានន័យមួយចំនួន ត្រូវបានគេយកមកអនុវត្ត ។

៩-វត្តអារាម ត្រូវតាំងខ្លួនជាមជ្ឈមណ្ឌលសម្រាប់ការអប់រំរៀបរយ និងមិនរៀបរយរបស់គ្រហស្ថ ដែលរស់នៅជិតខាងវត្តអារាម ។

នៅប្រទេសកម្ពុជា ក៏កើតមានវិធានការណ៍ប្រហាក់ប្រហែលគ្នានេះដែរ ប៉ុន្តែមិនជាសូវតឹងរ៉ឹង ម៉ត់ចត់ពេកទេ ។ នៅក្នុងបណ្តាឆ្នាំមុនប្រទេសកម្ពុជា បានទទួលឯករាជ្យក្នុងឆ្នាំ ១៩៥៣ និងបណ្តាឆ្នាំក្រោយប្រទេសបានឯករាជ្យ បន្តិចមក យុវជនណាមានបំណងប្រាថ្នាសុំផ្នួសជាសាមណេរ ឬសុំឧបសម្បទានជាភិក្ខុតែងត្រូវបានគេបញ្ជូនឱ្យទៅសិក្សាវិន័យធម៌អាចិ នៅវត្តអស់ពេលជាច្រើនខែ ។ បន្ទាប់មក កាលបើគិតថាចេះដឹងធម៌វិន័យជាមូលដ្ឋានបានសមស្របល្មមហើយបេក្ខសមណៈនោះ ត្រូវទៅសុំសេចក្តីអនុញ្ញាតដើម្បីបួស អំពីអធ្យាចារឃុំ ដែលនៅពេលនោះ អាជ្ញាធមរឃុំ បានធ្វើតេស ជាសំណួរផ្ទាល់មាត់ ចំពោះបេក្ខសមណៈនោះលើចំណេះដឹងធម៌វិន័យ ជាមូលដ្ឋាន ។ ក្រោយពេលបានបញ្ជាក់ឃើញថា បេក្ខសមណៈមានចំណេះដឹងធម៌វិន័យ សមស្របហើយ ទើបអាជ្ញាធរឃុំចេញលិខិតអនុញ្ញាតឱ្យបួសដល់បេក្ខសាមណៈនោះ ។ លិខិតអនុញ្ញាតនោះ មានឈ្មោះថា " បដិញ្ញាណ " ។

ការពោលនេះ មានន័យថា វត្តអារាម គម្បីរៀបចំចាត់ចែងដោយខ្លួនឯងឱ្យទៅជាស្ថាប័នអប់រំមួយ តាមបែបបទណាមួយ ។ ទីមួយ វត្តអារាមនោះត្រូវផ្តល់ឱ្យមានការអប់រំជាដំបូង និងជាប់លាប់ សម្រាប់ភិក្ខុ និងភិក្ខុនីដោយផ្ទាល់ ។ ក្នុងដំណាក់កាលដំបូង វត្តអារាមត្រូវរៀបចំឱ្យមានយ៉ាងហោចណាស់ នូវសេវាកម្មប្រចាំការណាមួយជាកំណត់ សម្រាប់អ្នកជំនាញខាងសូត្រអត្ថបទធម៌បានមកសម្តែង ។ អ្នកជំនាញគោរពចរនេះ គឺជាបាតុភូតមួយ មាននៅក្នុងដំណាក់

កាលដំបូងប៉ុណ្ណោះ ។ ទីពីរ វត្តអារាមត្រូវចាត់ចែងការអប់រំសម្រាប់គ្រហស្ថ ។ ការអប់រំនេះ អាចកំណត់ត្រឹមតែការសម្តែងធម៌ទេសនាជាទៀងទាត់ តាមកាលកំណត់ ឬជាការសម្តែងម្តងម្កាល ស្តីពីប្រធានបទសាសនា ជាដំណាក់កាលដំបូង ។ ប៉ុន្តែ ចំពោះគ្រហស្ថ ដែលស្វែងរកចំណេះដឹងជ្រាលជ្រៅ ដូចជាត្រៀមខ្លួនដើម្បីចូលបួសទៅក្នុងជួរព្រះសង្ឃ ឬដើម្បីចូលក្នុងការសិក្សាសម្រាប់ការកសាងខ្លួន ការសម្តែងធម៌ទេសនា ត្រូវប្រព្រឹត្តទៅដោយវិសាលភាពទូលំទូលាយ ។ មិនយូរប៉ុន្មាន ការប្រៀនប្រដៅសម្រាប់យុវជន ក៏បានក្លាយទៅជាការទទួលខុសត្រូវផ្នែកសង្គមកិច្ចរបស់ភិក្ខុសង្ឃដែរ ។

កំណត់: ១.វត្តអារាមជាកន្លែងប្រជុំប្រជាជន ដើម្បីសន្ទនាពីធម៌អាថ៌ ឬ ព្រឹត្តិការណ៍នានា តាមសេចក្តីចេះដឹងក្នុងសម័យ និយមនោះ ៗ ។ វត្តអារាមទុកជាអាងរៀនហត្ថកម្មមួយក្នុងផ្លូវសិល្បៈមានរៀនការងារជាងឈើការងារជាងកំបោរ ។ល។

២.វត្តអារាមជាឫសកែវ នៃព្រះពុទ្ធសាសនានៅប្រទេសខ្មែរយើង ។ បុណ្យទាន ជាឫសគល់វប្បធម៌ អរិយធម៌ របស់ខ្មែរសុទ្ធសឹងផ្តើមចេញពីវត្ត ។

៣.ប្រជាជនខ្មែរតាំងពីកើតទល់ស្លាប់ ( ពុទ្ធសាសនិក ) ត្រូវការវត្តទាំងអស់ ។

៤.និយាយអំពីវត្តគឺ ផ្សាភ្ជាប់ នឹងព្រះសង្ឃជានិច្ច។ វត្តល្អ វត្តមានសារៈប្រយោជន៍ពិតដល់ពុទ្ធសាសនិក គឺដោយសារព្រះសង្ឃ ។

៥.ករណីនេះឃើញថា ព្រះពុទ្ធសាសនានៅព្រទេសកម្ពុជាយើងមានព្រយោជន៍ដ៏ធំទូលាយ អាចជួយសង្គ្រោះទំនុកបំរុង ដល់ប្រទេសជាតិបាន គឺថាវត្តនៃព្រះពុទ្ធសាសនា ទុកដូចជា កន្លែងឧបត្ថម្ភអាហាររូបករណ៍មួយដ៏ប្រសើរដល់អ្នកក្រីក្រ អាចចិញ្ចឹមមនុស្សក្រទ័ល ក្រដែលមិនមានលំនៅជ្រកកោននិងអាហារបរិភោគ ។ វត្ត របស់ព្រះពុទ្ធសាសនា បានជួយសម្រាលភារៈរាជរដ្ឋាបាលឱ្យបានធូរស្រាលច្រើន ។

៦.បព្វជិតពុទ្ធសាសនិក នៅវត្តអារាមគ្រប់ស្រុក មានលោកចៅអធិការគ្រូសូត្រជាដើម ដែលលុះក្នុងការសិក្សាធម្មវិន័យ បានចុះស្នាមក្នុងផ្លូវសិក្សាតាមពុទ្ធនិយមអាណាចក្រនិយម ។ ការសិក្សាច្បាប់ព្រះពុទ្ធសាសនារបស់បព្វជិត ពុទ្ធសាសនិកនោះជាកម្លាំងមួយដែលនាំឱ្យមានប្រាជ្ញា ស្មារតីបរិបូណ៌ នាំឱ្យភ្លឺទាំងផ្លូវលោកទាំងផ្លូវធម៌

ទៀតផង ព្រោះការចេះដឹងទាំងខាងផ្លូវលោក ផ្លូវធម៌ ជាកត្តាចម្បងសម្រាប់ជួយបុគ្គលខ្លួនឯងនិងជួយដល់បព្វជិតចំណុះជើងវត្តនិមួយៗឱ្យមានសមត្ថភាព បំរើព្រះពុទ្ធសាសនា និង បំរើជាតិមាតុភូមិ ។

**៧.**ក្រុងភ្នំពេញជារាជធានី ជាមជ្ឈមណ្ឌលវប្បធម៌ សេដ្ឋកិច្ច និងជាទីប្រជុំភ្ញៀវជាតិអន្តរជាតិយ៉ាងច្រើនសន្ធឹកសន្ធាប់ព្រមទាំងមានវត្តអារាមធំៗ ដូចជាវត្តឧណ្ណាលោម វត្តលង្កា វត្តសារាវ៉ន វត្តបទុមវតី វត្តព្រះពុទ្ធមានបុណ្យ វត្តស្វាយពពែ វត្តប្រយូរវង្ស ជាដើមដែលទទួលបន្ទុក ព្រះភិក្ខុ សាមណេរ និង យុវជន ជាក្មេងវត្តជាច្រើន ។

សម័យមុន ច្បាប់ខ្មែរច្រើនផ្តើមចេញពីអ្នកបួស អ្នករៀននៅវត្ត ដូចជា:

១.គំនូរខ្មែរដោយច្បាប់បុរាណ

២.សុភាសិត

៣.ច្បាប់ក្រម

៤.ច្បាប់កូនចៅ

៥.ច្បាប់ក្រមសត្រវា

៦.ច្បាប់ទូន្មានខ្លួន

៧.ច្បាប់ព្រះរាជសម្ភារ

៨.ច្បាប់ស្រី

៩.ច្បាប់កេរ្តិ៍កាល

១០.ច្បាប់ថ្មី

១១.ច្បាប់បពិត្រមហារាជ

១២.ច្បាប់ប្រយោជន៍ជន

១៣.ច្បាប់ត្រៃនេតិ

១៤.ច្បាប់សូស្តី ។ល។

ប្រសិនបើសង្ឃសាសនិក ពុទ្ធសាសនិកទាំងឡាយបានក្តាប់ជាប់នូវវិន័យធម៌អារទាំងឡាយដែលចេះដឹងពីក្នុងវត្តអារាម ដោយយកផ្សព្វផ្សាយខាងក្រៅផង និងធ្វើជាគំរូ

ដ៏ល្អផង ម៉្លេះសមរាជរដ្ឋាភិបាល មិនមានទទួលបន្ទុកអ្វីធ្ងន់ធ្ងរ អំពីវិស័យនេះ ចំពោះសង្គមឡើយ ព្រោះពុទ្ធសាសនិកខ្មែរទាំងអស់ប្រហែល ៩៥ ភាគរយទៅហើយ ។

ឧទាហរណ៍ ដូចជា : កថាខណ្ឌ បណ្ឌិតវគ្គ ក្នុងគតិលោកភាគទី២ ទំព័រទី ៥៩-៦០ របស់លោក **សុត្តន្ត ប្រីជាឥន្ទ** ដោះស្រាយរវាងសិស្សនិងគ្រូ " សូមទាន ខ្ញុំករុណាសំគាល់ថាលោកអាចារ្យដែលចេះព្រះត្រៃបិដក១ លោកអាចារ្យដែលចេះព្រះកម្មដ្ឋាន១ លោកទាំងពីរនេះ ហៅថាអ្នកប្រាជ្ញ ឬ ? "អើ ឯងថានេះត្រូវដែរ តែមិនទាន់ចំ បើលោកអ្នកចេះព្រះត្រៃបិដក ព្រះកម្មដ្ឋាននោះ បើចេះហើយតែនៅមិនទាន់ទូន្មានខ្លួនឱ្យស្លូតត្រង់បាន នៅប្រកបដោយលោភៈទោសៈ មោហៈ ទិដ្ឋិ ខឹងឃោរឃៅ ជេរពោលប្រទេចផ្តាសា វាយគេ កាច់មួលព្រះពុទ្ធ ភាសិត ពុំប្រព្រឹត្តតាមក្រិត្យបន្ទាត់ព្រះវិន័យជាដើម យ៉ាងនេះ តើនឹងហៅថាអ្នកប្រាជ្ញដូចម្តេច ។

ករុណា បើលោកចេះព្រះត្រៃបិដក ចេះព្រះកម្មដ្ឋានហើយ ចិនោះនៅមាន លោភៈទោសៈ មោហៈ ជាដើមយ៉ាងនេះ ក៏ពុំបានរាប់ហៅថា ជាអ្នកប្រាជ្ញឡើយ ហៅថាពាលវិញ ។

"អើដូចយ៉ាង កបិលភិក្ខុ បួសក្នុងពុទ្ធសាសនាព្រះពុទ្ធកស្សបៈ ជាម្ចាស់នោះគឺជាភិក្ខុចេះព្រះត្រៃបិដកចប់ទាំងប្រាំបីហ្មឺនបួនពាន់ ធ្វើជាអាចារ្យធំ តែពុំប្រព្រឹត្តតាមធម៌ តាមវិន័យ ស្រដីកាច់មួលព្រះពុទ្ធវចនៈ ទៅផ្សេងៗ លុះអស់អាយុទៅ ក៏ធ្លាក់សោយទុកវេទនាក្នុងមហានរក ( ជាប់ទោស ) ។ ជាងនេះទៅទៀតនៅក្នុងបុណ្យផ្សេង ៗ ជាច្រើន ដែលដូនតាយើងចារទុកមក សុទ្ធតែមានបំណង អប់រំឱ្យយើងធ្វើឱ្យបានល្អឱ្យបានត្រឹមត្រូវ មានន័យថា ឱ្យមានចិត្តជា បុណ្យជានិច្ច ។

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

# ២

# អំពីបុណ្យ

## បុណ្យជាអ្វី ?

**ពាក្យថាបុណ្យ** ( សូមមើល ឃិន វ៉ន ប្រជុំបុណ្យប្រវត្តិបាត់ដំបង ឆ្នាំ ១៩៦៧ )

ពាក្យថា**បុណ្យ** ជាភាសាសំស្ក្រឹត , ភាសាបាលីថា **បញ្ញ** , បើភាសាខ្មែរថា **ពេញ** ឬថា ធម្មជាតិឯណា ដែលស្អាតបរិសុទ្ធផូរផង់ ប្រាសចាកមន្ទិលគឺ សេចក្ដីសៅហ្មងចិត្ត , សមដូចបទ ពិគ្រោះដែលលោកចងទុកក្នុងគម្ពីរ អភិធានប្បទីបិកាសូចិ ថា: សន្តានំ បុនាតិ សោធេ តីតិ > បុញ្ញំ ( ប្រែថា ) កុសលធម៌ឯណា ដែលជម្រះសន្តានចិត្តឱ្យស្អាតបរិសុទ្ធបាន កុសលធម៌ នោះ ឈ្មោះថា " **បុណ្យ** " ដូច្នេះ ។ ន័យមួយទៀត ថា បុណ្យនេះ លោកសំដៅយក សេចក្ដី សុខចម្រើន រីករាយដែលត្រូវបានដល់អ្នកធ្វើ ដូចមានពុទ្ធភាសិតសម្ដែងទុកក្នុងគម្ពីរអង្គុត្តរ និកាយសត្តនិបាតថា " **មា ភិក្ខវេ បុញ្ញានំ ភយិត្ថ សុខស្សេតំ ភិក្ខវេ អធិវចនំ យទិទំ បុញ្ញានំ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំខ្លាចបុណ្យឱ្យសោះ ម្នាលភិក្ខុទាំងឡាយ ព្រោះពាក្យដែលហៅថា បុណ្យនុ៎ះ មិនគឺអ្វីដទៃឡើយ គឺឈ្មោះនៃសេចក្ដីសុខ , សេចក្ដីសុខនុ៎ះ សោត ក៏ជាឈ្មោះរបស់បុណ្យ " ដូច្នេះ ។ ពុទ្ធភាសិតនេះព្រះបរមគ្រូជាម្ចាស់ ទ្រង់ត្រាស់ ទេសនាថា" បើបុរសស្ត្រីណាមួយបានធ្វើបុណ្យ ត្រូវខំធ្វើបុណ្យនោះ ឱ្យរឿយៗ គឺទ្រង់ដាស់តឿន ពុទ្ធបរិស័ទ ឱ្យប្រឹងធ្វើបុណ្យដែលជាហេតុ គឺធម្មជាតិជម្រះសន្តានចិត្ត ឱ្យប្រាសចាកសេចក្ដី លោភ សេចក្ដីខឹង សេចក្ដីវង្វេង ឱ្យញឹកញាប់ដើម្បីយកបុណ្យដែលជាផល គឺសេចក្ដីសុខ ចម្រើននោះឯង , ព្រោះអ្នកដែលបានធ្វើចិត្តឱ្យប្រាសចាកអកុសលធម៌ ៣ យ៉ាងជាដើម នោះ ទើបបានឈ្មោះថា " អ្នកមានចិត្តជាបុណ្យ " ។ ធម្មតាអ្នកមានចិត្តជាបុណ្យនុ៎ះឯង តែងធ្វើ

បុញ្ញកិរិយាវត្ថុទាំងឡាយ មានទានសីល ភាវនាជាដើម បានដោយងាយ ។ អំពើដែលធ្វើទាន សីលភាវនា នឹងហើយលោកហៅថា " ធ្វើបុណ្យ " បុណ្យនេះហើយដែលជាហេតុផ្តួចផ្តើម ឱ្យកើតទៅជាកម្រៃផល គឺសេចក្តីសុខសប្បាយដោយយសស័ក្តិ សម្បត្តិ បរិវារ អាយុយឺនយូរ នឹងសតិបញ្ញា ឱ្យបានផលក្នុងជាតិនេះ នឹងបរជាតិគឺជាតិ ខាងមុខ។

**ហេតុដែលនាំឱ្យកើតជាបុណ្យមាន ៣ យ៉ាងគឺ :**

១-មានចិត្តជ្រះថ្លា

២-មានចិត្តតក់ស្លុត

៣-មានសេចក្តីស្អាតដោយកាយវាចាចិត្ត

**បុណ្យមាន អានិសង្ស ៥ យ៉ាង គឺ**

| | |
|---|---|
| ១- ភិក្ខុបញ្ញាវិសារទា | មានប្រាជ្ញាក្លៀវក្លាមុះមុត |
| ២- សុវណ្ណតា | មានពណ៌សម្បុរល្អ |
| ៣- សុរូបតា | មានរូបល្អ |
| ៤- សុសណ្ឋានា | មានទ្រង់ទ្រាយល្អ |
| ៥- ចក្កវត្តិរាជាហោតិ | នឹងបានទៅជាស្តេចចក្រពត្តិក្នុងជាតិណាពុំខានឡើយ |

# I. បំភ្លឺបុណ្យ

(សូមមើល អ៊ុម ស៊ុម បំភ្លឺបុណ្យ ១៩៩០)

**អភិត្ថរេថ កល្យាណេ បាបា ចិត្តំ និវារយេ ទន្ធំ ហិករតោ**

**បុញ្ញំ បាបស្មឹ រមតី មនោ ។**

បុរសស្ត្រី គប្បីប្រញាប់ប្រញាល់ធ្វើនូវកល្យាណកម្ម (បុណ្យទាំងឡាយ) គប្បីរាំងស្កាត់ចិត្តចាកបាប ព្រោះថាបុណ្យកាលណាគេយឺតយូរក្រធ្វើចិត្តជាតួបុណ្យ រមែងត្រេកអរចំពោះបាប។

ពុទ្ធភាសិតនេះ គ្រាន់តែជាគោលធម៌សម្រាប់ជាមេគំនិតត្រិះរិះពិចារណា ប្រមូលផ្ដុំចងក្រងលើកឡើង បំភ្លឺអំពីបញ្ហាបុណ្យ និងបញ្ហាធ្វើពិធីបុណ្យផ្សេងៗ ប៉ុណ្ណោះរួចហើយសឹមធ្វើអត្ថាធិប្បាយពុទ្ធភាសិតខាងលើ ។

មុនដំបូងគួរចង់ដឹងថា :

១-អ្វីទៅបុណ្យ ?

២-អ្វីជាតួបុណ្យ ?

៣-បុណ្យប្រែដូចម្ដេច ?

៤-អ្វីជាឈ្មោះបុណ្យ ?

៥- អ្វីខ្លះជាអានិសង្សរបស់បុណ្យ ?

៦-តាមលទ្ធិព្រះពុទ្ធសាសនា គេធ្វើបុណ្យដើម្បីអ្វី ?

៧-ផ្លូវចិត្តជាបុណ្យ គេកត់សម្គាល់យ៉ាងណាខ្លះ ?

## ១-អ្វីទៅជាបុណ្យ ?

សភាវៈដែលហាមឃាត់ចិត្តចាកបាបផ្សេងៗ បញ្ឈប់ចិត្តដែលឱ្យត្រេកត្រអាលចំពោះបាប បំភ្លេចអារម្មណ៍បាប ចាស់ចោលឱ្យអស់ ធ្វើចិត្តឱ្យឃ្លាតផុតចាកបាប អកុសលថ្មីរួចហើយបំពេញបុណ្យ កុសល ជាជំនួយវិញភ្លាម កុំឱ្យទំនេរដើម្បីបង្វែចិត្តឱ្យងាកមកត្រេកត្រអាលខាងបុណ្យកុសលវិញដុះខាត់អប់រំឱ្យស្អាត មានរស្មីភ្លឺត្រចះត្រចង់ ដូចប្រក្រតីដើមវិញ ដោយពិធីឱ្យទាន រក្សា សីល ចម្រើនមេត្តា-ភាវនា ។ល។ ហៅថា "បុណ្យ" ។

## ២-អ្វីជាតួបុណ្យ ?

ចេតនាជាតួបុណ្យ ។ ការកសាងកុសលកម្មផ្សេងៗ ដែលជាអំពើល្អសុទ្ធតែសម្រេចដោយចិត្ត មានចិត្តជាប្រភពផ្ដួចផ្ដើម មិនប្រសើរវិសេសលើសអ្វីៗទាំងអស់ មានចិត្តជាសភាពដុះខាត់រំលីងនូវកិលេសគ្រប់ប្រភេទដែលជាគ្រឿងសៅហ្មង នឹងស្អុកស្អាញឱ្យស្អាត-ថ្លាឈ្វេងមានរស្មីភ្លឺថ្លាត្រចះត្រចង់ ជាចិត្តគួរដល់កុសលកម្មផ្សេងៗគួរសង្វេក គួរដល់ជ្រះថ្លា គួរដល់សុច្ចរិត ចេតនានេះហើយជាតួបុណ្យ ។ ដូច្នេះព្រះពុទ្ធដីការទ្រង់ត្រាស់ថាចេតនាហំ ភិក្ខវេ បុញ្ញំ វទាមិ ម្នាលភិក្ខុទាំងឡាយ តថាគតត្រាស់ថា ចេតនាជាតួបុណ្យ ។

## ៣-បុណ្យប្រែថាដូចម្ដេច ?

តាមធាតុវិគ្គហៈ បុណ្យ មកពីពាក្យបាលីថា បុញ្ញៈ គឺ បុធាតុ-ណ្យ បច្ច័យផ្លាស់ណ្យជាញ្ញៈ ផ្លាស់ញ្ញៈ ជាញ្ញៈ សម្រេចរូបជា បុញ្ញៈ សំស្រ្កឹតជាបុណ្យ វិគ្គហៈថា អត្តសន្តានំ បុនាតិ សោធេតីតិ បុញ្ញំ ( ធម្មជាតិ) ជម្រះនៅសន្តានរបស់ខ្លួនគឺថាសម្អាតនូវ សន្តានរបស់ខ្លួនហៅថាបុណ្យ ។

តាមអត្ថវិគ្គហៈថា សន្តានំ បុនាតិ សោធេតីតិ បុញ្ញំ ប្រែថាកុសលធម៌ណា ដែលជម្រះនូវសន្តានចិត្តឱ្យស្អាត-ផូរផង់ កុសលធម៌នោះ ឈ្មោះថាបុណ្យ ។

កុសលធម៌ក្នុងទីនេះ សំដៅយដល់មហាកុសលប្រាំបី ដែលប្រព្រឹត្តិទៅក្នុងបុញ្ញកិរិយាវត្ថុ ១០ ដែលជាសភាវៈសម្រាប់ដុះខាត់ សន្តានចិត្តឱ្យជ្រះស្អាតរលីង អស់មន្ទិលសៅហ្មងឱ្យនៅតែតួចិត្តសុទ្ធមានអ្វីលាយឡំ ជាចិត្តមានពន្លឺភ្លឺថ្លា ដូចប្រក្រតីដើម( បកតិមនោ) ។

ប្រភពបុណ្យនេះកើតឡើងក្នុងចិត្តជាមុន ទើបកើតក្នុងផ្លូវកាយនិងផ្លូវវាចាជាក្រោយ ។

បុណ្យដែលកើតឡើងដោយផ្លូវកាយ ហៅថា កាយវិការ គឺកម្រើកដៃកម្រើកជើងចលនាធ្វើការកុសលផ្សេងៗ មានអង្គុយបទជើងឬលត់ជង្គង់លើកដៃប្រណមថ្វាយបង្គំនមស្សការព្រះរតនៈត្រៃ នឹងធ្វើការ ហត្ថកម្មបំពេញកុសលផ្សេងៗ ដោយលើកដៃឈានជើងជាដើម ដូចរឿងស្ដេច ចណ្ឌប្បជោត ជាឧទាហរណ៍ សូមលើករឿងនេះមកសម្ដែង ដូចតទៅ :

ក្នុងកាលដ៏កន្លងរំលងទៅហើយ មានបច្ចេកពុទ្ធ ១ព្រះអង្គទ្រង់និមន្តទៅបិណ្ឌបាត្រ ចង្ហាន់នៅភូមិមួយ ពុំមានអ្នកណាដាក់បាត្រ ព្រះអង្គសោះ ។ ដល់ថ្ងៃត្រង់ជិតហួសពេលឆាន់ ព្រះអង្គទៅឈរស្ងៀមនៅក្បែរផ្ទះមន្ត្រីម្នាក់ ។ មន្ត្រីនោះចេញមកពីគាល់ព្រះរាជាវិញ បានឃើញព្រះបច្ចេកពុទ្ធ ទ្រង់ឈរស្ងៀមក៏ស្ទុះទៅបើកគំរបបាត្រមើល ឃើញគ្មានចង្ហាន់បន្តិចសោះ ក៏ស្ទុះប្រញាប់ចូលទៅក្នុងផ្ទះ បង្គាប់កម្មករឱ្យយកបាយនិងម្ហូបដែលអ្នកផ្ទះរៀបទុកឱ្យខ្លួន ទៅដាក់បាត្រព្រះអង្គថា "ចូរអ្នកយកចង្ហាន់នេះ ទៅដាក់បាត្រលោកជាប្រញាប់ព្រោះថ្ងៃជិតហួសពេលឆាន់ទៅហើយ ទៅចុះយើងចែកផលបុណ្យពាក់កណ្ដាលម្នាក់" ។ កម្មករឮដូច្នេះក៏ត្រេកអរវេតឧបមា ហើយខំកម្រើកដៃជើង ស្ទុះរត់ប្រញាប់ប្រញាល់យកចង្ហាន់ទៅដាក់បាត្រព្រះបច្ចេកពុទ្ធភ្លាម ។ លុះដាក់ហើយ សូមប្រាថ្នាថា " ដោយផលដែលខ្ញុំខំរត់ ទាំងកណ្ដាលថ្ងៃក្ដៅយក



ពិធីដង្ហែព្រះបរមសារីរិកធាតុ



ព្រះមហាក្សត្រ និង សម្តេចព្រះរាជអគ្គមហេសីជទីសក្ការៈ យាងដង្ហែព្រះបរម
សារីរិកធាតុនៅព្រះសក្យមុនីចេតីយ៍



សម្តេច **ហ៊ុន សែន** និង **លោកជំទាវ** ដង្ហែព្រះពុទ្ធបដិមាករទៅតម្កល់នៅព្រះសក្យមុនីចេតីយ៍

ម្សៅមកដាក់ បាត្រព្រះអង្គនេះ សូមឱ្យខ្ញុំកើតក្នុងជាតិខាងមុខមានកម្លាំងច្រើន មានយានជំនិះសុទ្ធតែលឿនៗ មានអំណាចខ្លាំងដូចព្រះអាទិត្យ ឋិតកណ្តាលអាកាស ។

ដោយអានិសង្សនៃកាយវិការដែលកម្រើកកាយ ស្ទុះប្រញាប់យកចង្ហាន់ទៅដាក់បាត្រព្រះបច្ចេកពុទ្ធនោះ បុរសនោះស្លាប់ពីមនុស្សលោកនេះទៅបានទៅកើត ទេវលោក សោយសុខអស់ ១ពុទ្ធន្តរ (ចន្លោះព្រះពុទ្ធ ព្រះអង្គ) លុះមកដល់ពុទ្ធកាលនៃព្រះសក្យមុនីគោត្តបរមគ្រូនៃយើង ចុះមកកើតក្នុងមនុស្សលោកបានជាស្តេច ១ព្រះអង្គក្នុងជម្ពូទ្វីបព្រះនាមព្រះបាទចណ្ឌប្បជោតិទ្រង់មានយានជំនិះ សេះដំរី សុទ្ធតែលឿនៗ ធ្វើដំណើរបាន១២០យោជន៍ក្នុងមួយថ្ងៃទ្រង់មានកម្លាំងខ្លាំង អំណាចរុងរឿងដូចព្រះអាទិត្យរះចែងចាំងកណ្តាលនភាល័យ ។

នេះជាអានិសង្សនៃកាយវិការ ដែលកម្រើកដៃជើងធ្វើការកុសលដោយចិត្តជ្រះថ្លា ។

បុណ្យដែលគេធ្វើដោយផ្លូវវាចា ហៅថា វចីវិការ គឺកម្រើកវាចា ធ្វើកុសលផ្សេងៗមាន បញ្ចេញសម្លេងសូត្រធម៌ នមស្ការព្រះរតនៈត្រៃនិងសូត្រឱ្យគេស្តាប់ ឬប្រកាសឃោសនាបបួល គេឱ្យចូលរួម ធ្វើកុសលផ្សេងៗមាន ធ្វើទានស្តាប់ធម៌ទេសនា សមាទានសីលជាដើម ។ ដូច រឿងឃោសិតសេដ្ឋីជាឧទាហរណ៍សូមនាំរឿងនេះ ដោយសង្ខេប មក សម្តែងដូចតទៅ :

ក្នុងសម័យមុនពុទ្ធកាល នៃព្រះសក្យមុនីគោត្តមជាអម្ចាស់យើងនេះ កាលនោះមានបុរសកំសត់ម្នាក់ស្វែងរកអាហារក្នុងពេលដែលស្រុកកើតទុរភិក្ស គឺអត់បាយ ដោយអស់កម្លាំងពេលវេលាទៀបនឹងស្លាប់គាត់ដេកសម្លឹងមើលមេឆ្កែដែលសេដ្ឋីម្នាក់ គេឱ្យវាស៊ីបាយដោយភាជន៍ប្រាក់ ក៏នឹកស្ងើចក្នុងចិត្តគិតចង់កើតជាឆ្កែដ៏មានភ័ព្វ បានអាហារឆ្ងាញ់ៗបរិភោគ លុះស្លាប់ទៅទៅកើតជាកូនឆ្កែនោះសេដ្ឋីក៏ស្រឡាញ់កូនឆ្កែនោះណាស់ ទៅណាមកណាតែងយកទៅតាមខ្លួន។ សេដ្ឋីនោះជាអ្នករាប់អានព្រះបច្ចេកពុទ្ធ ១ ព្រះអង្គដែលមាន អាស្រមនៅក្នុង ព្រៃមួយក្បែរភូមិរបស់ខ្លួន ។ វេលាមួយ សេដ្ឋីបាននាំកូនឆ្កែនោះទៅពីល្ងាច និមន្តព្រះបច្ចេកពុទ្ធ មកឆាន់នៅផ្ទះខ្លួនក្នុងវេលាព្រឹកថ្ងៃស្អែក ។ សេដ្ឋីនិមន្ត ហើយទូលព្រះបច្ចេកពុទ្ធថាព្រឹកស្អែក ខ្ញុំព្រះករុណានឹងប្រើកូនឆ្កែ ឱ្យមកនាំ ដំណើរព្រះអង្គទៅផ្ទះខ្ញុំព្រះករុណា សូមព្រះអង្គនិមន្តទៅតាមសញ្ញាដែលកូនឆ្កែនេះ នាំព្រះអង្គចុះ ។

ដល់ព្រឹកឡើង សេដ្ឋីបានប្រាប់កូនឆ្កែឱ្យទៅនិមន្តព្រះអង្គ ។ កូនឆ្កែនោះពិតមែនមិនចេះនិយាយ ភាសាមនុស្សតែមានគំនិតប្រាជ្ញាវៀងវៃ អាចស្តាប់ដឹងសេចក្តីសព្វគ្រប់បាន ។ កាលសេដ្ឋីប្រើហើយ កូនឆ្កែនោះក៏រត់តាមផ្លូវតម្រង់ទៅ អាស្រមរបស់ ព្រះបច្ចេកពុទ្ធ ។ ពេលរត់ទៅតាមផ្លូវកូនឆ្កែនោះវា ស្រែកព្រុះខ្លាំងៗ ដេញសត្វនានាតាមព្រៃស៊ប់ទ្រុប និងតាមដំបូកដែលនៅក្បែរផ្លូវនោះចេញអស់ ដើម្បីកុំឱ្យសត្វចឹកខាំព្រះបច្ចេកពុទ្ធ ។ លុះវារត់ទៅដល់អាស្រមវា ឈរព្រុះខ្លាំងៗនៅមុខអាស្រមជាសញ្ញានិមន្តព្រះអង្គ ។ព្រះបច្ចេកពុទ្ធឮសម្លេងព្រុះ ក៏ជ្រាបថាកូនឆ្កែមកនិមន្តហើយ ក៏ព្រះអង្គរៀបចំឃ្លុំចីពរប្រដាប់ដោយបាត្រ និមន្តតាមក្រោយ កូនឆ្កែទៅកាន់ផ្ទះសេដ្ឋី លុះដល់ផ្លូវបែកជាពីរព្រះអង្គចង់ដឹងគំនិតកូនឆ្កែក៏ធ្វើជានិមន្តទៅតាមផ្លូវ ១ ដែលខុសពីផ្លូវទៅផ្ទះសេដ្ឋី ។ កូនឆ្កែឃើញដូច្នោះវាស្ទុះទៅទាញជាយស្បង់បំបែរព្រះអង្គឱ្យមកខាងផ្លូវត្រូវ ។ ដល់ផ្លូវជាលំដាប់មក ព្រះអង្គធ្វើដូច្នោះទៀត កូនឆ្កែខាំទាញស្បង់ទៀត ទាល់តែរហែកជាយស្បង់ ។

លុះព្រះបច្ចេកពុទ្ធនិមន្តមកដល់ផ្ទះ សេដ្ឋីសួររឿងរហែកជាយស្បង់ ព្រះអង្គប្រាប់តាមដំណើរនោះសព្វគ្រប់ សេដ្ឋីចាត់ចែងដេរជាយស្បង់ហើយនិមន្តឆាន់ដោយរីករាយ ។ ឆាន់ហើយព្រះអង្គធ្វើអនុមោទនារួច លាសេដ្ឋីត្រឡប់ទៅអាស្រមវិញ ។

កាលព្រះបច្ចេកពុទ្ធត្រឡប់ទៅវិញ កូនឆ្កែតាមជូនទៅដែរដល់ផុតពីភូមិទៅ ព្រះបច្ចេកពុទ្ធ ព្រះអង្គហោះឡើងទៅលើអាកាស ។ វេលាព្រះអង្គហោះឡើង កូនឆ្កែក្រឡេកមើលមានចិត្តស្រងេះស្រងោចអាល័យព្រះអង្គ ដរាបដល់បែកទ្រូងស្លាប់ក្នុងពេលនោះទៅ បានទៅកើតជាទេវបុត្រនៅឋានត្រៃត្រិង្ស ទេវលោក ។

ដោយអានុភាពនៃស្រែកព្រុះនិមន្ត បច្ចេកពុទ្ធ ទេវបុត្រនោះកើតមានសម្លេង កងរំពងខ្លាំងជាងទេវបុត្រដទៃ គេឱ្យឈ្មោះថាឃោសកទេវបុត្រ សោយសុខក្នុងទេវលោក អស់ ១ ពុទ្ធន្តរ (ចន្លោះព្រះពុទ្ធ ១ ព្រះអង្គ) បុណ្យដែលគេធ្វើតាមផ្លូវចិត្តហៅថាធ្វើដោយ មនោវិការគឺកម្រើកចិត្តនឹកគិតដល់ការកុសលផ្សេងៗមានជ្រះថ្លានឹកដល់គុណព្រះរតនៈត្រៃជាដើម ដែលបានជួបប្រទះឃើញដូច រឿងមដ្ឋកុណ្ឌលី ទេវបុត្រ ។ សូមនាំរឿងនេះដោយសង្ខេបមកសម្តែងដូចតទៅនេះ :

កាលព្រះសម្មាសម្ពុទ្ធ ទ្រង់គង់នៅវត្ត ជេតពន ទៀបក្រុងសាវត្ថី មានព្រាហ្មណ៍ម្នាក់ជាមនុស្សកំណាញ់ មិនដែលបានឱ្យអ្វីតិចតួចដល់អ្នកណាសោះ ទើបអ្នកស្រុកហៅគាត់ថា អទិន្នបុព្វកៈ ។ ព្រាហ្មណ៍នោះ មានកូនប្រុសម្នាក់ឈ្មោះ មដ្ឋកុណ្ឌលី ព្រោះគាត់អារដុំមាសខ្លួនគាត់ ខាត់ឱ្យរលីង ធ្វើកុណ្ឌលឱ្យកូនពាក់ ។កូននោះអាយុ ១៦ឆ្នាំ មានជម្ងឺឈឺជាទម្ងន់ ។ អទិន្នបុព្វកៈព្រាហ្មណ៍មិនហ៊ានទុកកូននៅល្វែងផ្ទះខាងក្នុង ខ្លាចញាតិសន្ដានគេចូលទៅសួរកូនហើយឃើញសម្បត្តិទ្រព្យគេសុំ គាត់ក៏យកកូនមកដាក់ឱ្យដេកនៅតាកខាងក្រៅផ្ទះ ។

មដ្ឋកុណ្ឌលីមាណពជាកូនគិតថា **"ឪពុកអញគាត់កំណាញ់ណាស់នៅផ្ទះជិតវត្ត ជេតពន តែគាត់មិនដែលនិមន្តព្រះសង្ឃឆាន់ មិនដែលដាក់បាត្រព្រះពុទ្ធ ឬព្រះសង្ឃណាមួយវែកសោះ ទាំងខ្លួនអញក៏គាត់មិនឱ្យទៅវត្តស្ដាប់ទេសនា គោរពប្រណិបត្តិព្រះពុទ្ធនិងព្រះសង្ឃសោះ ឥឡូវខ្លួនអញឈឺធ្ងន់ ក្រោកមិនរួចជិតដល់មរណៈទៅហើយ ធ្វើម្ដេចនឹងបានឃើញព្រះពុទ្ធជាម្ចាស់?"** ។

ពេលគិតនោះ មដ្ឋកុណ្ឌលី មាណពដេកបែរមុខទៅក្នុងផ្ទះស្រាប់តែ ព្រះពុទ្ធជាម្ចាស់ព្រះអង្គទ្រង់ប្រមើលមើល ឧបនិស្ស័យសត្វទ្រង់ជ្រាបថា **"មដ្ឋកុណ្ឌលី មាណព ឈឺទៀបស្លាប់ព្រះអង្គក៏យាងទៅឈរនៅមុខផ្ទះ ទ្រង់បញ្ចេញព្រះឆព្វណ្ណរង្សី ៦ពណ៌ចាំងចំភ្នែក១ ទៅត្រង់ទីដែល មាណពដេក"** ។ មាណពឃើញព្រះ ឆព្វណ្ណរង្សី ក៏ងាកមកក្រៅផ្ទះបានឃើញព្រះអង្គ ក៏មានបីតិ ប្រាមោជ្ជត្រេកអរឥតឧបមា នឹកថា **"ព្រះអង្គមកប្រោសខ្ញុំៗក្រោកពុំរួចទេ សូមថ្វាយបង្គំព្រះអង្គតែដោយចិត្ត"** ហើយក៏ធ្វើមរណៈកាលទៅ បានទៅកើតជាទេវបុត្រក្នុងឋានត្រៃត្រឹង្សសួគ៌ មានអត្តិភាពប៉ុនទេវបុត្រទាំងពួងដែលកើត ១៦ ឆ្នាំ ក្រឡេកមើលខ្លួនប្រាណដឹងថាខ្លួនមកកើតក្នុងទេវលោក ហើយមើលមកមនុស្សលោក ឃើញសាកសពរបស់ខ្លួន គេកំពុងនាំ យកទៅធ្វើឈាបនកិច្ចក្នុងទីប៉ាឆា ។ វេលាធ្វើឈាបនកិច្ចហើយ អទិន្នបុព្វកៈព្រាហ្មណ៍ តែងទៅយំសោកបោកខ្លួន នៅទីប៉ាឆាជារៀងរាល់ថ្ងៃ ថ្ងៃមួយព្រាហ្មណ៍កំពុងតែយំកន្ទក់កន្ទេញ មដ្ឋកុណ្ឌ លី ទេវបុត្រក៏ចុះមកជាមដ្ឋកុណ្ឌលីមាណព យំសោកក្នុងទីជិតគ្នានោះដែរ ។

អទិន្នបុព្វកៈឃើញដូច្នោះ ក៏ងាកមកសួរថា **"អ្នកជានរណា ?"**

មដ្ឋកុណ្ឌលីទេវបុត្រឆ្លើយថា "ខ្ញុំជាកូនរបស់អ្នកដែលស្លាប់ហើយទៅកើតជាទេវបុត្រ នៅឋានត្រៃត្រឹង្ស ទេវលោក " ។

-អ្នកគ្មានធ្វើបុណ្យអ្វីសោះ ម្តេចទៅកើតជាទេវបុត្រ នៅឋានសួគ៌បាន ?

-ខ្ញុំគ្រាន់តែនឹកថ្វាយបង្គំព្រះពុទ្ធតែក្នុងចិត្ត នៅពេលដែលខ្ញុំទៀបស្លាប់ប៉ុណ្ណោះ ស្លាប់ទៅក៏បានទៅកើតក្នុងឋានសួគ៌ ។

-បើទៅកើតក្នុងឋានសួគ៌ហើយ ម្តេចក៏មកយំធ្វើអ្វី ?

-បានជាខ្ញុំមកយំ ព្រោះកង់រថរបស់ខ្ញុំបាត់ម្ខាង ខ្ញុំមកសុំវង់ព្រះអាទិត្យ ដែលកំពុងរះនៅលើអាកាសនោះ ធ្វើជាកង់រថរបស់ខ្ញុំជំនួសកង់រថដែលបាត់ទៅ ។

-អ្នកយំចង់បានវត្ថុដែលមិនគួរបាន ដូច្នេះមានអ្នកជាមនុស្សវិកលចរិត ?

-បើថាខ្ញុំយំព្រោះចង់បានវង់ព្រះអាទិត្យ ដែលមានវង់មូលក្រឡង់មើលឃើញជាក់នឹងភ្នែកលាំងៗ ជាមនុស្សវិកលចរិតខ្លួនអ្នកជាឪពុក យំចង់បានកូនដែលស្លាប់បាត់រូបរៀងទៅហើយនេះជាមនុស្សវិកលចរិតជាងខ្ញុំទៅទៀត មិនមែនឬ ?

អទិន្នបុព្វកៈ ព្រាហ្មណ៍ទាល់ប្រាជ្ញក៏លែងយំ ហើយគិតថា "ចាំអញទៅសួរព្រះសាមណគោត្តមមើល តើមនុស្សគ្មានធ្វើទានអ្វីសោះ គ្រាន់តែនឹកថ្វាយបង្គំព្រះពុទ្ធ តែក្នុងចិត្តប៉ុណ្ណោះ បានទៅកើតជាទេវបុត្រក្នុងឋានសួគ៌ទេវលោកមែនឬ ? បើមានមែនអញនឹងជឿកាន់ព្រះពុទ្ធសាសនាតទៅ " ។

លំដាប់ពីនោះ អទិន្នបុព្វកៈ ព្រាហ្មណ៍ចូលទៅកាន់វត្ត ជេតពន ឈរសួរព្រះដ៏មានបុណ្យថា "មនុស្សគ្មានធ្វើបុណ្យអ្វីសោះគ្រាន់តែនឹកថ្វាយបង្គំព្រះពុទ្ធ តែក្នុងចិត្តប៉ុណ្ណោះ តើបានទៅ កើតជាទេវបុត្រក្នុងឋានសួគ៌មែនឬ ?

ព្រះអង្គឆ្លើយថា " ចាំអ្នកមកសួរតថាគតធ្វើអ្វីទៀត បើព្រឹកមិញអ្នកបានឃើញជាក់នឹងភ្នែក នូវមដ្ឋកុណ្ឌលី ជាកូនអ្នកដែលទៅកើតជាទេវបុត្រ នៅឋានសួគ៌ចុះមកជួបនឹងអ្នក នៅទីប៉ាឆា បានសួរដេញដោលគ្នាសព្វគ្រប់ស្រាប់ហើយ ។

ព្រាហ្មណ៍នឹកស្ងើចក្នុងចិត្តថា " ឱ ! ព្រះពុទ្ធព្រះអង្គគង់នៅឯវត្ត ជេតពន ឯណ្ណោះម្តេចក៏ទ្រង់ជ្រាបសព្វគ្រប់ម្ល៉េះ ! ការនេះច្បាស់ជា ព្រះអង្គជាព្រះអរហន្តមានព្រះញាណទិព្វមែន

ហើយបានជាទ្រង់ជ្រាប ហើយព្រាហ្មណ៍ក៏ជ្រះថ្លា បានយកព្រះរតនត្រ័យជាទីពឹង ហើយធ្វើទានរក្សាសីលក្នុងព្រះពុទ្ធសាសនាតទៅ ។

## ៤-អ្វីជាឈ្មោះរបស់បុណ្យ ?

សេចក្ដីសុខជាឈ្មោះរបស់បុណ្យ ពីព្រោះជាលទ្ធផលកើតមក ពីធ្វើចិត្តឱ្យស្អាត ចាកកិលេស ជាគ្រឿងសៅហ្មងស្មុគស្មាញនាំឱ្យមានភ័យផ្សេងៗមានលោភៈ ទោសៈ មោហៈ ជាដើម អាទិដូចជាពុទ្ធភាសិតត្រាស់ថា មាភិក្ខវេ បុញ្ញានំ ភយិត្ថ សុខស្សេតំ ភិក្ខវេ អធិវចនំ យទិទំបុញ្ញានំ ម្នាលភិក្ខុ ( អ្នកឃើញភ័យក្នុងសង្សារវដ្ដទាំងឡាយ ) អ្នកទាំងឡាយកុំខ្លាចបុណ្យឱ្យសោះ ពីព្រោះពាក្យថាបុណ្យ គឺជាឈ្មោះនៃសេចក្ដីសុខទេតើ ។

ន័យនោះគួរយល់ថា ការធ្វើបុណ្យអ្វីមួយពីព្រោះតែចង់បានសុខ បើបុណ្យជាឈ្មោះនៃសេចក្ដីសុខស្រេចទៅហើយ អ្នកធ្វើបុណ្យទាំងឡាយគប្បីខិតខំសំអាតកាយ (កាយវិសោចេយ្យ) សម្អាតវាចា(វចីវិសោ ចេយ្យ) សម្អាតចិត្ត (មនោវិសោចេយ្យ)តែមួយយ៉ាងប៉ុណ្ណោះ ដើម្បីរង់ចាំទទួលបុណ្យគឺ សេចក្ដីសុខមិនគួរភ័យខ្លាច ឬព្រួយបារម្ភពីអ្វីដទៃឱ្យសោះ ។ បុគ្គលខ្លះមានទ្រព្យសម្បត្តិច្រើនល្មពេក មានសទ្ធាជ្រះថ្លាធ្វើបុណ្យផ្សេងៗមានបុណ្យផ្កា បុណ្យកឋិនជាដើម ចាប់ផ្ដើមធ្វើឡើងមានភ័យព្រួយបារម្ភទុកជាមុនជានិច្ច គឺភ័យខ្លាចក្រែង :

១-បានបច្ច័យសង្កត់ត្រៃតិច

២-រៀបចំទទួលភ្ញៀវ មិនរាក់ទាក់មិនសមរម្យ

៣-គោរពញាតិធម៌ មិនដិតដល់

៤-ភោជនាហារទទួលភ្ញៀវ ក្រែងមិនឆ្ងាញ់ពិសារ

៥-ភ្ញៀវអ្នកចូលបុណ្យ ខ្លះចូលតិចក្រែងគេអន់ចិត្ត មិនល្មមដល់ទឹកចិត្តគេទទួល ខ្លាចគេនិយាយដើម ឬមិនសូវបានបុណ្យ ។

៦-និមន្តលោកទេសនា ក្រែងមិនពិរោះ ពិរោះហើយ ខ្លាចក្រែងបច្ច័យបូជាធម៌បានតិចតូចខ្មាស់គេ ឬមិនសមរម្យដល់បុណ្យស័ក្តិធម្មកថិកអ្នកទេសនា ។ល។

បើគេមានគំនិតតែយ៉ាងនេះ គេបោះបង់ចោលលែងពឹងផ្អែកលើបញ្ហារបស់ខ្លួន ដឹកនាំពិធីបុណ្យចាត់ចែង អស់ស្មារតីស្វែងរកខុសត្រូវខាតចំណេញ ក្នុងមុខចំណាយទ្រព្យសម្បត្តិធ្វើ

បុណ្យបានច្រើន ឬតិចយ៉ាងណាហើយ ។ ម្ល៉ោះហើយទើបគេធ្វើបុណ្យម្តងៗគេមិនចាប់អារម្មណ៍លើលក្ខណៈរបស់បុណ្យ ៣យ៉ាងប៉ុន្មានទេគឺ :

១-បសាទៈ សេចក្តីជ្រះថ្លា

២-សំវេគៈ ាសេចក្តីសង្វេគតក់ស្លុត

៣-តេសុចរិតា ប្រព្រឹត្តសុចរិតទាំង ៣ ។ គេរវល់តែរឿងភ័យសស្លន់សស្លោរ អំពាវនាវរកគេឯងឱ្យជួយប្រកាសប្រាប់គេថា "ខ្ញុំព្រួយចិត្តណាស់ ! ធ្វើបុណ្យម្តងនេះមិនដឹងជា យ៉ាងណាទេ លោតែបានបច្ច័យតិចតួច ខ្ញុំខ្មាស់គេងាប់ហើយ មិនដឹងយកមុខទៅទុកឯណាទេ ។ល។ ចំណែកខាងប្រភពបុណ្យ មូលហេតុបុណ្យ តួបុណ្យ ចេញមកពីណា ហើយជាអ្វីទៀតនោះ គេបោះបង់ចោលអស់ លែងចាប់អារម្មណ៍នឹកគិតខ្វល់ខ្វាយដោះស្រាយ តែអំពីរឿងដែលឥតប្រយោជន៍ខាងលើ ។

ចូរអ្នកធ្វើបុណ្យទាំងឡាយ ពិចារណាមើល ព្រះពុទ្ធឱវាទខាងក្រោមនេះ

បុគ្គលមិនគួរមើលងាយបុណ្យថា បុណ្យមានប្រមាណតិចនឹងមិនឱ្យផលឡើយ សូម្បីក្អមទឹកដែលគេបើកគម្របចំហរបាន យ៉ាងណាមិញ ជនអ្នកមានប្រាជ្ញា គេសន្សំបុណ្យ ម្តងបន្តិចៗ យូរៗទៅគង់ពេញហឫទ័យដោយបុណ្យបានក៏យ៉ាងនោះដែរ ។

មានអ្នកខ្លះ មិនបានស្រាវជ្រាវ យល់ដោយស្មានយកពាក្យបុណ្យប្រែថា "ពេញ" ទៅវិញ ប្រហែលជាគេស្មានថា"បុណ្យ" មកពីប្ញធាតុដើមគេប្រែថា "ពេញ" ? លុះប្រែរួចហើយថែមទាំងអធិប្បាយវែកញែកនូវពាក្យថា "ពេញ" គឺពេញដោយមានពួកពុទ្ធបរិស័ទមកធ្វើបុណ្យពេញវត្ត ពេញផ្ទះ ពេញរោងបុណ្យ ចំណែកបាយ សម្ល ផ្លែឈើ នំចំណីពេញចាន ពេញតុ ពេញថាស ។ល។ ទៀតផង ។

តាមការពិត "បុណ្យ" ពុំមែនជារឿងអ្វីដ៏ទៃផ្សេងទេប៉ុន្តែជារឿងអស់មន្ទិលសៅហ្មងស្អាតរលីងធេងទេ តើ ! គឺធ្វើឱ្យអស់កិលេស មានលោភៈ ទោសៈ មោហៈ មច្ឆរិយៈ ជាដើម ដែលជាគ្រឿងធ្វើចិត្តឱ្យកករល្អក់សៅហ្មង ជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗឱ្យទៅជាចិត្តស្អាតរលីង មានពន្លឺភ្លឺថ្លាដូចប្រក្រតីដើមវិញ ។ ពីព្រោះចិត្ត កាលដើមឡើយជាធម្មជាតិស្អាតមានពន្លឺ

ស្មើត្រចះត្រចង់ ចែងចាំងភ្លឺថ្លា ប៉ុន្តែប្រែក្លាយទៅជាមន្ទិលសៅហ្មងទៅវិញ ដោយអាស្រ័យហេតុគឺកិលេស ដែលទើបកើត លាយឡំថ្មី ធ្វើឱ្យសៅហ្មង អាប់ពន្លឺខុសប្រក្រតីដើមទៅវិញ ។

**បុណ្យមាន ៣ស្ថានគឺ**

១-ពោលដោយឫសគល់របស់បុណ្យ បានដល់កុសលមូល ៣ គឺ អលោភៈ អទោសៈ អមោហៈ ។ គេលះលោភៈដោយឱ្យទាន ។ លះទោសៈដោយរក្សាសីល លះមោហៈ ដោយចម្រើនភាវនា ( អប់រំបញ្ញា) ឱ្យភ្លឺថ្លាហៅថា "បុណ្យជាហេតុ" ។

២-ពោលតាមវត្ថុដែលគេធ្វើសម្រេចទៅជាពិធីបុណ្យ នីមួយៗមាន ១០យ៉ាងហៅបុញ្ញកិរិយាវត្ថុ១០គឺ

ក-ទានមយៈ បុណ្យសម្រេចដោយការឱ្យទាន

ខ-សីលមយៈ បុណ្យសម្រេចដោយការរក្សាសីល

គ-ភាវនាមយៈ បុណ្យសម្រេចដោយការចម្រើនកុសល

ឃ-អបចាយនមយៈ បុណ្យសម្រេចដោយការគោរព ក្រែងចាស់ព្រឹទ្ធាចារ្យត្រកូលវៀមច្បង

ង-បត្តិទានមៈ បុណ្យសម្រេចដោយចែកចំណែកបុណ្យដល់គ្នា

ច-បត្តានុមោទនាមយៈ បុណ្យសម្រេចដោយត្រេកអរចំពោះចំណែកបុណ្យ ដែលអ្នកដទៃឱ្យ

ឆ-វេយ្យាវច្ចមយៈ បុណ្យសម្រេចដោយខ្វាល់ខ្វាយ ជួយខ្នះខ្នែងក្នុងពិធីបុណ្យគេ

ជ-ធម្មស្សវនមយៈ បុណ្យសម្រេចដោយការស្តាប់ធម៌

ឈ-ធម្មទេសនាមយៈបុណ្យសម្រេចដោយសម្តែងធម៌

ញ-ទិដ្ឋុជុកម្មមយៈ បុណ្យសម្រេចដោយធ្វើទិដ្ឋិឱ្យត្រង់( សម្មាទិដ្ឋិ)

៣-ពោលតាមផលរបស់បុណ្យនីមួយៗការសន្សំបុណ្យ គឺការរក្សាទុកនូវអារម្មណ៍ជាបុណ្យ ជាប់ជានិច្ច នាំមកនូវសេចក្តីសុខត្រជាក់ត្រជុំទូលំទូលាយ មិនមានក្តៅក្រហាយអន្ទះអន្ទែងរួមមកហៅថាបុណ្យជាផល ។

**៥-អ្វីខ្លះជាអានិសង្សរបស់បុណ្យ ?**

ចិត្តត្រេកអររីករាយ ទូលំទូលាយជ្រាលជ្រៅ ធំធេងគ្មានចង្អៀតចង្អល់ដូចមហាសាគរ មិនធ្វើ កំពុងធ្វើ និងធ្វើ និងធ្វើរួចហើយដោយបានសម្រេចផលជាទីពេញចិត្ត ទទួលបាននូវ បុញ្ញាសម្បទាគ្រប់យ៉ាង ទាំងក្នុងលោកនេះ និងលោកខាងមុខ ព្រមទាំងឧបត្ថម្ភអារម្មណ៍ជាបុណ្យជាប់ជានិច្ចទៀតផងនេះ ហៅថាអានិសង្សបុណ្យ ។

សម្បទាបុណ្យមាន ៥ យ៉ាងគឺ

១-ញ្ញាតិសម្បទា សម្បូរដោយញាតិ

២-អារោគសម្បទា បរិបូណ៌ដោយសុខភាព

៣-ភោគសម្បទា បរិបូណ៌ដោយទ្រព្យ

៤-សីលសម្បទា បរិបូណ៌ដោយសីលធម៌

៥-ទិដ្ឋិសម្បទា បរិបូណ៌ដោយទិដ្ឋិ គឺប្រាជ្ញាយល់ឃើញត្រូវ ។

លើកឡើងជាឧទាហរណ៍ បុគ្គលិកលក្ខណៈ នៃបុគ្គលដែលប្រកបដោយបុញ្ញសម្បទា គឺនាងវិសាខាមហាឧបាសិកាជាស្ត្រីប្រកបដោយបុញ្ញសម្បទា ៥យ៉ាងគឺ

១-ញ្ញាតិសម្បទា បរិបូណ៌ដោយញាតិ គឺនាងមានកូន ២០ ចៅ៤០០ ចៅទួត៨.០០០ បូករួមត្រូវជា៨.៤២០នាក់ ។

២-អារោគ្យសម្បទា បរិបូណ៌ដោយមិនមានរោគ គឺទាំង៨.៤២០នាក់រួមទាំងខ្លួននាងផង មានសុខភាពល្អដូចគ្នា នាងមានអាយុ ១២០ឆ្នាំ ។

៣-ភោគសម្បទា បរិបូណ៌ដោយទ្រព្យ គឺក្នុងសម័យពុទ្ធកាលអ្នកដែលមានភោគទ្រព្យច្រើនជាងគេ ព្រមទាំងមានសទ្ធាបរិច្ចាគធ្វើទានផង ផ្នែកបុរសគឺអនាថបណ្ឌិតសេដ្ឋី ផ្នែកស្ត្រី គឺនាងវិសាខា ។

៤-សីលសម្បទា បរិបូណ៌ដោយសីល គឺនាងវិសាខាបានសម្រេចសោតាបត្តិផលតាំងពីក្មេងអាយុ ៧ឆ្នាំ សីលរបស់នាងជាមុច្ឆេទប្បហានៈ ។

៥-ទិដ្ឋិសម្បាទា បរិបូណ៌ដោយប្រាជ្ញាជាសម្មាទិដ្ឋិ ទោះបីត្រកូលខាងប្តីនាងជាមិច្ឆាទិដ្ឋិក៏នាងនៅជាសមាទិដ្ឋិដដែល ។

## ៦-ធ្វើបុណ្យដើម្បីអ្វី ?

តាមលទ្ធិពុទ្ធសាសនា ធ្វើដើម្បីបំភ្លេចអារម្មណ៍បាបចាស់ដែលបានធ្វើហើយពីមុនមកទាំងប៉ុន្មាន ឱ្យជ្រះស្រឡះ លែងរសេមរសាមស្រមើស្រមៃ បញ្ឈប់រាំងស្ទាក់ចិត្តលែងត្រេកត្រអាលរីករាយ ចំពោះបាបថ្មីទៅទៀត កាត់ចិត្តឱ្យឃ្លាតឆ្ងាយចាកបាបរួចហើយ យកឱកាសទំនេរធ្វើបុណ្យជំនួសវិញភ្លាម ដើម្បីដុះខាត់ជម្រះសន្តានចិត្តឱ្យអស់មន្ទិលសៅហ្មងដោយពិធីឱ្យទានសមាទានសីល ចម្រើនមេត្តាភាវនាជាដើម ឱ្យទៅជាប់ចិត្តស្អាតមានពន្លឺរស្មីត្រចះត្រចង់ប្រក្រតីដើមវិញ (បកតិមនោ) តែប៉ុណ្ណោះ ពុំមែនជាពិធីលាងបាបដូចសាសនាដទៃឡើយ ។

៧-ផ្លូវចិត្តជាបុណ្យគេកត់សម្គាល់យ៉ាងណា ?

នៅពេលណាចិត្តអស់លែងមានទោសមានអភិជ្ឈា និងទៅជាមនុស្សជាដើមប្រទូស្តហើយជាចិត្តរងថ្លា ស្អាតបរិសុទ្ធ ដូចប្រក្រតីដើម (ភវង្គៈ)ដូចព្រះពុទ្ធដីកាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មានពន្លឺរស្មីភ្លឺថ្លាណាស់ ក៏ប៉ុន្តែលុះត្រូវឧបក្កិលេសទាំងឡាយ មានអភិជ្ឈាវិសមលោភៈជាដើមជារបស់ថ្មី កើតលាយឡំទើបធ្វើឱ្យសៅហ្មង ។ នៅពេលណាគេធ្វើឱ្យស្អាតភ្លឺថ្លាឡើងវិញពេលនោះហើយ គេត្រូវកត់សំគាល់ចិត្តនោះជាបុណ្យ ។

តើព្រះពុទ្ធដីកាត្រាស់ថា បុរសស្ត្រី គប្បីប្រញាប់ប្រញាល់ធ្វើកល្យាណកម្ម(បុណ្យ)ទាំងឡាយន័យនេះទ្រង់សំដៅលើអ្វី ?

ការដែលទ្រង់ណែនាំឱ្យប្រញាប់ប្រញាល់ធ្វើបុណ្យ គឺសំដៅលើន័យទាំង ៤យ៉ាង :

១-នាំឱ្យហាមឃាត់ចិត្តឈប់ត្រេកត្រអាលក្នុងបាប បានភ្លាមៗ

២-នាំឱ្យបំភ្លេចចោល នូវអារម្មណ៍ជាបាបចាស់អស់រលីងភ្លាមៗ

៣-នាំឱ្យបិទផ្លូវបាបថ្មី ដែលពុំទាន់មកដល់មិនឱ្យចូលមកតាមកាយទ្វារ វចីទ្វារ មនោទ្វា បានភ្លាមៗ

៤-នាំឱ្យឱកាស សន្សំបុណ្យកុសលថ្មីៗ ជាជំនួសវិញបានពេញបរិបូណ៌ភ្លាមៗដែរ

# II. ព្រះរាជពិធីទ្វាទសមាស

**ដោយ**

## សម្ដេចព្រះមហាសុមេធាធិបតី ជ.ណាត ជោតញ្ញាណោ

( បានស្រង់សេចក្ដីពីព្រះរាជពង្សាវតារនៃប្រទេសកម្ពុជា

ក្នុងរជ្ជកាលនៃព្រះបាទសម្ដេចព្រះហរិរក្សរាមា ឥស្សរាធិបតី )

( សូមមើល ជួន ណាត ព្រះរាជពិធីទ្វាទសមាសទស្សនាវដ្ដី ពន្លឺពុទ្ធចក្រ លេខ៨ /១៩៦២ទំព័រ៥០-៥៦)

ថ្ងៃអង្គារ ៣ កើត ខែ ផល្គុន ឆ្នាំមមែ នពស័ក ព.ស.២៣៩១ ម.ស.១៧៦៩ ច.ស. ១២០៩ គ.ស.១៨៤៧ **ព្រះអង្គឌួង**មានព្រះជន្មវស្សាគម្រប់៥២ឆ្នាំ ជាព្រះរាជបុត្រពៅនៃព្រះបាទសម្ដេច **ព្រះនារាយណ៍រាមា** (ព្រះអង្គអេង) ព្រះអង្គបានប្រាប្ដាភិសេកជា មុទ្ធាភិសិត្តរាជ ទ្រង់ព្រះនាមថា **ព្រះបាទសម្ដេចព្រះហរិរក្សរាមា ឥស្សរាធិបតី** ...ស្ដេចគង់នៅព្រះបរមរាជវាំងក្នុងក្រុង **ឧដុង្គមានជ័យ** ជាមហាក្សត្រិយ៍ប្រកបដោយទសពិធរាជធម៌ ។ល។ ព្រះអង្គស្ថិតក្នុងរាជសម្បត្តិ គិតពីឆ្នាំបានប្រាប្ដាភិសេកមកបាន ១៣ឆ្នាំ បើគិតពីឆ្នាំគ្រងរាជមកផងបាន ១៤ឆ្នាំ ព្រះអង្គសោយព្រះទីវង្គត នៅថ្ងៃសុក្រ ៥កើត ខែ កត្តិក ឆ្នាំវក ទោស័ក ព.ស.២៤០៤ គ.ស.១៨៦០ ក្នុងព្រះជន្មវស្សាគម្រប់៦៥ឆ្នាំ មានព្រះមរណនាមថា **ព្រះបរមគោដ្ឋ** ។

ព្រះបាទសម្ដេចព្រះហរិរក្សរាមា អង្គនេះ ព្រះអង្គបានបង្កើតឱ្យមាន **ព្រះរាជពិធីទ្វាទសមាស** " ព្រះរាជពិធី ១២ ខែ " គឺក្នុងខែទាំង១២ រៀងរាល់ឆ្នាំ រាប់ពីខែចេត្រជាទី ១ រៀងដល់ខែផល្គុន ជាទី ១២ តាមរាជប្រពៃណីពីព្រេងនាយមកម្លេះ បង្កើតថែមឡើងខ្លះ ដូចរៀបរៀងដោយសង្ខេបតទៅនេះ :

### ទី១_ ខែចេត្រ

ក- ថ្ងៃ៤កើត ព្រះរាជវង្សានុវង្ស សេនាបតី មន្ត្រីខ្ញុំរាជការក្នុងក្រៅ **ជំនាវខុនណាង** ចូលទទួលព្រះរាជទានទឹកវិភទ្ទសច្ចាក្នុងទិចុងព្រះរាជរោងក្រៅ (ជាគ្រាទី១ រៀងរាល់ ឆ្នាំ) ។

ខ- នៅថ្ងៃសង្ក្រាន្តចូលឆ្នាំថ្មី រៀបពិធីទទួលទេវតាថ្មី ពូនវាលុកចេតិយ ធ្វើបុណ្យ សុន្ទរ៍ទាន

ផ្សេង១ទ្រង់ក្រសាលចំបាប់ គុន ដាល់ និងល្បែងនក្សត្របូក្សផ្សេង១ គ្រប់ទាំង ៣ថ្ងៃ ។

គ- ត្រង់ថ្ងៃឡើងសករាជ ព្រះរាជវង្សានុវង្ស និងមន្ត្រីខ្ញុំរាជការបុរសស្ត្រីគ្រប់ក្រសួងត្បូងក្រុមចូលថ្វាយទឹកថ្វាយទៀន ក្នុងចុងព្រះរាជរោងក្រៅ និមន្តព្រះភិក្ខុសង្ឃស្រង់ទឹក ។

## ទី២. ខែពិសាខ

ក- ថ្ងៃ១៥កើត ធ្វើបុណ្យសលាកភត្ត វេរប្រគេនព្រះភិក្ខុសង្ឃ ។

ខ- ថ្ងៃ១-៣រោច ក្រុមបារគូបុរោហិតតាំងពិធីរក្សាព្រឹត្តិទាំង៣ថ្ងៃ ក្នុងរោងពិធីព្រាហ្មណ៍ ។

គ- ថ្ងៃ៤រោច ស្តេចយាងចេញកាន់ព្រះរាជពិធីច្រត់ព្រះនង្គ័ល ជាវប្បមង្គល នាំមុខប្រជាជនឱ្យធ្វើស្រែចំការ ។

## ទី៣. ខែជេស្ឋ

ក-ថ្ងៃ១៥ កើត ពិធីចម្រើនព្រះបរិត្តខ្វាន់នាគខ្វាន គឺនាគព្រះរាជទ្រព្យនៅចុងព្រះរាជរោងក្រៅ ។

ខ- ថ្ងៃ១៥ កើត ស្តេចយាងចេញជាព្រះរាជាធិបតីក្នុងពិធីបំបួសនាគខ្វាន នៅព្រះ ដំណាក់ផែកំពង់ហ្លួងក្នុងឧទកុក្ខេបសីមា ។

## ទី៤. ខែអាសាឍ

ក- ថ្ងៃ៨ កើត ស្តេចយាងចេញសិតទៀនវស្សា នៅចុងព្រះរាជរោងក្រៅ ។

ខ- ថ្ងៃ ១៤ កើត មន្ត្រីមុខក្រសួងហែទៀនវស្សាដាក់ក្នុងវិហារគ្រប់វត្តក្នុងក្រុង ។

គ- ថ្ងៃ ១៥ កើត ស្តេចយាងចេញជាព្រះរាជាធិបតីក្នុងពិធីបំបួសព្រះរាជវង្សានុវង្សក្នុងវិហារវត្តណាមួយក្នុងក្រុង ច្រើនតែក្នុងវិហារវត្តពុទ្ធប្រាង្គ ហៅដោយកាត់ខ្លីថាវត្តប្រាង្គ ។

ឃ- ថ្ងៃ១ រោច អុជទៀនវស្សាជាពុទ្ធបូជាគ្រប់វត្តក្នុងក្រុងដែលបានហែទៀនវស្សាដាក់នៅថ្ងៃ ១៤ កើត ហើយ និមន្តព្រះភិក្ខុសង្ឃឱ្យចូលចាំវស្សា ព្រមទាំងបវារណាដោយ បច្ច័យ ៤ផង ។

ង- ថ្ងៃ៨.៩.១០រោច និមន្តព្រះរាជាគណៈ ឋានានុក្រម ចៅអធិការ គ្រូសូត្រ និង ភិក្ខុ អណ្តាប់រួមទាំងអស់ចំនួន ៥០០អង្គ ប្រជុំទេសនាសង្គាយនាតាមទំនៀមគ្រប់ទាំង ៣ថ្ងៃ នៅចុងព្រះរាជរោងក្រៅ ។

## ទី៥៖ ខែស្រាពណ៍

ថ្ងៃ ១៥ កើត ព្រះរាជវង្សានុវង្ស នាម៉ឺនសព្វមុខមន្ត្រី បុរសស្ត្រី និង ប្រជាជន ហែស្តេចយាងចេញបេះផ្កាឈូក ផ្កាឧប្បល (ព្រលិត លំចង់) ផលជាតិ និង ផ្កាឈើផ្សេងៗ មានផ្កាម្លិះរួត ម្លិះលា ចំប៉ីចំប៉ាជាដើម ដោតក្រងជាភួងមាលា ថ្វាយព្រះពុទ្ធរូបគ្រប់វត្តក្នុងព្រះរាជធានី។ ប្រជាជនពុទ្ធបរិស័ទគ្រប់វត្តអារាមនានាក៏នាំគ្នាតត្រឹកតគ្រេងធ្វើពុទ្ធបូជាតាមលំអានព្រះរាជពិធីនេះដែរ តាមសទ្ធាជ្រះថ្លារៀងៗខ្លួន។

## ទី៦ ខែភទ្របទ

ក- ថ្ងៃ៤ កើត ព្រះរាជពិធីទទួលព្រះរាជទានទឹកវិភទ្ទសច្ចា ដូចកាលនៅថ្ងៃ ៤ កើត ខែចេត្រដែរ (ជាគ្រាទី២ រៀងរាល់ឆ្នាំ) ។

ខ- តាំងពីថ្ងៃ ១ រោចដល់ថ្ងៃ១៤ រោជ ពិធីបុណ្យកាន់បិណ្ឌ ក្នុងព្រះបរមរាជវាំង។ ព្រះបាទសម្តេចព្រះហរិរក្សរាមា ជាអម្ចាស់ជីវិតលើត្បូង ទ្រង់លាងអង្ករដើមផ្ទាល់ព្រះហស្តព្រះអង្គ ទ្រង់ពុះច្រៀកឧសដុតភ្លើងដាំបាយ រាប់បាត្ររាល់ថ្ងៃ។

គ- ថ្ងៃ ១៤ រោច ពិធីថ្វាយបង្គំព្រះបិតរ ទេសនាប្រថមត្រាស់ អភិសេកព្រះពុទ្ធបដិមាអង្គថ្មី ។

ឃ- ថ្ងៃ ១៥ រោច ពិធីភ្ជុំបិណ្ឌ ទេសនាគាថាព័ន្ធ ១ចប់ ក្នុងព្រះបរមរាជវាំង ជូនកាលព្រះអង្គសព្វព្រះរាជហឫទ័យ និមន្តធម្មកថិកតែ១ អង្គ ឬ ១៣ អង្គ ទេសនាមហាជាតកក៏សម្រាយទាំង១៣កណ្ឌ ។ ចំណែកខាងពុទ្ធបរិស័ទគ្រប់វត្តអារាមនានាក្នុងព្រះរាជអាណាចក្រ ក៏និមន្តធម្មកថិកទេសនាមហាជាតក ហែតាមលំអានព្រះរាជពិធីជាកុសលកិរិយា នេះដែរ ជាប់ជាប្រពៃណីតរៀងមក ។

## ទី៧៖ ខែអស្សុជ ចូលដល់ខែកត្តិក

ក- ថ្ងៃទី១៤-១៥ កើត និង ថ្ងៃ១ រោចខែអស្សុជ ស្តេចយាងទៅគង់ឯព្រះតំណាក់ផែកំពង់ហ្លួង (ជាគ្រាទី១រៀងរាល់ឆ្នាំ) ស្តេចទតពិធីប្រណាំងទូក ក្នុងវេលាយប់មានពិធីបណ្តែតប្រទីបជ្វាលា អុជកាំជ្រួច រន្ទា ភ្ញីទៀន បូជាចំពោះទៅព្រះពុទ្ធបាទទាំង៥ ឋាន និង ព្រះចង្កូមកែវនៃ ព្រះសក្យមុនីសម្មាសម្ពុទ្ធនៅនាគបុរី ព្រមទាំងជាសក្ការបូជាចំពោះ **ទេវោរោហនកាល** គឺកាលដែលព្រះសក្យមុនីអរហន្តសម្ពុទ្ធ ស្តេចយាងចុះចាកឋានត្រ័យត្រិង្សសួគ៌ទេវលោក មកចុះនា **សំកស្សនគរ** នៅថ្ងៃ ១៥ កើត ខែអស្សុជ ប្រកបដោយមហាស្ធារ្យនោះផង ។

ខ- នៅពេលព្រឹកនៃថ្ងៃ ១៥ កើតខែអស្សុជនេះព្រះអង្គមានព្រះរាជបញ្ជាឱ្យនិមន្ត ព្រះរាជា គណៈឋានានុក្រមសង្ឃទៅចម្រើនព្រះសត្តប្បករណាភិធម្ម ទ្រង់រាប់បាត្រឯព្រះតំណាក់ផែផង រាប់ថាជាបុណ្យរាប់បាត្រចេញវស្សា។ ចំណែកខាងពុទ្ធបរិស័ទគ្រប់វត្តអារាមនានា ក្នុងព្រះរាជអាណាចក្រក៏នាំគ្នាធ្វើបុណ្យរាប់បាត្រ ចេញវស្សានេះដែរ ។ វត្តអារាមណានៅជិត មាត់ទន្លេ មាត់ព្រែក មាត់ស្ទឹង ក៏ច្រើន តែធ្វើពិធីបណ្តែតប្រទីបជ្វាលានៅថ្ងៃ ១៥កើត ខែអស្សុជ តាមលំអានព្រះរាជពិធីនេះដែរ ។

គ- នៅវេលាពាក់កណ្តាលអាធ្រាត្រនៃយប់ ១៥ កើតខែអស្សុជនេះ ព្រះអង្គមានព្រះរាជបញ្ជាឱ្យគ្រូអ្នកជំនាញការខាងវិជ្ជាវេទមន្ត រៀបពិធីបញ្ចុះអថ័ន (អថព្វវេទតាមលទ្ធិព្រាហ្មណ៍) ក្នុងទន្លេនៅកំពង់ហ្លួង បង្ការកុំឱ្យសត្វទឹកមានក្រពើកាចជាដើមបៀតបៀនសាធារណជនទូទៅ ទាំងជាគ្រឿងការពាររារាំងបច្ចាមិត្តខាងផ្លូវទឹកផង ។ ពិធីបញ្ចុះអថ័នក្នុងទន្លេនេះមានធ្វើនៅយប់ ១៥កើត ខែអស្សុជរៀងរាល់ឆ្នាំ ។

ឃ- តាំងពីថ្ងៃ ១ រោច ខែអស្សុជរហូតដល់ថ្ងៃ ១៥ កើតខែកត្តិក រួមជា២៩ថ្ងៃ នៅថ្ងៃណាមួយ , តាមសព្វព្រះរាជហឫទ័យប្រាថ្នា , ព្រះអង្គស្តេចយាងថតព្រះកឋិនទានវេរប្រគេន ចំពោះ ព្រះភិក្ខុសង្ឃ ៤ វត្ត គឺខាងជើងគោក ២ វត្ត ខាងជើងទឹក ២ វត្ត ឯវត្តក្រៅ ពីនោះព្រះអង្គប្រទាន ដល់ព្រះរាជបុត្រាព្រះរាជបុត្រី ឬ ព្រះរាជវង្សានុវង្សឯទៀត ជួនកាលទ្រង់ប្រទានដល់សេនាបតី មន្ត្រីខ្លះ ឱ្យទៅថតកឋិនជំនួសព្រះអង្គ។

## ទី៨. ខែកត្តិក

ថ្ងៃ ១៤-១៥ កើត និង ថ្ងៃ ១ រោជ ស្តេចយាងទៅគង់ឯព្រះតំណាក់ផែកំពង់ហ្លួង ( ជាគ្រាទី ២ រៀងរាល់ឆ្នាំ ) ទ្រង់ទតពិធីប្រណាំងទូក , បណ្តែតប្រទីបផ្កាលា អុជកាំជ្រួច-រន្ទា ភ្លឺទៀន ( ដូចកាលនៅថ្ងៃ ១៤-១៥ កើត និងថ្ងៃ ១ រោជ ខែអស្សុជ ដែរ ) ។ នៅថ្ងៃ១៥ កើតខែកត្តិក វេលាម៉ោង ១២ អាធ្រាត្រ រៀបពិធីថ្វាយតង្វាយព្រះច័ន្ទ ដោយមានអំបុក និងចេកទុំជាប្រមុខ ព្រមទាំងពិធីអកអំបុកផង ។ ប្រជាជនក្នុងព្រះរាជអាណាចក្រ ក៏នាំគ្នាធ្វើពិធីអកអំបុក ព្រមទាំងពិធីសម្រក់ទៀនផ្សងមើលទឹកភ្លៀងក្នុងឆ្នាំខាងមុខបន្ទាប់ឆ្នាំនេះផង ច្រើនតែប្រជុំគ្នាធ្វើក្នុង វត្តអារាម ជាប់ជាប្រពៃណីរៀងដរាមក ។

## ទី៩. ខែមិគសិរ

ថ្ងៃ ១៤-១៥ កើតនិងថ្ងៃ ១រោជ ទាំង៣ថ្ងៃនេះ និមន្តព្រះរាជាគណៈឋានានុក្រមសង្ឃចម្រើនព្រះបរិត្តពុទ្ធមន្ត , ក្នុងរោងពិធីទាំង ៥ កន្លែង ដែលមន្ត្រីមុខក្រសួងបានរៀបចំដោយមានបង្ហូត គោមបង្ហោះគោមព្រោងព្រាតទាំង៣យប់ ព្រមទាំងមានធ្វើខ្លែងពួងមានឯក សម្រាប់បង្ហើរផង.ត្រូវសេនាបតីនិងមន្ត្រីគ្រប់ក្រសួងត្បូងក្រុមចាត់ការធ្វើខ្លែងពួងនិងគោមហោះសម្រាប់បង្ហើរបង្ហោះហែជាយសបរិវារនៃខ្លែងពួង និងគោមហោះ ព្រះរាជទ្រព្យ ។ នៅថ្ងៃ ១៥ កើត ខែមិគសិរ ក្នុងវេលាយប់ មានពិធីបង្ហូតគោមបង្ហោះគោមច្រើនភ្លឺព្រោងព្រាត មានបង្ហោះគោមបង្ហើរខ្លែងពួកច្រើនជាងថ្ងៃ ១៤ កើតនិងថ្ងៃ ១ រោច ឮសូរសព្ទឯកខ្លែងបន្លឺឆ្លើយគ្នារងំឯផ្ទៃអាកាស ជាការបូជាថ្វាយចំពោះទៅព្រះចូឡាមណីចេតតិយ (ដែលតម្កល់ព្រះមោលីគឺផ្នួងព្រះកេសាសិទ្ធត្ថៈ សក្យមុនី )នៅឋានត្រ័យត្រិង្សសួគ៌ទេវលោក ។ នៅភូមិលំនៅនានាខ្លះក្នុងព្រះរាជាអាណាចក្រ ក៏មានធ្វើពិធីបង្ហោះគោម បង្ហើរខ្លែងពួងនៅថ្ងៃនេះ ដង្ហែតាមព្រះរាជពិធីនៃ ព្រះមហាក្សត្រិយ៍ដែរ ច្រើនតែធ្វើពិធីនេះនៅទីវាលស្រឡះ ដែលងាយនឹង បង្ហោះគោមបង្ហើរខ្លែងបាន។

## ទី១០. ខែបុស្ស

ថ្ងៃ ១៣ កើត ព្រះអង្គមានព្រះរាជបញ្ជាឱ្យមន្ត្រីមុខក្រសួងចាត់ការឱ្យជម្រះស្មៅសំអាតទីដីនៅទីដ៏សមគួរ ហើយឱ្យសង់រោង សង់តូប ព្រមទាំងអោយធ្វើរានភ្លើងផង សម្រាប់

ប្រគេនព្រះភិក្ខុសង្ឃដែលត្រូវការចូលបរិវាសកម្ម ។ មានធ្វើបាយតម្រាហៅថា **សីតលភត្ត** វេរប្រគេន ព្រះភិក្ខុសង្ឃដែលចូលបរិវាសកម្ម និង ព្រះភិក្ខុសង្ឃឯទៀតផង ឆាន់នៅពេលព្រឹករាល់ថ្ងៃ តាមកាលានុរូប ។

## ទី១១. ខែមាឃ

ថ្ងៃ ១២ កើត មន្ត្រីមុខក្រសួងចាត់ការធ្វើរោងពិធី ៥អន្លើ ក្រុមបារគូបុរោហិតត្រូវចូលកាន់ពិធីរក្សាព្រឹត្តិក្នុងរោងទាំង ៥ អន្លើ នោះគ្រប់ ៣ថ្ងៃ ដល់ថ្ងៃ ១៥ កើតធ្វើពិធី **បរមាឃ** ហៅស្តេចមាឃធ្វើការបូជាភ្នំស្រូវ ។ល។

## ទី១២. ខែផល្គុន

តាំងពីថ្ងៃ ១២ រោចដល់ថ្ងៃ១៥រោច ព្រះរាជពិធី **ត្រុស្តិសង្ក្រាន្ត** គឺព្រះរាជពិធីបញ្ជាន់ត្រុស្តិផ្តាច់ឆ្នាំចាស់ ( តាំងពីថ្ងៃ ១ កើត ខែចេត្រទៅ បើមិនទាន់ដល់ថ្ងៃចូលឆ្នាំថ្មី ឡើងសករាជរួចហើយនៅឡើយទេ ត្រូវប្រើសម្បូណិតចុតហ្លាយផ្សេងៗ ចុះកាលបរិច្ឆេទចេញឈ្មោះឆ្នាំថ្មីថា:

"ថ្ងៃ...... ឆ្នាំ...... នៅក្នុង........ស័ក " រហូតដល់ថ្ងៃឡើងសករាជរួចហើយទើបប្រើស័កឆ្នាំថ្មី រៀងទៅ ជាទម្លាប់ជាប់មានរហូតមកដល់សម័យសព្វថ្ងៃនេះ ) ។

ក. នៅថ្ងៃ ១២ រោច ខែ ផល្គុន វេលាម៉ោង ៥ ល្ងាច ស្តេចយាងចេញអុជទៀនជ័យដែលតាំង នៅក្នុងចុងព្រះរាជរោងក្រៅ ជាមួយនឹងសម្តេចព្រះមហាសង្ឃរាជ ។

ខ. តាំងពីថ្ងៃ ១២ រោច ដល់ថ្ងៃ ១៤ រោច ខែផល្គុន ក្រុមបារគូបុរោហិតចូលកាន់ពិធីរក្សា ព្រឹត្តិគ្រប់រោងពិធីខាងក្រៅទាំង ៥ អន្លើ។ នៅពេលព្រលប់ ព្រះរាជាគណឋានានុក្រមសង្ឃចម្រើនព្រះបរិត្តពុទ្ធមន្តនៅចុងព្រះរាជរោងក្រៅ និងក្នុងរោងពិធីទាំង ៥ គ្រប់ទាំង ៣ ថ្ងៃ។

គ. នៅថ្ងៃ ១៤ រោច ខែ ផល្គុន ពេលព្រឹក ព្រះរាជាគណៈ ១អង្គសូត្រប្រកាសទេវតានៅទី ចុងព្រះរាជរោងក្រៅ , ពេលព្រលប់ ព្រះរាជាគណៈ ១អង្គផ្សេងទៀត សូត្រប្រកាសទេវតាម្តង ទៀតពិស្តារជាងពេលព្រឹក។ បន្ទាប់មកព្រះរាជាគណៈ ៤ អង្គសូត្រធម៌ចក្កប្បវត្តនសូត្រ ពេញ១ចប់ រួចហើយព្រះរាជាគណៈ៤អង្គផ្សេងទៀតសូត្រធម៌មហាសមយសូត្រពេញ១ចប់ដែរ។

ឃ. បន្ទាប់ពីមហាសមយសូត្រមក ព្រះរាជាគណៈ ១ អង្គសូត្រធម៌ បន្ទាប់មក ព្រះរាជាគណៈ ឬឋានានុក្រម ៤អង្គម្តង១ សូត្រធម៌កាណយក្ខ-កាណព្រះតាមលំដាប់ រហូតដល់ភ្លឺ .ចំណែខាងរោងពិធីខាង ក្រៅទាំង ៥ អន្លើក៏សូត្រធម៌នោះទាល់ភ្លឺដូចគ្នា ។ យប់នេះ មានបាញ់កាំភ្លើងដៃ និងកាំភ្លើងធំតាមរយៈដែល ត្រូវបាញ់ម្តង ៧ ទាល់ភ្លឺដែរ ។

ង. នៅថ្ងៃ ១៥ រោច ខែផល្គុន ពេលព្រឹក ស្តេចយាងចេញលត់ទៀនជ័យ ជាមួយនឹងសម្តេចព្រះមហាសង្ឃរាជ , បន្ទាប់មក ប្រគេនចង្ហាន់ភិក្ខុសង្ឃ ។ ចំណែកខាង សេនាបតី មន្ត្រីធំតូច និងប្រជាជនក្នុងព្រះរាជធានីនាំគ្នាដាក់បាត្រភិក្ខុសាមណេរទាំងឡាយ ដែលនិមន្តមកទទួលចង្ហាន់បិណ្ឌបាតនៅទីជិតរោងពិធីខាងក្រៅព្រះបរមរាជវាំង , ហៅការកុសលនេះថា បុណ្យត្រស្តិសង្ក្រាន្ត ឬថាបុណ្យដាក់បាត្រផ្តាច់ឆ្នាំ , គេច្រើនជឿថា បុណ្យផ្តាច់ឆ្នាំនេះអាចរំងាប់ផ្តាច់គ្រោះកាចឧបទ្រពចង្រៃទាំងពួងក្នុង បច្ចុប្បន្ននេះបាន ។

ច. នៅថ្ងៃ ១៥ រោចនេះ, ក្រោយពេលដែលព្រះភិក្ខុសង្ឃឆាន់ត្រង់រួចហើយ , ព្រះមហាវិមលធម្ម និង ព្រះមហាព្រហ្មមុនី , ដោយមានក្រុមសង្ឃការីអបអមផង , និមន្តប្រោះទឹកពុទ្ធមន្ត ក្នុងព្រះបរមរាជវាំងតាមកំពែងជុំវិញ ជាកិច្ចប្រសិទ្ធិពរឱ្យកើតមានសិរីសួស្តីជ័យមង្គលវិបុលសុខចំរុងចម្រើនគ្រប់ប្រការរៀងទៅ ។

<u>កំណត់:</u> បុណ្យខ្មែរមានច្រើនណាស់ បុណ្យខ្លះមានរបៀបរបបផ្សេង គ្នាទៅតាមតំបន់ ទៅតាម ស្រុក ភូមិ ឃុំ របស់គេ និង តាមសម័យកាល ទៀតផង ប៉ុន្តែ មានខ្លឹមសារដូចគ្នា។ យ៉ាងណាមិញ ដូចជា បុណ្យនៅសតវត្សទី ១៨ ដើមសតវត្សទី ២០ នៅខេត្តបាត់ដំបងមានសម័យ "លោកម្ចាស់" គឺលោកម្ចាស់ **កថាវនឈុំ** ជាដើម ។ សម័យនោះខេត្តបាត់ដំបង ស្ថិតនៅក្នុងការគ្រប់គ្រងរបស់សៀម នៅឡើយ ហើយបុណ្យទានមានរបៀបរបបខុសពីបច្ចុប្បន្នច្រើន។ អាចថា សម័យបុរាណកាន់តែផ្សេងជាងនេះទៅទៀតក៏ថាបាន ។ ជាក់ស្តែងដូចបុណ្យនៅក្នុងសៀវភៅ បាត់ដំបងសម័យលោកម្ចាស់ ដែលបកស្រាយដោយលោក **តួច ឈួន** អំពីបុណ្យចូលឆ្នាំ បុណ្យចេញវស្សា បុណ្យផ្លូវការ បុណ្យក្នុងគ្រួសារ លោកម្ចាស់ និងអភិជន និងបុណ្យខ្មោចជាដើម។

## III. សង្ខេបបុណ្យបែបព្រះពុទ្ធសាសនាក្នុងជំនឿទំនៀមទម្លាប់ខ្មែរ

ពិធីបុណ្យក្នុងព្រះពុទ្ធសាសនា យើងមិនបានពិពណ៌នាដោយវិត្ថារៈពីស្តារទេ ។ នៅទីនេះ យើងគ្រាន់តែពោលដោយសង្ខេបត្រួសៗ គ្រាន់តែឱ្យលោកអ្នកអានជ្រាបប៉ុណ្ណោះ ។ ពិធីបុណ្យក្នុងព្រះពុទ្ធសាសនាគឺ វិសាខបូជា ពិធីបុណ្យបំបួសនាគ ពិធីបុណ្យចូលព្រះវស្សា ពិធីបុណ្យដាក់បិណ្ឌ ពិធីបុណ្យភ្ជុំបិណ្ឌ ពិធីបុណ្យចេញព្រះវស្សា ពិធីបុណ្យបញ្ចុះសីមា ពិធីបុណ្យមាឃបូជា ។ ក្រៅពីនេះនៅមានពិធីបុណ្យចូលឆ្នាំជាដើម ។ មានពិធីបុណ្យខ្លះដូចជា កោរសក់កូន ពិធីបុណ្យឡើងផ្ទះថ្មី ពិធីបុណ្យវិវាហមង្គលការកូនប្រុសស្រី ពិធីសាសនា ពិធីបុណ្យតាមប្រពៃណីជាច្រើន ពិធីអភិសេកព្រះពុទ្ធរូបជាដើម ។ល។

### ១. ពិធីបុណ្យព.ស ២៥០០ នៃប្រទេសកម្ពុជា

ពិធីបុណ្យនេះ គឺធ្វើនៅខែវិសាខ៥៦ ឬ៥៧ ចំពោះប្រទេសដែលកាន់ព្រះពុទ្ធសាសនា។

ប្រជាជនទាំងលាននាក់ បានសិក្សារៀនសូត្រព្រះពុទ្ធសាសនា ប្រព្រឹត្តប្រតិបត្តិតាមបានសេចក្តីសុខចម្រើន ក៏បាននឹករឭកដល់ព្រះគុណូបការៈ ព្រះបរមសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់ដ៏ឧត្តម ក៏បាននាំគ្នាធ្វើពិធីបុណ្យ ព.ស ២៥០០ ។

តាំងពីថ្ងៃពេញបូណ៌មីខែវិសាខ នៅមុខស្ថានីយអយស្ម័យយានភ្នំពេញ មានធ្វើពិធីបុណ្យព្រះពុទ្ធសាសនាគ្រប់បែបយ៉ាង មានពិធីដាក់បាត្រ សុំសីល ស្តាប់ធម៌ទេសនា បួងសួងព្រះបរមសារីរិកធាតុមានអាគារតាំងព្រះពុទ្ធរូប សិល្បៈពុទ្ធសាសនា រឿងរ៉ាវព្រះពុទ្ធសាសនាមានល្ខោនជាតិរាំរឿងព្រះពុទ្ធប្រវត្តិ មានការហែបុប្ផាយានមានផ្ទាំងគំនូរព្រះពុទ្ធសាសនាប្រដាប់ស្លឹករុក្ខា ផ្កាឈើគ្រប់ពណ៌រចនាជាក្បាច់ច្រើនស្ថាន មានបាញ់កាំជ្រួចរន្ទាភ្លឺដាលវាលពេញមហាមេឃ។

មានអ្នកតំណាងប្រទេសនានា បានអញ្ជើញរួមប្រជុំក្នុងពិធិបុណ្យនេះគឺមហាពោធិសមាគមឥណ្ឌា ប្រទេសម៉ាឡាយូ ប្រទេសភូមា ប្រទេសថៃឡង់ ប្រទេសចិនប្រជាមានិត ប្រទេសឡាវ ប្រទេសជប៉ុន ប្រទេសវៀតណាម ប្រទេសឥណ្ឌូនេស៊ីជាដើម ។

មានបុរសឧបសម្បទាជាភិក្ខុជាច្រើន បុរសអ្នកកាន់សីល១០ ប្រកាន់អតិរេកសីល ឧបាសក ឧបាសិកាមកពីខេត្តក្រៅ ជនជាតិដទៃបាននិមន្ត និងអញ្ជើញមកកាន់ទីបុណ្យនេះ គឺកកកុញពេញពាសពេញ ។

ព្រះបរមសម្ពុទ្ធបរមគ្រូជាម្ចាស់ព្រះអង្គទ្រង់បរិនិព្វាន្ត ២៥០០ ឆ្នាំហើយទ្រង់បានទុកព្រះពុទ្ធរូបស្នងព្រះអង្គឱ្យសព្វសត្វទាំងឡាយគោរពបូជា ព្រះពោធិព្រឹក្សឱ្យមនុស្សនិងទេវតាធ្វើសក្ការៈ ព្រះបរមសារីរិកធាតុឱ្យមា មកជនសម្ដែងសេចក្ដីជ្រះថ្លាចំពោះព្រះពុទ្ធសាសនា ព្រះស្តូបពុទ្ធបូជនីយដ្ឋាន ឱ្យពុទ្ធសាសនិកជនថ្វាយបង្គំយកបុណ្យកុសល យើងទាំងអស់គ្នាបានទាន់នូវរតនវត្ថុទាំងអស់នេះទុកជាមានភ័ព្វសំណាងដ៏ធំ ជោគជ័យមង្គលសិរីសួស្ដីគ្រប់យ៉ាង ។

ពិធីបុណ្យទាំង៩ នៃព្រះពុទ្ធសាសនាជាមធ្យោបាយដ៏ប្រសើរដើម្បីញុំាងចិត្តឱ្យជ្រះថ្លាចំពោះព្រះពុទ្ធសាសនា សោមនស្សចំពោះគុណព្រះរតនត្រ័យ ធ្វើលោភៈ មច្ឆរិយគឺសេចក្ដីកំណាញ់ឱ្យអស់ទៅ ញុំាងសទ្ធានិងប្រាថ្នាឱ្យ ដុះដាលចម្រើនឡើងជាហេតុឱ្យធ្វើសីល សមាធិបញ្ញាបារមីតទៅទៀត ។

## ២. ពិធីច្រៀងបទលើកទង់ជ័យព្រះពុទ្ធសាសនា

ពិធីនេះទើបនឹងមាននៅសម័យបច្ចុប្បន្ន ដោយការណែនាំសម្ដេចព្រះមហាសុមេធាធិបតី ជួន-ណាត (ជោតញ្ញាណោ) សង្ឃនាយកគណៈមហានិកាយ :សម្ដេចបានបង្ហាត់ក្មេងឱ្យស្លៀកពាក់ឯកសណ្ឋានជាង ១០០នាក់ល្អស្អាត ហើយរៀបជាជួរហែរួចតាំងច្រៀងបទលើកទង់ជ័យដូចខាងក្រោម :

### បទសុវណ្ណតិលកាឆន្ទ

(សម្រាប់សូត្រលើកទង់សាសនា)

សូមើលទង់ជ័យ-ឆព្វណ្ណរង្សី ដែលមានរស្មីភ្លឺស្រស់ល្អ
ខៀវលឿង ក្រហម-ព្រមទាំងពណ៌ស ហង្សបាទនិងពណ៌ដ៏ភ្លឺផ្លេក ។
ប្រទេសតូចធំ-បានស្ម័គ្រស្វាគម ជំនុំគ្នាច្រើនអនេក

ព្រមយករស្មីព្រះពុទ្ធគួរត្រេក ប្រសើរពន់ពេកក្រៃកន្លង ។
ធ្វើជាសញ្ញា-ទង់ជ័យសាសនា នៃសម្ពុទ្ធធំចម្បង
ចូរយើងរាល់គ្នា-យកចិត្តចាំចង នឹកដល់ព្រះអង្គជាម្ចាស់ ។
ទោះជាតិផ្សេងគ្នា-ក៏ត្រូវដឹងថា សុទ្ធសឹងតែជាពុទ្ធសាសនី
ត្រូវមានសាមគ្គី-ទាំងក្មេងទាំងចាស់ ប្រឹងប្រែងឱ្យណាស់គ្រប់ៗគ្នា ។
សូមសាសនាពុទ្ធ-ថ្កុំថ្កើងខ្ពស់ផុត រុងរឿងវិសុទ្ធថ្លៃថ្លា
ហើយមានជ័យជោគ ផ្សាយពេញលោកា

ដោយជនជ្រះថ្លារាប់ច្រើនលាន ។

មានចិត្តស្នេហា-គោរពបូជា ចំពោះព្រះធម៌ដ៏កល្យាណ
ទាំងមនុស្សទេព្តា-ស្នេហាគ្រប់ប្រាណ ប្រាថ្នាចង់បានសេចក្តីសុខ ។
យើងខេមរជាតិ-នាំគ្នាខ្មីឃ្មាត កាន់ធម៌ខឹងបានផុតទុក្ខ
រួបរួមសាមគ្គី-ពីនេះទៅមុខ យើងនឹងបានសុខក្សេមសាន្តត្រាណ ។
ព្រមព្រៀងប្រព្រឹត្ត-តាមធម៌សុច្ចរិត ឆ្ពោះទៅកាន់ស្ថាននិព្វាន
ជាទីផុតទុក្ខ-បានសុខក្សេមក្សាន្ត ជាតិយើងនឹងបានសោយសុខា ។

## ៣. បុណ្យក្នុងគ្រួសារលោកម្ចាស់និងអភិជន

(សូមមើល : សម័យលោកម្ចាស់បាត់ដំបង ១៩០៧)

បុណ្យក្នុងគ្រួសារធំដែលចាំបាច់ជាងគេ គឺបុណ្យកោរសក់ និងបំបួសនាគ ។ នៅសម័យមុន កូនក្មេងតែងតែកោសក់ទុកជុក ។ គេកោរសក់ជុំវិញ ហើយទុកជុកកណ្តាលក្បាល ។ គេបួងសក់នេះដោយមានដាក់ស្នៀតសក់ ។ អ្នកធំ ឬអ្នកមានប្រើស្នៀតសក់អំពីមាស ហើយជួនកាលមានដាំពេជ្រ ។ កាលណាក្មេងអាយុបាន ១២ ឬ ១៣ ឆ្នាំ គេត្រូវកោរជុកនេះចោល ។ ការកោរជុកនេះ ជាពិធីមួយមានសារៈសំខាន់ប្រហាក់ប្រហែលនិងពិធីមង្គលការដែរ ។

នៅក្នុងកំផែង ពិធីកោរសក់នេះមានភាពអ៊ឹកអធឹកដូចបុណ្យផ្លូវការមួយដែរ ។ គេកេណ្ឌរាស្ត្រប្រជាឱ្យផ្តល់ឈើ ឬ ស្បូវ មកធ្វើរោងបុណ្យ ។ គេនិមន្តព្រះសង្ឃមកចម្រើនព្រះបរិត្ត

និង ប្រគេនចង្ហាន់ព្រះសង្ឃ ។ តែរឿងដែលចម្លែកនោះ គឺគេធ្វើបុស្សបុកយ៉ាងខ្ពស់ នមន្តព្រះគ្រូសម្តេចចៅទៅស្រោចទឹក រួចទើបមានបុរោហិតកោរសក់ឱ្យកូននោះ ។ ពេលជាមួយនេះ គេប្រគុំភ្លេងយ៉ាងគឹកកង ហើយមានសម្តែងរឿងរាមកេរ្តិ៍បីយប់បីថ្ងៃ ។

ពិធីបំបួសនាគ មានលក្ខណៈប្រហាក់ប្រហែលសព្វថ្ងៃដែរ ។ តែលោកយាយ អ៊ឹ នៅភូមិវត្តកណ្តឹង បានរំឭកទស្សនីយភាពមួយដ៏ចាប់ចិត្ត គឺពិធីដង្ហែនាគកូនលោកម្ចាស់ ។ គេរៀបចំក្បួនដង្ហែជាពីរក្រុមដាច់ពីគ្នា ។ ក្រុមនីមួយៗសុទ្ធតែមានវង់ភ្លេងរបស់ខ្លួន ។ ក្រុមទីមួយដែលមានដង្ហែនាគនោះ មានតួល្ខោនប្រហែលហាសិបនាក់ តែងជាពលព្រះរាម ជិះសេះទេស ។ ក្រុមទី ២ មានតួល្ខោនប្រមាណហាសិបនាក់ដែរ តែងតួជាពលរាពណ៍ ។ ក្រុមទីមួយ ជាក្រុមធំ ចេញដំណើរពីក្នុងកំផែងទៅត្បូងតាមដងស្ទឹង ដល់ក្បែរវត្តសំពៅឆ្លងទឹកនៅត្រើយម្ខាង ហើយបត់ទៅជើងសំដៅវត្តសង្កែ ។ ក្រុមទីមួយនេះមានអ្នកនាគ ញាតិមិត្តអ្នកនាគ នាម៉ឺនមន្ត្រីនិងវង់ភ្លេងច្រើនវង់ ។ ក្រុមទីពីរមានដូរ្យដន្ត្រីកំដរដែរ តែមានគ្នាតិច គឺមានតែពលរាពណ៍ជិះក្របីស្នែងនប់ ។ ក្រុមទីពីរចេញដំណើរពីកំផែងទៅជើងដល់ត្រង់មុខវត្តកណ្តាល ក៏ឆ្លងស្ទឹងទៅត្រើយខាងកើត ហើយដើរសំដៅទៅវត្តសង្កែដែរ ។ នៅពេលដែលក្បួនទាំងពីរក្រុមជួបគ្នានៅមុខវត្តសង្កែ ពលព្រះរាមចុះពីសេះទេស ពលរាពណ៍ក៏ចុះពីក្របីស្នែងនប់ ហើយក៏ច្បាំងគ្នាយ៉ាងកោលាហលក្រោមសម្លេងដូរ្យដន្ត្រីដ៏កងរំពង ។ ឆាកប្រយុទ្ធនេះរំឭកកាលដែលព្រះសាមណគោតមចេញទៅសាងផ្នួស ហើយត្រូវជិនះទ័ពមារាដែលតាមជ្រែក ។ ក្រោយពីច្បាំងឈ្នះពលរាពណ៍ហើយ ពលព្រះរាមក៏តាមដង្ហែនាគចូលទៅក្នុងវត្ត ប្រទក្សិណ ហើយចូលទៅក្នុងវិហារ ។

## ក- បុណ្យចូលឆ្នាំ

គេប្រារព្ធពិធីបុណ្យចូលឆ្នាំនៅខែចេត្រ គឺនៅពេលដែលប្រជាកសិករទំនេរ ផុតពីការងារស្រែចំការ គឺជាពិធីបុណ្យប្រជាប្រិយ៍ដ៏អ៊ឹកអធឹកជាងគេ ហើយដែលមានរយៈពេលច្រើនថ្ងៃ។ នៅវត្តអារាម មានពិធីចម្រើនពុទ្ធមន្តជ័យមង្គលពិធីពូន ភ្នំខ្សាច់ និង ពិធីស្រង់ព្រះ ។ គេនាំគ្នាយកទឹកទៅដុះលាងព្រះពុទ្ធរូប រួចហើយលាបគ្រឿងក្រអូបផ្សេងៗ ។ អ្នកមាន សទ្ធាច្រើននាំគ្នារែកទឹកដាក់ពាងក្នុង វត្តប្រគេនព្រះសង្ឃ ដើម្បីជាកុសលរបស់គេទៅអនាគតជាតិ ។

រាល់ពេលចូលឆ្នាំម្តងៗ គេនាំគ្នាទៅលេងកំសាន្តនៅឯវត្តសំរោងក្នុង ព្រោះនៅទីនោះមានប្រាសាទបុរាណ មានទីធ្លាធំទូលាយមានដើមឈើម្លប់ទ្រឈឹងទ្រឈៃ ។ អ្នកស្រុកនាំគ្នាលេងកំសាន្តច្រើនកកកុញជាងសព្វថ្ងៃទៅទៀត ។ ក្រៅពីវត្តសំរោងក្នុង គេទៅលេងកំសាន្តនៅវត្តឯកភ្នំ ខ្លះដែរ តែមិនច្រើនគ្នាទេ ។ សម័យនោះគេមិនដែលទៅលេងភ្នំសំពៅទាល់តែសោះ ដោយនៅពេលនោះក៏គ្មានផ្លូវទៅទៀតផង ។

នៅវត្តសំរោង មានលេងល្បែងប្រជាប្រិយ៍ផ្សេងៗ ដូចជាលេងអង្គុញ ចោលឈូង ទាញព្រ័ត្រ ទាត់សីដក់ ។ ល្បែងសីដក់ជាកីឡានិងជាសិល្បៈដ៏ល្បី មានក្បាច់និងស្នៀតគួរឱ្យស្ញប់ស្ញែង ។ ក្រៅពីល្បែងទាំងនេះ មានល្បែងប្របកៃ ។ ស្រីប្រុសជាក្រុមៗនាំគ្នាច្រៀងឆ្លងឆ្លើយដោយឥតមានប្រកែប្រកាន់អ្វីឡើយ ។

នៅតាមផ្លូវ គេនិយមធ្វើបុណ្យដាក់ទានដល់អ្នកដំណើរទៅមកនៅពេលចូលឆ្នាំ ។ គេធ្វើនំបញ្ចុក ឬបបរចែកឱ្យអ្នកដើរទៅមកបរិភោគដោយឥតចេញសោហ៊ុយអ្វីឡើយ ។ ចំណីមួយមុខទៀត ដែលគេនិយមធ្វើដើម្បីដាក់ទាននោះ គឺគ្រាប់ជី ។ គេត្រាំគ្រាប់ជីទាំងពាងៗ ដាក់តាមផ្លូវឱ្យអ្នកដំណើរកំសាន្តបរិភោគតាមត្រូវការ ។ អ្នកដើរត្រូវតែទទួលទានរបស់គេជាដាច់ខាត ទោះតិចក្តី ច្រើនក្តី ។ អ្នកដើរលេងកំសាន្តមិនសូវពិបាកត្រឡប់ទៅទីលំនៅ ដើម្បីបរិភោគបាយទេ ។

នៅពេលចូលឆ្នាំនេះហើយ ដែលគេដោះលែងទាសករដែលជាខ្ញុំកញ្ជះគេឱ្យបានទទួលការសប្បាយ ដោយចែកលុយឱ្យបន្តិចបន្តួចសម្រាប់ចាយវាយ ។

## ១- បុណ្យចេញវស្សា

ថ្ងៃ ១៥ កើតខែ អស្សុជ ជាថ្ងៃចេញវស្សា ។ មានពិធីតាមរបៀបពុទ្ធសាសនានៅវត្តអារាម ។ តែនៅវេលាយប់ថ្ងៃពេញបូណ៌មីនេះ អ្នកស្រុកតាមដងស្ទឹងសង្កែ តែងប្រារព្ធធ្វើពិធីមួយដែលជាប្រពៃណី ។ គេនាំគ្នាធ្វើប្រទីបបណ្តែតភ្លើងព្រោងព្រាត នៅតាមដងស្ទឹង ។ ប្រទីបនេះគឺជា ទៀន ធូប ដែលគេដោតជាក្បាច់ក្បូរលើដើមចេកដែលភ្ជាប់គ្នា ។ ប្រទីបមានពីរយ៉ាងគឺប្រទីបធំ ដែលមានក្បាច់រចនាជារូបរាងផ្សេងៗ ហើយនិងប្រទីបរយដែលជាស្រទបចេកខ្ចីមានដោតទៀនតែមួយ ។ នៅពេលនោះគ្រប់គ្រួសារនិង វត្តអារាមនៅតាមដងស្ទឹង តែង

ធ្វើប្រទីបតូច ឬ ធំមួយមិនដែលខានទេ ។ ពិធីលយប្រទីបនេះ មានគោលបំណងខមាទោសព្រះគង្គាដោយគេ បានជ្រុលជ្រួសប្រព្រឹត្តអំពើមិនគប្បីផ្សេងៗ មានជុះនោមដាក់ទឹកជាដើម ។

ព្រឹកស្អែកឡើង គឺថ្ងៃ ១ រោជ គេនាំគ្នាចុះទូកទៅកំសាន្តនៅតម្កល់ប្រាសាទវត្តឯកភ្នំ ដែលកាលដើមមានថ្លាទឹកយ៉ាងធំទូលាយ ដែលសព្វថ្ងៃរលុបបាត់អស់ទៅហើយ ។ ថ្លាទឹកនេះគេហៅថា រហាល ។ គេណាត់គ្នាប្រណាំងទូកយ៉ាងគឹកកងនៅត្រង់រហាលនេះ ។ ការប្រណាំងទូកនេះធ្វើដោយស័គ្រចិត្តរៀងៗខ្លួន ពុំមែនជាការរៀបចំជាផ្លូវការទេ ។ ការប្រណាំងនេះទៀតក៏ឥតមានចែករង្វាន់ ឬភ្នាល់ដាក់លុយកាក់អ្វីដែរ ។ ទូកណាដែលមិនរួមប្រណាំងនិងគេ ក៏នាំគ្នាចែវអុំទៅ កំសាន្តនៅតម្កល់លិចទឹកនៅជិតខាង បេះផ្កាស្មៅ ឬ ដកព្រលិតយ៉ាងសប្បាយ ។ ដំណើរកំសាន្ត តាមទូក នៅពេលចេញវស្សានេះ ប្រព្រឹត្តទៅពីរ បី ថ្ងៃ ជាប់ៗគ្នា ។

ចាប់ពីថ្ងៃចេញវស្សានេះទៅ រហូតដល់ថ្ងៃពេញបូណ៌មី ខែ កត្តិក គេនាំគ្នាបង្ហួតគោមនៅគ្រប់ផ្ទះ នៅពេលយប់ ។ គេធ្វើគោមក្រដាស ឬក៏យកចង្កៀងអំផ្លុងចងបង្ហួតនៅចុងបង្គោលឬស្សីយ៉ាងខ្ពស់ ។ គឺ នៅក្នុងរយៈពេលមួយខែដែលគេបង្ហួតគោមនោះហើយ ដែលគេប្រារព្ធធ្វើបុណ្យកឋិនទាន ។

## គ- បុណ្យផ្លូវការ

បុណ្យផ្លូវការមានពីរយ៉ាងគឺ បុណ្យស៊ីយិត ឬសៃយិត ហើយនិងបុណ្យ ឆ្លឹម ឬឆះព្នុម នៅពេលចូលឆ្នាំ នាម៉ឺនមុខមន្ត្រីទាំងអស់នៅក្នុងខេត្តត្រូវទៅធ្វើពិធីសច្ចាប្រណិធាន ផឹកទឹកសំបថនៅវត្តសង្កែ ។ គេហៅពិធីបុណ្យនេះថា បុណ្យសៃយិត ឬបុណ្យផឹកទឹក ។ គេយកដាវលំពែង កាំភ្លើង កូរទឹកឱ្យនាម៉ឺនមុខមន្ត្រីគ្រប់រូបផឹក ដោយសច្ចាថា ស្មោះត្រង់នឹងលោកម្ចាស់ និងស្មោះត្រង់ចំពោះព្រះចៅសៀម ។

ក្នុងពិធីនេះ នាម៉ឺនគ្រប់រូបទាំងតូចទាំងធំ ទាំងលោកម្ចាស់សុទ្ធតែស្លៀកពាក់ឯកសណ្ឋានពេញយស ពាក់សក្តិ ពាក់មេដាយ ហើយមានស្ពាយដាវនៅចង្កេះ ។ សិស្សានុសិស្សក៏ត្រូវចូលរួមក្នុងពិធីនេះ ដោយមានឯកសណ្ឋានស្បែកជើងស្រោមជើងដែរ ។

នៅពេលបញ្ចប់ពិធីបុណ្យសៃយិតនេះ គេបាញ់កាំភ្លើងធំច្រើនណាត់ជាកិត្តិយស ។ ឯបុណ្យឆ្លឹម ឬ ឆះព្នុម ជាបុណ្យខួបថ្ងៃកំណើតព្រះចៅសៀម ។ គេប្រារព្ធពិធីបុណ្យឆ្លឹម ដោយ

និមន្តព្រះសង្ឃមកចម្រើនពុទ្ធមន្តនៅវិមានលោកម្ចាស់ ដែលគេហៅថា តឹកពងក្រពើ ។ បន្ទាប់មកមានប្រគុំដូរ្យដន្ត្រី និងសម្តែងល្ខោនរបាំនៅក្នុងកំផែងជូនសាធារណជនទស្សនា ដោយសេរី ។

នៅក្នុងកំផែង នាម៉ឺនធំៗសុទ្ធតែរៀបចំរោងតាំងគ្រឿងក្បាច់រចនា និង វត្ថុត្រកាលផ្សេងៗ ដូចជាពិធីតាំងតុក្នុងរាជវាំងភ្នំពេញដែរ ។

## ឃ- ពិធីបុណ្យខ្មោច

អ្នកស្រុកបាត់ដំបង ជំនាន់នោះ មានទម្លាប់ម្យ៉ាងក្នុងការធ្វើបុណ្យខ្មោច ។ បើមានមនុស្សស្លាប់ គេធ្វើបុណ្យតែបន្តិចបន្តួច ក៏យកខ្មោចនោះទៅកប់មួយអន្លើសិន ។ គេមិនធ្វើបុណ្យធំដុំទេ ព្រោះគេយល់ថាគ្រួសារកំពុងមានទុក្ខហើយមានលុយកាក់តិចតួច ។ ចាប់ពីពេលនោះមកគ្រួសារសពត្រូវខិតខំរកលុយកាក់បម្រុងធ្វើបុណ្យខ្មោចនោះ នៅពេលណាមួយឱ្យបានអធិកអធម ។ ក៏ប៉ុន្តែតាមធម្មតាមានតែពួកអភិជនទេ ដែលអាចធ្វើបុណ្យខ្មោចគ្រួសារគេបានអធិកអធមសប្បាយ ។ អ្នកក្រធ្វើបុណ្យខ្មោច យ៉ាងស្តួចស្តើងដោយវិធីសង្ខេប ក៏យកទៅកប់ ឬដុតទៅ ។ អ្នកមានធនធានតិចតួច ច្រើនរួមគ្នាជាសមាគម ធ្វើបុណ្យខ្មោចគ្រួសារខ្លួន ។

អ្នកក្រុងបាត់ដំបងនិយមយកកន្លែងមួយ នៅខាងអាគ្នេយ៍កំផែងត្រង់មាត់ស្ទឹង ក្បែររោងអារឈើ **ហូ តុខ ហាន់** សព្វថ្ងៃដើម្បីធ្វើបុណ្យខ្មោច ។ គេនិយមគាស់ខ្មោច ដែលកប់យកមកធ្វើបុណ្យនៅរវាងខែផល្គុន ចេត្រ និង ពិសាខ ដែលជាពេលដែលអ្នកផងទំនេរផុតពីការស្រែចំការ ហើយជារដូវល្អគ្មានភ្លៀង។ បើកាលណាគេធ្វើ បុណ្យខ្មោចដែលគេគាស់មកពីដីមកយ៉ាងនេះ គេនិយមឱ្យមានល្បែងប្រជាប្រិយ៍ ល្ខោន របាំ ដូរ្យដន្ត្រី អុជកាំជ្រួចភ្ជិទៀនហើយច្រើនមានការប្រកួតកីឡាប្រដាល់ទៀតផង ។ តែបើគេធ្វើបុណ្យ ខ្មោចដែលទើប និងស្លាប់ភ្លាមៗ ដែលគេហៅថា " **ខ្មោចស្រស់** " នោះគេត្រូវសំរួមចិត្តសំរួមអាត្មាជាការកាន់ទុក្ខ មិនដែលឱ្យមានការសប្បាយល្បែង របាំ រាំច្រៀងទេ ។ គេតម្កល់សពច្រើនយប់ច្រើនថ្ងៃនៅក្នុងរោងបុណ្យ រួចទើបគេដង្ហែ សពកាត់តាមទីក្រុង ហើយយកទៅតម្កល់ក្នុង " **ភ្នំយោខ** " ដើម្បីបូជា។ មានជួនកាលគេដង្ហែខ្មោចចេញពីរោងបុណ្យនៅពេលយប់ទៅតម្កល់នៅវត្តណាមួយរួចទើបហែមក កាន់កន្លែងបុណ្យវិញនៅថ្ងៃបន្ទាប់ ។ ការដង្ហែពេលយប់នេះ អ្នកហែត្រូវកាន់ចន្លុះ ឬគោម ។ គេហៅរបៀបហែនេះថា " **លួចសព** " ។

គេច្រើនសាងមេរុខ្ពស់ស្កឹមស្កៃ សម្រាប់បូជាសពលោកចៅអធិការវត្ត ឬ សម្តេច ចៅ ឬ ជាពិសេសសពលោកម្ចាស់ ។ គេដាក់សពលោកម្ចាស់ ឬមន្ត្រីសង្ឃទីរាជគណៈ ក្នុងកោដ្ឋដែលមានសណ្ឋានផ្សេងៗ ទៅតាមកម្រិតឋានន្តរសក្តិ ។ គេនិយមធ្វើរូបទេវតាអំពីចំបើងបិតក្រដាសយ៉ាងប្រិមប្រិយ៍ ឱ្យកាន់ភ្លើងហើយគេបង្ហូតពីទីខ្ពស់ណា មួយក្បែរនោះមកដុតសព ។ គេច្រើនបូជាសពនៅពេលយប់ ទើបឃើញជាទស្សនីយភាពមួយដ៏រំភើប គឺគេឃើញទេវតាហាក់ ដូចជាចុះមកពីស្ថានសួគ៌យកភ្លើងមកបូជា សពនោះនៅពេលដែលគេអុជកាំជ្រួច ភ្ញីទៀន យ៉ាង ទ្រហឹងអ៊ឹងអាប់ ។

លោកតា **លិម ស៊ុត** នៅវត្តកណ្តឹង និងលោកតា **ញឹក ហួត** នៅកំពង់ឆ្នួង បានទៅមើលពិធីបុណ្យបូជាសពលោកម្ចាស់ **កថាថន ញ៉ុញ** នៅវាំងឆ្នាំ ១៨៩៥ ។ គេដាក់សពលោកម្ចាស់ **ញ៉ុញ** ក្នុងកោដិដម្កល់ក្នុងមេរុយ៉ាងស្កឹមស្កៃ ដែលគេស្ថាបនានៅខាង ត្បូងវត្តកំផែងត្រង់មុខក្លោងទ្វារចូលពីខាងត្បូង ។ ព្រះសង្ឃគ្រប់វត្តត្រូវគេ គេណ្ឌឱ្យមកធ្វើរោង បុណ្យក្នុងមួយវត្តរោងមួយ ។ រោងនីមួយៗ សុទ្ធតែមានគ្រឿង តាំងជាទីទាក់ទាញមហាជន ។ គេមានលេងភ្លេង របាំ រាំ ច្រៀង របៀបខ្មែរគ្រប់បែបយ៉ាងថែមទាំងមានល្ខោនកូឡា និងអាប៉េលាវទៀតផង ។នៅពេលយប់គេមានអុជកាំជ្រួចភ្ញីទៀនគ្រប់បែបយ៉ាងហើយថែមទាំងមានបាញ់កាំភ្លើងធំទៀតផង ។

រាស្ត្រប្រជាដែលចូលទៅមើល ពិធីបុណ្យនេះត្រូវគេបញ្ញត្តិយ៉ាងតឹងរឹង ឱ្យយកក្រមាក្រវាត់ចង្កេះពីក្រៅអាវ ។ (នេះប្រហែលជាវិធានការខាងសុជីវធម៌ មិនមែនវិធានការខាងសន្តិសុខទេ ព្រោះនៅពេលបុណ្យតាំងតុនៅក្នុងវាំងភ្នំពេញ ក៏មិនឱ្យពាក់ស្បែកជើងឈើ ឬពាក់អាវក្រៅខោចូលដែរ ។ សូមបញ្ជាក់ថា ការក្រវាត់ចង្កេះនេះ ជាសុជីវធម៌ចាំបាច់នៅពេលនោះ ។ កូនប្រុសារជួបឪពុកក្មេក អ្នកតូចជួបអ្នកធំ ត្រូវតែយកកន្សែងក្រវាត់ចង្កេះចេញ ។ បើពុំនោះទេ គេថាយើងព្រហើន ឥតពូជអម្បូរ ។

ឪពុកក្មេកខ្លះយកលេសត្រង់កូនប្រសារនិយាយជាមួយមិនក្រវាត់ចង្កេះនេះ ដើម្បីផ្តាច់កូនក្រមុំអស់ច្រើនគ្នាហើយ ។ រាស្ត្រប្រជានៅសម័យនោះត្រូវតែចេះក្រវាត់ ចង្កេះគ្រប់ៗគ្នា ទើបគេអនុញ្ញាតិឱ្យចូលក្នុងបរិវេណពិធីបុណ្យ ។ លោកតា **ញឹក ហួត** ទោះបីគាត់ទើបមានអាយុប្រហែល ១០ ឆ្នាំក៏ដោយ ក៏គាត់ត្រូវតែក្រវាត់ចង្កេះ នឹងគេដែរ ។)

នៅបញ្ចប់បុណ្យខ្មោចលោកម្ចាស់ព្រះកោដិនេះ មានពិធីបោះទាន ។ គេមានឆ្លាក់រូបជារង្វាន់ដែលគេបង្កប់ក្នុងផ្លែល្វា ឬផ្លែចេកខ្ចី ហើយបោះពីផ្កាយព្រឹកមក ។ រង្វាន់ដែលធំជាងគេត្រូវបានដីរ ។ នៅពេលបោះទាន រង្វាន់ធំបានទៅយាយចាស់កំសត់ម្នាក់ ។ យាយចាស់នោះទ្រហោរយំនៅពេលដែលគេនាំដីរយកមកឱ្យគាត់ ។ គាត់មិនយកទេ តែគេឱ្យគាត់ជិះដីរទាំងបង្គំពីទីបុណ្យរហូតដល់ផ្ទះ ។ គេសរសើរព្រេងសំណាងគាត់ រួចគេក៏សុំលោះដីរនោះមកវិញ ។ យើងកុំឆ្ងល់ប្រាក់ដែលគេលោះគាត់នោះ មិនស្មើនិង តម្លៃដីរពិតប្រាដកទេ។

## ខ-បុណ្យព្រះពុទ្ធសាសនា

វចនានុក្រម ឡឺប៉ុទីឡារូស ឆ្នាំ ១៩៦៩ ត្រង់ទំព័រ ១១៦៥ បានឱ្យកិត្តិយសខេត្តបាត់ដំបងថាជា " **មជ្ឈមណ្ឌលព្រះពុទ្ធសាសនា**"។ ពិតមែនហើយ ក្រុងបាត់ដំបងត្រូវតែមានកិត្តិយសជាមជ្ឈមណ្ឌលព្រះពុទ្ធសាសនាមែន ព្រោះក្រុងបាត់ដំបងមានវត្តអារាមច្រើនដែលជាកេរ្តិ៍ដំណែលតាំងពីបុរាណមក ។វត្តអារាមខ្លះមានតម្លៃណាស់ក្នុងវិស័យសិល្បៈដូចជា **វត្តកណ្ដឹង វត្តសង្កែ វត្តដំរីស វត្តពោធិវាល វត្តពិភិទ្ធ** ។ល។ កិត្តិយសក្រុងបាត់ដំបងដែលថាជាមជ្ឈមណ្ឌលពុទ្ធសាសនានេះ គឺជាកេរ្តិ៍ដំណែលតាំងពីបុរាណមក ព្រោះវត្តអារាមទាំងប៉ុន្មាន ដែលយើងឃើញសព្វថ្ងៃនេះសុទ្ធតែមានកំណើតតាំងពីមុនលោកម្ចាស់ **កថាថនឈុំ** សឹងតែទាំងអស់។ ព្រះឧត្តមព្រឹទ្ធាចារ្យ **អ៊ុំ សុខ** វត្តតាមិមបានមានថេរដិការថា តាំងពីលោកដឹងក្តីឡើងកាលណា លោកមិនដែលឃើញគេកសាងវត្តថ្មីទេ ។ លក្ខណៈប្លែកពីសម័យនោះមកសម័យនេះ គឺវត្តខ្លះធ្លាប់ចុំថ្កើង ដូចជា **វត្តកណ្ដាល វត្តសង្កែ វត្តដំរីស** ឯវត្តខ្លះទៀត មានលក្ខណៈមិនទាន់សមរម្យ ។ ឯវត្តដែលកើតមុនគេ នៅបាត់ដំបងប្រហែលជា **វត្តកំពង់អំពិល** និង**វត្តកណ្ដឹង**។

ព្រះគ្រូសាសន **គីរីត កែ ម៉ូ** វត្តសូរភីបានរំឭកពីសំនួនវោហារកាព្យឃ្លោងរបស់លោកគ្រូ **យឹត** ដែលជាអតីតចៅអធិការ**វត្ត សុរតី** តាំងពីយូរ មុនលោកឧញ៉ា**សុត្តន្តប្រីជាឥន្ទ** ទៅទៀតស្តីពីវត្តនានា ដែលមាននៅតាមដងស្ទឹងជំនាន់លោក ។ បើយកតាមកំណាព្យនេះ យើងនឹងអាចវែកញែកឃើញ **វត្តថ្មី** និង **វត្តចាស់** ដែលមាននៅសម័យនោះ។ តែទោះជាថាវត្តនោះទើបកសាងថ្មីក៏មិនមែនថ្មីនៅជំនាន់ក្រោយលោកម្ចាស់ដែរ ។

ឯកំណាព្យរបស់លោកគ្រូវិច មានដូចតទៅ :

"សតិតាំងដើម ឯវត្តកំពង់ អំពិលហើយត្រង់ តម្រង់វត្តខ្វែង
តាមិមតាអាត់ កណ្ដឹងហើយវត្ត សំពៅកំផែង ដំរីសលែង
វត្តកណ្ដាលឯង សែទៅសែមក។ ឯវត្តពិភិទ្ធ ទទ្ទឹមគ្នាពិត
ទៀបនិងវត្តពោធិ រីឯវត្តល្បៀប ទៀបនិងវត្តសុ បរមនោ
វត្តបាឡាត់ផង ឯវត្តនរា ចុះតាមគង្គា ដល់វត្តក្ដុលឆ្លង
ត្រឡប់ទៅកោះ កកែងកកោង ដល់វត្តសំរោង វត្តព្នៅវត្តកែវ "។

ព្រះគ្រូសាសន **ភីរត កែម្ញ៉** បានមានថេរដិការថែមទៀតថា កំណាព្យនេះនៅខ្វះវត្តពីរ គឺ **វត្តឯកភ្នំ** និងវត្តមួយទៀត នៅតាមដងស្ទឹងសង្កែ ទៅក្រោម គឺ **វត្តស្ដីសំបូរមាស** ។

បើស្ដាប់តាមកំណាព្យនេះ យើងឃើញថា នៅសម័យលោកគ្រូឃីត នៅតាមដងស្ទឹងសង្កែ មានវត្តប្រហែលតែ ២០ ប៉ុណ្ណោះ គឺវត្តកំពង់អំពិល វត្តខ្វែង វត្តតាមិម វត្តកណ្ដឹង វត្តសំពៅ វត្តកំផែង វត្តដំរីស វត្តកណ្ដាល វត្តសង្កែ វត្តពិភិទ្ធ វត្តពោធិ វត្តល្បៀប វត្តសូរភី វត្តរំដួល វត្តបាឡាត់ វត្តនរា វត្តក្ដុល វត្តសំរោង វត្តព្នៅ វត្តកែវ ថែមវត្តឯកភ្នំ និងវត្តស្ដីសំបូរមាស ។ លោកតា ហ៊ុន ជា អាចារ្យវត្តគរ បានប្រាប់ថា វត្តគរមានកំណើតយូរយារហើយ មុនវត្តសំពៅទៅទៀត តែយើងមិនឃើញឈ្មោះវត្តគរក្នុងកំណាព្យខាងលើនេះទេ ដោយមិនដឹងហេតុអ្វី ។

ព្រះវិហារបុរាណដែលនៅសល់ពីសម័យលោកម្ចាស់ មកដល់សព្វថ្ងៃមាន ព្រះវិហារវត្តកណ្ដឹង វត្តសង្កែ និងវត្តដំរីស។ វត្តកណ្ដឹងមានព្រះវិហារពីរ ព្រះវិហារខាងជើងស្ថាបនាយូរយារ ហើយឯព្រះវិហារខាងត្បូង ស្ថាបនាដោយលោកស្រី **អ៊ុំខ** ប្រពន្ធធំរបស់លោកម្ចាស់ ។

វត្តសង្កែជាវត្តធំជាងគេ ជាវត្តរបស់សម្ដេចចៅ គឺវត្តព្រះមេគណ ជាវត្តដែលលោកម្ចាស់ទៅធ្វើបុណ្យ ជាពិសេសបុណ្យសែយិត ដែលជាបុណ្យផ្លូវការ ។

លោកម្ចាស់បានចាត់ឱ្យសាងព្រះវិហារវត្តដំរីស ប៉ុន្មានឆ្នាំមុនដែលលោកទៅបស្ទឹម ។

វត្តក្ដុលជាវត្តបុរាណ មានកំណើតនៅសម័យនោះដែរ ។ កាលដើមឡើយ វត្តនេះជាទីតាំងបន្ទាយរបស់**ចៅពញា បឪន** ។ តែក្រោយមក គេបានឧទ្ទិសដីនេះថ្វាយព្រះពុទ្ធសាសនា

ដើម្បីសាងវត្តអារាមមួយដាក់ឈ្មោះថា " **វត្តព្រាបព្រាមបច្ចាមិត្រ** " ។ គេសង្កេតឃើញមាននៅសល់ចេតិយ ខាងក្រោយព្រះវិហារ ក្នុងលក្ខណៈរចនាបទចម្លែក ប្លែកខុសពីវត្តនានា នៅក្នុងខេត្ត ។

ក្នុងសម័យលោកម្ចាស់ វត្តអារាមទាំងប៉ុន្មានត្រូវដាក់នៅក្រោមបង្គាប់ព្រះសង្ឃមួយអង្គទីជារាជាគណៈ ដែលរាស្ត្រសាមញ្ញហៅថា " **សម្តេចចៅ** " ។ បន្ទាប់ពីសម្តេចចៅ មិនមានអនុគណដូចសព្វថ្ងៃទេ គឺមានតែព្រះឧបជ្ឈាយ៍ ។ សម្តេចចៅ និងព្រះឧបជ្ឈាយ៍ក៏មិនមាននាទីដូចមេគណ មិនអនុគណសព្វថ្ងៃដែរ ព្រោះពេលនោះមិនសូវមានការចាត់ចែងខាងរដ្ឋបាល ។ **សម្តេចចៅ** ដែលជាមេគណ គង់នៅវត្តសង្កែមានព្រះនាម **ឡៀង** ។ លោកមានជម្ងឺចាងស្បែក ទើបពុទ្ធសាសនិកជនហៅថា សម្តេចចៅចាង ។ ក្រោយមកទៀតឋានៈសម្តេចចៅត្រូវបានទៅព្រះគ្រូព្រះនាម **ហាស ថោង** គង់នៅវត្តសូរភី ។ រីឯព្រះឧបជ្ឈាយ៍វិញ មាននៅវត្តសំពៅ និងវត្តកែវ ។ ព្រះគ្រូ ឧបជ្ឈាយ៍ដែលគង់នៅវត្តសំពៅមាន ព្រះនាម **យស** ។ នៅវត្តកែវ ដំបូងព្រះឧបជ្ឈាយ៍ មានព្រះនាម **គង់** តែក្រោយដែលលោក សុគតទៅនោះ លោក **កថាថន ឈុំ** បានបញ្ញត្តិ ឱ្យពុទ្ធសាសនិកទាំងអស់ហៅថា " **លោកគ្រូ ព្រះកោដ្ឋ** " ។ នៅវត្តកែវដដែលព្រះគ្រូមួយអង្គទៀតព្រះនាម **ណាំម** ក៏ឡើងទទួលទីជាព្រះឧបជ្ឈាយ៍បន្តពី លោកគ្រូ ព្រះកោដ្ឋទៀត ។ នៅពេលសុគត សពសម្តេចចៅ និង ព្រះឧបជ្ឈាយ៍ត្រូវគេតម្កល់ ក្នុងកោដ្ឋ ធ្វើបុណ្យទក្ខិណានុប្បទាន ។

សូមបញ្ជាក់ថា នៅក្រោយឆ្នាំ ១៩០៧ ដែលសៀមប្រគល់ខេត្តបាត់ដំបងមកឱ្យខ្មែរវិញនោះ រាជការភ្នំពេញបានតែងតាំងសម្តេចចៅព្រះនាម **ថោង** ជាព្រះធម្មចរិយាព្រឹទ្ធ ឯព្រះឧបជ្ឈាយ៍ ព្រះនាម **ណាំម** ជាព្រះគ្រូធម្មានុសិទ្ធិសាទរ ។

យើងមិនបាច់ធ្វើអត្ថាធិប្បាយអំពីព្រះពុទ្ធសាសនានេះ ឱ្យវែងទេ ព្រោះមិនសូវខុសពីសព្វថ្ងៃប៉ុន្មាន ។ យើងលើកយកតែលក្ខណៈដែលប្លែកមកកត់ទុកជាចំណាំទៅពេលក្រោយ ។

លោកម្ចាស់តែងបរិច្ចាគទ្រព្យសម្បត្តិ ប្រគេនជាបៀវត្សសម្រាប់ព្រះសង្ឃគ្រប់វត្តទាំងអស់ក្នុងខេត្ត។ ព្រះឧត្តមព្រឹទ្ធាចារ្យ **អ៊ុំ សុខ** វត្តតាមិម កាលលោកនៅជាសាមណេរ លោកធ្លាប់ចូលក្នុងកំផែងជាមួយលោកគ្រូលោក ទៅបើកបៀវត្សដែលលោកម្ចាស់ប្រគេនដល់វត្តនីមួយៗ

តែលោកមិនចាំទេថា ប្រាក់ដែលគេប្រគេនទៅវត្តនីមួយៗនោះប៉ុន្មាន ។ ព្រះឧត្តមព្រឹទ្ធាចារ្យមាន ថេរដីការថែមទៀតថា នៅសម័យដើម គេមិនដែលធ្វើបុណ្យផ្កាប្រាក់ទេ ។ ឯបុណ្យដទៃទៀត មានដូចសព្វថ្ងៃ តែមានទម្លាប់ខ្លះដែលសព្វថ្ងៃគេបោះបង់ចោល។ ព្រះសង្ឃជំនាន់ដើម មុនឆាន់ ត្រូវលើកព្រះហស្តប្រណម្យ ហើយសូត្រធម៌សិន ។ តែសព្វថ្ងៃ លោកសង្ឃឈប់លើកព្រះហស្ត សំពះ សូត្រធម៌ទៀតហើយ ព្រោះមានពាក្យគេរិះគន់ ។

លក្ខណៈខុសប្លែកមួយទៀតគឺសាមណេរ ។ សាមណេរមិនមានចីពរទេ មានតែស្បង់ អង្សឹត និងសំពត់ពានាពណ៌លឿង ។ គេមិនបំបួសលោកនេននៅក្នុងវិហារទេ គេបំបួសតែតាម កុដិ ។ ពេលបិណ្ឌបាត្រ ភិក្ខុមានឃោគសម្រាប់ស្ពាយបាត ឯលោកនេនកាន់បាតផ្ទាល់ដៃ ដូចព្រះ សង្ឃខាងគណៈធម្មយុត្តិសព្វថ្ងៃ ។ លោកនេនមិនឆាន់នៅពេលជាមួយលោកភិក្ខុទេ តែយក ចង្ហាន់ ដែលសល់ពីភិក្ខុមកឆាន់ ។ លោកនេនឆាន់រួមថាសជាមួយក្មេងៗដែលជាកូន សិស្សលោក តែមានបញ្ញត្តិមួយ ឱ្យលោកនេនឆាន់បីម៉ាត់មុនកូនសិស្ស ។

សាមណេរដែលមានលក្ខណៈខាងលើនេះ គឺមានអាចនៅសម័យ១៩០៧ (សម័យ លោកម្ចាស់និងអភិជន) អាចមុនទៅទៀតក៏ថាបាន ។ វិន័យសាមណេរត្រឹមត្រូវទើបបានរៀបចំ ដោយសម្តេច ជួន ណាត នៅសម័យព្រះអង្គក្នុងទសវត្សទី ៣០-៤០-៥០-៦០-៧០ នៃសតវត្ស ទី ២០ ។ ព្រះត្រៃបិដកមានព្រះវិន័យ ១៣ គម្ពីរ មកដល់ប្រទេសកម្ពុជាយើងយូរពិតមែន ប៉ុន្តែ ការស្រាវជ្រាវបកប្រែទើបហើយនៅទសវត្សរ៍ទី ៦០ នៃសតវត្សទី ២០ ហេតុនេះការដាក់ចុះប្រើ ប្រាស់ត្រឹមត្រូវអាចយឺត ។ ម្យ៉ាងទៀត មិនអាចបកស្រាយឱ្យដូចគ្នាបេះបិទទៅតាមប្រទេស ទេ។ ឧទាហរណ៍ : វិន័យនៅសេរីលង្កាព្រះសង្ឃមិនអាចឆាន់បារីបានទេ ប៉ុន្តែព្រះសង្ឃនៅ កម្ពុជាអាចឆាន់បារីបាន ។

## ៤. ពិធីបំបួសនាគ

(សូមមើល ពេជ សល់ ពិធីប្រចាំដប់ពីរខែ ១៩៦៦ ទំព័រទី ៣៩-៤២)

ពិធីបំបួសនាគអាចធ្វើនៅខែពិសាខក៏បានលើកលែងតែខែ ៣ ដែលព្រះសង្ឃចូលព្រះ វស្សា គឺចាប់តាំងពីថ្ងៃ ១ រោជ ខែអាសាធទៅ ។ ប៉ុន្តែជាទំនៀមរៀងមក ពិធីបំបួសនាគហ្លួង តែងធ្វើនៅថ្ងៃ ១៥ កើត ខែអាសាធជានិច្ច គឺថាមុនថ្ងៃកំណត់ចូល ព្រះវស្សា ។

ក្នុង១ឆ្នាំៗ បុត្រក្រុមព្រះរាជវង្សានុវង្ស និងបុត្រនៃមន្ត្រីជាន់ខ្ពស់ ដែលបានចូលទៅសុំឱ្យព្រះករុណាបំបួស សុទ្ធតែមានកំណត់គឺថា យកត្រឹមតែ ១២ នាក់យ៉ាងច្រើនលើសចំនួនកំណត់នេះ អ្នកចូលទៅសុំ ត្រូវចាំទៅ ឆ្នាំមុខទៀត ។

មានដំណាលកាលពីព្រេងនាយថា មានសត្វនាគមួយដំណែងខ្លួនជាមនុស្ស ហើយចូលទៅសុំបួសយកនិស្ស័យ ក្នុងសំណាក់ព្រះពុទ្ធសាសនា ។ ថ្ងៃមួយលោកគ្រូប្រើលោកនេនឱ្យទៅហៅជូនជាពេលនោះលោកនេនដែលជាសត្វនាគនោះកំពុងដេកលក់ពុំដឹងខ្លួន ហើយក្លាយខ្លួនទៅជាសត្វនាគពេនទ្រេលពេញក្នុងបន្ទប់ ។ ដំណឹងនោះ ក៏ជ្រាបទៅដល់ព្រះបរមសាស្តា ព្រះអង្គទ្រង់បង្គាប់ឱ្យលោកនាគនោះចាកសិក្ខាបទទៅវិញដោយហេតុថាច្បាប់ ព្រះពុទ្ធសាសនា ហាមមិនឱ្យសត្វ ចូលបួសផងបានទេ ប៉ុន្តែដោយទ្រង់មេត្តាករុណាដល់នាគដែលមានសេចក្តីជ្រះថ្លានឹងសាសនាព្រះអង្គ ទ្រង់ក៏សន្យានឹងនាគថា ចាប់អំពីថ្ងៃនេះតទៅ តថាគត សន្មតឱ្យនាមអ្នកសុំផ្នួសថា " **នាគ** " ដើម្បី ជាទីរំឮកដល់នាគអ្នក ។ ហេតុនេះបានជាមានឈ្មោះថា " **បំបួសនាគ** "ដរាបរៀងមកទល់សព្វថ្ងៃ ។

ឯទំនៀមបំបួសនាគក៏មានលំនាំផ្សេងៗខុសគ្នាបន្តិចៗ ដូចជាទំនៀមធំៗ ដទៃទៀតដែរ មានទំនៀមខ្លះ ដែលគេយល់ឃើញថា មិនត្រឹមត្រូវតាមច្បាប់ព្រះពុទ្ធសាសនា គេក៏កាត់ចោលទៅទំនៀមខ្លះដែលកើតឡើងតាមកាលៈទេសៈ ក៏ត្រូវបញ្ចូលមកវិញ ។ ហេតុនេះ. យើងសូមជំរាបថា សេចក្តីអធិប្បាយអំពីពិធីបំបួសនាគ ដែលយើងនឹងអធិប្បាយ ជូនក្នុងទីនេះពុំមែនជារបៀបតួយ៉ាង ដែលគេត្រូវតែធ្វើតាមនោះទេ គឺជារបៀបទំនៀមយ៉ាងសង្ខេបមួយដែលគេធ្លាប់បានឃើញធ្វើមកហើយ ។

មុនថ្ងៃបំបួសនាគចំនួន ៤-៥ ថ្ងៃ អ្នកដែលត្រូវចេញទៅបួស ត្រូវកាន់ទៀនធូបទៅជំរាបលាបងប្អូន និងញាតិមិត្តរបស់ខ្លួន ដើម្បីឱ្យគេបានដឹងផងថា : ខ្លួននឹងចូលទៅបំម្រើព្រះពុទ្ធសាសនាហើយ ។

ទំនៀមដែលយើងអធិប្បាយដូចតទៅនេះ ជាទំនៀមដែលគេធ្វើនៅគេហដ្ឋានសាមីខ្លួនក៏បាន ឬ ធ្វើនៅទីអារាមក៏បាន . ប៉ុន្តែពិធីខ្លះ គេលះបង់អស់ទៅហើយ ។

បើបំបួសសាមណេរ ត្រូវមានរៀបចំត្រៃចីវរ បាត្រ កន្ទេល ខ្នើយ ។ បើបំបួសជាភិក្ខុវិញ ត្រូវមានកំបិតកោរ ថ្នសំលៀង . បំពង់ម្នុរ . ថែមលើបរិក្ខារខាងលើនេះទៀតទើបគ្រប់ ។ ក្រៅអំពីបរិក្ខាទាំងនេះមានដបទឹកអប់ បាយសីធំមួយ ធ្វើដោយដើមចេកមួយដើម ដែលមានកំពស់ត្រឹមចិញ្ចើមមនុស្សឈរ ។ បាយសីនោះមាន ១៩ ថ្នាក់ ដែលជាជំនាងព្រលឹងមនុស្សទាំង ១៩ ប៉ុន្តែមានអ្នកខ្លះ ធ្វើសង្ខេបត្រឹមតែ ៩ ថ្នាក់ ។ នៅលើកំពូលបាយសីមានកន្ទោងស្លឹកចេកមួយ ដាក់បាយព្រលឹង ១៩ ( ឬ ៩ ពមនូត) . មានសាជីធ្វើដោយស្លឹកចេកគ្របពីលើ ហើយនៅកំពូលសាជីមានដោតទៀនរាយមួយផង ។ គេយកស្លឹកចេក ៣ ធាង មករុំព័ទ្ធបាយសីនោះ ១ ជាន់ រួចទើបយកសំពត់ហូលរុំ ១ ជាន់ពីក្រៅទៀត ។

លុះរៀបគ្រឿងបរិក្ខារដូចបានពោលមកនេះជាជួរតាមលំដាប់ស្រេចហើយ នាគត្រូវចូលទៅអង្គុយជិតបាយសីធំ ដើម្បីស្តាប់ព្រះសង្ឃចម្រើនព្រះបរិត្ត ដោយមានឪពុកម្តាយបងប្អូន និងក្រុមញាតិមិត្តអង្គុយអមផង ។ បន្ទាប់មក គេរៀបធ្វើពិធី " **ហៅព្រលឹងនាគ** " គ្រានោះអាចារ្យកាន់អំពៅខ្មៅ១ដើម ដែលគេទុកឱ្យមានស្លឹកពីរ ឬ បីនៅចុង ហើយចងឱ្យមានទំនងដូចជាចំពុះបក្សី ។ អាចារ្យកាន់ដើមអំពៅបង្វែរចំពុះនោះទៅគ្រប់ទិស បោយហៅព្រលឹងឱ្យនាគ បន្ទាប់មកគេរៀប " **ធ្វើធ្មេញ** " ឱ្យនាគទៀត ។

កាលជំនាន់ដើម នៅពេលបំបួសនាគក្តី នៅពេលរៀបអាពាហ៍ពិពាហ៍ក្តី គេនិយមយកម្រ័ក្សបុកលាយនឹងរុក្ខជាតិខ្លះទៀត ដើម្បីយកទៅលាបធ្មេញសាមីខ្លួនឱ្យមានសម្បុរខ្មៅស្រិលមែន១ ។ សព្វថ្ងៃនេះ អាចារ្យគ្រាន់តែរៀប " ធ្វើធ្មេញ " បំពេញកិច្ចទេ តមកទៀតអាចារ្យរៀបចំ " បញ្ចុកបាយនាគ " គឺគេយកបាយព្រលឹងទៅដាក់ក្នុងទឹកដូង ហើយបញ្ចុកមាត់នាគទៅរួច ហើយទើបយកអំបោះជ្រលក់ក្នុងទឹកមន្ត ចងដៃនាគ ។ បន្ទាប់មកទៀត . ពួកក្រុមញាតិសាច់សាលោហិត នាំគ្នាអង្គុយជារង់ជុំវិញនាគ ហើយរៀបបង្វិលពពិល ដើម្បីចម្រើនសេរីសួស្តីជ័យមង្គលដល់នាគនោះ ។ ជាធម្មតា គេត្រូវបង្វិលពពិល ១៩ជុំ ហើយបក់ផ្សែងសំដៅទៅរកនាគផង ។ លុះគ្រប់ គម្រប់កំណត់ជុំហើយ អាចារ្យពន្លត់ទៀន រួចយកកំញមលាយជាមួយ នឹងទឹកអប់បន្តិចយកទៅលាបចិញ្ចើមនិងថ្ងាសនាគ ។

ថ្ងៃបន្ទាប់មក គេរៀបក្បួនហែនាគទៅកាន់វត្តព្រះកែវមរកត , បើប្រសិនជានាគនោះជាវង្សត្រកូលក្សត្រ ឬជាកូននាម៉ឺនជាន់ខ្ពស់ ការហែនាគមានសភាពគគ្រឹកគគ្រេងណាស់ ស្ទើរតែប្រហាក់ប្រហែលនឹងការរៀបចំហែស្តេច ១ ព្រះអង្គដែរ , ព្រោះកាលដែលព្រះបរមសាស្តាយើងទ្រង់ចេញទៅសាងព្រះផ្នួស ព្រះអង្គជាព្រះរាជបុត្រាក្សត្រគ្រងរាជ្យដែរ ។

គេឃើញមានភ្លេងផៃយាំមួយក្រុមចេញដើរមុខក្បួន , មាននមនុស្សទ្រពាន ប្រាក់តម្កល់ត្រៃចីវរ ទ្របាត្រនិងគ្រឿងសក្ការៈបូជា ដើរមុខនាគ ។ បន្ទាប់មកទៀត នាគដែលមានសំលៀកបំពាក់ដូចជាស្តេចសម័យបុរាណ ជិះសេះមានមនុស្សបាំងក្លស់ឱ្យ ផង ។

នៅមុខវត្ត មានមនុស្សកំប្លែងម្នាក់ធ្វើជាមារាធិរាជ ដែលចាំរារាំងព្រះពោធិសត្វមិនឱ្យចេញទៅបួស ស្ទុះទៅចាប់មុខសេះដែលនាគជិះ ហើយធ្វើហាក់ដូចជាឃាត់មិនឱ្យនាគចូលទៅបួស ។ ប៉ុន្តែនាគមិនព្រមលោតចុះពីលើខ្នងសេះ ហើយដើរចូលទៅក្នុងទីវត្ត ដោយមានក្រុមញាតិសាលោកហិតហែតាមពីក្រោយផង ។ ដល់ហើយ , ក្បួនហែនាគដើរប្រទក្សិណព្រះវិហារ ៣ ជុំ អាចារ្យស្រែកអនុមោទនា ដើម្បីសម្តែងសេចក្តីត្រេកអរនឹងកិច្ចរបស់កុលបុត្រ ដែលស្ម័គចិត្តលះបង់ភេទគ្រហស្ថ ហើយទទួលយកភេទជាបព្វជិត ។

## ៥. ពិធីចូលព្រះវស្សា

( សូមមើល ពេជ សល់ ពិធីប្រចាំដប់ពីរខែ ឆ្នាំ១៩៦៦ ទំព័រ ៤៦-៤៩ )

តាមទំនៀមជាប្រពៃណីនៃព្រះពុទ្ធសាសនា ព្រះសង្ឃទាំងឡាយគ្រប់អារាមក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវនិមន្តចូលកាន់ព្រះវស្សាអស់ថិរវេលា៣ខែ ចាប់តាំងពីថ្ងៃ ១ រោជ ខែអាសាធតទៅ ។

ពាក្យថា " **វស្សា** " មកពីពាក្យបាលីថា : " **វស្សៈ** " ប្រែថា " **ភ្លៀង** " ឬ " រដូវភ្លៀង " ដែលមានកំណត់៤ខែ (រាប់ពីថ្ងៃ១រោជខែអាសាធ ដល់ ១៥កើតខែកត្តិក) ។ ព្រះបរមសាស្តាយើង ទ្រង់បានបញ្ញត្តិឱ្យមានកិច្ចចូលព្រះវស្សានេះ ប៉ុន្តែសព្វថ្ងៃនៅប្រទេសកម្ពុជា ការចូលព្រះវស្សាមានកំណត់ត្រឹមតែ ៣ ខែទេ (រាប់ពីថ្ងៃ១រោជ ខែអាសាធ ដល់ ១៥

កើតខែអាស្សុជ ) ។ ក្នុងរយៈវេលា៣ខែនេះ នៅគ្រប់ព្រះវិហារនៃទីវត្តទាំងឡាយ គេតែងរក្សាភ្លើងទៀនព្រះវស្សាឱ្យនៅឆេះជានិច្ច ។ តួទៀនធ្វើអំពីឈើ មានទំហំប្រមាណ ២ចាប់ , កំពស់ ២ហត្ថ មានរចនាក្បាច់យ៉ាងល្អ និងរំលេចពណ៌ដ៏ប្រណិតផង ។ ខាងក្នុងតួពុម្ពទៀនមានដោតអំបោះឆៅជាប្រឆេះ ហើយគេបង្ហូរក្រមួនឃ្មុំចូលទៅក្នុងពុម្ពនោះ ប៉ុន្តែដោយក្រមួនឃ្មុំពុំសូវសម្បូណ៌ គេនិយមប្រើប្រេងជំនួសវិញ ហើយចាក់ក្រមួនឱ្យមានកម្រាស់តែ ៥ ធ្នាប់ខាងលើទេ។ លុះឆេះអស់សាច់ក្រមួនហើយ ទើបឆេះដល់ប្រេងគេធ្វើដូច្នេះដើម្បីឱ្យទៀននោះឆេះជាប់ ដរាបគ្រប់៣ ខែ ។

កាលដល់ថ្ងៃកំណត់ចូលព្រះវស្សាហើយ ព្រះករុណាឬ ព្រះរាជវង្សានុវង្សមួយអង្គទ្រង់យាងចេញអុជទៀនវស្សាទាំង ៤ យ៉ាងឧឡារឹកជារៀងរាល់ឆ្នាំ ។ បណ្តាទៀនវស្សាទាំង៤នោះ ទៀន ១ ត្រូវតម្កល់នៅហោព្រះរូប ក្នុងព្រះបរមរាជវាំង ដែលជាកន្លែងតម្កល់ព្រះពុទ្ធរូប ។ ទៀន១ ទៀតតម្កល់នៅក្នុងហោព្រះអដ្ឋិ នៅក្នុងព្រះទីនាំងទេវាវិនិឆ្ឆ័យ ដែលជាទីតម្កល់នូវកោដ្ឋអដ្ឋិធាតុ របស់ក្រុមព្រះរាជវង្សានុវង្ស ។ ទៀនទី៣ តម្កល់នៅក្នុងហោព្រះខាន់ ទៀនទី ៤ តម្កល់នៅក្នុង ព្រះវិហារ ព្រះកែវមរកត ។ ម្យ៉ាងទៀត ព្រះករុណាទ្រង់តម្រូវឱ្យធ្វើទៀនទៅតម្កល់នៅទីវត្តក្នុងព្រះរាជធានីនិង ទីវត្តជិតៗ នៅក្នុងទីក្រុងផង រហូតនេះហើយទើបទៀនវស្សាព្រះរាជទ្រព្យមានដល់ទៅ ១៩ដើម ។

នៅថ្ងៃដែលធ្វើពិធីអុជទៀនវស្សានៅព្រះបរមរាជវាំង ក្រុមបារគូបុរោហិតរៀបធ្វើពិធីអញ្ជើញព្រះបញ្ចក្សេត្រឱ្យចូលកាន់ព្រះវស្សាដែរ ។ ចាប់តាំងពីថ្ងៃពេញបូរមីខែអាសាឍ គឺមុនថ្ងៃចូលព្រះវស្សា ១ថ្ងៃ គេសង្កេតឃើញមាន ភាពអ៊ូអរស្មើតែគ្រប់វត្តអារាម ។ ពីព្រលឹមព្រះសង្ឃទាំងឡាយដែលនៅក្នុងវត្ត និមន្តចូលទៅក្នុងព្រះវិហារដើម្បីថ្វាយបង្គំព្រះ រតនត្រ័យនិងស្វាធ្យាយធម៌ ដារបញ្ជូនផលានិសង្សដល់វិញ្ញាណក្ខន្ធអ្នកដែលធ្វើមរណភាពទៅហើយ។ ដល់ថ្ងៃត្រង់ ពួកទាយកទាយិការៀបចំចង្ហាន់ប្រគេនព្រះសង្ឃឆាន់ពេលល្ងាច ព្រះសង្ឃសម្តែងធម៌ទេសនាជាការស្រេច ។

ថ្ងៃជាបន្ទាប់មកជាថ្ងៃចូលព្រះវស្សា នៅវេលារសៀល គេធ្វើពិធីហែទៀនព្រះវស្សានិងគ្រឿងបរិក្ខារផ្សេងៗ មានសំពត់វស្សិកសាដកជាដើម ប្រទក្សិណព្រះវិហារ៣ជុំជាមុន ទើប

នាំទៀនចូលទៅ-គេវេរទៀនរួចទើបអុជទៀននោះជាក្រោយ ។ នៅឱកាសនោះ គេនិមន្ត ព្រះសង្ឃឱ្យគង់តាមលំដាប់វស្សាចាស់-ខ្ចី ។ ព្រះសង្ឃដែលចាស់វស្សាជាងគេ ប្រកាសប្រាប់ ទីប្រជុំថា ថ្ងៃនេះជាថ្ងៃចូលព្រះវស្សា ដែលមានថេរវេលា៣ខែ ឱ្យព្រះសង្ឃឯទៀតថាតាម ។

ក្នុងកំណត់រដូវចូលវស្សា៣ខែនោះ ព្រះសង្ឃពុំអាចនិមន្តទៅណាមកណាដូចពេលក្រៅ វស្សាទេ ។ បើកាលណាមានកិច្ចពិសេសព្រះសង្ឃអាចនិមន្តទៅផ្ទះឯកជនបាន បើប្រសិនជាគេ និមន្ត ឬបើមានធុរៈញោមឈឺ ឬ ក៏ឧបជ្ឈាយ៍អាចារ្យឈឺ លោកអាចចេញទៅគង់ក្រៅអា រាមបាន ប៉ុន្តែត្រូវកុំឱ្យហួសពីប្រាំពីរថ្ងៃ ។ មុននឹងចេញទៅលោកត្រូវទៅទូលលោកគ្រូជា មេវត្តសិន ដោយ សន្យានឹងលោកថា នឹងវិលមកវិញឱ្យទាន់មុនអរុណរះនៃថ្ងៃទី ៧ មិនខាន ។ ដល់ពេលត្រឡប់ ចូលទីអារាមវិញភ្លាម ត្រូវចូលទៅបង្ហាញខ្លួនដល់លោកគ្រូមេវត្តជាដំណឹង ។

ជូនកាល មានព្រះសង្ឃខ្លះពុំបានចូលព្រះវស្សាតាមកំណត់កាលវេលា ដោយមានធុរៈ អ្វីមួយ ឬ ដោយរោគាពាធនោះ លោកអាចចូលបច្ឆិមិតវស្សាបាន គឺលោកចូលនៅថ្ងៃ១រោជខែ ស្រាពណ៍ ហើយត្រូវគិតវស្សាឱ្យគ្រប់៣ខែ ដូចលោកដែលចូលមុន គឺត្រូវចេញវិញនៅថ្ងៃ ១ រោជ ខែ កត្តិក ។

## ៦. ធំនៀមរាស្ត្រ

( សូមមើល ពេជ សល់ ពិធីប្រចាំដប់ពីរខែ ឆ្នាំ ១៩៦៦ ទំព័រទី ៥៦-៥៩)

ថ្ងៃដាច់ខែភទ្របទជាថ្ងៃសំខាន់ជាងគេក្នុងរដូវបិណ្ឌ គឺជាថ្ងៃ " ប្រជុំបិណ្ឌ " ឬ "ភ្ជុំបិណ្ឌ"

មុនថ្ងៃភ្ជុំមួយថ្ងៃ ជាថ្ងៃវេនធំ ។ នៅគ្រប់គ្រួសារខ្មែរគេនាំគ្នាធ្វើនំអន្សម នំគមដើម្បី យកទៅវត្តអារាម ចែកញាតិមិត្តជិតខាង និងសែនជូនជីដូនជីតា ដែលធ្វើមរណកាលទៅហើយ នោះ ។

ចំណែកនៅឯទីវត្ត គេរៀបចំបោសសំអាត តាក់តែងសាលាបុណ្យឱ្យសមរម្យតាម របៀប . ព្រោះនៅវេលាយប់ថ្ងៃ ១៤ រោជនោះ ព្រះសង្ឃត្រូវនិមន្តស្វាធ្យាយធម៌និងទេសនា ទាល់ភ្លឺ ហើយគេមានធ្វើពិធីបង្សុកូល និងអភិសេកព្រះពុទ្ធរូប ដូចជាយើងបានពោលមក ហើយ ក្នុងព្រះរាជពិធី ។

មានរឿងដំណាលថា : កាលនោះព្រះបរមពោធិសត្វទ្រង់មានសេចក្ដីតក់ស្លុតនឹងជរា ព្យាធិ និងមរណៈជាពន់ពេក ទ្រង់យាងចាកភេទជាក្សត្រ ដើម្បីទៅស្វែងរកព្រះនិព្វានជាឋាន បរមសុខ ។ ព្រះអង្គទ្រង់ធ្វើទុក្ករកិរិយា អស់រយៈកាល៦ឆ្នាំទាល់តែមានព្រះកាយស្គាំងស្គម យ៉ាងខ្លាំង . ប៉ុន្តែក្រោយបន្តិចមកព្រះអង្គទ្រង់ពិចារណាឃើញថា ការដែលទ្រង់ប្រព្រឹត្តនេះ មិន អាចធ្វើឱ្យសម្រេចមគ្គផលបានទេទើបព្រះអង្គចាប់ឆាន់ចង្ហាន់ឡើងវិញ ។ តពីនោះមក ព្រះអង្គ ក៏ព្រមទទួលចង្ហាន់ដែលនាងសុជាតាបានធ្វើដោយផ្ចិតផ្ចង់អស់ពីចិត្តថ្វាយព្រះអង្គ ។

ព្រះអង្គទ្រង់បានសម្រេចព្រះសម្ពោធិញ្ញាណ នៅពេលដែលព្រះអង្គទ្រង់គង់នៅក្រោម ដើមពោធិព្រឹក្សមួយ ។ ប៉ុន្តែមុននឹងទ្រង់បានត្រាស់ដឹង . មារាធិរាជដែលជាសត្រូវ តាមព្យាបាទ ព្រះអង្គជាយូរណាស់មកហើយ ហើយដោយសេចក្ដីក្ដៅក្រហាយនឹងបំបែរព្រះទ័យព្រះអង្គឱ្យ ងាកចាកផ្លូវល្អពុំបាន ក៏លើកពលដំរីជាដើមមកបណ្ដេញព្រះអង្គឱ្យ ចុះអំពីរតនបល្ល័ង្ក ។ ព្រះ បរមសាស្ដាទ្រង់អាងដល់នាងគង្ហីងព្រះធរណីជាកសិណ នាងគង្ហីងចាប់ផ្នួងសក់ច្បូតចេញជាទឹក លិចលង់ពលមារបរាជ័យក្នុងពេលនោះហោង ។ ឯទំនៀមធ្វើបុណ្យអភិសេកព្រះពុទ្ធរូប ជា ទំនៀមរំឮកដល់រឿងពុទ្ធប្រវត្តិត្រង់ ដែលព្រះអង្គផ្ចាញ់មារាធិរាជនេះឯង ។

ហេតុនេះហើយ ទើបក្នុងពិធីពុទ្ធាភិសេក មានក្មេងព្រហ្មចារី អង្គុយបកស្រូវភោជសា លី និងចំអិនមធុបាយាស ដោយទឹកដូងនឹងភ្លើងទៀនជាតំណាងនាងសុជាតា ។ ដល់ពេលទៀប ភ្លឺ មានយុវជនជាច្រើនរូបតំណាងពលមារ ចូលទៅធ្វើអាការហាក់ជាកំហែងព្រះអង្គ ពេលនោះ ពួកកុមារីបានព្រោចនូវស្រទាប់ផ្កាឈូក ជាការរំឮកដល់កាលដែលនាងគង្ហីង ធរណីច្បូតសក់បង្ហូរ ទឹកឱ្យលិចលង់ពលមារ ។

ពេលភ្លឺស្រាង១ ទាយកទាយិកា នាំគ្នាត្រឡប់ទៅកាន់ទីលំនៅរៀង១ខ្លួន ទៅសម្រាក បន្តិចដើម្បីនឹងត្រឡប់មកកាន់វត្តវិញនៅពេលថ្ងៃជិតត្រង់ ។

ជិតដល់ពេលហើយ អ្នកស្រុកជើងវត្តនាំគ្នាទូលបាយបត្តបូរ បាយបិណ្ឌ ម្ហូបចំណី នំនែក ផ្សេង១ ដែលធ្វើដោយផ្ចិតផ្ចង់ទៅប្រគេនព្រះសង្ឃ ដើម្បីឱ្យបានផលដល់ខ្មោចជីដូនជីតា ដែល គេលែងឱ្យមកជួបជុំក្នុងពេលនោះ។ នៅស្រុកខ្លះ គេបង្ហិលពពិលបំបួសដូនជីមួយផង នៅឱកាស នោះ ។

ពេលព្រលប់ថ្ងៃដដែល អ្នកស្រុកប្រមូលក្រុមញាតិនៅផ្ទះរៀងខ្លួនដើម្បីសែនជីដូន ជីតា។ គេក្រាលកន្ទេល១ ដាក់សំពត់សក្រាលពីលើមានខ្នើយស ១ផង នៅអមកន្ទេលទាំងសងខាង មានថាស ចំអាប បង្អែម បាយបិណ្ឌ និងបាយបត្តបូរ ។ លុះរៀបចំស្រេចកាលណា មនុស្សចាស់ម្នាក់ ក្នុងគ្រួសារអុជធូបទៀន សំបូងសម្រូង អញ្ជើញជីដូនជីតាញាតិមិត្ត ដែលបានធ្វើមរណៈ កាលទៅនោះ ឱ្យអញ្ជើញមកសេពសោយអាហារភោជន ដែលគេរៀបជូន និងឱ្យសព្ទសាធុកាពរដល់កូនចៅញាតិសន្តានផង ។

ថ្ងៃជាបន្ទាប់មក គឺថ្ងៃ១កើតខែអស្សុជ គេក្រោកតាំងពីយប់នាំយកក្បូនដើមចេកផ្ទុកដោយស្បៀងអាហារ ស្រូវអង្ករ នំនែកគ្រប់យ៉ាង យកទៅបណ្តែតឱ្យរសាត់តាមខ្សែទឹកហូរ ហើយនិយាយថា សូមឱ្យជីដូនជីតាអញ្ជើញត្រឡប់ទៅស្រុកដើមវិញចុះ ។

ក្នុងភូមិខ្លះនៅក្បែរក្រុងភ្នំពេញ នាថ្ងៃដដែលនោះ គេមានធ្វើពិធីសែន ឬ ថ្វាយព្រះភូមិផង ។ គេរៀបចំកន្ទេលខ្នើយ បាយទឹកនិងសំណែនផ្សេងៗ ដូចជាសែនដូនតាពីល្ងាចដែររួច គេអញ្ជើញព្រះភូមិ ព្រះធរណី ឱ្យមកសេពសោយព្រមទាំងសុំឱ្យកើតផលានុផលបរិបូណ៌ផង ។

ជួនកាល បន្ទាប់អំពីការសែនព្រេននិងបួងសួងនោះមក កូនក្មេងដែលនៅចំក្រោមផ្ទះនាំគ្នាស្រែកហ៊ោកញ្ជ្រៀវវាយសរសរផ្ទះក្ដុងក្ដាំងបណ្តើរថា : " **ឱ ព្រះភូមិករ ព្រះធរណី យាងមកឱ្យយើងសុខសប្បាយហើយ** " , រួចនាំគ្នាសើចលាន់យ៉ាងសប្បាយទៅ ។

បន្ទាប់មកទៀត គេយកអំបោះឆៅទៅចងដៃម្ចាស់ផ្ទះប្រុសស្រី ចងសរសរកន្លោងចងស្នែងគោក្របី នង្គ័លនិងរនាស់ ។ អំបោះនេះជានិមិត្តរូបនៃសម្ព័ន្ធមួយយ៉ាងតឹងឬងរវាងភ្ញៀវចូលមកជួបជុំនិងអ្នកផ្ទះ ។ គេយកប្រេងម្សៅទៅលាបស្នែងសត្វពាហនៈទាំងនោះ ហើយសុំខមាលទោស កុំឱ្យមានកម្មពៀរដោយបានប្រើនិងវាយដំសត្វនោះ ក្នុងការធ្វើស្រែចំការ ។ រួចហើយអ្នកស្រែចំការ នាំគ្នាយកច្រមទៅដោតមួយៗ គ្រប់ស្រែ ។ ច្រមនោះធ្វើអំពី ដើមឫស្សីមួយកំណាត់ គេច្រៀកចុងម្ខាងជាបន្ទះស្តើងៗ ហើយយកវល្លិក្រងឱ្យមានរាងរីកចុងរួម គល់ដូចជីវឡាវ , មានដាក់បាយ នំចំណី និងចងស្លាបមាន់ខ្មៅ១នៅមាត់ច្រមនោះផង ។ អ្នកស្រែយកច្រមទៅដោតនៅទិសឥសាន្តស្រែ ហើយថយមកអង្គុយបួងសួងមួយសន្ទុះ សុំឱ្យធ្វើ ស្រែបានផលច្រើន ។ នៅកន្លែងខ្លះទៀត គេយកបាយបិណ្ឌទៅចោលក្នុងស្រែដើម្បីឱ្យបានផលច្រើន ។

# ៧. បវារណាចេញវស្សា

(សូមមើល ពេជ សល់ ពិធីប្រចាំដប់ពីខែ ភ្នំពេញ ឆ្នាំ ១៩៦៦ ទំព័រ ៦០-៦១)

កាលបានគង់ចាំព្រះវស្សាគ្រប់ ៣ខែ ហើយព្រះសង្ឃត្រូវបវារណាចេញព្រះវស្សា នៅថ្ងៃពេញបូរមីខែអស្សុជ ។ ក្នុងថ្ងៃជាមួយគ្នានោះ នៅព្រះបរមរាជវាំងពួកបារគូធ្វើពិធីអញ្ជើញទេវរូបចេញព្រះវស្សាដែរ គឺព្រះឥសូរ-ព្រះនាងឧមា-ព្រះគណេស.ព្រះនារាយណ៍និង ពលទេព។ ថ្ងៃនោះនៅគ្រប់ទីវត្ត ព្រះសង្ឃប្រជុំគ្នាធ្វើកិច្ចបវារណាចេញវស្សា គឺសុំខមាទោស កំហុសរបស់ខ្លួនគ្រប់ព្រះអង្គ ។ ចំណែកទាយកទាយិកា ក៏ជ្រះថ្លាធ្វើទានប្រគេនព្រះសង្ឃឯវត្ត តាមទំនៀមគឺធ្វើចំពោះព្រះសង្ឃដែលខ្លួនបានចាប់ស្លាក កាន់អង្គតាំងពីថ្ងៃភ្ជុំមក ។

ក្រោយពេលព្រះសង្ឃសូត្របវារណា គេនិមន្តលោកទេសនាមហាជាតក (ព្រះសង្ឃវេស្សន្តរ) គឺជាតិដែលព្រះបរមគ្រូ ទ្រង់ធ្វើមហាបរិច្ចាគ , ព្រោះព្រះអង្គទ្រង់ដាក់ទាន ទាំងព្រះរាជទេពី និងរាជព្រះបុត្រា-បុត្រីដល់ជូជក ។

នៅយប់ថ្ងៃពេញបូរមីខែអស្សុជនោះ អ្នកស្រុកនាំគ្នាបណ្តែតប្រទីប ឬ លយប្រទីបដែល ធ្វើពីដើមចេកដោតភ្ជាប់គ្នាជាក្បូន ។ ក្បូននេះជូនកាលមានរាងធំសម្បើម ហើយមានធ្វើរាងជាសាលា ជាព្រះចូឡាមណីចេតិយ មានគោមរាងកន្ទ្រាមតាឪ នៅត្រង់កំពូលផង ។ គេធ្វើនំនែក ផ្សេងៗ ហើយនាំគ្នាសែងក្បូននោះទៅមាត់ទឹក គេនិយាយឧទ្ទិសបូជាប្រទីបនោះចំពោះព្រះរតនត្រ័យគឺ : ព្រះពុទ្ធ-ព្រះធម៌-ព្រះសង្ឃ ។ ចំណែកជនសាមញ្ញក៏សូត្រនមស្ការស្នាមព្រះពុទ្ធបាទ និង និយាយស្មាលាទោស ព្រះគង្គានិងព្រះធរណី ដោយខ្លួនបានបន្ទោរបង់នូវវត្ថុក្រខ្វក់ផ្សេងៗ ក្នុង ឆ្នាំនោះ ស្រេចហើយ ទើបនាំគ្នាអូសក្បូនទម្លាក់ទឹកទៅ ។

តាមធម្មតា មុននឹងបណ្តែតប្រទីបទៅតាមខ្សែទឹកហូរ គេច្រើនយកទូក រចនាដោយភ្លើផ្កាយ៉ាងវិចិត្រ ទៅសណ្តោងប្រទីបហែជាក្បូននៅកណ្តាលទន្លេ ហើយមាននិមន្តព្រះសង្ឃគង់ក្នុងទូកនោះផង ។ នៅភូមិខ្លះ អ្នកស្រុកមាននាំគ្នាលេងប្រណាំងទូកងទៀត ។ ទំនៀមលយប្រទីបនេះមានប្រភពច្រើនបែបណាស់ ប៉ុន្តែមានប្រភព២ ដែលគេដឹងច្រើនជាងគេ ។ រឿងទី១ថា : ធ្វើបុណ្យបណ្តែតប្រទីបដើម្បីបូជាចំពោះព្រះចង្កូមកែវ ដែលប្រតិស្ឋានទុកនៅឯពិភពនាគឯនោះ

រឿងទី២ថា ជាបុណ្យរំឭកថ្ងៃដែលស្តេចភុជង្គនាគ សុំឱ្យព្រះពុទ្ធអង្គទ្រង់ប្រតិស្ឋានស្នាមព្រះបាទ ទុកជាទីគោរពសក្ការៈ នៃពួកសត្វទឹកទាំងឡាយ ។

ចំណែកបុណ្យអុំទូក ដែលត្រូវធ្វើក្រោយពេលចេញវស្សាមួយខែមកទៀតនោះ ក៏មាន សេចក្តីអធិប្បាយអំពីជំនឿដូចគ្នានឹងរឿងលយប្រទីបចេញវស្សានេះដែរ ។

## ៨. បុណ្យនៅរដូវអស់ទឹកភ្លៀង

( សូមមើល ពេជ សល់ ពិធីប្រចាំដប់ពីរខែ ១៩៦៦ ទំព័រទី ៦២-៦៨)

ចាប់តាំងពីថ្ងៃ១រោជខែអស្សុជ ទៅថ្ងៃពេញបូរមីខែកត្តិក អ្នកស្រុកនាំគ្នាធ្វើកឋិននិង និមន្តព្រះសង្ឃឆាន់តាមបឹង ។

បុណ្យកឋិនជាបុណ្យពុទ្ធានុញ្ញាតមួយ ព្រោះព្រះសង្ឃមានស្បង់ចីពរមិនស្អាតដោយ ប្រឡាក់ភក់ ទទឹកទឹកភ្លៀង នៅពេលដែលលោកនិមន្តបិណ្ឌបាតនៅរដូវចេញវស្សា ទើបព្រះពុទ្ធ ទ្រង់អនុញ្ញាតឱ្យព្រះសង្ឃទទួលត្រៃចីវរ អំពីទាយកទាយិកា ដែលស្ម័គ្រចិត្តវេរប្រគេន ។

ហេតុនេះ ទើបនៅក្នុងបុណ្យកឋិន មានត្រៃចីវរជាប្រធានលើគ្រឿងបរិក្ខារឯទៀត ទាំងអស់ មានបាត្រ-គ្រែ-កន្ទេល-ខ្នើយ-មុង-ចាន និងប្រដាប់សម្រាប់ព្រះសង្ឃប្រើប្រាស់ជាដើម ។

បុគ្គលិកក្រសួងណាមួយ ឬក្រុមគ្រួសារណាមួយ អាចនាំគ្នាប្រមូលប្រាក់កាសដើម្បីហែ អង្គកឋិនទៅចូលវត្តណាមួយតាមដែលខ្លួនស្ម័គ្រ ហើយបានទៅទាក់ទង ទូលលោកទុកជាមុន កុំឱ្យលោកទទួលគេទៀត ។ វត្តនីមួយៗ មានអំណាចទទួលបានតែកឋិនទានមួយទេក្នុង១ឆ្នាំ ។ ធម្មតាគេច្រើនរើសរកតែវត្តណា ដែលខ្សត់ខ្សោយជាងគេ ។

មុនថ្ងៃចូលបុណ្យ១ថ្ងៃ គេរៀបរណ្តាប់កឋិនដាក់ទុកសង្ឃឹកមួយ រួចគេដង្ហែចាប់ដៃអ្នក ស្រុកអ្នកភូមិ ដោយមានភ្លេងនាំមុខ មានផ្តិលមួយដាក់កណ្តាលរណ្តាប់ទាំងនោះ សម្រាប់ទទួល ប្រាក់ ដែលអ្នកមានសទ្ធាចូលចាប់កុសលផង ។ ក្រោយពីនោះមក គេនាំយកសង្ឃឹកមកដាក់នៅ ទីប្រជុំ រៀបនិមន្តព្រះសង្ឃចម្រើនព្រះបរិត្ត , ជូនកាលមានលេងភ្លេង លេងល្ខោន និងរាំច្រៀង កំដរបុណ្យឱ្យបានឧឡារិកផង ។

ព្រឹកស្អែកឡើង ពួកភ្ញៀវនិងក្រុមគ្រួសារអ្នកផ្ដើមបុណ្យ នាំគ្នាទៅប្រជុំនៅកន្លែងតាមដែលបានកំណត់ក្នុងកម្មវិធីបុណ្យ ដើម្បីចេញដំណើរឆ្ពោះទៅកាន់ទីវត្ត ។ អ្នកទៅបុណ្យកឋិនស្លៀកពាក់សំពត់អាវយ៉ាងល្អៗ ឯរថយន្តគេតុបតែងដោយផ្កាក្រដាស និងដោតទង់សាសនាជាសំគាល់ ។ នៅស្រុកស្រែដែលអ្នកស្រុកពុំសូវសម្បូរប្រាក់កាស គេនាំគ្នាធ្វើដំណើរនាំអង្គកឋិនដោយរឺម៉កជិះកាត់វាលស្រែ មើលទៅឃើញឆ័ត្រ និង សំលៀកបំពាក់ពណ៌ស្រស់ញញឹមកណ្ដាលស្រែពណ៌បៃតងស្រងាត់គួរសប្បាយណាស់ ។

ទៅដល់វត្ត អ្នកស្រុកហែអង្គកឋិនប្រទក្សិណព្រះវិហារ៣ជុំ ដោយមានក្រុមភ្លេងឆៃយ៉ាំ ដែលគេតែងនិយមយកមកលេងក្នុងពេលបុណ្យហែយោងមុខ ។

ឆៃយ៉ាំជាភ្លេងមួយបែប មានស្គរវែងៗ ពាសដោយស្បែកពស់ថ្លាន់ ហើយមានជីបកំណាត់ពណ៌ស្រស់ ៗ ជារំភាយដាក់ជុំវិញមុខស្គរ ។ ពេលលេង , អ្នកភ្លេងយកស្គរនោះមកស្ពាយដាក់ចំហៀងខ្លួន ទះនឹងដៃតាមចង្វាក់ភ្លេងបណ្ដើរ ច្រៀងបណ្ដើរ ឡកបណ្ដើរ ។ ភ្លេងឆៃយ៉ាំមានលក្ខណៈកំប្លែងរស់រវើក ហាក់ដូចជាគ្រលុកចិត្តមនុស្សឱ្យកម្រើកតាម ។

ហែប្រទក្សិណគ្រប់ ៣ ជុំហើយ ក្បួនហែចូលទៅក្នុងព្រះវិហារ ដែលមានព្រះសង្ឃគង់ចាំនៅទីនោះស្រាប់ ។ ឯសង្ឃឹកនិងគ្រឿងបរិក្ខារទាំងអស់ គេរៀបចំពោះព្រះភក្ត្រព្រះសង្ឃ ។ ទាយកទាយិកា នាំគ្នានមស្ការព្រះរតនត្រ័យ រួចអារាធនាសីល ។ បន្ទាប់មកអាចារ្យរៀបវេរអង្គកឋិនព្រមទាំងគ្រឿងបរិក្ខារជាបរិវារកឋិនប្រគេនព្រះសង្ឃ ព្រះសង្ឃទទួលហើយក៏ធ្វើកិច្ចបង្វែរប្រគេនចំពោះភិក្ខុសង្ឃមួយអង្គ ដែលចេះដឹងយល់ច្បាស់ក្នុងកិច្ចក្រាលគ្រងកឋិន ឱ្យទទួលបំពេញកិច្ចនោះតាមច្បាប់វិន័យទៅ ។ រួចកិច្ចនេះហើយ ព្រះសង្ឃអនុមោទនាឱ្យពរជ័យដល់អ្នកមានសទ្ធាទាំងឡាយ ដែលបានមកជួបជុំក្នុងទីនោះ ។

ក្រោយពីនោះមក គេប្រគេនចង្ហាន់ដល់ព្រះសង្ឃ រួចអ្នកស្រុកអញ្ជើញភ្ញៀវចូលបរិភោគអាហារតាមតុដែលរៀបចាំទទួលយ៉ាងហ្មតចត់ ។ អ្នកទៅលេងបុណ្យកឋិន ច្រើននៅលេងអស់ចិត្ត ទើបត្រឡប់មកផ្ទះវិញ ។ ព្រោះក្នុងឆ្នាំនីមួយៗ បុណ្យកឋិនជាបុណ្យសប្បាយជាងគេ ។ ដល់ ពេលល្ងាច ឬ យប់ដែលឡានបុណ្យត្រឡប់មកវិញ គេឮសូរតែមាត់ក្មេងហោកព្រៀវទះស្គរ ច្រៀងយ៉ាងសប្បាយ ។

នៅជាមួយគ្នានឹងរដូវកឋិននេះ នៅស្រុកណាដែលលិចដោយទឹកតម្លើង និងសម្បូណ៌ ដោយចង្កោមផ្កាស្មោរ ពណ៌លឿងខ្ចី ដុះផុតពីទឹក មានទំនៀមនិមន្តព្រះសង្ឃឆាន់តាមបឹង ។

មុនដំបូង មានទូកមួយផ្ទុកដោយឆើងម្សៅ ចង្ក្រានខ្ទះ និងខ្លាញ់ជ្រូកដាក់នៅក្បាលទូក អុំ ទៅបឹងមុនគេ ហើយដាក់ខ្លាញ់ក្នុងខ្ទះក្ដៅ កាលណាដល់ដើមស្មោរ គេបន្ទន់ដើមស្មោរយក ផ្កាវាជ្រលក់ក្នុងម្សៅ រួចដាក់ចៀនក្នុងខ្លាញ់ក្ដៅឱ្យឆ្អិន រួចគេបន្តដំណើរទៅទៀតទាល់តែនៅ ក្នុងបឹងនោះ គេឃើញសុទ្ធតែនំផ្កាស្មោរ ជាប់នៅនឹងដើមស្មោរមិដេរដាស ។ ពេលដែលអ្នក ស្រុកនិមន្តព្រះសង្ឃដាក់ទូកទៅឆាន់នំផ្កាស្មោរចៀននោះ គេនាំគ្នាដកព្រលឹត ដកសារាយ រួចទើប នាំគ្នាទៅប្រជុំនៅទីទួលណាមួយដែលគេកំណត់ទុក ដើម្បីនាំគ្នាលេងប្រណាំងទូក ។ នៅស្រុកខ្លះ ទូកអុំប្រុសប្រណាំងនឹងទូកស្រី ៗ ហើយមានច្រៀងឆ្លើះឆ្លងគ្នាយ៉ាងសប្បាយ ។

ដល់ពេលឡើងគោក គេរៀបកំសាន្ដដោយយកអាហារទៅបរិភោគដោយព្រៃ មាន ត្រី អណ្ដើកដុត ព្រលឹត ស្មោរ ត្រកៀតជាដើម ។

ក្នុងការកំសាន្តបែបដូចខាងលើនេះ ប្រជាជនខ្មែរ ហាក់ដូចជាចង់ភ្លក់គ្រែបនូវអំណោយ របស់ទឹកជំនន់ដែលតែងនាំមកនូវជីជាតិគ្រប់យ៉ាងមុននឹងធ្វើពិធីសងគុណទឹក ដែលជាកិច្ចក្រោយ បំផុត ។

ដល់ថ្ងៃពេញបូរមីខែកត្តិក មានធ្វើបុណ្យមួយទៀតយ៉ាងឧឡារិក ដែលបារាំងនាំគ្នាឱ្យ ឈ្មោះថា " បុណ្យទឹក " ។ បុព្វហេតុដែលនាំឱ្យធ្វើបុណ្យនេះ ក៏ដូចគ្នានឹងការបណ្តែតប្រទីប ដែរ មតិខ្លះថាធ្វើដើម្បីសងគុណទឹកដី និងសុំខមាទោសទឹកដី ដោយបានបន្ទោរបង់នូវរបស់មិន ស្អាត ។ មតិខ្លះទៀតពោលថា គេធ្វើដើម្បីគោរពចំពោះស្នាមព្រះពុទ្ធបាទ ដែលបានប្រតិស្ឋាន ទុកនៅលើផ្អកខ្សាច់នម្មទា ដែលជាទន្លេរបស់ប្រទេស **យោនកៈ** (លាវប៉ែកខាងលិច) . ខ្លះ ថា គេធ្វើរំឭកដល់ទូកដែលគេធ្វើថ្វាយព្រះពុទ្ធអង្គ នៅពេលដែលទ្រង់និមន្តទៅធ្វើឱ្យបាត់រាំង ភ្លៀង នៅនាក្រុង **វេសាលី** ។ ខ្លះថា ជាការបូជាចំពោះព្រះចង្កូមកែវដែលប្រតិស្ឋានទុកឯ ពិភពនាគឯណោះ ។

ជិតដល់ថ្ងៃប្រណាំងទូក ទូក-ង ទាំងឡាយដែលនៅសន្ទឹងស្ដូក ហាក់ដូចជាដេកក្នុងទីវត្តនៅ តាមក្បែរមាត់ទន្លេមេគង្គនិងទន្លេសាប អ្នកស្រុកនាំគ្នាធ្វើពិធី " **ដាស់ទូក** " ដើម្បីដាក់ទូកទៅ ក្នុងទឹកនឹងចេញទៅប្រណាំងឱ្យមានជ័យជំនះ ។

ពីល្ងាច. ពេលលោកសូត្រមន្ត គេរៀបចំសុំណែនផ្សេងៗ ដាក់លើទូក ហើយដាក់ប្រវាយោង ដែលមានលាបពណ៌យ៉ាងល្អស្អាតជាងគេ នៅលើក្បាលទូក ជួនកាលមានបាំងឆ័ត្រ ឬក្លស់ផង ។

នៅតំបន់ជាច្រើន ក្នុងពិធីដាក់ទូកនេះ មានរូបសំណឹងចូលជាន់ដើម្បីជួយទ្រទ្រង់ទូកនិងអ្នកអុំ ។ គេក្រាលកន្ទេលមួយនៅក្បែរទូកសម្រាប់រូបសំណឹង ហើយលេងភ្លេងអន្ទងលោមខ្មោចឱ្យចូលជាន់ ។ ដល់ខ្មោចចូលជាន់ភ្លាម រូបនោះឡើងរាំធ្វើអាការជាអុំទូក ហើយយកអំបោះ ឬ កន្សែងចងដៃឱ្យអ្នកអុំ ធ្វើកិច្ចប្រោះព្រំដោយទឹកមន្ត សុំឱ្យទូកនិងអ្នកអុំ ចេញទៅមានជ័យជំនះ ។ ជួនកាលរូបរលាស់ទឹក លើអ្នកភូមិដែលចូលមកជួបជុំក្នុងទីនោះផង ដើម្បីឱ្យបានសេចក្ដីសុខគ្រប់ៗគ្នា ។

ពេលព្រឹមថ្ងៃបន្ទាប់ គេយកភ្នែកទៅពាក់ឱ្យទូក ហាក់ដូចជាឱ្យទូកមានជីវិត ភ្លេងលេងបទតាមទម្លាប់ក្នុងពិធីនោះ គេស្រែកហ៊ោពាដងមុននឹងសែងទូកចេញពីបង្គងដាក់ចុះទៅក្នុងទឹក ។

នៅព្រះរាជធានីភ្នំពេញ . គេធ្វើពិធីប្រណាំងទូកនៅពេលរសៀលពាថ្ងៃជាប់គ្នា ។ នៅរសៀលថ្ងៃបង្ហើយបុណ្យ គេចងសន្ទឹងព្រ័ត្រមួយនៅកណ្ដាលទន្លេ ។ លុះដល់ពេលផ្ដាច់ព្រ័ត្រនោះ បារគូម្នាក់កាន់ដាវជិះលើក្បាលទូក-ង ធ្វើកិច្ចបួងសួងដល់គុណព្រះគង្គាសព្វគ្រប់ហើយទើបអុំទូកតម្រង់ទៅរកព្រ័ត្រ ហើយធ្វើកិច្ចជន្លួ រួចថយមកវិញគម្រប់ ៣ ដង ទើបកាត់ផ្ដាច់ទៅ ។ នៅពេលនោះ ពួកទូក-ង ដែលឡើងទៅត្រៀមចាំនៅទីឯលើទឹក ក៏អុំចែវចុះមកស្រព្រមគ្នាតែម្ដងហ៊ោកញ្ជ្រៀវលាន់ទ្រហឹងហាក់ដូចជាសន្ទាប់ដេញទឹកឱ្យរត់ចុះសម្ដៅសមុទ្រ ។

រាល់ពេលព្រលប់ ក្នុងកំណត់ ៣ ថ្ងៃបុណ្យ . ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់យាងអុជប្រទីប ។ ប្រទីបនោះគឺជារាងឈើ ឬ ឫស្សីដែលគេរចនាជារូបភាពផ្សេងៗ ដែលគាត់តែងបន្ដុបបន្ថែតលើទូក ឬ កប៉ាល់ មានរំលេចពណ៌ឱ្យភ្លឺព្រោងព្រាតលយបន្តបន្ទាប់គ្នាតាមដង

ទន្លេ មើលទៅឃើញភ្លឺសន្ធោហាក់ដូចជាគំនូរនៅលើផ្ទាំងខ្មៅនៃរាត្រីកាល ។ នេះហើយ ដែលគេហៅថា លយប្រទីប ។

នៅទីរួមខេត្តខ្លះ នៅឆ្ងាយពីព្រះរាជធានី ក៏មានធ្វើពិធីប្រណាំងទូកដែរ ដូចជានៅដែនកូសាំងស៊ីន ពួកខ្មែរក្រោមនាំគ្នាធ្វើពិធីប្រណាំងទូកនៅតម្លល់មួយចំងាយ ១០ គ.ម ពីស្រុកត្រាំង់ (ខេត្តឃ្លាំង) ។ តាមពតិមានរបស់អ្នកស្រុកថា ពិធីនេះបានចាប់ផ្តើមធ្វើឡើងក្នុងចុងសតវត្សទី ១៦ គឺនៅពេលដែលមានស្តេចក្រាញ់ នៅត្រួតត្រាក្នុងតម្លល់នោះ ។

នៅថ្ងៃពេញបូរមីខែកត្តិក គឺយប់កណ្តាលនៃបុណ្យអុំទូក ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ព្រះបញ្ចាឱ្យរៀបធ្វើពិធីសំពះព្រះខែនៅក្នុងដំណាក់ផែ ។ ទ្រង់ស្រប់ព្រះហស្តនិង ព្រះភក្ត្រដោយទឹកក្លស់ ទឹកស័ង្ខ ហើយទ្រង់យកស្លឹកពោរលាស់លើព្រះរាជបុត្រាបុត្រីទាំងអស់ ។ ស្លឹកពោរនេះទំនៀមស្រុកឥណ្ឌា គេសម្រាប់តែថ្វាយចំពោះព្រះឥសូរទេ ។

ផ្នែកខាងស្រែចំការ នៅវេលាយប់ជាមួយគ្នានោះ អ្នកស្រុកនាំគ្នាប្រជុំនៅកន្លែងមួយក្នុងភូមិ តែតាមធម្មតា ច្រើនប្រជុំនៅទីវត្ត ដើម្បីធ្វើពិធីសំពះព្រះខែ-អកអំបុក ។ អ្នកស្រុកជើងវត្ត នាំគ្នាយកផ្លែឈើ នំចំណី អំបុក-ចេក ជាការចាំបាច់មកចាក់រួមគ្នានៅទីវាលដែលពុំមានស្លឹកឈើអ្វីបាំងសោះ មើលទៅលើឃើញតែមេឃនិងព្រះច័ន្ទស្រឡះផេង ហើយនាំគ្នាដាំឫស្សីជាបង្គោលពីរ ចងឫស្សី១ដើមទទឹងជារាងខ្លោងទ្វារ នៅកណ្តាលទីធ្លានោះ ។

គេរៀបចំដង្វាយព្រះច័ន្ទដាក់លើកន្ទេល លុះដល់ខែត្រង់ អ្នកស្រុកនាំគ្នាអុជធូប ៣សរសៃម្នាក់ សំពះបន់ស្រន់តាមបំណងរបស់ខ្លួន ។ នៅពេលនោះ អាចារ្យអុជទៀនដែលបិទភ្ជាប់នឹងដើមឫស្សីចងទទឹង ។តាមធម្មតា គេច្រើនបិទទៀន៣ ទៀនកណ្តាលតំណាងស្រុក របស់អ្នកដែលធ្វើកិច្ច ទៀនសងខាងតំណាងស្រុកជិតខាង ។ នៅពីក្រោមទៀននោះ មានក្រាលស្លឹកចេកផ្ទាល់នឹងដី។ ហើយអាចារ្យបង្វិលឫស្សីទទឹងនោះ ៣ជុំ ទើបដាក់ទៀនសំយុងចុះ ក្រោមឱ្យស្រក់ក្រមួនទៅលើស្លឹកចេក ។ គេទាយទឹកភ្លៀងតាមភាពដែលទៀននោះស្រក់ញាប់ ឬ រង្វើល ហើយគេទាយផលស្រូវក្នុងស្រុក តាមរូបភាពក្រមួនដែលស្រក់ទៅលើស្លឹកចេក ។ លុះ គេជជែកគ្នាអំពីផលដំណាំ តាមទំនាយរួចស្រេចកាលណា ក៏នាំគ្នាយកអំបុក ចេកទុំ បង្អក មនុស្សចាស់ក្មេងតាមទំនៀម ហើយគក់ខ្នងបណ្តើរ បង្អកអំបុកតាមមាត់បណ្តើរ សួរបណ្តើរថា:

- ពេញហើយ ឬ នៅ ?

- នៅ !

គេសួរដូច្នេះគម្រប់ ៣ ដង ទាល់តែអ្នកហារមាត់ស្រែកថា : ពេញហើយ ! ពេញហើយ! ទើបអ្នកឈរមើលទាំងអម្បាលម៉ាននាំគ្នាទទួលព្រមគ្នាឡើងថា : សាធុ ! សាធុ !

នៅកន្លែងខ្លះ គេរចនាបុណ្យនោះឱ្យមានការប្លែកទៅទៀត ដូចជានៅភូមិថ្មី ស្រុករំដួល ខេត្តស្វាយរៀង នៅពេលបុណ្យមានមនុស្ស ៣ នាក់តំណាងបំម្រើព្រះឥន្ទ អ្នកទី ១ សួរថា តើអ្នក ដែលមកប្រជុំនោះមានការអ្វី អ្នកទី២ យកក្រាំងមកចាំកត់សំណូមពររបស់បណ្ដារ ជន ហើយ អ្នកទី ៣ យកផ្លែចេកមួយមកបោះលើទំព័រដែលសរសេរនោះធ្វើជាត្រា ។ គេធ្វើដូច្នេះ ដើម្បីឱ្យទេវបុត្របញ្ជូនទឹកភ្លៀងឱ្យធ្លាក់មកតាមរដូវកាល និងឱ្យព្រះធរណី ប្រទេសកម្ពុជាមាន ជីជាតិល្អផង ។

## ៩. កឋិនទានានិសង្សកថា

(សូមមើល ឃិន វ៉ន ប្រជុំបុញ្ញាប្រវត្តិ ឆ្នាំ ១៩៦៧ ទំព័រទី ៧៦-៧៧)

ជនទាំងឡាយឯណាប្រាថ្នានូវសេចក្ដីសុខ ឱ្យនូវចីវរដើម្បីកឋិនទាន ជនទាំងឡាយនោះ ឯង រមែងរួចចាកទុក្ខក្នុងទេវតា នឹងមនុស្សទាំងឡាយ នឹងមិនកើតក្នុង អបាយទាំងឡាយមាន នរកជាដើម នេះជាផលរបស់កឋិនទាន ជនទាំងឡាយនោះ នឹងបានសោយនូវសម្បត្តិដ៏ជាទិព្វ ក្នុងទេវលោកទាំង ៦ ជាន់ អស់កាលដ៏យូរអង្វែង លុះ ច្យុតអំពីទេវលោកនោះមក នឹងបានជា ស្ដេចក្នុងមនុស្សលោកនេះ , ជាស្ដេចមាន កម្លាំងច្រើនបរិបូណ៌ ដោយរតនៈ ៧ប្រការ នឹងបាន ជាធំក្នុងទ្វីបទាំង ៤ កាលបើនៅ អន្ទោលទៅមកក្នុងមនុស្សលោកនេះ នឹងមិនបានទៅក្នុងអបាយ រមែងកើតក្នុងត្រកូល ទាំងពីរគឺ : ខត្តិយត្រកូល១ ,ព្រាហ្មណៈត្រកូល១ , មិនកើតក្នុងត្រកូល ថោកទាបឡើយ , នេះជាផលរបស់កឋិនទានដែលជនទាំងឡាយបានកសាងហើយ ។

## ១០. អំពីសេនាសនទាន

ពាក្យថា " *សេនាសនទាន* " នេះចែកចេញជា ៣ បទគឺ : **សេនៈ ១បទ , អាសនៈ ១ បទ , ទាន ១ បទ ។ សេនៈ** ប្រែថា ទីដេក , **អាសនៈ** ទីអង្គុយ , **ទានៈ** ប្រែថា ឱ្យ ជូន ថ្វាយ

ប្រគេន . រួមទៅសេនាសនទាន ប្រែថា ថ្វាយ . ប្រគេន . ឬជូន ឱ្យទីដេក ទីអង្គុយ . ឯសេនាសនទាននេះចែកចេញជា ៤ យ៉ាង គឺ :

១- វិហារសេនាសនៈ ២- មញ្ចបីឋសេនាសនៈ

៣- សណ្ឋតសេនាសនៈ ៤- ឱកាសសេនាសនៈ ។

ទី១ ត្រង់ពាក្យថា វិហារសេនាសនៈនោះ ដៅដល់សេនាសនៈធំៗ មានកុដិ . សាលា . វិហារជាដើម ដែលផ្តល់ឱ្យនូវឥរិយាបទទាំង៤ គឺ ដេក . ដើរ ឈរ អង្គុយបាន . បើពោលឱ្យខ្លីមកថា កុដិ . សាលា រោង តូប ថែវ ដែលអាចដេក ដើរ ឈរ អង្គុយបានមិនចង្អៀតចង្អល់ឈ្មោះថា សេនាសនៈទាំងអស់ ។

ទី ២ ត្រង់ពាក្យថា មញ្ចបីឋសេនាសនៈនោះ ដៅដល់សេនាសនៈតូចខ្លះធំខ្លះ ដូចយ៉ាងគ្រែ . តុ-តាំង . កៅអីជាដើម រហូតដល់កប្បិយកុដិ ( ផ្ទះបាយ) នឹងរោងភ្លើង ។

ទី ៣ ត្រង់ពាក្យថា សណ្ឋតសេនាសនៈ . នោះ ដៅដល់កន្ទេល គ្រឿងកម្រាល .មានពូក ខ្នើយ . ចៀមព្រំជាដើម . នឹងដៅដល់គ្រឿងកម្រាលខាងលើ មានមុង . រនាំង . ពិតាន . កួស់ . ឆ័ត្រ . តាំងយូជាដើម ។

ទី ៤ ត្រង់ពាក្យថា ឱកាសសេនាសនៈនោះ ដៅដល់ឱកាសគឺទីវត្តអារាមវត្តទាំងមូល ដូចយ៉ាងទីលាន ឬ បរិវេណចេតិយ ឧទ្យាន . សួនច្បារ . ទីព្រៃសម្រាប់ធ្វើបរិវាសកម្ម ដីស្រែចម្ការ ជាដើម ដែលគេឧទ្ទិសប្រគេនសម្រាប់វត្ត សម្រាប់សង្ឃពុទ្ធសាសនា ។

ឯសេនាសនៈទាននេះ ជាទានដែលជាប់ទាក់ទងព្រះវិន័យ ព្រោះថា ទានដែលមាននៅក្នុងព្រះវិន័យនោះ លោកពោលថាមាន ៤ យ៉ាងគឺ :

ចីវរទាន ១ បិណ្ឌបាតទាន ១

សេនាសនទាន ១ . គិលានភេសជ្ជទាន១ ។

បណ្តាទានក្នុងព្រះវិន័យនេះ មានតែសេនាសនទាននេះហើយ ដែលឆ្នើមមានផលានិសង្សវិសេសជាទីបំផុតជាងទានទាំង ៣ ព្រោះថា សេនាសនទាននេះ ជាទានមានអាយុវែងជាងទានឯទៀតៗ មានសេចក្តីថា បើទានណាមានអាយុវែង គ្រពុកផុយរលួយវិនាសបាក់បែកបាត់បង់ ឯភិក្ខុសាមណេរក៏បានប្រើប្រាស់ ឬ នៅអាស្រ័យរៀន សូត្រអប់រំចិត្តដោយសីល .

សមាធិ . បញ្ញាបានយូរ ទាននោះក៏បានផលានិសង្សច្រើនដល់លោក អ្នកប្រើប្រាស់ផង និងមានផលដល់អ្នកជាម្ចាស់ទានផង ។ ផលនិសង្សនៃការកសាងទីសេនា សនទានមានកុដិ សាលា វិហារជាដើមនេះ បើពោលដោយខ្លីមកគឺ អ្នកជាម្ចាស់ទានដែលបានកសាង ត្រូវតែទទួលសោយនូវសេចក្ដីសុខ-ចម្រើន ទាំងយប់ទាំងថ្ងៃក្នុងលោកនេះ នឹងលោកខាងមុខពុំខាន ។

សឹងមានរឿងមួយជាក់ច្បាស់នៅក្នុងគម្ពីរជាមួយនេះដែរសេចក្ដីថា ក្នុងក្រុងសាវត្ថី មានបុរសម្នាក់ ឈ្មោះ **នន្ទិយៈ** មានសទ្ធាជ្រះថ្លា ជាអ្នកបំម្រើមាតាបិតានឹងភិក្ខុសង្ឃ ។ កាលអំពើសឥតពីមាតាបិតាទៅ នន្ទិយៈ ក៏បានឡើងជាម្ចាស់ទាន ជំនួសមាតាបិតា គាត់ក៏ចាប់ផ្ដើមធ្វើទានដល់ភិក្ខុសង្ឃ ព្រមទាំងឱ្យទានដល់ស្មូមយាចក អ្នកកំសត់ទុគ៌តនិងអ្នកដំណើរ ។ លុះចំណេរមកខាងក្រោយ គាត់បានស្ដាប់ធម្មទេសនាព្រះបរមសាស្ដា ហើយក៏កំណត់ចាំ បាននូវអានិសង្សនៃអាសនៈទាន ( ឱ្យទីនៅអាស្រ័យ ) រួចហើយគាត់ក៏បានធ្វើសាលា ៤ ធ្វើបុណ្យ ៤ ក្នុងមហាវិហារនាព្រៃឥសិតបនៈ ព្រមទាំងបានសាងនូវសេនាសនៈឯទៀត១ មានគ្រែនិងតាំងជាដើម រួចហើយក៏ប្រគេននូវអាវាសទាននោះ នឹងធ្វើទានឯទៀតដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន រួចហើយជ្រួចទឹក ទក្ខិណោទកដាក់លើព្រះហស្ដព្រះបរមសាស្ដា ។ ពេលនោះ មានប្រាសាទទិព្វកើតពីកែវ៧ប្រការកំពស់ឡើងទៅ លើ ១០០ យោជន៍ ទំហំ ១២ យោជន៍ គ្រប់ទិសព្រមទាំងមានពួកនារីទេវធីតា ផុសឡើងក្នុងទេវ លោក ឈ្មោះ **តាវត ឹង្ស** សម្រាប់ **នន្ទិយៈ**ក្នុងពេលដែលនន្ទិយៈ ច្រួចទឹកទក្ខិណោទក ដាក់លើព្រះហស្ដព្រះបរមសាស្ដានោះដែរ។ ថ្ងៃក្រោយមកទៀត ព្រះមហាមោគ្គល្លានត្ថេរបាននិមន្តទៅកាន់ទេវលោក បានទៅឈរជិតប្រាសាទនន្ទិយៈនោះ ហើយបានសួរទេវបុត្រដែលមក ជិត១ លោកថា ប្រាសាទទិព្វដែលពេញទៅដោយពួកស្រីអប្សរនេះ តើប្រាសាទរបស់អ្នកណា ? គ្រា នោះទេវបុត្រទាំងឡាយក្រាបទូលថា បពិត្រលោកម្ចាស់ដ៏ចម្រើន កូនគហបតីឈ្មោះនន្ទិយៈ បានកសាងសាលា វិហារថ្វាយដល់ព្រះបរមសាស្ដាក្នុងព្រៃឥសិបតនៈ . បពិត្រលោកម្ចាស់ដ៏ចម្រើន វិមាននេះហើយដែលជាវិមានកើតឡើងសម្រាប់នន្ទិយៈនោះឯង ។ ចំណែកខាងពួកស្រី អប្សរ កាលឃើញព្រះមហាមោគ្គល្លានហើយ ក៏នាំគ្នាចុះមកពីប្រាសាទ ហើយផ្ដាំព្រះមហាមោគ្គ ល្លានថា បពិត្រលោកម្ចាស់ដ៏ចម្រើន យើងខ្ញុំទាំងឡាយបានកើតឡើងក្នុងទីនេះបម្រុងនឹងបម្រើ **នន្ទិយៈ** តែយើងខ្ញុំទាំងឡាយមិន

បានឃើញ **នន្ទិយៈ** នោះសោះ កាលបើយើងខ្ញុំទាំងឡាយមិន បានឃើញ **នន្ទិយៈ** នោះហើយ រមែងមានសេចក្ដីអផ្សុកក្រៃលែងពេក ហេតុនេះសូមលោកម្ចាស់ និមន្ត ត្រឡប់ទៅវិញប្រាប់ **នន្ទិយៈ**ថាៈឱ្យគាត់លះបង់មនុស្ស សម្បត្តិ ហើយមកកាន់ទិព្វ សម្បត្តិដូចជាការទំលាយនូវភាជនៈ ដី ហើយកាន់យកនូវភាជនៈមាសទៅវិញ គឺថាសូមឱ្យគាត់ អញ្ជើញ មកកើតក្នុងទីនេះឯង ។ លុះព្រះថេរៈនិមន្តត្រឡប់មកពីស្ថានសួគ៌នោះ ក៏បានចូលទៅសួរ ព្រះបរមសាស្ដាថា បពិត្រព្រះអង្គដ៏ចម្រើន ចុះមានជនណាដែលបានធ្វើអំពើល្អមានកសាងកុដិ សាលា វិហារជាដើម តែជននោះនៅរស់ក្នុងមនុស្សលោកនៅឡើយ តើមានសម្បត្តិទិព្វផុះនៅចាំ អ្នកនោះក្នុងទេវលោកដែរឬទេ ? ព្រះសម្ពុទ្ធទ្រង់លាន់ព្រះឱស្ឋថា យី ! អើ រឿងនេះក្រែង បាមោគ្គល្លាន ឯងបានទៅឃើញសម្បត្តិទិព្វផុះក្នុងស្ថានសួគ៌រង់ចាំទទួលនន្ទិយៈ ដោយខ្លួនឯង ទាំងបានសួរបញ្ជាក់ទេវបុត្រនឹងទទួលបណ្ដាំទេវតាទៀតផង មិនដូច្នោះឬ ? ចាំបាឯងមកសួរ តថាគតធ្វើអ្វីទៀត។ ព្រះមោគ្គល្លានទូលថា បពិត្រព្រះអង្គដ៏ចម្រើន រឿងនេះពិតប្រាកដមែន , តពីនោះទៅព្រះអង្គទ្រង់សម្ដែងថា បុណ្យរមែងចាំទទួលដោយរីករាយនូវអ្នកមានបុណ្យដែល បានធ្វើទុកហើយ ដូចជាញាតិរមែងរង់ចាំទទួលដោយរីករាយនូវញាតិដែលត្រូវជាកូន ឬ ជាបងប្អូនដែលព្រាត់គ្នាអស់កាលយូរ ។

## ១១. បុណ្យកតញ្ញូកតវេទី

(សូមមើល **យិន ខន** ឆ្នាំ១៩៦៧ ទំព័រ ៧២-៧៥)

ពាក្យថា " កតញ្ញូកតវេទី " ចែកជាពីរបទគឺ : កតញ្ញូ១បទ , កតវេទី ១ បទ ,កតញ្ញូ ប្រែថា អ្នកដឹងឧបការគុណ ,កតវេទីប្រែថា ដឹងឧបការគុណហើយបានធ្វើតប ។ ជនក្នុងលោកនេះ ទោះបីបុរស ស្ត្រី គ្រហស្ថ បព្វជិត ណាមួយក៏ដោយ ដែលបានទទួលផលប្រយោជន៍ នឹងសេចក្ដីសុខចម្រើនជាដើម អំពីអ្នកដទៃដែលគេបានឧបត្ថម្ភទំនុកបម្រុងផ្គុងផ្គើមខ្លួន ឱ្យបានសម្រេចប្រយោជន៍ណាមួយ ហើយយើងមិនបានបំភ្លេចចោលនូវគុណបំណាច់គឺ សេចក្ដីល្អ ដែលធ្វើដល់យើងនោះ, យើងគប្បីរកឱកាសឆ្លៀតធ្វើបតវិញ ដោយឧត្តមគតិថា អាត្មាអញ ដែលបានទទួលផលប្រយោជន៍ និងសេចក្ដីសុខ-ចម្រើនក៏ដោយ សារតែលោកអ្នកនេះមួយ នោះ

មួយជួយបណ្ដុះបណ្ដាលអញឱ្យរស់រានមានជីវិត ព្រមទាំងបានទទួលសេចក្ដីសុខចម្រើនរហូតមកដល់សព្វថ្ងៃនេះ ដូច្នេះអាត្មាអញ គង់មានថ្ងៃ ខែឆ្នាំណាមួយជាពេលដ៏សមគួរ នឹងធ្វើតបវិញពុំខានឡើយ ។

ប៉ុណ្ណេះជាដើម ទើបបានឈ្មោះថា ជាកតញ្ញូកតវេទី បុគ្គលមែន ! ផ្ទុយទៅវិញបើគ្រាន់តែដឹងៗ ថា អ្នកនេះមួយអ្នកនោះមួយមានឧបការគុណលើអាត្មាអញ ប៉ុន្តែ ការដឹងនេះគ្រាន់តែ ដឹងប៉ុណ្ណោះ . ហើយមិនធ្វើតបវិញក៏គ្មានប្រយោជន៍អ្វីដែរ ។ ដូចយើងដឹងថាការដែលសិក្សា រៀនសូត្រវិជ្ជាក្បួនតម្រាអក្សរសាស្ត្រ ផ្លូវលោក ផ្លូវធម៌ ជាហេតុឱ្យកើតប្រាជ្ញាស្មារតី និងធ្វើខ្លួនឱ្យប្លែកវិសេសជាងជនធម្មតាដូចយ៉ាងលោក អ្នករាជការដែលបានទទួលដំណែងក្រសួងណាមួយហើយបានដល់នូវលាភយសសរសើរ សុខបរិបូណ៌ នឹងលោកអ្នកប្រាជ្ញទាំងឡាយដែលមានឋានន្តរ ស័ក្តិ ជាក្រុមជំនុំ ជារាជាគណៈ មានកិត្តិស័ព្ទកេរ្តិ៍ឈ្មោះពិរោះឆ្ងាយនោះក៏បានមកតែអំពីផលនៃការព្យាយាម រៀនសូត្រនោះឯង. បើមានការដឹងដូច្នេះហើយៗយើងមិនយកចិត្តទុកដាក់រៀនសូត្រទេ ក៏មិនមានប្រយោជន៍អ្វីត្រង់ការដែលដឹងហើយ មិនយកចិត្តទុកដាក់រៀនសូត្រនោះដែរ ។

ម្យ៉ាងទៀតមាតាបិតា ដែលបានចិញ្ចឹមបីបាច់ថែរក្សាទំនុកបម្រុងបុត្រធីតាឱ្យបានរស់រានមានជីវិតដរាបមក ពីតូចដល់ធំបានបង្ហឹកបង្ហឺនទូន្មានប្រៀនប្រដៅ ឱ្យយល់ខុសត្រូវល្អអាក្រក់ជាដើម . ឈ្មោះថា បុព្វការីរបស់បុត្រធីតា ។

បុត្រធីតាណាដែលជាអ្នកមានសន្តានចិត្តល្អ បានព្យាយាមប្រកាសគុណូបការៈដែលមាតាបិតាបានធ្វើហើយដល់ខ្លួន ឱ្យអ្នកដទៃដឹងច្បាស់មិនបំបិទបំបាំងបំភ្លេចចោលបានធ្វើបដិការៈតបស្នងសងគុណក្នុងកាលជាខាងក្រោយ តាមកម្លាំងសទ្ធានឹងចេតនារបស់ខ្លួន . ឯការដែលបុត្រធីតាត្រូវផ្គត់ផ្គង់ទំនុកបម្រុងនឹងសងគុណចំពោះមាតាបិតាវិញនោះ អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម តែងទ្រង់ត្រាស់សរសើរជាអនេកបរិយាយថា : បព្វជិត គ្រហស្ថ បុរស ស្ត្រី ឯណាដែលបានកើតមកក្នុងលោកនេះ ហើយបានធ្វើនូវសេចក្ដីគោរពប្រតិបត្តិលើកតម្កើងនូវមាតាបិតារបស់ខ្លួនឱ្យបានតាំងនៅក្នុងគុណធម៌ និងគុណសម្បត្តិផ្សេងៗ បព្វជិត គ្រហស្ថ បុរស ស្ត្រីនោះបានឈ្មោះថា ជាអ្នកធ្វើ លើកំពូលនៃសេចក្ដីចម្រើនយ៉ាងខ្ពង់ខ្ពស់បំផុត ហើយបានឈ្មោះថា

ជាកតញ្ញូកតវេទី បុគ្គលផង. ជាពិសេសអ្នកនោះឯងគង់នឹងបានសម្ពុជប្រទះនូវប្រយោជន៍នឹងសេចក្ដីសុខ-ចម្រើន ក្នុងលោកនេះ និងបរលោកពុំខានឡើយ ។

តាមពុទ្ធឱវាទទ្រង់ត្រាស់សម្ដែងថា មាតាបិតាត្រូវទំនុកបំរុងបុត្រធីតា ដោយស្ថានធម៌ ៥យ៉ាង ចំណែកបុត្រធីតាវិញ ក៏ត្រូវទំនុកបំរុងមាតាបិតាវិញដោយធម៌ ៥ យ៉ាងដែរ (សូមមើល **"ប្រជុំកងធម៌"** និង **"សិក្ខាបទមនុស្សល្អ"** របស់លោកអគ្គបណ្ឌិត្យ **ប៊ុត សាវង្ស** ព.ស ២៥៤៥ ) ។

# ១២. បុណ្យបញ្ចុះសីមា

(សូមមើល យិន វន ១៩៦៧ ទំព័រ ៩៣-៩៦)

១-បុណ្យបញ្ចុះសីមានេះ គឺជាបុណ្យសេនាសនៈទាន ឬថាបុណ្យសម្ពោធិ រោងឧបោសថ ខ្លះថាបុណ្យឆ្លងព្រះវិហារ . បើនិយាយអំពីលក្ខណៈបុណ្យវិញមិនជា វិសេសជាងបុណ្យដទៃៗទេ ព្រោះជាបុណ្យក្នុង ក្របខ័ណ្ឌបច្ច័យ ៤ ។

ប៉ុន្តែដែលនាំឱ្យពុទ្ធបរិស័ទឈ្ងរ ទៅចោមរោមបុណ្យនោះ មកអំពី យូរ ៗ ទើបមានធ្វើបុណ្យនេះម្ដង យូរស្មើនឹងអាយុរោងឧបោសថគឺព្រះវិហារ ទាល់តែព្រះវិហារនោះ ចាស់បាក់បែកប្រើការមិនកើត រុះរើធ្វើថ្មីទៀតទើបមានបុណ្យបញ្ចុះសីមាជាថ្មីម្ដង ។ ជួនកាលមិនបាច់បញ្ចុះសីមាទៀតក៏មាន បើធ្វើចំកន្លែងចាស់ គ្រាន់តែធ្វើបុណ្យ សម្ពោធិឆ្លងព្រះវិហារប៉ុណ្ណោះ ។ បើធ្វើចំកន្លែងចាស់ហើយ ចង់ធ្វើបុណ្យបញ្ចុះសីមាជាថ្មីទៀតក៏បាន ។ ចំពោះវត្តដែលកសាងថ្មី ត្រូវតែធ្វើបុណ្យបញ្ចុះសីមានេះជាការចាំបាច់ ដើម្បីឱ្យមានព្រំដែនសម្រាប់សង្ឃ ធ្វើសង្ឃកម្ម ផ្សេងៗ មានឧបោសថកម្មជាដើម ។

មយ៉ាងទៀត ដែលនាំឱ្យពុទ្ធបរិស័ទចូលចិត្តនោះព្រោះធ្លាប់ឮពាក្យតាំងពីព្រេងនាយមកថា បើអ្នកណាបានទៅធ្វើបុណ្យបញ្ចុះសីមាគ្រប់ ៧វត្ត នឹងរួចកម្មពៀរវេរាទាំងអស់ទោះមានធ្វើកម្មអកុសលយ៉ាងណា ក៏កម្មនោះទៅជាអហោសិកម្ម។ បុណ្យបញ្ចុះសីមាជួយមិនទៅឱ្យទៅកើតក្នុងអបាយភូមិអស់៥០០ជាតិ ។ ស្គាល់តែសុខចម្រើន ក្នុងសុគតិភពប្រាថ្នាអ្វីបានសម្រេចដូចបំណងមានប្រាថ្នាឱ្យមានរូបល្អ មានចិត្តមុតភ្លា ហាន មានសក់ល្អ មានភ្នែកភ្លឺ មានប្រាជ្ញាច្រើន ជាដើម ។

អាស្រ័យហេតុដូចខាងលើនេះ ទើបពុទ្ធបរិស័ទភាគច្រើនជ្រះថ្លាចំពោះបុណ្យសីមានេះណាស់ ។

តាំងពីសម័យដើមរហូតបច្ចុប្បន្ន ប្រជាពលរដ្ឋខ្មែរ ស្រឡាញ់បុណ្យនេះណាស់ តាំងពីថ្នាក់ដឹកនាំរដ្ឋកំពូល មានព្រះមហាក្សត្រ ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា នាយករដ្ឋមន្ត្រី រហូតដល់មហាជនទាំងឡាយ ។

## កម្មវិធី

## សម្តេច នាយករដ្ឋមន្ត្រី អញ្ជើញចុះ ទៅមូលដ្ឋាន

- ១/៣ /០៣ :បញ្ចុះខណ្ឌសីមា វត្តវៃឡវ័ន្ត ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ
- ២/៣ /០៣ :ពិនិត្យការដ្ឋានសាងសង់ស្ពានស្រុកឆ្លូងខេត្តក្រចេះ
- ៥/ ៣/០៣ :ប្រកាសសម្ពោធ បរិស្ថានអាស៊ាន ២០០៣ ខេត្តសៀមរាប
- ៦/៣/០៣ :សម្ពោធ មន្ទីរពេទ្យបង្អែក ស្រុកប្រត្តិបត្តិក្រឡាញ់ ខេត្តសៀមរាប
-១១/៣/០៣ :សម្ពោធសមិទ្ធិផល វត្តមុនីរវសិទ្ធិវង្ស ឃុំ ព្រែកត្មៅ ស្រុកពញាឮ ខេត្តកណ្តាល
-១៣/៣/០៣ :បញ្ចុះខណ្ឌសីមា វត្តបាកាន ឃុំត្រពាំងជង ស្រុកត្រពាំងជង ខេត្តពោធិសាត់
-១៥/៣/០៣ :បញ្ចុះខណ្ឌសីមា វត្តត្បែងខ្ពស់ ឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង
-១៦/៣/០៣ :បញ្ចុះខណ្ឌសីមា វត្តចកអណ្តែត ឃុំដូង ស្រុកបាទី ខេត្តតាកែវ
-១៨/៣/០៣ :បញ្ចុះខណ្ឌសីមា វត្តច្រកស្វាយ ឃុំស្តៅកោង ស្រុកបាភ្នំ ខេត្តព្រៃវែង
-២០/៣/០៣ :សម្ពោធ វិទ្យាល័យសិលាវេទី តាត-ឈន់ ស្រុកឆ្លូង ខេត្តក្រចេះ
-២៣/៣/០៣ :បញ្ចុះខណ្ឌសីមា វត្តដូងកែវមុនី ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ
-២៥/៣/០៣ :សម្ពោធវិទ្យាល័យ ហ៊ុន សែន - ស្តន់ ស្រុកជើងព្រៃ ខេត្តកំពង់ចាម
-២៧/៣/០៣ :បញ្ចុះខណ្ឌសីមា វត្តឫស្សីស្រុក ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល
-២៩/៣/០៣ :សម្ពោធស្ពាន ពង្រ ស្រុកកោះសូទិន ខេត្តកំពង់ចាម
-៣១/៣/០៣ :បញ្ចុះខណ្ឌសីមា វត្តឧទុម្ពា ហៅព្រៃទ័ព ឃុំព្រះស្តេច ស្រុកព្រះស្តេច ខេត្តព្រៃវែង

## ខែ មេសា:

-១/៤/០៣ :សម្ពោធសមិទ្ធិផល ឃុំបានកាម ស្រុក ព្រៃកប្បាស ខេត្តតាកែវ

-២/៤/០៣ :បញ្ចុះខណ្ឌសីមា វត្តបញ្ញាជី ឃុំ ត្បូងក្រពើ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ

-៣/៤/០៣ :បញ្ចុះខណ្ឌសីមា វត្តកងចក្របឹងត្រាប ឃុំសូរគង ស្រុកកងមាស ខេត្តកំពង់ចាម

-៤/៤/០៣ :សម្ពោធស្ពាន ពាមទេរ ស្រុកឆ្លូង ខេត្តក្រចេះ

-៥/៤/០៣ :បញ្ចុះខណ្ឌសីមា វត្ត គិរីវង្គត ( ភ្នំរាប់បាត្រ ) ឃុំអណ្តូងស្នាយ ស្រុក រលាប្អៀរ ខេត្តកំពង់ឆ្នាំង

-៧/៤/០៣ :បញ្ចុះខណ្ឌសីមា វត្តជ្រោយឧត្តម ឃុំព្រៃកតាសរ ស្រុកពារាំង

-៨/៤/០៣ :បញ្ចុះខណ្ឌសីមា វត្តប្រាសាទវដ្ដី ឃុំព្រៃកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម

-៩/៤/០៣ :បញ្ចុះខណ្ឌសីមា វត្តវាលុកការាម និងសមិទ្ធផល ឃុំទ្រា ស្រុកសំរោង ខេត្តតាកែវ

-១០/៤/០៣:បញ្ចុះខណ្ឌសីមា វត្តព្រះដាក ឃុំព្រះដាក ស្រុកបន្ទាយស្រី ខេត្តសៀមរាប

-១២/៤/០៣:បញ្ចុះខណ្ឌសីមា វត្ត ថ្មី ( វត្តពាមអំបិល ) ឃុំសង្កែ ស្រុករំដួល ខេត្តស្វាយរៀង

-១៦/៤/០៣:បញ្ចុះខណ្ឌសីមា វត្តចេតីយថ្មី ឃុំវិហារហ្លួង ស្រុកពញាឮ ខេត្តកណ្តាល

-១៩/៤/០៣:សម្ពោធសមិទ្ធផល វត្តជ័យគីរី និងផ្លូវលំ១ខ្សែនៅឃុំហាន់ជ័យ ស្រុកកំពង់សៀម ខេត្តកំពង់ចាម

-២១/៤/០៣:សម្ពោធដាក់ឱ្យប្រើប្រាស់ផ្លូវលំ ២០ គ.ស និងសាលារៀន ៥ ខ្នង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

-២២/៤/០៣:បញ្ចុះខណ្ឌសីមា វត្តពោធិសុវណ្ណរាម ហៅត្រពាំងល្ពៅ ឃុំជយោ ស្រុកចំការលើ ខេត្តកំពង់ចាម

-២៣/៤/០៣:បញ្ចុះខណ្ឌសីមា វត្តសំរោង ឃុំដីជុំ ស្រុកមេសាង ខេត្តព្រៃវែង

-៣០/៤/០៣:បញ្ចុះខណ្ឌសីមា វត្ត អូរមុនី ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង

## ខែ ឧសភា

-៥/៥/០៣ :សម្ពោធ វិទ្យាល័យ ហ៊ុន សែន - កណ្តៀង ឃុំកណ្តៀង ស្រុកកណ្តៀង ខេត្តពោធិសាត់

-៦/៥/០៣ :សម្ពោធអគារមន្ទីរពេទ្យ ខេត្តកំពង់ធំ

-៨/៥/០៣ :បញ្ចុះខណ្ឌសីមា វត្តឧត្តមព្រឹក្សា និងចេ្សរជ័រកូនកៅស៊ូ នៅស្រុកពញាក្រែក ខេត្តកំពង់ចាម

-១០/៥/០៣:បញ្ចុះខណ្ឌសីមា វត្តអង្គប្រិយ៍ សិរីមានជ័យ ឃុំកំពង់សំរោង ស្រុកកំពត ខេត្តកំពត

-១២/៥/០៣:សម្ពោធអនុវិទ្យាល័យ ឈ្វាំង ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្ដាល

-១៣/៥/០៣:បញ្ចុះខណ្ឌសីមា វត្តពោធិវង្សី និងចេ្សរជ័រកូនកៅស៊ូ នៅចំការកៅស៊ូជប់ ស្រុកត្បូងឃ្មុំ

-១៥/៥/០៣:បញ្ចុះខណ្ឌសីមា វត្តសន្ទរវង្សី ឃុំខ្ចបតាងួន ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

-២០/៥/០៣:សម្ពោធ វិទ្យាល័យ ហ៊ុន-សែន-កោះអណ្ដែត ឃុំរមេញ ស្រុកកោះអណ្ដែត ខេត្តតាកែវ

-២៥/៥/០៣:បញ្ចុះខណ្ឌសីមា វត្តត្រពាំងអំពិល ឃុំជ្រៃវៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម

-២៩/៥/០៣:បញ្ចុះខណ្ឌសីមា វត្តព្រៃពោន ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង

**ខែ មិថុនា**

-១០/៦/០៣:បញ្ចុះខណ្ឌសីមា វត្តប្រើសមាស ឃុំត្រប់ ស្រុកបាធាយ ខេត្តកំពង់ចាម

២- បុណ្យបញ្ចុះសីមានេះ បើនិយាយតែពិធីដែលមានក្នុងវិន័យពុទ្ធានុញ្ញាត នោះគ្រាន់តែព្រះសង្ឃពិនិត្យនូវនិមិត្តសីមាឱ្យឃើញថា វៀរចាកវិបត្តិ ១១ យ៉ាង និងប្រកបដោយសម្បត្តិ ៣ យ៉ាង ហើយសូត្រដកសីមាចាស់ និងសូត្រសន្មតសីមាថ្មីជាកិច្ចចប់បុណ្យបញ្ចុះសីមា។

ប៉ុន្តែបុរាណបណ្ឌិតទាំងឡាយបានបង្កើតពិធីផ្សេងៗ ជាបរិវារបុណ្យនោះយ៉ាងច្រើនមកទៀត ដូចជា ជីករណ្ដៅ រកដុំថ្ម ជានិមិត្តសីមា យកមកបិទទឹកមាសស្រោក់ខ្សែ ចងនាំគ្នាសែងហែប្រទក្សិណព្រះវិហារ យកទៅវេរប្រគេនព្រះសង្ឃ ហើយមានធ្វើកាំបិតសម្រាប់ពិធីកាត់ខ្សែដែលចងថ្មឱ្យធ្លាក់ទៅក្នុងរណ្ដៅហៅថា កាត់ឫសសីមា ។

កិច្ចពិសេសដែលគួរពិចារណានោះគឺ តាំងពីថ្ងៃចូលបុណ្យគេនាំគ្នាយកវត្ថុគ្រប់យ៉ាងតាមបំណងរបស់គេ ដូចជាសក់ក្បាល កាំបិត ម្ជុលចេស មាសប្រាក់ ជាដើមទៅ ដាក់ក្នុងរណ្តៅសីមា ហើយគេជឿតៗគ្នាមក ថា " បើចង់ឱ្យមានសក់ល្អ គេយកសក់ទៅ ដាក់ក្នុងរណ្តៅសីមា ចង់ឱ្យមានចិត្តក្លាហានចិត្តមុតគេសម្រក់ ឈាមដាក់ក្នុងរណ្តៅ ឬ ដាក់គ្រឿងអាវុធមានកាំបិត ដាវ លំពែង ជាដើម ។ល ។

ការយល់ហើយធ្វើដូច្នេះសមហេតុផលម្យ៉ាងដែរ មិនអាចបដិសេធថា ឥតផល នោះទេ ព្រោះមានចេតនាជាបុណ្យកុសលទៅហើយ ប្រាថ្នាអ្វីក៏បានដូចប្រាថ្នា តែយូរ និងឆាប់ប៉ុណ្ណោះ ។ ប៉ុន្តែការធ្វើបុណ្យប្រាថ្នាដូច្នេះនៅក្នុងអំណាចតណ្ហាមិនងាយនឹង រើខ្លួនឱ្យរួចពីវដ្តសង្សារបានទេ ។ ការធ្វើដូច្នេះក៏គ្មានក្នុងគម្ពីរត្រឹមត្រូវណាមួយក្នុងព្រះត្រៃបិដកថា ឱ្យយកអ្វីៗទៅដាក់ក្នុងរណ្តៅសីមានោះទេ គឺគ្រាន់តែជាទំនៀមទម្លាប់ ធ្វើតៗគ្នា មកប៉ុណ្ណោះ ។

៣- បុណ្យបញ្ចុះសីមា គឺសន្មតសីមានេះមានតាំងពីពុទ្ធកាលមក , ប៉ុន្តែគ្មានធ្វើគ្រប់បែបយ៉ាងដូចសព្វថ្ងៃនេះទេ គ្រាន់តែព្រះសង្ឃធ្វើសង្ឃកម្មសន្មតឱ្យដឹងព្រំដែន សីមាត្រឹមណាៗ សម្រាប់រូបរួមធ្វើសង្ឃកម្ម ប៉ុណ្ណោះ ។

ហេតុដែលបញ្ចុះសីមា គឺសន្មតសីមានេះកាលជំនាន់ព្រះសម្មុទ្ធគង់ព្រះជន្មនៅ ពួកឆព្វគិយភិក្ខុនាំគ្នា ធ្វើឧបោសថកម្មតែក្នុងពួកភិក្ខុជាបរិវាររបស់ខ្លួន ខ្លួនបែកគ្នាព្រោងព្រាតក្នុងអាវាសវត្តមួយៗ ធ្វើឧបោសថកម្ម បួនប្រាំកន្លែង ។

## ១៣. ពិធីបុណ្យឆ្លងផ្សេងៗ

(សូមមើល ញាណ ភឿន និង ម៉ម ឆៃ លំអានទំនៀមខ្មែរបុរាណ ព.ស២៥៤៦ គ.ស២០០២ ទំព័រ៩៤-៩៥)

បុណ្យឆ្លងថ្នល់ ស្ពាន សាលាឆទាន ដើមពោធិ៍ អណ្តូង ស្រះជាដើម ។ល ។ ពិធីទាំងនេះមុនដំបូងអាចារ្យត្រូវរៀបចំពិធីក្រុងពលីជាចាំបាច់ រួចបន្តធ្វើពិធីផ្សេងៗ តាមទម្លាប់នៃបុណ្យ ។ តែចាំបាច់ព្រះសង្ឃពេលឆ្លងត្រូវសូត្រ ពហុទេវា ដារឆ្លង ។

ពិធីឆ្លងនេះគឺធ្វើតាមលំអាននាងវិសាខា មានការប្រគេនភេសជ្ជៈ អង្គាសចង្ហាន់រាប់បាត្រ ប្រគេនត្រៃចីវរ សាដកទៀតផង ។

យើងបានឮគេដំណាលថា : បើដាំដើមពោធិ៍មិនឆ្លងនឹងកើតជាសត្វរាជសីហ៍ រកស៊ីនៅក្រោម ដើមពោធិ៍នោះ ។ បើធ្វើស្រះ អណ្ដូង មិនឆ្លង កើតជាតិក្រោយគ្មានទឹកផឹក ។ល។

ពាក្យនេះក្លាយទៅជាជំនឿប៉ុន្តែ ជំនឿនោះមិនសមហេតុផលសោះទេ ព្រោះបុណ្យកើតដោយ ចេតនា ៣ គឺ :

**បុព្វចេតនា** ត្រេកអរជ្រះថ្លាមុននឹងឱ្យ

**មុញ្ចនចេតនា** ត្រេកអរជ្រះថ្លាក្នុងពេលកំពុងឱ្យ

**អបរាបរចេតនា** ឱ្យរួចហើយត្រេកអរជ្រះថ្លាជានិច្ចត្រូវតែនឹក ។

ដូច្នេះការធ្វើបុណ្យអ្វីមួយ បុណ្យតែងសម្រេចដោយចេតនា ៣ នេះស្រេចទៅហើយ។ មិនមែនបានបុណ្យព្រោះតែឆ្លង បើមិនបានឆ្លង ថាបែរជាមិនបានបុណ្យ ថែមទាំងបានបាបទៀតផងនោះទេ ។ ប៉ុន្តែការធ្វើអ្វីមួយចុងក្រោយត្រូវធ្វើបុណ្យឆ្លងនោះ ព្រោះចង់បន្ថែមកុសលឱ្យឫតតែចម្រើនឡើងជាគ្រឿងរំឭកបញ្ញាស្មារតីបង្កើននូវអនុស្សតិនោះឯង ។

## ១៤. ប្រវត្តិលោកអភិធម្ម និងលោកមាតិកា (ពេលដង្ហែសព)

(សូមមើល ញាណ គឿន និង ម៉ម រៃ លំអានទំនៀមទម្លាប់បុរាណ ២០០២ ទំព័រ ១១០-១១១)

មានរឿងនិទានថា ក្នុងអតីតសម័យព្រេងនាយ មានព្រះរាជាមួយអង្គទ្រង់សោយរាជ្យនៅនគរ **ឈោងស្លោ** (ស្យាមប្រទេស) ។ ព្រះរាជាអង្គនេះទ្រង់មានព្រះរាជហឫទ័យជ្រះថ្លានិងព្រះពុទ្ធសាសនាយ៉ាងក្រៃលែង តែងធ្វើបុណ្យទានជាអចិន្ត្រៃយ៍ ហើយទ្រង់មានព្រះទ័យរាប់អានស្និទ្ធស្នាល និងព្រះសង្ឃដែលគង់នៅវត្តក្បែរព្រះបរមរាជវាំង ។ ទ្រង់តែងផ្គត់ផ្គង់ព្រះសង្ឃដោយខាទនីយាហាររាល់ថ្ងៃពុំដែលខាន ។ លុះកាលក្រោយមក ព្រះរាជាអង្គនេះ ទ្រង់ប្រឈួនយ៉ាធ្ងន់ ពេទ្យហ្លួងនានា ដែលអញ្ជើញមកព្យាបាលជម្ងឺព្រះអង្គក៏ពុំអាចរកថ្នាំណាមកទ្រទ្រង់ជីវិតព្រះអង្គបាន ទ្រង់ក៏សោយទីវង្គតទៅ ។ នាម៉ឺនសព្វមុខមន្ត្រី ក៏ជំនុំគ្នានឹងរៀបចំដង្ហែសពនោះឱ្យសមតាមឋានៈព្រះអង្គ ។ និយាយពីភិក្ខុ ៥ អង្គដែលទ្រង់តែងតែប្រគេននូវចង្ហាន់ជានិច្ចកាល នោះក៏ប្រជុំប្រឹក្សាថា (ព្រះរាជាអង្គនេះកាលទ្រង់គង់ព្រះជន្មាយុនៅឡើយ ព្រះអង្គតែងតែផ្គត់ផ្គង់រូបយើងទាំង ៥ នេះខ្លាំងណាស់ ឥឡូវនេះព្រះអង្គចូលទីវង្គតហើយ តើយើងរាល់គ្នា

ត្រូវធ្វើកិច្ចដូចម្តេច ដើម្បីជាសក្ខីភាពនៃការតបស្នងសងគុណព្រះអង្គនៅពេលដង្ហែព្រះសពចេញទៅ ប្រទក្សិណទីក្រុងដោយយើងទាំង៥ រូបជាអ្នកចម្រៀងស្រាប់ គួរនិមន្តលោកគ្រូចៅអធិការឱ្យគង់នៅ មុខព្រះសព ហើយចម្រើនធម៌ **អភិធម្មមាតិកា** ឯ ៤ រូបទៀតគួរនៅគង់អមព្រះសព ហើយចម្រើន **សុត្តន្តមាតិកា** ចុះ ។ គិតគ្នាស្រេចហើយ លុះដល់ថ្ងៃកំណត់ដង្ហែព្រះសព ព្រះសង្ឃទាំង ៤ អង្គក៏នាំគ្នាចូលទៅសុំពួកនាម៉ឺនចាត់ការបុណ្យ ដើម្បីឱ្យបានទៅអង្គុយហែតាមសេចក្តីប្រឹក្សាគ្នាមកនោះ ។ពួកមន្ត្រីចាត់ការបុណ្យក៏យល់ព្រមតាមការសុំរបស់ព្រះសង្ឃ ៥អង្គ។ ហើយភាវនា ធម៌រហូតដល់កន្លែងបូជាសព ។

តាមរឿងដូចបានពោលខាងលើនេះ ទើបកម្មវិធីបុណ្យខ្មោចមានលោកអភិធម្ម ១ អង្គ និងលោកមាតិកា ៤ អង្គ ជាប់ជាតំណរហូតមក ។

## ១៥. ប្រវត្តិទាក់ទងនិងទៀនកាល្ប នៅពេលមានមនុស្សស្លាប់

(សូមមើល ញាណេ ភឿន និង ម៉ម ឆៃ លំអានទំនៀមទម្លាប់បុរាណ ២០០២ ទំព័រទី ១១១-១១៤)

អតីតកាល មានបុរសម្នាក់ជាមនុស្សត្រឹមត្រូវណាស់ បើទៅកាន់ទីជំនុំចំណោមឯណា គេតែងរាប់រកទុកជាមនុស្សមានប្រាជ្ញាអ្នកដឹងខុសត្រូវ ។ អ្នកភូមិផងរបងជាមួយ បើមានការអ្វីធំដុំតែងតែអញ្ជើញបុរសនោះមកជាប្រធាន ដើម្បីសួរជាយោបល់ឱ្យជួយអារកាត់រឿងដែលជាប់ជំពាក់ស្មុគស្មាញ ។

ថ្ងៃមួយក្នុងរដូវប្រាំង មាណពនោះបបួលបុរសពីរនាក់ទៀតដែលនៅផ្ទះក្បែរគ្នា ទៅរកឃ្មុំយកក្រមួននិងទឹកមកលក់ដើម្បីបំពេញសេចក្តីខ្វះខាតក្នុងគ្រួសារ ។ បុរសទាំងពីរនាក់នោះក៏ស្រុះ ស្រួល សុខចិត្តទៅជាមួយគ្នា តែបណ្តាអ្នកទាំងពីរនាក់នោះ អ្នកមួយជាមនុស្សចេះស្តាប់បង្គាប់ ឯអ្នកមួយទៀតរបឹងប្ញងរូសមិនសូវចេះស្តាប់ចេះត្រង់ត្រាប់ពាក្យប្រៀនប្រដៅទេ ។

លុះដើរដល់ព្រៃ ឃើញខ្ទមអ្នកតាមួយដែលពួកថ្មើរព្រៃតែងបូជា ដើម្បីសុំបើកព្រៃរួចទើបចូលទៅ ។ មកដល់ជិតកន្លែងអ្នកតានោះ ទើបអ្នកទាំង ៣ នាក់ នាំគ្នាធ្វើជំរកឈប់សម្រាកបន្តិចសិនយកកម្លាំង នឹងដើរទៅមុខទៀត ។ ក្នុងថ្ងៃនោះគេរកបានឃ្មុំមួយសំបុកមានចំនួន ១២ តម្លឹង ហើយត្រឡប់មកជំរកវិញ នាំគ្នាដាំបាយដុតត្រីបរិភោគ ។ តែមុនបរិភោគគេចាប់បាយ

និងត្រីខ្លះដាក់លើស្លឹកឈើ ថ្វាយអ្នកតាសុំសេចក្ដីសុខសប្បាយ និងសុំឱ្យទៅរកឃ្មុំ បានប្រទះដូចក្ដីប្រាថ្នា។ ឯបុរសម្នាក់ទៀតជាអ្នករឹងរូស នោះឃើញពីរនាក់ សែនអ្នកតាក៏នឹកខ្ចាញ់ក្នុងចិត្តតែមិនចេញស្ដី ។ លុះព្រឹកឡើងមុននឹងចេញទៅរកឃ្មុំទៀត គេនាំគ្នាដាំបាយទទួលទាន ហើយចាប់បាយ បេះត្រីដាក់ថ្វាយអ្នកតាដូចថ្ងៃមុនទៀត ។ បុរសរឹងរូសទើសចិត្តណាស់ទ្រាំអត់ពុំបានក៏និយាយគំរោះថា " **មិនដឹងជាថ្វាយស្អី ក៏ថ្វាយម្ល៉េះទេ ម្ហូបអាហារតិចផង យកទៅដាក់ចោលទៀត តើដាក់ឱ្យអាណាស៊ី** " ថាហើយក៏ងើបដើរទៅយកបាយរុកបញ្ចុកមាត់អ្នកតា ហើយនិយាយបែបចង់បញ្ឆោះឱ្យអ្នកតាដែលដាក់ថ្វាយនោះផងថា " **ហ៎ ស៊ីទៅអ្នកតា ពីមុនថាគេមិនដាក់ដល់មាត់ ឥឡូវអញដាក់ដល់មាត់ហើយម្ដេចក៏មិនស៊ីទៅ ឃើញតែទុកចោលឱ្យស្រមោចរោមម្ដងនេះតែ មិនស៊ីឱ្យអញឃើញទេ លើកក្រោយអញលែងឱ្យទៀតហើយ** "។ អ្នកទាំងពីរ ទៀតឃើញ បុរសនោះធ្វើមិនគប្បីក៏នៅស្ងៀម រួចបបួលគ្នាចេញដំណើរទៅ ។ ក្នុងថ្ងៃនោះ គ្មានរកបានឃ្មុំមួយ សំបុកសោះ ព្រោះបុរសរឹងរូសនោះ វល់តែចុកពោះរមួលខ្លួនដើរមិនរួច ទាល់តែសែងរហូតដល់ជំរកវិញ ។ មកដល់ហើយនាំគ្នាធ្វើម្ដេច ក៏ជម្ងឺនោះមិនស្រាកស្រាន្តឡើយ ។ លុះដល់កម្លាំង កាន់តែតិចទៅ បុរសឈឺនោះនិយាយនឹងសម្លាញ់ទាំងពីរថា : " **ចូរឯងចែកក្រមួនមួយភាគផង ត្បិតខ្ញុំក៏បានទៅរកជាមួយដែរ** " ។

បុរសពីរនាក់ឆ្លើយថា" **ឯងចង់បានក្រមួនយកមកធ្វើអ្វី បើឯងជិតស្លាប់ទៅហើយយ៉ាងនេះ** " ។ បុរសឈឺនោះឆ្លើយវិញថា ខ្ញុំយកទៅបានឱ្យតែឯងចែកមកឆាប់ឡើង បើឯងមិនឱ្យខ្ញុំទេ តើខ្ញុំបានអ្វីបំភ្លឺផ្លូវចេញពីព្រៃនោះរួច ។ ឮដូច្នោះ បុរសសម្លាញ់ពីរនាក់ ក៏នាំគ្នាថ្លឹងក្រមួនចែកជាបីភាគស្មើគ្នា ហើយយកស្លឹកឬស្សីងាប់ប្រវែងបង្គុយលលក ធ្វើជាប្រឆេះ ហើយយកក្រមួនមួយចំណែកទម្ងន់ប្រហែលជា ៤ តម្លឹង លៃជា៤ភាគ យកពាភាគលញ់ធ្វើទៀនគោល។ ក្រមួនសល់មួយភាគទៀត គេយកស្លឹកត្រែងស្ងួតមកធ្វើជាប្រឆេះ លញ់ទៀនរាយ ៤ ទៀន ហើយកាប់មែកឈើដាក់គងលើមាត់ត្រឡោក ។ លុះអុជទៀនរួច ក៏អោននិយាយដាក់ត្រចៀក បុរសដែលឈឺនោះថា " **នែសម្លាញ់ ចំណែកក្រមួនរបស់ឯង យើងធ្វើជាទៀនអុជឱ្យឯង ចូលឯងយកទៅតាមខ្លួនគ្រាន់បានបំភ្លឺផ្លូវចេញពីព្រៃនេះទៅចុះ** " បុរសឈឺទទួលថា អឺ ហើយក៏ដាច់ ខ្យល់ស្លាប់ទៅ ។

បុរសជាមិត្តក៏នាំគ្នារកអុសភ្លើងមកដុតខ្មោចនោះ ហើយនាំគ្នាវេចខ្ចប់ធាតុយកមកឱ្យប្រពន្ធ ដោយប្រាប់តាមដំណើរតាំងពីរឿងឈើ ដល់រឿងចែកក្រមួន ។ តែមកដល់ត្រង់នេះប្រពន្ធនៃសពមិនយល់ព្រមដោយអាងថា : ប្ដីខ្លួនស្លាប់ទៅហើយតើអាចយកក្រមួនទៅផងម្ដេចបាន ? បុរសសម្លាញ់ពីរនាក់ពន្យល់យ៉ាងដូម្ដេចនាងនោះក៏នៅតែមិនព្រម ទទួចយកតែចំណែកក្រមួនតាំងពីថ្ងៃរហូតដល់យប់ ហើយចូលទៅដេករៀង១ខ្លួនទៅ ។ និយាយពីប្រពន្ធរបស់បុរសស្លាប់ លុះដេកលក់ទៅ ក៏យល់សប្ដិឃើញប្ដីកាន់ទៀនដើរចូលមក ។ នាងស្រែកទាំងអរផងថា "**អ្នកអើយគេមកប្រាប់ខ្ញុំថា អ្នកឯងស្លាប់ទៅហើយ ថែមទាំងបានចែកក្រមួនទៅអ្នកផងឥឡូវ មានស្លាប់ឯណា ? អ្នកមកវិញហើយតើ** " ឯខ្មោចនោះឆ្លើយវិញថា " **បងស្លាប់មែនហើយបងបាន ក្រមួនដែលគេចែកឱ្យនោះ ធ្វើជាទៀនអុជរកផ្លូវចេញមកផ្ទះ កុំអីមិនដឹងជាវង្វេងទៅណាទេ** ។ ប្រពន្ធឮដូច្នេះក៏ស្រវាឱបប្ដីភ្ញាក់ទាំងខ្លួនឡើង ទើបដឹងច្បាស់ថាខ្លួនយល់សប្ដិ ។ លុះព្រឹក ឡើង ទៅប្រាប់បុរសទាំងពីរតាមដំណើរយល់សប្ដិ ហើយក៏ឈប់ប្រកាន់ឈ្លោះទៀតទៅ ។

ដោយហេតុមានរឿងដូច្នេះហើយ ទើបបុរាណប្រកាន់ជឿថា បើមនុស្សណាជិតស្លាប់គេត្រូវតែធ្វើទៀនកាល្ប អុជដើម្បីឱ្យខ្មោចបានភ្លឺសម្រាប់បំភ្លឺផ្លូវទៅរកឋានសុខ ។

## ១៦. បុណ្យភ្ជុំបិណ្ឌ

( សូមមើល យិន វន ប្រជុំបុញ្ញប្រវត្តិ ១៩៦៧ ទំព័រ ៥២-៥៤ និងវប្បធម៌ទូទៅ ១៩៩៨ ធ-សោ វប្បធម៌អរិយធម៌ខ្មែរ ១៩៨៨ )

បុណ្យភ្ជុំបិណ្ឌ ដែលយើងគេបានធ្វើជាប់ទាក់ទងត១គ្នារហូតមកទល់សម័យសព្វថ្ងៃនេះ គឺមកអំពីមាននិទាន មួយពោលទុកមកថា : ក្នុងកាលនោះមានពពួកញាតិរបស់ពួកព្រះរាជា ព្រះនាមព្រះបាទ **ពិម្ពិសារ** មួយក្រុម បានបំពេញទានមានវត្ថុមិនបរិសុទ្ធស្អាតល្អ (គឺស៊ីបាយមុនលោក) លុះដល់ពេលស្លាប់ ទៅកាន់លោកខាងមុខ ក៏ទៅចាប់កំណើតកើតក្នុងបេតវិស័យ "**ប្រេត**" សោយទុក្ខវេទនាជាយូរអង្វែង លុះដល់ព្រះ **សម្ពុទ្ធ**ព្រះនាម **កកុសន្ធោ** បានត្រាស់ដឹងឡើងក្នុងលោកពួកប្រេតក៏នាំគ្នាសួរថា បពិត្រព្រះអង្គដ៏ ចំរើនចុះយើងខ្ញុំកាលណានឹងបានអាហារ

បរិភោគ ? ព្រះសម្ពុទ្ធ ព្រះនាមកុក្កុសន្ធោទ្រង់ត្រាស់ថា ចាំសួរព្រះពុទ្ធជាន់ក្រោយចុះ ក្នុងសាសនាតថាគត គាត់នេះអ្នកទាំងឡាយមិនត្រូវបានអាហារបរិភោគទេ លុះផែនដីដុះបានមួយយោជន៍ឡើង ព្រះពុទ្ធទ្រង់ព្រះនាម **កោនាគមនោ** បានត្រាស់មកទៀតពួកប្រេតក៏បាននាំគ្នាទៅសួរព្រះអង្គ ក៏ត្រាស់ដូចព្រះពុទ្ធមុនទៀត លុះផែនដីដុះបានមួយយោជន៍ទៀត ព្រះពុទ្ធទ្រង់ព្រះនាម **កស្សបោ** បានត្រាសដឹងឡើង ពួកប្រេតទៅសួរ ព្រះអង្គ ក៏ប្រាប់ដូចព្រះពុទ្ធមុនទៀតលុះផែនដីដុះបានមួយយោជន៍ទៀតទើបមកដល់ព្រះពុទ្ធព្រះនាម **គោត្តម** យើងនេះ ពួកប្រេតទាំងឡាយនាំគ្នាទៅសួរព្រះអង្គ ព្រះអង្គទ្រង់ត្រាស់ថា ចាំមើលពេលណាដែលព្រះបាទ **ពិម្ពិសារ** ជាញាតិរបស់អ្នកទាំងឡាយទ្រង់ ឱ្យនូវទានដល់តថាគត និងញ៉ាំងអាហារឱ្យសម្រេចដល់អ្នកទាំងឡាយៗនឹងបាននូវអាហារក្នុងពេលនោះ ។ លុះព្រះបាទ **ពិម្ពិសារ** បានថ្វាយទានជាដំបូង ហើយមិនបានផ្សាយផលឱ្យទៅពួកញាតិ ក៏ស្រាប់តែពួកប្រេតជាញាតិទាំងឡាយនោះយំស្រែកទ្រហឹងអឹងកងក្នុងរាត្រីនោះ ព្រះបាទពិម្ពិសារស្តេចយាងទៅកាន់វត្ត **វេឡុវ័ន្ត** ហើយបានសួរ ព្រះសម្ពុទ្ធ ព្រះអង្គទ្រង់ត្រាស់ថា ពួកប្រេតជាញាតិរបស់ព្រះអង្គនាំគ្នាយំស្រែករកអាហារព្រោះប្រេតទាំងនោះ ត្រូវបានអាហារបរិភោគក្នុងសាសនាតថាគតនេះហើយ ប៉ុន្តែព្រះរាជាស្តេចបានធ្វើបុណ្យទានហើយមិនបានផ្សាយផលឱ្យ ពួកប្រេតនោះ ចេះតែយំស្រែកបែបនេះ ។ ដល់ព្រះរាជាបានដឹងហេតុដូច្នោះហើយ ក៏ចាត់ចែង ធ្វើបុណ្យទាន ម្តងទៀតមានបាយចំណីសំពត់អាវសាវ ស្បៃ ជាដើមដល់ព្រះសម្ពុទ្ធជាប្រធាន ព្រះអង្គក៏អនុមោទនាដោយ ( តិរោកុឌ្ឌសូត្រ ) ស្រេចហើយ ក៏ពួកប្រេតទាំងនោះបានទទួលផលក្នុងពេលនោះ ហើយក៏បានទៅកើតក្នុងទិព្វវិមានជា ឋានប្រកបដោយសុខភាពរៀងរាបតទៅ រឿងប៉ុណ្ណេះជាដើម ហើយដែលលើកយកមកបញ្ចាំងបំភ្លឺ ឱ្យឃើញអំពីបុណ្យភ្ជុំបិណ្ឌ ។

ប្រជាជនខ្មែរយើងទម្លាប់ធ្វើបុណ្យភ្ជុំបិណ្ឌរៀងរាល់ឆ្នាំចាប់ពីថ្ងៃ មួយរោច ខែភទ្របទ ដើម្បីឧទ្ទិសផលានិសង្ស ដល់ជនដែលបានធ្វើមរណៈកាលទៅកាន់បរលោក ។ ពិធីនេះត្រូវធ្វើអស់រយៈពេលកន្លះខែគត់ ។

គេប្រារព្ធបុណ្យភ្ជុំបិណ្ឌនារនោចនៃខែ ព្រោះថាព្រះច័ន្ទក៏កាន់តែហោចពន្លឺទៅ ធ្វើឱ្យវេលា យប់កាន់តែងងឹតបន្តិចម្តងៗនៅវេលានោះ ហើយដែលស្តេចមច្ចុរាជដោះលែងពួកសត្វនរក

ទាំងឡាយក្នុងមួយឆ្នាំម្តង ឱ្យឡើងទៅរកបងប្អូនកូនចៅ ដើម្បីនឹងទទួលកុសលផលបុណ្យដែលគេធ្វើឧទ្ទិសឱ្យ ។ ដោយសត្វនរកជាសត្វខ្លាចពន្លឺ ទើបអ្នកស្រុកនិយមធ្វើបុណ្យឱ្យអ្នកទាំងនោះនៅវេលាខែងងឹត ។

អ្នកខ្លះនិយាយថា នៅពេលដល់រដូវហើយសត្វនរកដែលគេដោះលែងនោះខំដើររកបងប្អូនកូនចៅប្រាំពីរវត្ត បើមិនឃើញអ្នកណាធ្វើបុណ្យឧទ្ទិសកុសលបញ្ជូនបុណ្យឱ្យទេនោះនឹងត្រូវកើតក្តីក្តៅក្រហាយស្រេកឃ្លាន ហើយនឹង ប្រទេចផ្តាសារ ដល់ពពួកញាតិមិនលែងឡើយ ។

ដោយជំនឿនេះ ជនជាតិខ្មែរម្នាក់ ៗ ទោះបីមាន ក្រយ៉ាងណាក៏ដោយត្រូវតែធ្វើបុណ្យនេះដោយខានមិនបានក្នុងមួយឆ្នាំម្តង គឺត្រូវយកនំចំណីអាហារ ទៀន ធូបទៅវត្តរៀងរាល់ថ្ងៃចាប់ពីថ្ងៃ ១រោច ដល់ថ្ងៃ ១៥ រោច ខែភទ្របទ ។

នៅថ្ងៃចុងក្រោយ ព្រឹកឡើងគេធ្វើពិធីសែនព្រេន ជូនដំណើរដូនតាត្រឡប់ទៅស្រុកវិញ។

## ១៧. បុណ្យវិសាខបូជា

(សូមមើលត្រឹងងា អរិយធម៌ខ្មែរ គ.ស ១៩៧៥ ទំព័រទី ១២៤

យិន វន ប្រជុំបុញ្ញប្រវត្តិ គ.ស ១៩៦៧ ទំព័រទី ១៣-១៤)

តាមការស្រាវជ្រាវគេបានឱ្យដឹងថា បុណ្យពិសាខបូជាទំនងធ្វើនៅក្រោយព្រះពុទ្ធបរិនិព្វានច្រើនរយឆ្នាំ ។ គេថាប្រទេសឥណ្ឌានិងប្រទេសស្រីលង្កាបានប្រារព្ធធ្វើពិធីបុណ្យនេះយូរយាមកហើយ ។ ចំណែកប្រទេសសៀមនិងប្រទេសខ្មែរ ទើបតែចាត់ចែងធ្វើនៅសតវត្សទី ១៩ នេះ ។ នៅប្រទេសសៀមស្តេចរាមាបានចាប់ផ្តើមធ្វើនៅឆ្នាំ១៨១៧ ។ ចំណែកនៅប្រទេសខ្មែរបុណ្យវិសាខបូជាត្រូវបានធ្វើឡើងនៅឆ្នាំ ១៨៥៥ ដោយព្រះ **មហាប៉ាន** ដែលស្តេចសៀមបានបញ្ជូនមកកាន់ឧត្តុង្គតាមសេចក្តីស្នើរបស់ព្រះបាទ **អង្គឌួង** ។ ដំបូងពិធីនេះប្រារព្ធធ្វើឡើងដោយគណៈធម្មយុត្តិហើយក្រោយមកទើបជ្រួតជ្រាបទៅដល់គណៈមហានិកាយ (យល់ព្រមដោយព្រះបាទស៊ីសុវត្ថិ) ។ ✓

ពិសាខបូជា ជាពិធីបូជាយ៉ាងធំដែលពុទ្ធបរិស័ទ្ធប្រារព្ធឡើង ដើម្បីរំលឹកដល់ព្រះពុទ្ធគោតម ។ គេកំណត់យកថ្ងៃពេញបរមី "១៥ កើត" ខែពិសាខ ព្រោះជាថ្ងៃ ខែ មហាមង្គលត្រូវថ្ងៃ

ខែ ដែលព្រះពុទ្ធទ្រង់ប្រសូត្រ ទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ និងទ្រង់រំលត់ខន្ធចូលបរិនិព្វាន ។ ដូចនេះព្រះពុទ្ធទ្រង់ប្រសូត្រ ត្រាស់ដឹង និងបរិនិព្វាន សុទ្ធតែក្នុងថ្ងៃពេញបូរមី "១៥ កើត" ខែ ពិសាខ ខុសគ្នាតែឆ្នាំប៉ុណ្ណោះ ។

វិសាខបូជានេះពុទ្ធបរិស័ទទាំងអស់ ដែលជាអ្នកមានជំនឿស៊ប់ក្នុងព្រះពុទ្ធសាសនា តែងតែនិយមនាំគ្នាធ្វើពុំដែលខានឆ្នាំណាមួយឡើយឱ្យតែដល់ថ្ងៃ ១៥ កើត ពេញបូរមី ខែពិសាខ ហើយពុទ្ធបរិស័ទក្នុងវត្តនីមួយៗ ក៏នាំគ្នាទៅកាន់ទីអារាមរៀងៗខ្លួនមានផ្កាភ្ញី ប្រទីបធូបលា ទៀនធូប ជាដើមយកទៅបូជាចំពោះព្រះស្តូបជាទីបញ្ចុះព្រះសារីរិកធាតុ និង ឧទ្ទេសិកចេតិយគឺព្រះពុទ្ធបដិមាករ ដែលបានប្រតិស្ឋានទុកជាគ្រឿងសំគាល់ក្នុងអារាមផ្សេងៗ ឧទ្ទិសចំពោះព្រះសម្ពុទ្ធដែលបរិនិព្វានទៅជាយូរអង្វែង ហើយប្រជុំគ្នាស្តាប់ព្រះសង្ឃសូត្រស្វាធ្យាយ និងស្តាប់ព្រះធម៌ទេសនា ។ ការធ្វើបូជានេះដើម្បីរំលឹកដល់កាលដែលព្រះអង្គទ្រង់ប្រសូត្រ និង ទ្រង់បានត្រាស់ដឹងនូវសព្វញ្ញុពុទ្ធ និង កាលដែលទ្រង់បរិនិព្វាន ។ ការធ្វើវិសាខបូជាសំដៅចំពោះនក្ខត្តសម័យកាលទាំងបីនេះឯង ។ ព្រះអង្គទ្រង់ប្រសូត្រនៅថ្ងៃ សុក្រ ពេញបូណ៌មី ខែ វិសាខ ឆ្នាំច វេលាជិតថ្ងៃត្រង់ ។ ត្រាស់ដឹងនៅថ្ងៃពុធ ពេញបូណ៌មី ខែ វិសាខ ឆ្នាំ រកា ពេលជិតភ្លឺមុនពុទ្ធសករាជ ៤៥ ឆ្នាំព្រះជន្មាយុ ៣៥ វស្សា ។ បរិនិព្វានក្នុងថ្ងៃអង្គារ ពេញបូណ៌មី ខែ វិសាខ ឆ្នាំម្សាញ់ វេលាចែកបច្ចុ សម័យមុនពុទ្ធសករាជមួយឆ្នាំ ព្រះជន្ម ៨០ វស្សា ។

តាមទំនាមពិធីបុណ្យពិសាខបូជា ប្រព្រឹត្តទៅនៅវេលាយប់ក្នុងវត្ត ។ ដូចនេះហើយបានជាគេឃើញនៅគ្រប់វត្តអារាម មានអុជគ្រឿងប្រទីបធូបលាបូជាភ្លឺព្រោងព្រាតហើយមានមហាជនប្រុស ស្រី ក្មេងចាស់ប្រកបដោយគ្រឿងសក្ការៈបូជា មានផ្កាភ្ញី ទៀនធូប ជាដើម ទៅប្រជុំគ្នាស្តាប់ការសម្តែងទេសនាអំពីពុទ្ធប្រវត្តិ តាំងពីដើមរហូតដល់ចប់ ដើម្បីឱ្យមានបសាទសទ្ធា ចំពោះព្រះរតនត្រ័យកាន់តែខ្លាំងក្លាឡើង ។

## ១៨. បុណ្យមាឃបូជា

(សូមមើល ត្រីងងា អរិយធម៌ខ្មែរ ១៩៦៧ ទំព័រ ១២៤-១២៥)

បុណ្យមាឃបូជា ក៏ជាពិធីបុណ្យមួយយ៉ាងធំដែរ ដែលព្រះពុទ្ធសាសនិកនាំគ្នាប្រារព្ធធ្វើនៅថ្ងៃពេញបូរមីខែ មាឃ ។ គេកំណត់យកថ្ងៃពេញបូរមី (១៥កើត)ខែ មាឃ ព្រោះថ្ងៃ ខែ

នេះទាក់ទងទៅនឹងពុទ្ធប្រវត្តិដូចពិសាខបូជាដែរ ។ គឺនៅថ្ងៃពេញបូរមីខែ មាឃ ក្នុងឆ្នាំដំបូង ដែលព្រះពុទ្ធបានត្រាស់ដឹងក្នុងជន្មាយុ ៣៥វស្សាមានមហាសន្និបាតមួយដែលមានព្រះអរហន្ត ចំនួន ១២៥០ អង្គ "ក្រុមបុរាណជដីលចំនួន ១០០០ក្រុមអគ្គសាវ័ក ២៥០ " ។ នៅពេល ដែលជួបជុំគ្នាព្រះពុទ្ធ ទ្រង់សម្តែងឱវាទប្បាតិមោក្ខ ហើយទ្រង់តាំងព្រះសារីបុត្រជាបឋមសាវ័ក ព្រះមោគ្គលានជា ទុតិយសាវ័ក ។

ក្នុងមជ្ឈិមវ័យលុះព្រះជន្មគំរប់ ៨០ វស្សាមុនថ្ងៃបរិនិព្វាន ៣ ខែ គឺនៅថ្ងៃពេញបូរមី ខែមាឃ មានក្រុងមារមកនិមន្តព្រះពុទ្ធឱ្យចូលបរិនិព្វាន ព្រះអង្គទ្រង់ឆ្លើយប្រាប់មារថា ព្រះអង្គ នឹងបរិនិព្វាននៅបីខែទៀត គឺដល់ថ្ងៃពេញបូរមីខែ ពិសាខខាងមុខ ។ នៅពេលព្រះអង្គ ទ្រង់ដាក់ព្រះជន្មាយុសង្ខារនោះ មានការកក្រើកញាប់ញ័រផែនដីយ៉ាងខ្លាំង ព្រមទាំងផ្គរលាន់កងរំពងពេញផ្ទៃមេឃ ។ អាស្រ័យដោយថ្ងៃពេញបូរមី ខែ មាឃ ជាថ្ងៃអស្ចារ្យ ២(ពីរ)បែបនេះ ហើយ "ប្រជុំព្រះអរហន្ត និង ដាក់អាយុសង្ខារ" បានជាពុទ្ធបរិស័ទនាំគ្នារៀបចំគ្រឿងសក្ការៈបូជា ព្រះរតនត្រ័យ រំលឹកដល់ថ្ងៃខួបនោះជាប្រពៃណី ។ ទៅប្រទេសខ្មែរគេផ្តើមធ្វើបុណ្យមាឃបូជាប្រហែលគ្នានឹងបុណ្យពិ សាខបូជាដែរ ។

បុណ្យមាឃបូជានេះ ធ្វើឡើងដើម្បីរំលឹកនឹកដល់ជំនាន់ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ដាក់នូវ អាយុសង្ខារនៅចំពោះមុខមារ នាថ្ងៃអាទិត្យ ពេញបូរមី ១៥កើត ខែមាឃ ឆ្នាំម្សាញ់ ។ និងរំលឹកដល់ថ្ងៃ ដែលព្រះអង្គទ្រង់ធ្វើចតុរង្គសន្និបាត សម្តែងឱវាទបាតិមោក្ខ ចំពោះភិក្ខុក្នុងវត្តវេឡុវ័ន ។

ពិធីបុណ្យមាឃបូជាប្រព្រឹត្តទៅនៅពេលយប់ក្នុងវត្តអារាមនីមួយ ៗ ។ តាមទំនៀមពុទ្ធបរិស័ទត្រូវដើរប្រទក្សិណព្រះវិហាបីជុំសិនមុននឹងចូល ។ គេយកទេយ្យវត្ថុរៀបដាក់នៅមុខពុទ្ធរូប រួចអុជទៀនធូប ។ លុះជួបជុំគ្នាហើយ ព្រះសង្ឃមួយអង្គដែលចាស់វស្សាជាងគេសូត្រសិក្ខាបទ។ បន្ទាប់មកព្រះសង្ឃពីរអង្គ ដែលគង់នៅមុខទេយ្យវត្ថុសូត្រសរសើរគុណព្រះពុទ្ធគុណ លុះចប់បទខាងដើម ព្រះសង្ឃមួយ អង្គសម្តែងទេសនាអំពីជីវប្រវត្តិរបស់ព្រះពុទ្ធ ។ ការសូត្រពុទ្ធគុណ និងការសម្តែងធម្មទេសនាប្រព្រឹត្តឆ្លាស់គ្នារហូតដល់អាធ្រាត ជូនកាលទល់ភ្លឺ ។ ពេលនោះ គេប្រគេន យាគូដល់ព្រះសង្ឃ ដើម្បីបញ្ចប់ពិធីបុណ្យ ។

# ១៩. បុណ្យចូលឆ្នាំ

( សូមមើល ត្រឹងងា អរិយធម៌ ត.ស ទំព័រទី ១២៨-១២៩

យិន វន ប្រជុំបុញ្ញប្រវត្តិ ឆ្នាំ ១៩៦៧ ទំព័រ ១៧-១៨

យិន វន ប្រជុំបុញ្ញប្រវត្តិ ឆ្នាំ ១៩៦៧ ទំព័រ ១៦១ )

មនុស្សគ្រប់តែជាតិសាសន៍ តែងប្រារព្ធធ្វើពិធីបុណ្យចូលឆ្នាំថ្មី ។ គេនិយមកំណត់ពេលវេលា និងរៀបចំធ្វើពិធីបុណ្យនេះ ប្លែកៗពីគ្នាសមស្របទៅតាមជំនឿទំនៀមទម្លាប់ និងប្រពៃណីរបស់ជាតិគេ ។ ជនជាតិខ្មែរយើងបាននាំគ្នាធ្វើបុណ្យចូលឆ្នាំ តាំងពីបុរាណកាលរៀងរាល់ឆ្នាំរហូតមក ។

បុព្វហេតុដែលនាំឱ្យបញ្ចប់ឆ្នាំចាស់ ហើយផ្លាស់ចូលឆ្នាំថ្មីនេះ ដោយអ្នកខ្លះមានជំនឿតាមរឿងព្រេងមួយដែល មានសេចក្តីជាអាទិ៍ថា " **កបិលមហាព្រហ្ម** " បានចោទប្រស្នា ៣ខ ដល់ចំពោះធម្មបាលកុមារជាកូនសេដ្ឋីដែលបានរៀនចេះចប់នូវត្រៃវេទ និងចេះភាសារបស់បក្សីទាំងពួងផងទៀត ហើយបានធ្វើកិច្ចសន្យាថា បើដោះប្រស្នានេះមិនរួចទេ និងត្រូវកាត់ក្បាលធម្មបាល ធម្មបាលកុមារ ផ្ទុយទៅវិញបើធម្មបាលដោះប្រស្នានោះរួច កបិលមហាព្រហ្មនឹងកាត់ក្បាលឱ្យមកវិញ ។ ធម្មបាលកុមារទាល់ប្រាជ្ញា ប៉ុន្តែនៅទីបំផុតបានស្តាប់ឮសត្វ ឥន្ទ្រីញី-ឈ្មោលដែលសន្ទនាគ្នាអំពីប្រស្នានោះទើបបានយល់ឡើងហើយដល់ថ្ងៃកំណត់ក៏បានឆ្លើយ ថា :

ខទី១-វេលាព្រឹកសេរីសួស្តីនៅមុខ ទើបមនុស្សយកទឹកលប់មុខ

ខទី២-វេលាថ្ងៃត្រង់ សេរីសួស្តីនៅទ្រូង ទើបមនុស្សយកទឹកលាងទ្រូង

ខទី៣-វេលាល្ងាច សេរីសួស្តីនៅជើង ទើបមនុស្សយកទឹកលាងជើង

កបិលមហាព្រហ្មត្រូវកាត់ក្បាលបូជាធម្មបាលកុមារ ហើយឱ្យកូនស្រីទាំងប្រាំពីរនាក់យកជើងពានមកទទួលយកក្បាល រួចឱ្យកូនស្រីច្បងទូលដើរហែរប្រទក្សិណភ្នំព្រះសុមេរុ ៦០ នាទី ទើបយកទៅតម្កល់ទុកក្នុងគុហាគន្ធមាលី នៃភ្នំកៃលាស់ ។ លុះគម្រប់មួយឆ្នាំសង្រ្កាន្ត ទេពធិតាទាំងប្រាំពីរ ក៏ផ្លាស់វេនគ្នា ហែរក្បាលកបិលមហាព្រហ្មប្រទក្សិណភ្នំព្រះសុមេរុរាល់ៗឆ្នាំរហូតមក ។ ហេតុ នេះបានជាមាន សង្រ្កាន្ត ឬទំនៀមដាច់ឆ្នាំចាស់ចូលឆ្នាំថ្មីនេះ ។

បុណ្យចូលឆ្នាំរបស់ខ្មែរ កាលពីដើមគេប្រារព្ធធ្វើឡើងនៅខែមិគសិររួចប្តូរ ទៅធ្វើនៅខែ ចែត្រវិញ ដែលជាខែមួយគ្មានភ្លៀង ហើយប្រជាពលរដ្ឋទំនេរក្រោយពីការបោកបែនប្រមូលផលស្រូវដាក់ជង្រុក ។ ម្យ៉ាងទៀត ខែ ចែត្រនេះ ជាខែនៅចន្លោះរដូវច្រូតកាត់ និងរដូវវស្សា សម្រាប់ការដាំដុះថ្មីទៀត ដែលអាចបង្កការសប្បាយរីករាយដល់ប្រជាពលរដ្ឋ ខ្មែរយើង ។

បុណ្យចូលឆ្នាំនេះខ្មែរយើងនិយមធ្វើច្រើនសណ្ឋាន និងលេងល្បែងផ្សេងៗមានលេងឈូង លោតអន្ទាក់ ទាញព្រ័ត្រ ជាដើមតាមការនិយមនៃជនក្នុងសង្គមមួយ ៗ ការលេងទាំងអស់នេះហៅថា លេងបុណ្យនក្ខត្តឫក្ស ជាបឋមនោះមានបុត្រធីតាជំពូកខ្លះមានចិត្តសម្មាទិដ្ឋបាននាំគ្នាយកម្ហូបចំណីប្រាក់កាសជាដើម ជូនចំពោះគុណូបការិជនមាន មាតាបិតារបស់ខ្លួនជាដើម ឱ្យគាត់បរិភោគ មុននឹងជប់លៀងនោះ បានផ្ងូតទឹកដុះលាងមន្ទិលកាយ ប្រោះព្រំគន្ធពិដោរ ហើយជូនសំលៀកបំពាក់ថ្មីៗ ឱ្យអ្នកមានគុណស្លៀកពាក់ បើបុត្រធីតាទាំងឡាយបាននាំគ្នានិយមបែបនេះជាការប្រសើរបំផុត ជាលំដាប់មកទៀតបាននាំគ្នាដងទឹក ស្រង់ព្រះជំរះមន្ទិល និងបោសសំអាតទីវត្តអារាមជាដើម រួចក៏នាំគ្នាធ្វើបុណ្យឱ្យទានរក្សាសីល ដើម្បីផ្លាស់ចិត្តគំនិតថ្មី ឱ្យបានថ្លាស្អាត ផូរផង់ ទើបបានទទួលនូវសេរីសួស្តី និង សេចក្តីសុខចំរើន ដែលកើតមានឡើង ដោយអំណាច នៃទេវតាដែលចុះមករក្សាសត្វលោកក្នុងឆ្នាំនេះជាដើម ។

ហេតុនេះបុណ្យចូលឆ្នាំបើគិតទៅតាមលំអានរបស់ខ្មែរឃើញថា អ្នកកាន់ពុទ្ធសាសនាដែលបានប្រតិបត្តិការមកបុណ្យនេះឃើញថា ក្នុងជំនាន់ពុទ្ធសម័យ ក៏មានន័យដូច្នេះដែរ ។

ជាពិសេសក្នុងឱកាសបុណ្យចូលឆ្នាំនេះ ចាត់ជាសំរេជនីយឱកាស សម្រាប់មនុស្សលោកពិចារណា នូវកាលបរិច្ឆេទនៃអាយុសង្ខាររបស់ខ្លួនឱ្យច្បាស់ក្នុងគំនិតថា " **ឆ្នាំមួយកន្លងទៅផុត ហើយប្រវែងនៃអាយុរបស់អញក៏កាន់តែខ្លីទៅ ជីវិតរបស់អញធ្វើដំណើរកាន់តែជិតមរណៈ ហើយ រូបកាយរបស់អញក៏ជិតបែកធ្លាយហើយដែរ**" កាលបានពិចារណា ដូច្នោះហើយ លោភៈ ទោសៈ មោហៈ ក៏ទ្រុឌទ្រោមចុះទៅ ចិត្តក៏ល្អបរិសុទ្ធឡើងក្នុង ឆ្នាំថ្មីនេះជាងឆ្នាំចាស់ដែលកន្លងផុតទៅ។ កាលបើចិត្តយើងបរិសុទ្ធ ចិត្តជាកុសលមានសេរីសួស្តីហើយ ទេព្តាក៏យកចិត្តទុកដាក់ទទួលស្គាល់ ជួយបីបាច់ថែរក្សាយសសក្តិភោគទ្រព្យទាំងឡាយក៏កើតមានឡើង ព្រោះសេរីសួស្តីជាលំនៅនៃភោគទាំងឡាយ ព្រះសម្ពុទ្ធទ្រង់សម្តែងថា "សេរីភោគានមោសយោ " ។

## ២០. បុណ្យទេសនាមហាជាតិ

(សូមមើល ឃិន វន ប្រជុំបុញ្ញប្រវត្តិ ឆ្នាំ ១៩៦៧ ទំព័រ ៦១-៦៣)

បុណ្យទេសនាមហាជាតិនេះ ពុទ្ធសាសនិកជនខ្មែរយើងនិយមរាប់អានណាស់ ហើយនាំគ្នាធ្វើជារៀងរាល់ៗឆ្នាំស្ទើរគ្រប់កន្លែងទាំងអស់ ។ ហើយបុណ្យនេះក៏ជាបុណ្យមួយដ៏ឧឡារិក ក្នុងល្ងាចថ្ងៃដំបូងមានការនិមន្តព្រះសង្ឃចំរើនព្រះបរិត្ត រួចនិមន្តធម្មកថិកសម្តែងធម៌ទេសនា លុះព្រឹកឡើងក៏ចាប់ផ្តើម ទេសនាមហាជាតិតែម្តង ។

ការដែលយើងនាំគ្នានិយមធ្វើបុណ្យទេសនាមហាជាតិរៀងៗរាល់ឆ្នាំនេះគឺ ធ្វើឡើងដើម្បីប្រារព្ធដល់ព្រះរាជបេសកកម្មរបស់ព្រះអង្គក្នុងកាល ដែលព្រះអង្គទ្រង់សោយព្រះជាតិជាព្រះវេស្សន្តរ ហើយក្នុងព្រះជាតិរបស់ព្រះអង្គនេះ ព្រះអង្គបានបំពេញនូវទានបារមីធម៌យ៉ាងឧក្រិដ្ឋបំផុត ។ ដូចយ៉ាងការបរិច្ចាគទាន ព្រះអង្គគ្មានព្រះទ័យរុញរាក្នុងការឱ្យនោះសោះទេ បើមានស្មូមយាចកណាមួយប្រាថ្នា ចង់បានអ្វី ជាទ្រព្យសម្បត្តិមាសប្រាក់ក្តី ព្រះអង្គក៏តែងតែបំពេញនូវសេចក្តីប្រាថ្នារបស់ស្មូមយាចក នោះដោយព្រះទ័យជ្រះថ្លាជាទីបំផុត រហូតដល់បុត្រភរិយារបស់ព្រះអង្គ ក៏ព្រះអង្គអាចលះបង់ឱ្យទៅជាទានដែរ ។ មិនត្រឹមតែប៉ុណ្ណោះឡើយ បើទុកជានរណាមួយត្រូវការចង់បានសូតសាច់ឈាមរបស់ព្រះអង្គ ក៏ព្រះអង្គអាចនឹងលះបង់ជីវិតដើម្បីជាទានទាំងអស់ ដែលជាហេតុអស្ចារ្យកម្រមាន មនុស្សក្នុងលោកធ្វើតាមព្រះអង្គបាន ។

បុណ្យទេសនាមហាជាតិដែលយើងនាំគ្នាធ្វើរាល់ៗឆ្នាំនោះ គឺធ្វើឡើងដើម្បីប្រារព្ធនឹកដល់ការកសាងរបស់ព្រះអង្គ ឱ្យឃើញថាមានរឿងយ៉ាងនេះខ្លះ យ៉ាងនោះខ្លះ មានការកសាងយ៉ាងនេះ សុខទុក្ខដូច្នេះ ដូច្នោះជាដើម ដើម្បីឱ្យកើតនូវសេចក្តីសង្វេគ សេចក្តីជ្រះថ្លា និងបានជាវត្តប្រតិបត្តិតាម ដោយលើកយករឿងរ៉ាវរបស់ព្រះអង្គជាតួយ៉ាង ។

ឯរបៀបបុណ្យទេសនាមហាជាតិ នៅប្រទេសកម្ពុជាយើងនេះមិនសូវជាខុសគ្នាប៉ុន្មានទេ ពេលដែលប្រារព្ធធ្វើពិធីនេះលោកអាចារ្យបានឃោសនាប្រាប់ឧបាសកឧបាសិកាជើងវត្តទាំងអស់មកជួបជុំគ្នា ហើយសរសេរឈ្មោះគម្ពីរមហាជាតិតាំងពីកណ្ឌទី១ដល់ចប់ធ្វើជាឆ្នោត ហើយចែកឧបាសកឧបាសិកាជាក្រុមៗឱ្យគ្រប់តាមចំនួនកណ្ឌ ហើយឱ្យក្រុមមួយៗចាត់ឆ្នោត បើត្រូវ

កណ្ឌណាដូចកណ្ឌកុមារបា ឬ មទ្រីបាជាដើមក៏សំគាល់ថា កណ្ឌនោះជាកណ្ឌរបស់ ក្រុមខ្លួន ទើបនាំគ្នារៀបគ្រឿងសក្ការៈ សម្រាប់បូជាក្នុងពេលដែលធម្មកថិកសម្ដែងនូវកណ្ឌរបស់ខ្លួននោះ ។

ឯធម្មកថិករបស់អ្នកសម្ដែងវិញ ក៏លោកគ្រូចៅអធិការបានរើសភិក្ខុ ឬ សាមណេរ ដែលឈ្លាសវៃបាន សំដីវោហារចាត់ឱ្យទេសន៍មួយកណ្ឌមួយអង្គ១ ឯគ្រឿងសក្ការបូជាក៏លោកគ្រូប្រគល់ឱ្យធម្មក ថិកនោះ១ដែរ ។ ការទេសនាមហាជាតិនេះច្រើននិយមទេសន៍មើលសាស្ត្រា ទោះបីធម្មថិកនោះ ចេះចាំស្ទាត់យ៉ាងណា ក៏ត្រូវតែមើល ឬកាន់គម្ពីរជាចាំបាច់ ។ ឯគ្រឿងសក្ការៈបូជាវិញមានវត្ថុ ប្លែក១គ្នាទៅតាមកណ្ឌគម្ពីរ ដូចជាកណ្ឌចូឡពន្ធ មហាពន្ធ ច្រើនបូជាផ្លែឈើគ្រប់មុខមានចេក អំពៅជាដើម ។

សរុបឱ្យខ្លីគឺគេរៀបបូជាទៅតាមដំណើររឿងដែលមានសម្ដែងក្នុងកណ្ឌនីមួយ១ នេះជាទំនៀមពីបូរាណ ។

## ២១. បុណ្យពុទ្ធាភិសេក

(សូមមើល យិន វន ប្រជុំបុញ្ញប្រវត្តិ ឆ្នាំ ១៩៦៧ ទំព័រទី ៨៧-៩១)

បុណ្យពុទ្ធាភិសេក បើចាត់ជារបៀបដែលគេធ្លាប់ប្រតិបត្តិដោយខ្វះការត្រិះរិះនោះមាន ៤ យ៉ាងគឺ :

១-ចងព្រះពុទ្ធរូបចាស់ នឹងថ្មីឱ្យឆ្លងបារមីគ្នា

២-ពិធីបញ្ចុះលក្ខណៈ(ឯមហាបុរិសៈលក្ខណៈ៣២ប្រការមានស្រាប់ហើយ)

៣-ពិធីបើកព្រះនេត្រ (ព្រះនេត្ររបស់ព្រះសម្ពុទ្ធមាន ៥ស្រេចហើយដែរគឺ : មំសចក្ខុ , ព្រះនេត្យធម្មាតា ១ , ទិព្វចក្ខុ ព្រះនេត្រទិព្វ ១ , បញ្ញាចក្ខុ ព្រះនេត្រឃើញអរិយសច្ចៈ ទាំង ៤ មួយ , ពុទ្ធចក្ខុ ព្រះនេត្រ ឃើញនិស្ស័យរបស់ សត្វ១ , សមន្តចក្ខុ ព្រះនេត្រឃើញជុំវិញ ១ ។

៤-ពិធីផ្ចាញ់មារ (ជាកិច្ចដ៏គ្រោតគ្រាត) ពិធីនេះព្រះអង្គបានផ្ចាញ់ផ្ចាលព្រះអង្គឯងរួចស្រេច ហើយ ។ ឯពាក្យថា មារនេះមាន ៥ យ៉ាងគឺ :

-ខន្ធមារ មារគឺខ្ធន ៥ បានដល់រូប , វេទនា , សញ្ញា , សង្ខារ , វិញ្ញាណ

-កិលេសមារ មារគឺកិលេសបានដល់រាគៈ ទោសៈ ‚ មោហៈ ដែលជាតួកិលេសធ្វើបុរស ស្ត្រីបានដល់សេចក្តីខ្វល់ខ្វាយក្តៅក្រហាយក្នុងចិត្ត ។

-អភិសង្ខារមារ មារគឺសេចក្តីប្រាថ្នាក្នុងភពទាំង ៣

-មច្ចុមារ មារគឺសេចក្តីស្លាប់

-ទេវបុត្តមារ មានគឺកូនទេវបុត្ត ឬកូនរបស់អ្នកធ្លាប់ទទួលនូវសេចក្តីសុខ ដ៏ល្អិតល្អន់ដូចជា ទេវបុត្ត ។ បណ្តាមារទាំង ៥ នេះ ព្រះសម្ពុទ្ធព្រះអង្គបានផ្ចាញ់រួចស្រេចអស់ហើយ វានៅតែយើងទេតើ! ដែលបណ្តោយឱ្យមារទាំងឡាយចាប់ចាក់ច្រមុះខ្លះដឹកនាំទៅកាន់ផ្លូវខុស ផ្លូវប្រកបដោយតម្រេកត្រេកត្រអាលភ្លើតភ្លើន លោភលន់ពន់ប្រមាណជាទីបំផុត ។

ចុះហេតុដូចម្តេចបានជាយើងមិននាំគ្នាផ្ចាញ់មារក្នុងខ្លួនយើង បែរទៅជាផ្ចាញ់ឱ្យព្រះសម្ពុទ្ធ ដែលព្រះអង្គឆ្លងផុតពីអន្ទាក់មារ ទ្រង់យាងទៅសោយផលញ្ញាណ នៅស្ថានព្រះនិព្វាននោះទៅវិញ ? ត្រង់ចំណុចខ្សោយនេះហើយ ដែលយល់លាមកថាជាផ្កា ព្រោះកិលេសមារនៅគ្របស្រោបស្បែក បញ្ចាចក្ខុមិនឱ្យមើលឃើញសភាវៈពិត ។

ព្រះពុទ្ធរូបនេះ បើគិតទៅសុទ្ធតែកើតឡើងពីស្នាដៃរបស់ជាង និងអ្នកស្រឡាញ់ព្រោះព្រះពុទ្ធរូបនេះកើតក្នុងកាល ពុទ្ធសករាជកន្លងទៅបាន ៤០០ ឆ្នាំ មិនមែនកើតមកពីជំនាន់ពុទ្ធកាលទេ ព្រោះអ្នកប្រវត្តិសាស្ត្រដេញដោលស្រាវជ្រាវទៅឃើញ នៅប្រទេសឥណ្ឌាជាដើមមានសាងទុកជាច្រើន បើតាមដំណាលពុទ្ធចេតិយ៍ថា ៖ ព្រះពុទ្ធរូបនេះកើតមុនគេបង្អស់នៅប្រទេសគន្ធារៈ ព្រះបាទ (កនិស្ក) មានចិត្តជ្រះថ្លាសាងឡើងដូចជាព្រះបាទធម្មាសោកដែរ បន្ទាប់មកពួក យោនក ជាតិ ក្រិកចេះតែសាងត។មកអំពីថ្មខ្លះ ឈើខ្លះ តាមបែបផ្សេង។តាំងពីកាលនោះមក ។

ព្រះពុទ្ធរូបមាន ៥ យ៉ាងគឺ ៖

១-វិតកិមុទ្រ* ៖ទ្រង់ភ្នែន ផ្ងាព្រះហស្តស្តាំដាក់លើព្រះហស្តឆ្វេង ធ្វើសមាធិ ។

២-ភូមិសមុទ្រ ៖ទ្រង់ភ្នែនដូចជាសមាធិដែរ ប៉ុន្តែដាក់ព្រះហស្តចុះទៅផែនដីផ្ចាញ់មារ ។

---

* មុទ្រៈ មុទ្រ នេះជាពាក្យសំស្ក្រិត បាលីថា "មុទ្ទៈ" ប្រែថា បញ្ជាក់ថា គ្រឿងសំគាល់ អាការៈ បែបយ៉ាងសណ្ឋានទ្រង់ទ្រាយ ។

៣-ធម្មចក្រមុទ្រ : ទ្រង់ភ្នែន ព្រះហស្តដាក់លើឧទរក្តោបព្រះហស្តខ្លះ លាតខ្លះដូចកង
ចក្រទ្រង់សម្តែង ធម្មចក្រ ។

៤-អភយមុទ្រ : ទ្រង់ភ្នែនខ្លះ ឈរខ្លះ លាព្រះហស្តចេញខ្លះ ចូលខ្លះ ( ទ្រង់ឱ្យអភ័យ
ដល់សត្វ ) ។

៥-វរមុទ្រ : ទ្រង់បំបែរបាតព្រះហស្តទាំង២សំយុងចុះទៅខាងមុខ ទ្រង់ភ្នែនខ្លះ
ឈរខ្លះគឺប្រទានពរដល់សត្វ។

ព្រះពុទ្ធរូបនេះនៅមានច្រើនទៅទៀត រូបខ្លះគួរបូជា រូបខ្លះមានលក្ខណៈ ខុសពីពុទ្ធប្រវត្តិឃ្លាតចាកពុទ្ធចរិយាមិនគួរបូជា ឯព្រះពុទ្ធរូប ៣ បែបទៀត គឺ រូបប្រក់នាគ ១ , ឈរបិណ្ឌបាត១ , រូបទ្រង់ផ្ទំបរិនិព្វានមួយ រូបនេះសុទ្ធតែជាស្នាដៃនៃបុព្វបុរសពីបូរាណគួរឱ្យជ្រះថ្លាធ្វើសក្ការៈបូជាតរៀងទៅ ។ ចំណែករូបទ្រង់គ្រឿងនោះ មិនឃើញមានក្នុងផ្ទៃបិដកពុទ្ធបញ្ញត្តិណាមួយសោះ តែមានក្នុងសាស្ត្រាមហាជម្ពូទិព្វរាជក្រៅពីពុទ្ធដិកា និងអដ្ឋកថា ហើយនាំឱ្យទំនាស់ដល់វិន័យបញ្ញត្តិផង បើតាមដែលព្រះពុទ្ធទ្រង់សម្តែងបរិទ្ធិនោះឃើញមានតែ ៨ ពួក (ក្នុងធម៌ពាហុំ) មិនឃើញមានមហាជម្ពូទិព្វរាជមួយជាតិណាសោះ ដូច្នោះជាសទ្ធម្មឱ្យរូបទេដឹង ? ប៉ុន្តែក្នុង ដំណាលពុទ្ធចេតិយ៍ថា ពួកលទ្ធិមហាយានប្រកាន់ទុកព្រះពុទ្ធរូបទ្រង់គ្រឿងនេះថា ជាអាទិ-ទេព ឬ អាទិពុទ្ធ ដែលកើតនឹងដំណាលពិភពលោកប្រចាំនៅជានិច្ចក្នុងឋានសួគ៌ មិនចេះច្យុតិ បានជាខ្មែរពីបុរាណកាន់តាមលទ្ធិមហាយាន ព្រោះមិនមានមនុស្សស្ទាត់ជំនាញខាងលទ្ធិព្រះពុទ្ធសាសនា ទើបបានជានាំគ្នាកសាងព្រះពុទ្ធរូបទ្រង់គ្រឿងដោយការពេញចិត្តតៗមក ។

**អភិសេក** នេះមកអំពី អភិបុព្វបទ , សិចៈធាតុ , ណុ បច្ច័យ ប្រែថា ស្រោចចុះ ឬស្រោចស្រប់ ប្រកបព្រមតម្កុំតម្កើង អធិដ្ឋាន ប្រសិទ្ធិពរទូទៅ តាមឋានៈរបស់មនុស្សគ្រប់ប្រភេទទាំង អស់ក្នុងលោក។ បុណ្យ **ពុទ្ធាភិសេក** នេះបើធ្វើឱ្យសមទៅតាមហេតុផលគឺ គ្រាន់តែយកព្រះពុទ្ធរូបដែលបានសាងហើយនោះមកតម្កល់លើអាសនៈដែលវិចិត្ររចនាដ៏ល្អ ហើយរៀបចំសក្ការៈ បូជាទៀនធូប ផ្កាភ្ញី ជាដើម និមន្តព្រះសង្ឃចំរើនព្រះបរិត្ត សូត្របាលីពុទ្ធាភិសេក ពុទ្ធជ័យ មង្គល ជយន្តោ ដើម្បីសរសើរគុណបារមីដែលព្រះអង្គទ្រង់ឈ្នះលើពលមាររួច

និមន្តធម្មកថិក សម្តែងធម៌ទេសនាអំពីពុទ្ធប្រវត្តិ លុះព្រឹកឡើងវេរសង្ឃភត្ត ឬ បរិក្ខារណាមួយតាមសទ្ធាចំពោះព្រះសង្ឃ ប៉ុណ្ណោះទុកជាកិច្ចបង្ហើយបុណ្យ "ពុទ្ធាភិសេក" ឆ្លង ព្រះពុទ្ធរូបដ៏ប្រសើរបំផុតហើយមិនបាច់ធ្វើអ្វីឱ្យលើស ពីនេះទៅទៀតដរាបដល់នាំឱ្យថោកទាបដល់កិត្តិយសនៃព្រះពុទ្ធបរមគ្រូនោះឡើយ ។

## ២២. បុណ្យចំរើនព្រះជន្ម

(សូមមើល យិន វន ប្រជុំបុញ្ញប្រវត្តិ ឆ្នាំ ១៩៦៧ ទំព័រ ៩៤-៩៥)

បុណ្យចំរើនព្រះជន្មនេះ បើនឹងសម្តែងអំពីកម្មដែលគេត្រូវធ្វើនោះ មាន ៣ ប្រការគឺ :

១-ជីវិតមហកម្ម : ប្រែថាអំពើដែលគេធ្វើដើម្បីអប់រំ ឬ អប-ស្អប ជប់លៀងនូវជីវិតរបស់សត្វ គឺថាជប់លៀងជីវិតសង្ខារបង្ការទុកឱ្យហើយ ដោយយល់ឃើញថា សត្វលោកទាំងអស់ក្នុងត្រៃភព សុទ្ធតែឋិតនៅក្នុងអនិច្ចលក្ខណៈទាំង ៣ គឺ អនិច្ចំ ទុក្ខំ អនត្តា មិនទៀងជាទុក្ខ និងមិនមែនជាខ្លួនប្រាណ ជីវិតអសារោ ជីវិតឱ្យមានខ្លឹមសារ កុំឱ្យជីវិតរស់នៅទទេៗដោយគ្មានផលប្រយោជន៍អ្វី គឺត្រូវខំបំពេញកុសល ទាំងឡាយ មានឱ្យទាន រក្សាសីលជាដើមតាមកាលៈទេសៈ នឹងសម័យនិយម មិនបណ្តោយឱ្យ ជីវិតរស់នៅឃ្លាតឆ្ងាយចាកពីសេចក្តីចំរើនកុសល ។ល។

២-អាយុវឌ្ឍនកម្ម : ប្រែថា អំពើដែលគេធ្វើ ដើម្បីចំរើននូវសង្ខារ ឱ្យចំរើនយឺនយូរទៅបាន ដោយគុណានុភាពនៃធម្មរតនៈ មានការចំរើននូវព្រះបរិត្តជាដើម ។ល។

៣-អនុប្បទានកម្ម : ប្រែថា អំពើដែលគេធ្វើឡើង ដើម្បីអនុគ្រោះរំដោះទុក្ខទោសដល់សត្វទាំងអស់ ដែលជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងៗ មានសត្វដែលកំពុងទទួលនូវទុក្ខដោយប្រការ ផ្សេងៗមានការអត់ឃ្លានជាដើម ព្រោះនៅក្នុងលោកយើងនេះ តែងតែមានសត្វដែលមានជីវិតរស់នៅ ខុសគ្នា គឺ សត្វមានជីវិតខ្ពង់ខ្ពស់ កណ្តាល ទាប សោយសុខ ទុក្ខ ជាធម្មតាព្រោះសង្ខារតាក់តែងតាមពូជដើម ។ បណ្តាកម្មទាំងបីនេះ បានជាឱ្យឈ្មោះថា បុណ្យចំរើនព្រះជន្ម ព្រោះថា កម្មគឺសត្វត្រូវតែធ្វើដើម្បីជប់លៀងជីវិតសង្ខារបង្ការទុកឱ្យហើយ ព្រះសម្មុទ្ធទៀត

សោត ក៏ទ្រង់សម្ដែងទុកមក ហើយថា : **តស្មា ករេយ្យ កល្យាណំ និច្ចយំ សម្បរាយិកំ បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណនំ ។**

បុណ្យទាំងឡាយរមែងបានជាទីពឹងរបស់សត្វទាំងឡាយក្នុងលោកខាងមុខ ។ បានជារៀបរាប់មកអំពីបុញ្ញកម្ម ទាំង៣ ប្រការនេះគឺដើម្បីតម្រូវ ដល់បុណ្យចំរើនព្រះជន្មដោយធម៌៣ប្រការដូចបានពណ៌នាមកខាងលើស្រាប់ ។

ដូច្នេះបុរសស្ត្រី គ្រហស្ថ បព្វជិត មិនត្រូវធ្វេសប្រហែសភ្លេចខ្លួនឡើយគួរប្រញាប់ប្រញាល់ស្វែងរកទីពឹង មានសីល-ទានជាដើម កុំបណ្ដោយឱ្យជីវិតរស់នៅឥតខ្លឹមសារ ។

## ២៣. បុណ្យឈាបនកិច្ច

( សូមមើល យិន វន ប្រជុំបុញ្ញប្រវត្តិ ឆ្នាំ ១៩៦៧ ទំព័រ ១០១-១០៩)

សពមនុស្សក្នុងលោក មានពិធីធ្វើ ៤ យ៉ាង : បូជាដោយព្រះអគ្គី ១ , កប់ទុកក្នុងព្រះ-ធរណី ១ , បណ្ដែតចោលក្នុងស្ទឹងស័ក្ដិសិទ្ធ ១ , ចោលក្នុងទីស្មសាន ១ ។

ពិធីទាំង៤បែបនេះ អ្នកកាន់ព្រះពុទ្ធសាសនាច្រើនបូជាដោយព្រះអគ្គី ព្រោះបរមសពព្រះសម្ពុទ្ធក៏បូជាដែរ ។ ឯជាតិអឺរ៉ុប នឹង អាស៊ីខ្លះ ដូចចិនជាដើម ច្រើនកប់ទុកក្នុងព្រះធរណីដែលគេជ្រើសរើសរកទីដី ជ័យភូមិ ( ហុង-ស៊ុយ ) សម្រាប់ផ្ដល់សុខចម្រើនដល់កូនចៅ ។ ឯអ្នកកាន់ សាសនាព្រហ្មណ៍ភាគខ្លះនៅឥណ្ឌាសម័យមុន គេច្រើនដាក់ក្បូនបណ្ដែតចោលក្នុងស្ទឹងគង្គា ដែលគេយល់ថា ជាស្ទឹងស័ក្ដិសិទ្ធ មានទឹកហូរចេញមកពីព្រះនាងគង្គា ដែលឋិតនៅលើកំពូលព្រះឥសូរ អាចនាំព្រលឹងនៃសត្វណាដែលអណ្ដែតក្នុងស្ទឹងនោះឱ្យទៅកើតក្នុងស្ថានសួគ៌បាន។ ឯមនុស្សសម័យមុន គេច្រើនយកសពទៅចោលក្នុងព្រៃស្មសាន លើកំពូលភ្នំ ឬក្នុងជ្រោះភ្នំជាដើម ។

បណ្ដាពិធីទាំង ៤ បែបនេះ យកតែពិធីឈាបនកិច្ចមួយមកនិយាយត្រង់លក្ខណៈសំខាន់ៗ ដែលជាទំនៀមទម្លាប់របស់បុព្វាចារ្យ បាននាំគ្នាធ្វើតៗមក ព្រោះទំនៀមទម្លាប់ខ្លះ ប្រែក្លាយទៅ

ជាគ្មានន័យអស់ទៅហើយ គ្រាន់តែនាំគ្នាធ្វើៗទៅដោយយល់ថា បើធ្វើមិនគ្រប់សព្វ បុណ្យឈាបនកិច្ច នេះនឹងមិនបានរុងរឿង ។

ពិធីឈាបនដ្ឋាននៅប្រទេសកម្ពុជាយើង មុននឹងនាំសពទៅឈាបនដ្ឋាន (ទីបូជា) មានរៀប ជាក្បួនហែរយ៉ាងសមរម្យ ហើយក្នុងក្បួនហែរនោះមានព្រះសង្ឃអភិធម្ម-មាតិកា ១ មានអ្នកបម្រុងបួសមុខភ្លើងម្នាក់ ដែល គេបំពាក់កម្រងស្បូវភ្លាំង ឬ ខ្សែលើក្បាលសណ្តោង ភ្ជាប់មកមឈូសសព ១ អ្នកប្រាយលាជ ១ អ្នកកៀសចិញ្ចៀនត្បូង ១ ហើយមានអាចារ្យ កាន់ទង់ព្រលឹងដើរមុខមិនយោគី ៤ នាក់លីចប ពុនក្អមដើរក្រោយ ក្រៅពីនេះមានភ្លេងត្រៃ លក្ខណ៍ និងអ្នកហែហមតិចច្រើនទៅតាមសមត្ថភាពគ្រួសាររបស់សព ។ល។ ដល់បូជាសពភ្លើង កំពុងឆេះពេញក្រមុំ ទើបបំបួសកុលបុត្រម្នាក់ ដែលបម្រុង បួសហៅថា បួសមុខភ្លើង ហើយ មានទេសនាក្នុងពេលនោះ ផងហៅថាទេសនាមុខភ្លើងដែរ ។ លុះបូជារួចហើយមុននឹងរើសឆ្អឹង អាចារ្យធ្វើពិធីប្រែរូបសិនទើបរើសជាក្រោយ ។

ប៉ុន្តែទំនៀមទម្លាប់នេះប្រែជាគ្មានន័យ ព្រោះថា ចំពោះជនភាគច្រើនដែលពេញចិត្ត ធ្វើពិធីទាំងឡាយ មានប្រាយលាជជាដើមនេះ ហើយមិនដឹងថា ក្នុងពិធីមួយៗមានន័យដូចម្តេច ធ្វើដើម្បីអ្វី ? ការធ្វើហើយមិនដឹងពីអត្ថប្រយោជន៍ពិតប្រាកដ មិនដឹងន័យដូច្នេះអន់ជាងអ្នកមិន បានធ្វើទៅទៀត ព្រោះមិនបានធ្វើមិនខាតលុយចំណាយទិញវត្ថុនោះៗ ជូនកាលមានទោសថែម ទៀត ដោយយល់ខុសឃ្លាតពីច្បាប់ព្រះពុទ្ធសាសនា ។ ករណីនេះជាភារៈលើអាចារ្យយោគី (អាចារ្យខ្មោច) ដែលមិនបានដឹងន័យរបស់ពិធីមួយៗឱ្យប្រាកដតាមសភាវៈពិត ដែលនាំឱ្យ កើតប្រយោជន៍ ។

ក្នុងពិធីនេះមានលក្ខណៈសំខាន់ ៥៥ ដែលមានន័យផ្សេងៗគ្នាហើយគួរយកមកវែក ញែកក្នុងទីនេះ :

១- សណ្តោងស្បូវភ្លាំង ឬ ខ្សែពីក្បាលម្នាក់មកភ្ជាប់នឹងមឈូសសព ។ ពិធីនេះមាន ន័យសំខាន់ណាស់ ជាន័យដុះចេញពីព្រះពុទ្ធសាសនា ។ មនុស្សម្នាក់ដែលពាក់កម្រងស្បូវភ្លាំង នោះ ទុកជាប្រតិភូជំនួសមនុស្សលោកទាំងអស់ ដែលកើតក្នុងវដ្តសង្សារនេះ ។ ឯកម្រងស្បូវ ភ្លាំងគឺ កិលេសតណ្ហាដែលបណ្តាលឱ្យមានជាតិជរា ព្យាធិ មរណៈ ចងធ្លាស់ជាប់គ្រប់ក្បាល

មនុស្សសត្វទាំងអស់ ។ ដែលសណ្ដោងកម្រងស្បូវភ្លាំងមកជាប់នឹងសពនោះ ជាឧទាហរណ៍ស័ក្តិសិទ្ធិ ឱ្យមនុស្សសត្វគ្រប់រូបឃើញនឹងភ្ញែកដឹងច្បាស់នឹងងចិត្តថា : យើងគេមុខតែស្លាប់ដូចសពក្នុងមឈូសនេះទាំងអស់គ្នា គ្មាននរណាម្នាក់អង់អាចក្លាហាន ជៀសឱ្យផុតរត់ឱ្យរួចផុតពីសេចក្ដីស្លាប់បានទេ ព្រោះមាន ចំណងស្បូវភ្លាំងគឺ កិលេសតណ្ហាទាក់ជាប់គ្រប់ៗគ្នា ។ល។ នេះជាកិច្ចសំខាន់មួយសម្រាប់ពិចារណាឱ្យកើតធម្មសំវេគ ។

២- ប្រាយលាជៗ : នេះក៏មានន័យសំខាន់ណាស់ដែរ ដែលគេចាប់លាជលាយដោយសំឡី នឹងវត្ថុផ្សេងៗ បានសាចរាត់រាយព្រោងព្រាតទៅលើព្រះធរណី ជាភស្តុតាងឱ្យឃើញច្បាស់នឹងភ្ញែកថា សក់ រោម សាច់ ស្បែក ឆ្អឹង របស់មនុស្សសត្វគ្រប់រូប ដែលកើតស្លាប់ៗក្នុងវដ្តសង្សារនេះ តែងតែចោលរាត់រាយលើផែនដី ដូចជាលាជដូច្នោះ នេះក៏ជាឧបាយមួយយ៉ាងសំខាន់សម្រាប់ពិចារណាដែរ ។

៣-កៀសចិញ្ចៀនត្បូង : ពិធីនេះកន្លែងខ្លះមានដាក់ប្រេងក្នុងត្រលប់ ឬចានដាក់ប្រឆេះអុជ តម្កល់លើគំនរស្រូវក្នុងកញ្ជើ ។ នេះក៏មានន័យវិសេសណាស់ដែរជាបដិមវត្ថុប្រៀបនឹងរូបរបស់មនុស្សសត្វទាំងឡាយ ដែលកើតក្នុងលោកសន្និវាសនេះគឺ ភ្លើងដែលឆេះភ្លឺបភ្លែតៗ នោះជាជីវិតរស់នៅ ប្រឆេះជារូបកាយ ប្រេងជាអាយុសង្ខារ ។ សម្រាប់ពិចារណាថា បើប្រេងអស់ហើយភ្លើងត្រូវរលត់ ប្រឆេះក៏ជារបស់ឥតប្រយោជន៍មិនអាចធ្វើភ្លើងឱ្យឆេះវិញបាន ។ ឯមនុស្សសត្វទាំងឡាយក៏ដូច្នោះដែរ បើអាយុសង្ខារអស់ហើយ ត្រូវតែស្លាប់មិនអាចមានជីវិតរស់នៅបានរូបកាយក៏ជារបស់ឥតប្រយោជន៍ ប្រើការមិនកើត ។ល។ នេះក៏ជាឧបាយចំណានមួយ សម្រាប់ពិចារណាឱ្យកើតសេចក្ដីនឿយណាយចាកសត្វ និង សង្ខារ ។

៤-បួសមុខភ្លើង : ការបួសនេះបើគិតទៅតាមវិន័យ មិនពេញជាបព្វជ្ជាទេ ព្រោះកន្លែងខ្លះឱ្យអាចារ្យបំបួស ធ្វើដូច្នេះគ្មានសមហេតុផលសោះ ទៅជាឱ្យឧបាសកធ្វើឧបជ្ឈាយ៍បំបួសលោកសង្ឃ បើធ្វើត្រឹមត្រូវតាមទំនៀមដើម គឺគេបំបួសមែនទែន ពេលដែលហែសពទៅដល់រៀបចំបូជាហើយ គេនាំអ្នកដែលបម្រុងបួសនោះទៅវត្តបំបួសជាសាមណេរត្រឹមត្រូវតាមវិន័យទើបនាំគ្នាមកកន្លែងបូជាវិញ ឱ្យគង់ក្បែរទីបូជានេះ ទើបអាចារ្យប្រជុំគ្នាមកពន្យល់ថា មានតែភេទអ្នកបួសដូច្នេះហើយទើបឆាប់កាត់ផ្ដាច់នូវចំណងស្បូវភ្លាំងគឺ កិលេសតណ្ហា ដែលចងឆ្នាក់

ជាប់ នឹងក្បាលគ្រប់រូបទាញឱ្យចូលទៅរក ជាតិ ជរា ព្យាធិ មរណៈ នោះបាន ។ល។ នេះជាឧបាយពន្យល់យ៉ាងវិសេសជាងមុនៗទាំងអស់ ។

ការបួសនេះជំនាន់មុនមានខ្លះបួសរហូតទៅក៏មាន បួសពីរខែ បីខែ មួយអាទិត្យ ឬមួយថ្ងៃ ពីរថ្ងៃក៏មានតាមសទ្ធា ។ ដល់ពេលសឹកវិញមិនមែនឱ្យអាចារ្យផ្សឹកដូចកន្លែងខ្លះធ្លាប់ធ្វើនោះទេ គឺសឹកត្រឹមត្រូវតាមច្បាប់វិន័យ ។

៥-ពិធីប្រែរូប ៖ ពិធីនេះច្រើនធ្វើច្រឡូកច្រឡំនិងលទ្ធិព្រាហ្មណ៍សាសនា ដូចជាការបូជារូចរលត់ភ្លើងស្រួលបួលហើយមានព័ទ្ធសីមាអូមអាមកុំឱ្យខ្មោចលងជាដើម ។ ឯពិធីដែលមានន័យយ៉ាងសំខាន់ដូច្នេះ កាលលត់ភ្លើងត្រជាក់ហើយ អាចារ្យប្រជុំញាតិសព នឹងបរិស័ទដែលជួយ ទាំងប៉ុន្មានទៅជួបជុំនូវកន្លែងថ្កើងថ្កាន និមន្តព្រះសង្ឃបង្សុកូល ហើយអាចារ្យយកឈើឬចប គូសរាំសកំទេចធ្យូងដែលលាយដោយឆ្អឹងនោះធ្វើជារូបមនុស្ស មានដៃជើង ខ្លួនក្បាលជាដើម ហើយសួរថា រូបនេះដូចរូបបុគ្គលដែលស្លាប់ទៅនោះទេ ? អ្នកទៅប្រជុំឆ្លើយថា មិនដូចទេ ហើយ លុបចេញគូរទៀត សួរទៀតអស់វារៈ៣ដង ត្រូវឆ្លើយតាមពិតថា មិនដូចៗគ្រប់៣ដង ទើបអាចារ្យពន្យល់ថា នេះជាសច្ចធម៌ ជាសភាវៈពិត រូបកាយយើងទាំងអស់គ្នា តែវិញ្ញាណ ចេញហើយ តែងតែពុកផុយរលួយទៅជាធាតុដី ទឹក ភ្លើង ខ្យល់ ជាអនត្តា មិនអាចពូតផ្សំផ្គុំគូសវាស ឬជប់ឱ្យកើតឱ្យដូចរូបដើមវិញបានទេ ដូច្នេះអ្នកទាំងឡាយកុំសោយសោកអាលោះ អាល័យនឹងរូបកាយឱ្យសោះ មិនយូរមិនឆាប់រូបយើងទាំងឡាយក៏នឹងក្លាយទៅជាធាតុ ៤ ដូច្នេះដែរ ចូរនាំគ្នាខំប្រព្រឹត្តសុច្ចរិត ធម៌ ធ្វើទាន សីល សមាធិ ភាវនា គ្រប់ៗគ្នាទៅ ទើបបានសុខចំរើនទៀងទាត់រួចពីជាតិជរា ព្យាធិ មរណៈបាន ។ លុះធ្វើកិច្ចរួចហើយក៏នាំគ្នារើសឆ្អឹងទៅ ។ ប៉ុន្តែមាន អាចារ្យខ្លះនាំធ្វើពិធីនេះឱ្យក្លាយទៅជាមានន័យផ្ដេសផ្ដាសទៅវិញ ដូចជាលត់ភ្លើង ហើយរោយ គ្រាប់សណ្ដែក ល្ង និងយកស្លឹកចេកមួយធាងគ្របពីលើធ្យូង ហើយធ្វើមាត់អូចៗក៏ចាប់ស្លឹកចេកនោះឡើងរួចនិយាយថា ឥឡូវកូនចៅញាតិមិត្តបានធ្វើពិធីប្រែរូបហើយ សូមឱ្យប្រែរូបឆោម ទៅកើតឋានបរមសុខ ក៏បោះស្លឹកចេកទៅទិសខាងកើតបញ្ជូនព្រលឹងសពនោះឱ្យជិះស្លឹកចេកទៅចាប់ជាតិទៀត ហើយឧបកិច្ចនឹងគ្រាប់សណ្ដែក ល្ង ថា

ឱ្យឆាប់កើតឆាប់ធំ ដូចជាការដុះដាលនៃ ធញ្ញជាតិនោះ ។ លុះរើសឆ្អឹងហើយព័ទ្ធសីមាចង ខ្មោចទៀត កុំឱ្យលងគេឯង ។

ឯយោគី ៤ នាក់ ដែលលីចប ពុនក្អមនោះ គ្មានន័យសំខាន់ទេ យោគីគឺជាអ្នកដុតខ្មោច ខ្លះហៅថា ភ្ជុក ដែលពុនចប និងក្អមនោះ គឺចបសម្រាប់ជីកដីធ្វើជើងថ្ក ឬសម្រាប់ឆ្កើសភ្លើងឱ្យ ឆេះល្អឯក្អមនោះសម្រាប់ដងទឹកលត់ភ្លើងដែលបូជារួចហើយ ។ ប៉ុន្តែក្រោយមកក៏ក្លាយ ទៅជា យកកូនក្អមតូចៗខ្លះយកកូនឆ្នាំងទៅវិញ ហើយខ្លះមានឧបកិច្ចដាំបាយផ្តេស ផ្តាសថែមទៀត ។

ចំណែកទង់ព្រលឹងវិញក៏គ្មានន័យអ្វីសំខាន់ដែរ សំពត់ដែលចងធ្វើទង់នោះ គឺជារង្វាន់ គេជូនអាចារ្យ គេធ្វើសំពត់ធំវែងល្មមប្រើប្រាស់កើត ពុំមែនធ្វើប៉ុនបាតដៃ ហើយយល់ផ្តេសផ្តាស ថា ព្រលឹងអ្នកស្លាប់ទៅទំនឹងសំពត់ទង់ឱ្យអាចារ្យគាត់នាំទៅរកសុគតិភពនោះទេ ។ល។

ដើម្បីឱ្យមានរបៀបល្អហើយ បានផលប្រយោជន៍ផង គឺមុននឹងចេញហែសព អាចារ្យត្រូវ ពន្យល់ប្រាប់អ្នកហែទាំងឡាយឱ្យដឹងន័យអំពីចងស្បូវភ្លាំងឬខ្សែ អំពីប្រាយលាជ អំពីកៀសចិញ្ចៀនត្បូង ។ ដល់បូជាអាចារ្យត្រូវពន្យល់អំពីការបួសមុខភ្លើង ។ ដល់រើសឆ្អឹង អាចារ្យត្រូវ ពន្យល់ពីពិធីប្រែរូបទៀត ។

ចំពោះអ្នកមិនបានធ្វើ គ្រាន់តែហែទៅបូជា មាននិមន្តព្រះសង្ឃបង្សុកូលដូច បានធ្វើខ្លះៗមកហើយនោះ ក៏គ្មានទាស់ខុសអ្វីទេ ឱ្យតែធ្វើទៅហើយត្រូវហេតុផលកើត ផលប្រយោជន៍សមរម្យតាមគន្លងទ្រឹស្តីព្រះពុទ្ធសាសនា ។

ប៉ុន្តែបើមានឱកាសគួរតែធ្វើ ដើម្បីរក្សាប្រពៃណីនេះឱ្យគង់វង្សជាអង្វែងទៅ ។ ព្រោះជាពិធីដែលមានន័យល្អ គួរយកជាវត្តប្រតិបត្តិតាមបាន ។

## ២៨. បុណ្យឆាកបង្សុកូល

(សូមមើល យិន វន ប្រជុំបុញ្ញប្រវត្តិ ឆ្នាំ ១៩៦៧ ទំព័រ ១១២-១១៦)

ពាក្យថាឆាកបង្សុកូលនេះ ចែកចេញជា២បទគឺ : ឆាក១បទ , បង្សុកូល១បទ

-ឆាក : មានន័យថា ទាញយកធ្វើឱ្យឃ្លាតពីទី ឱ្យដាច់ចេញពីគ្នា......

ពាក្យឆាកនេះ ជាពាក្យរបស់ខ្មែរមុនសម័យអង្គរទៅទៀត ជានាមក៏មាន ជាកិរិយាក៏មាន ។ ឆាកជានាមគឺ ឆាកទ្រូ , ឆាកល្ខោន ។ ឯឆាកជាកិរិយាស័ព្ទមានន័យ ២ យ៉ាង

១-ទាញយក , ទាញទប់: ឆាកយកបន្ទង ឆាកបង្សុកូលដោយគ្រាន់តែទាញទប់អម្បោះ ។

២-កាត់ដោយប្រណាកៈ ឆ្លាក់ស្លា ឆាកមែកឈើ.........។ មានមតិវិភាគខ្លះយល់ច្រឡំថា ជាពាក្យសៀមទៅវិញ ព្រោះសៀមចេះនិយាយពាក្យនេះដែរ តែអានមិនច្បាស់ដូចខ្មែរទេ បានជាសៀមចេះនិយាយពាក្យនេះ ព្រោះកាលដើមដំបូងសៀមជាមនុស្សព្រៃគ្មានចេះសម្ដីភាសាច្រើនទេ ដល់មកធ្វើជាខ្ញុំចំណុះខ្មែរជាច្រើនរយឆ្នាំទើបចេះនិយាយទាន់សម័យ ចេះរាប់លេខចេះសរសេរអក្សរតាមខ្មែរ ព្រោះហេតុនោះ ទើបពាក្យសៀមស្ទើរតែទាំងអស់ សុទ្ធតែជាពាក្យខ្មែរតាំងពីរាប់លេខថា ហាសិប ហុកសិប ជាដើម ។ ឯអក្សរទៀត ក៏ប្រើអក្សរខ្មែររហូតមក ទើបនឹងផ្លាស់ក្នុងសតវត្សរ៍ក្រោយនេះទេ ដូចមានភស្ដុតាងក្នុងគម្ពីរស្លឹករឹត និងក្រាំងក្នុងបណ្ណាល័យសៀមស្រាប់ ។

-បង្សុកូល : ប្រែថា សំពត់ជិតប្រឡាក់ដោយធុលី ឬដោយមន្ទិលមានសំពត់ដែលគេបោលនៅរានផ្សារជាដើម ។ រួមស័ព្ទទាំង ២ ថាឆាកបង្សុកូល ខ្លះថា ឆាកមហាបង្សុកូល ប្រែថា ទាញយកនូវសំពត់ដែលជិតប្រឡាក់ដោយធុលី ។

ឆាកបង្សុកូល ឬ មហាបង្សុកូលនេះមាន ២ យ៉ាងគឺ : ឆាកបង្សុកូលមនុស្សរស់មួយ , ឆាកបង្សុកូលមនុស្សស្លាប់មួយ ។

១-បង្សុកូលមនុស្សរស់នោះ គឺគេយកសំពត់ទៅដាក់លើមនុស្សនោះ ហើយភិក្ខុទៅទាញសំពត់នោះ ដោយពោលថា អចិរំ វត្តយំ កាយោ បឋវឹ អធិសេស្សតិ ឆុទ្ធោ អបេតវិញ្ញាណោ និរត្ថំ វកលិង្គរំ ។ ប្រែថា កាយនេះមិននៅយូរប៉ុន្មានឡើយតែមានវិញ្ញាណប្រាសទៅហើយជាកាយគឺគេបោះបង់ចោល ក៏នឹងដេកសង្កត់នៅលើផែនដីដូចជាអង្កត់អុសរកប្រយោជន៍គ្មាន ។ គាថានេះ ព្រះសម្មាសម្ពុទ្ធទ្រង់ប្រារព្ធរឿងដែលជាដើមហេតុថា : មានកុលបុត្រម្នាក់ឈ្មោះ តិស្សៈ នៅក្នុងនគររមគធៈ ក្រុងសាវត្ថី បានស្ដាប់ធម៌ទេសនារបស់ព្រះសម្ពុទ្ធមានសេចក្ដីជ្រះថ្លាក៏ប្រគល់កាយថ្វាយជីវិតបួសក្នុងព្រះពុទ្ធសាសនា លុះកន្លងមកភិក្ខុនោះក៏កើតរោគពង

បែកពេញខ្លួន មានក្លិនគួរជាទីបដិកូលពន់ពេក ភិក្ខុសាមណេរដែលធ្លាប់ព្យាបាល ក៏ធុញទ្រាន់រអាចិត្តមិនហ៊ានចូលទៅជិត រត់ចោលអស់រលីងទៅ ទើបសម្តេចព្រះមហាករុណាទិគុណព្រះអង្គទ្រង់ព្យាបាលរក្សាដោយព្រះអង្គឯង ។ ទ្រង់ដាំទឹកក្តៅឱ្យងូតជម្រះលាងឱ្យអស់មន្ទិល ក្លិនបដិកូល ផ្លាស់ស្បង់ជីពរថ្មី បោកស្បង់ចីពរចាស់ហាលថ្ងៃ ផ្លាស់ទីកន្លែងថ្មីឱ្យនៅតាំងអំពីពេលនោះមក លោកក៏មាននាមប្រាកដថា : បូតិគតតិស្សត្ថេរ។ នេះលោកមានសេចក្តីរីករាយ រោគក្នុងកាយក៏បានជាសះស្បើយទៅ ។ នៅពេលដែលព្រះសម្ពុទ្ធទ្រង់ព្យាបាលរោគនោះ ព្រះអង្គទ្រង់ប្រៀនប្រដៅភិក្ខុទាំងឡាយថា ម្នាលទាំងឡាយ លោកទាំងឡាយជាអ្នកចេញមក អំពីត្រកូលផ្សេង។ពីគ្នា មកបួសក្នុងសាសនាជាមួយគ្នា រូបណាឈឺចាប់ ប្រសិនបើមិនរក្សាគ្នា តើបាននរណានឹងមកបីបាច់រក្សា ? ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាក៏ដោយ បើប្រាថ្នាប្រតិបត្តិតថា គត : ចូរប្រតិបត្តិភិក្ខុមានជំងឺជួសតថា គតចុះ ។ ចាប់តាំងពីពេលនោះមក ភិក្ខុទាំងឡាយក៏ព្យាបាលជំនួសព្រះអង្គ ។

កាលឥន្ទ្រីយ៍ របស់បូតិគតតិស្សត្ថេរនោះសមគួរហើយព្រះអង្គទ្រង់ប្រទានធម៌ទេសនាថា " អចិរំ វត យំ កាយោ ។ល។ " ជាអាទិ៍ ព្រះថេរនោះបានទទួលព្រះសទ្ធម្មទេសនារបស់ព្រះអង្គ ក៏បានសម្រេចព្រះអរហត្តផលជាចតុប្បដិសម្ភិទាញាណ ភិក្ខុទាំងឡាយក្រាបទូលសួរព្រះបរមសាស្តាអំពីហេតុមានជំងឺ និងសួរអំពីទៅកើតក្នុងទីណាជាដើម ព្រះសម្ពុទ្ធព្រះអង្គទ្រង់សម្តែងអំពីហេតុនោះថា :

ក្នុងកាលកន្លងទៅហើយ ព្រះសម្ពុទ្ធទ្រង់ព្រះនាម **កស្សបៈ** ឧប្បត្តិកើតឡើងក្នុងលោកកាលនោះឯង **បូតិគតតិស្សត្ថេរ** បានទៅកើតជាព្រានចាប់សត្វរស់មកសម្លាប់ចិញ្ចឹមជីវិត កាលបើគាត់ចាប់បានច្រើនមកហើយបរិភោគមិនអស់គាត់ក៏កាច់ជើងកាច់ស្លាបទុកដើម្បីលក់ និងបរិភោគឱ្យបានយូរ សម័យថ្ងៃមួយព្រានព្រៃនោះក៏មានសេចក្តីជ្រះថ្លាបានថ្វាយបិណ្ឌបាតទានដល់**ព្រះខីណាស្រព** ១ព្រះអង្គ ។ ព្រះសម្មាសម្ពុទ្ធក៏ទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ កម្មដែលធ្វើក្នុងកាលឯងនោះបានផ្តល់ឱ្យតិស្សៈ នេះដែលស្អុយពេញខ្លួន បែកទាំងឆ្អឹងផងដោយ ផលកម្មដែលកាច់ឆ្អឹងសត្វទាំងឡាយ ។ ដែលបានលុះអរហត្តដោយអានិសង្សថ្វាយបិណ្ឌបាត ទានដល់**ព្រះខីណាស្រព** នោះឯង ។

២-បង្សុកូលមនុស្សស្លាប់ ៖ គឺសំពត់ដែលគេបោះបង់ចោលដោយគំនរសំរាមជាសំពត់ដែលគេដាច់អាល័យដូចជា រំយោលចាប-សេក សំពត់ដែលនៅដោយរានផ្សារ ឬ សំពត់រុំខ្មោចជាដើម សំពត់ទាំងអស់នេះឯង ព្រះអង្គទ្រង់អនុញ្ញាតឱ្យភិក្ខុរើសយកមកប្រើប្រាស់តាមសេចក្តីត្រូវការ ពួកជនអ្នកមានសទ្ធា លុះបានឃើញដូច្នេះហើយ ក៏នាំយកសំពត់ថ្មីទៅចោលនឹងអសុភទីប៉ាឆាហៅថា សំពត់បង្សុកូល ។ លុះយូរកន្លងមកអ្នកមានសទ្ធាបានឃើញថា ធ្វើដូច្នេះទើបជាទីបដិកូល ទើបយកសំពត់ទៅគ្របលើឈើមឈូសខ្មោច ឬទាញខ្សែអំពីខ្មោច ហើយដាក់សំពត់លើខ្សែ ភិក្ខុអ្នកបង្សុកូលត្រូវពិចារណាដោយគាថាថា " អនិច្ចាវតសង្ខារាជាអាទិ៍ " ហើយនាំយកសំពត់នោះមកបានជាគាថានេះ សម្រាប់បង្សុកូលមនុស្សស្លាប់ ។

កាលដើមកន្លងទៅហើយ មានភិក្ខុមួយអង្គឈ្មោះមហាកាល លោកមានចិត្តជ្រះថ្លាពិចារណានូវ អសុភកម្មដ្ឋានក្នុងទីប៉ាឆា ។ ថ្ងៃមួយមានគេយកសពស្ត្រីម្នាក់មានរូបល្អសោភាទើប និងធ្វើកាលកិរិយាថ្មីៗ ទៅធ្វើឈាបនកិច្ចក្នុងទីប៉ាឆានោះ ភិក្ខុមហាកាល លោកបានពិចារណានូវគាថា ថា ៖ អនិច្ចា វតសង្ខារា ជាដើមនេះ លោកពិចារណាធម៌នេះ ដោយយោនិសោមនសិការៈ លោកក៏បានសម្រេច អរហត្តផល ព្រមទាំងចតុប្បដិសម្ភិទាញាណក្នុងពេលនោះឯង ។

**ព្រោះហេតុនេះ បានជាគាថានេះជាប់ជាទំនៀមទម្លាប់សម្រាប់បង្សុកូលមនុស្សស្លាប់រហូតមកដល់សព្វថ្ងៃនេះ ។ វិធីបង្សុកូលបានធ្វើឱ្យអ្នករស់នៅបានតបស្នងសងគុណដល់អ្នកដែលធ្វើមរណកាលទៅហើយ ថែមទាំងផ្តល់ឱកាសដល់អ្នករស់នៅពេញចិត្តថ្លើមចំពោះបុណ្យនេះណាស់ ។**

## ២៥. បុណ្យឆាកម្សៅងទៀត

(សូមមើល យិន វន ប្រជុំបុញ្ញប្បវត្តិ គ.ស ១៩៦៧ ទំព័រ ៥៧-៦០)

បុណ្យឆាកនេះ កើតពីត្រឹមព្រះ **អនុរុទ្ធត្ថេរ** មក ព្រោះលោកប្រព្រឹត្តបង្សុកូលជាវត្តបានជាមានដំណាលរឿងមួយរបស់ព្រះ **អនុរុទ្ធត្ថេរ** ថា ៖ មានស្ត្រីមួយរូបឈ្មោះនាង **ជាលិនី** ទៅកើតក្នុងទេវលោក បានយកសំពត់ទិព្វមួយមានបណ្តោយ ១៣ ហត្ថ ទទឹង ៤ ហត្ថ មកកប់ក្នុងគំនរសំរាម ព្រះ **អនុរុទ្ធត្ថេរ** លោកក៏ទៅបង្សុកូលយកមក បានជាអ្នកកាន់ព្រះពុទ្ធសាសនា នាំគ្នា

ធ្វើបុណ្យឆាកត១មក គឺធ្វើតាមគតិនេះឯង ។ ពិធីធ្វើបុណ្យឆាកនេះ បើគិតឱ្យសមរម្យតាមឋានៈរបស់បុណ្យទៅទំនងជាប្រសើរជាងបុណ្យឯទៀត១ ប៉ុន្តែត្រូវធ្វើឱ្យស្រតាមច្បាប់ព្រះពុទ្ធសាសនាផង ទើបបានអានិសង្សច្រើន គឺធ្វើតាមហេតុដែលឱ្យកើតបុណ្យទាំង ៣ យ៉ាងគឺ :

**-បសាទោ** : ធ្វើសេចក្ដីជ្រះថ្លាឱ្យកើតឡើងជាមុន ។

**-សទ្ធេគោ** : ធ្វើចិត្តឱ្យតក់ស្លុតចំពោះសត្វនិងសង្ខារ

**-តេសុចរិត្តា** : ធ្វើសុច្ចរិតទាំង៣ គឺកាយវិសោចេយ្យ វចីវិសោចេយ្យ មនោវិសោចេយ្យ ។

ធ្វើស្អាតទាំង៣នេះឱ្យបានគ្រប់គ្រាន់ពេញលេញ ចាកគ្រឿងសៅហ្មងចិត្តមានៈ លោភៈមោហៈ ជាដើម ទើបសមរម្យតាមឋានៈនៃបុណ្យ ។ ម្យ៉ាងទៀតបុណ្យឆាកនេះបើធ្វើប្រយ័ត្នកុំឱ្យក្លាយទៅជាបាដិបុគ្គលិកទាន ត្រូវធ្វើឱ្យកើតទៅជាសង្ឃគតាទក្ខិណាទាន ទើបបានផលច្រើនលើសជាងបុណ្យដទៃ ។ បើធ្វើឱ្យទៅជាបាដិបុគ្គិលិកទានវិញគឺ យកលោកតែមួយអង្គអាចឱ្យបានអានិសង្សនោះតិចណាស់ ហេតុនេះពុទ្ធបរិស័ទ អ្នកមានសទ្ធាជ្រះថ្លាត្រូវមានបញ្ញាត្រិះរិះឱ្យឃើញជាក់ច្បាស់ក្នុងចិត្តទើបបដិវត្តន៍ ដើម្បីឱ្យសមហេតុផលនឹងឋានៈនៃបុណ្យកុំអាងតែមានទ្រព្យហើយចេះតែធ្វើស្មាន១ទៅ ដោយមិនយកលក្ខ័គោលព្រះពុទ្ធសាសនាជាគោលគំនិតផងទេ ទាននេះក៏ក្លាយទៅជាទានមានអានិសង្សតិចតួចទៅវិញប្រាកដ ។ ព្រោះនេះបុណ្យឆាកនេះជាបុណ្យគឺអ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើមតែងសរសើររាប់អានយ៉ាងឆ្នើម ក្នុងព្រះពុទ្ធសាសនា ហើយបុណ្យនេះចាត់ចូលក្នុងកតញ្ញូតកវេទិតាធម៌ ដែលបុត្រធីតាទាំងឡាយធ្វើ ឡើងដើម្បីតបស្នងសងគុណ ចំពោះបុព្វការីជន គឺមាតាបិតាដើម ។

ម្យ៉ាងទៀតមានន័យមួយសម្ដែងអំពីគុណ ៤ យ៉ាងគឺ :

១-**អនន្តគុណ** : គុណដែលរាប់មិនបាន

២-**អនេកប្បគុណ** : គុណច្រើនជាអនេក

៣-**អសមគុណ** : គុណឥតអ្វីប្រៀបស្មើ

៤-**អបរិមាណគុណ** : គុណប្រមាណមិនបាន

បានជាលោកប្រៀបឧបមាថា ឱ្យយកផែនដីមកធ្វើជាសៀវភៅ យកភ្នំព្រះសុមេរុមកធ្វើជាទឹកខ្មៅ ហើយសរសេររៀបរាប់តែអំពីគុណមាតាបិតា ឱ្យត្រាតែអស់ផែនដី និងរិចរិលភ្នំព្រះសុមេរុ ព្រមទាំងរីងទឹកនព្វមហាសមុទ្រ ក៏នៅមិនអស់គុណមាតាបិតាផង បានជាព្រះពុទ្ធទ្រង់ត្រាស់សម្តែងថា តេហិ អត្តនោ មាតាបិតូនំ នប្បមជ្ជិតព្វំ អ្នកទាំងឡាយមិនគប្បីប្រមាថមើលងាយចំពោះមាតាបិតារបស់ខ្លួនទេ ព្រោះមាតាបិតាជាអ្នកមានគុណដ៏ធ្ងន់ យើងត្រូវតែគោរពប្រតិបត្តិស្រឡាញ់ កោតខ្លាចទាំងយប់ថ្ងៃ ។

បុណ្យឆាកនេះប្លែកពីឆាកបង្សុកូលត្រង់រៀបប្រដាប់ប្រដាគ្រប់មុខមិនចំពោះតែសំពត់ដូចឆាកបង្សុកូលនោះទេ ហើយនិមន្តលោកមកឆាក ឬ យកទៅវត្តអារាម និមន្តលោកឆាកជូនអ្នកមានគុណទាំងឡាយ មានមាតាបិតាជាដើម ។

## ២៦. ពិធីបុណ្យ អំទូក អកអំបុក សំពះព្រះខែបណ្តែតប្រទីប

(សូមមើល យិន វន ឆ្នាំ ១៩៦៥ ទំព័រ ៦១-៧៥)

ប្រវត្តិសាស្ត្របានបញ្ជាក់ថានៅ "ថ្ងៃទី ១៤-១៥ កើតខែអស្សុជ និង ១រោជខែកត្តិក" ពិធីអុំទូក អកអំបុក បណ្តែតប្រទីប ជាបុណ្យប្រពៃណីជាតិដ៏ធំសម្បើម មានដើមកំណើតតាំងពីបូរាណកាលមក ហើយដែលគេបានចែងទុកក្នុងឯកសារជាតិ និង អន្តរជាតិ ឬតាមសិលាចារឹកនៃ ប្រាសាទជាដើម ។

ពិធីនេះ រីកចំរើនយ៉ាងខ្លាំងនៅសង្គមខ្មែរ នាសម័យអង្គរក្នុងរាជព្រះបាទជ័យវរ្ម័នទី៧ សតវត្សទី ១២ និងសម័យលង្វែកនាពុទ្ធសករាជ ២០៧១ គ្រិស្តសករាជ ១៥២៨ ក្នុងរាជព្រះបាទអង្គច័ន្ទទី ១ ទ្រង់តាំងពញាតាត ងារជាស្និទ្ធភូបាលជាស្តេចក្រាញ់នៅកម្ពុជាក្រោមស្រុកបាសាក់។ ពីព្រោះ :

ក/ នៅ សម័យអង្គរសតវត្សទី ១២ ក្រុងកម្ពុជាមានសេចក្តីសុខសប្បាយក្សេមក្សាន្តរុងរឿងណាស់ ដោយព្រះបាទជ័យវរ្ម័នទី ៧ ស្តេចចេញធ្វើសង្គ្រាមជើងទឹកបង្ក្រាបជាតិបរទេសចាម ដោយកងទ័ពទូកជា ចម្បាំងរំដោះក្រុងកម្ពុជា ឱ្យរួចផុតពីកណ្តាប់ដៃខ្មាំងសត្រូវ ។ គ្រិស្តសករាជ ១១៧៧-១១៨១ រឿងចម្បាំងទាំងអស់ត្រូវបានបុព្វបុរសខ្មែរឆ្លាក់ទុកនៅលើ

ជញ្ជាំងប្រាសាទបាយ័ន និង ប្រាសាទ បន្ទាយឆ្មារ ដែលមានរូបព្រះឆាយាលក្ខណ៍នៃព្រះបាទជ័យវរ្ម័នទី៧ និងទ្រង់ឈរលើនាវាចម្បាំង ទ្រង់កាន់ធ្នូរដំបង ដែលមានកងទ័ពយ៉ាងច្រើនមហិមា ។

ខ/ តាមឯកសារប្រណាំងទូករបស់ក្រុមជំនុំទំនៀមទម្លាប់ និពន្ធដោយ ថាច់ ប៉ែន ចែងថា សម័យលង្វែក ព.ស ២០៧១ គ.ស ១៥២៨ ព្រះបាទអង្គច័ន្ទទី១ ទ្រង់តាំងពញាតាតងារជាសិទ្ធ ភូបាល ជាស្ដេចនៅកម្ពុជាក្រោម ស្រុកបាសាក់ ឱ្យរៀបចំកងទ័ពជើងទឹកចែកចេញជាបីក្រុម ។

ក្រុមទី១ : គឺកងទ័ពស្រួចហាត់ច្បាំងដោយទូកកង

ក្រុមទី២ : គឺជាកងទ័ពជំនួយហាត់ច្បាំងដោយទូកចែវពីរជួរ

ក្រុមទី៣ : គឺជាទ័ពបាសាក់ ជាទូកធំមានដំបូល ១ កាត់ មានក្ដោងដូចជាទូកប៉ុកចាយតែរាងស្ដួចវែង សម្រាប់ផ្ទុកស្បៀងកងទ័ព ។

គ/ តាមឯកសារមហាបុរសខ្មែរ ព.ស ២៤០៤ គ.ស ១៨៦០ បានចែងថា ព្រះបាទ នរោត្តមត្រាស់បង្គាប់មន្ត្រីរាជការរៀបចំពិធីបុណ្យទ្វាទសមាស ។ ស្ដេចគង់ព្រះរាជដំណាក់ផែ ទត ទូក ទូកមួង ទូកចែវ ដែលអុំប្រណាំងថ្វាយ ផ្ដាច់ព្រ័ត្រក្នុងពេលចេញវស្សា និងដង្ហាយដល់ ព្រះច័ន្ទ និង បណ្ដែតប្រទីបថ្វាយដល់ព្រះចង្កូមកែវ ។

- ពិធីបុណ្យអុំទូក :

ដើម្បីជាការសក្ការៈដឹងដល់បុព្វបុរសខ្មែរយើង ដែលរក្សាបាននូវបូរណភាពទឹកដី បង្ក្រាបបានរាល់សង្គ្រាមឈ្លានពាននៃបច្ចាមិត្រ ដែលមានបំណងដណ្ដើមយកនូវសម្បត្តិជាតិ ត្រូវបុព្វបុរសយើងកំទេចឱ្យវិនាសមហន្តរាយ ហើយការប្រឆាំងតបនិងសត្រូវទាំងនោះ ដូចតាយើងមានកងទ័ពជាច្រើនផ្នែកពិសេសគឺកងទ័ពជើងទឹកនេះឯង ។ ដូច្នេះពិធីអុំទូកជាពិធីមួយរំលឹកឡើងវិញនូវអនុស្សាវរីយ៍ នៃការរៀបចំក្បួនសមយុទ្ធកងទ័ពជើងទឹករបស់ខ្មែរបូរាណ ដែលពីដើមគេតែងតែប្រារព្ធធ្វើឡើងនៅថ្ងៃទី ១៤ , ១៥ កើត និង ១ រោចខែអស្សុជ រៀងរាល់ឆ្នាំ ។

ម្យ៉ាងទៀតដោយមានការនឹករលឹកគុណ ដល់ទឹកដីដែលយើងគ្រប់គ្នាបានរស់នៅសុខសាន្តនេះ ជាទីសក្ការៈរបស់ដូនតានៃយើងទាំងឡាយ ក៏មូលមតិគ្នាជាឯកច្ឆ័នតាក់តែងប្រារព្ធពិធីនេះឡើង ដើម្បីជាដង្ហាយដល់ព្រះគង្គានិងពេះធរណី ។

-ប្រវត្តិពិធីអកអំបុកសំពះព្រះខែ:

បុណ្យប្រពៃណីអកអំបុក សំពះព្រះខែ មានប្រវត្តិជាប់ទាក់ទងយ៉ាងជិតស្និទ្ធ ទៅនឹងប្រវត្តិរបស់ព្រះពុទ្ធជាម្ចាស់នៃយើង ។ ពិធីនេះប្រហែលជារីកចំរើនដំណាលគ្នានឹងបុណ្យអុំទូក បណ្តែតប្រទីបដែរ ។

តាមគម្ពីរ បរមត្ថទីបនី អដ្ឋកថាចរិយាបិដកភាសាបាលីចែងថា ក្នុងដើមភទ្ទកប្បនេះព្រះបរមពោធិសត្វនៃយើងទ្រង់យោនយកកំណើតជាទន្សាយពោធិសត្វ ។ វេលាខែពេញបរមីមួយ ទន្សាយពោធិសត្វបាន អធិដ្ឋាន ឧបោសថសីល ហើយឧទ្ទិសមំសៈជាទានបរមត្ថបារមី ដើម្បីបំពេញសម្មាសម្ពោធិញាណឱ្យបានត្រាស់ជាព្រះពុទ្ធ ។ ព្រះឥន្ទទ្រង់ជ្រាបពីហេតុការណ៍នោះទ្រង់ក្រឡាខ្លួនជាព្រាហ្មណ៍ចាស់ម្នាក់មកសុំ មំសៈ របស់ទន្សាយព្រះពោធិសត្វធ្វើជាអាហារ ។ ទន្សាយព្រះពោធិសត្វបានឱ្យព្រាហ្មណ៍នោះបង្កាត់ភ្លើងឆេះយ៉ាងសន្ធោសន្ធៅ ។ ទន្សាយព្រះពោធិសត្វក៏រលាស់ខ្លួនឡើងបីដង ដើម្បីឱ្យសត្វល្អិតដែលជាប់និងរោមជ្រុះចេញរួចក៏លោតចូលក្នុងភ្លើងភ្លាម ភ្លើងនោះប្រែជាពុំឆេះសន្ធោសន្ធៅដូចមុនឡើយ ឃើញដូច្នេះ ព្រះឥន្ទ្រព្រាហ្មណ៍ក៏ស្ទុះទៅពយកទន្សាយពោធិសត្វឡើងទៅដល់មណ្ឌលព្រះច័ន្ទ ហើយទ្រង់ក៏យកម្នាងសិលាគូររូប ទន្សាយពោធិសត្វ ហើយឥន្ទ្រព្រាហ្មណ៍អធិដ្ឋានថា សូមឱ្យរូបទន្សាយពោធិសត្វដែលយើងខ្ញុំគូរ នេះនៅជាប់រហូតដល់ទីបំផុតកប្ប ។

ដោយអនុភាពទានបរមត្ថបារមីនៃព្រះពោធិសត្វផង និងសេចក្តីអធិដ្ឋានរបស់ឥន្ទ្រព្រាហ្មណ៍ផង រូបទន្សាយក៏ឃើញប្រាកដក្នុងមណ្ឌលជាដរាបរហូតដល់សព្វថ្ងៃ ។

ពិធីបុណ្យនេះរីកចំរើននៅក្នុងសង្គមខ្មែរ ពីព្រោះឥទ្ធិពលនៃព្រះពុទ្ធសាសនាបានចាក់ឫសយ៉ាងជ្រៅទៅក្នុងព្រលឹងរបស់ប្រជាជាតិទាំងមូល ដែលតែងតែគោរពបូជាដល់ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ពិសេសគឺព្រះពោធិសត្វដែលយោនយកកំណើតជាទន្សាយ បានផ្តិតរូបព្រះឆាយា លក្ខណ៍របស់ព្រះអង្គនិងលោកខែ ដើម្បីបានបំភ្លឺសត្វលោកតរៀងទៅ ។

-អត្ថន័យនិងខ្លឹមសារ ពិធីអកអំបុក សំពះព្រះខែ :

- សក្ការៈបូជាចំពោះទន្សាយព្រះពោធិសត្វដែលរូបព្រះឆាយាលក្ខណ៍របស់ព្រះអង្គ ផ្តិតជាប់និងលោកខែ ដើម្បីបំភ្លឺសត្វលោករៀងមក ។

ដើម្បីឧទ្ទិសថ្វាយព្រះពោធិសត្វ នូវផលានុផល ដែលជាចំណីរបស់ព្រះអង្គកំពុងតែបញ្ចេញភោគផលយ៉ាងល្អប្រសើរ ក្នុងវេលាយប់ពេញបូរមីនៃខែកត្តិក ជាពេលព្រះខែលេចរូបរាងច្បាស់ ដើម្បីថ្វាយចំណីទាំងនោះមាន ត្រាវ ដំឡូង ដូង ចេក អំបុក ។ល។

ដើម្បីអបអរសាទរនូវទិន្នផល ដែលបានមកពីការបង្កបង្កើនផលរបស់ប្រជាជាតិកម្ពុជាខិតខំធ្វើពលកម្មយ៉ាងខ្លាំងតាំងពីរដូវភ្លៀងធ្លាក់កន្លងមកជាសញ្ញាប្រាប់ថារដូវស្រូវទុំព្រមទាំងផលានុផលទាំងឡាយបានមកដល់ហើយ ។

ពិធីបណ្តែតប្រទីបជាបុណ្យប្រពៃណីជាតិដែលប្រព្រឹត្តទៅនៅវេលាយប់ថ្ងៃទី ១៤-១៥ កើតនិង ១ រោច ខែ កត្តិក ភ្ជាប់និងពិធីអុំទូក ដែលប្រព្រឹត្តទៅនៅពេលថ្ងៃ មានកំណើតដំណាលគ្នានឹងពិធីអុំទូករីកចំរើននៅក្នុងសង្គមខ្មែរតាំងពីសម័យអង្គរដែរ ពិធីបណ្តែតប្រទីបមានប្រវត្តិយ៉ាងជិតស្និទ្ធនឹងព្រះពុទ្ធសាសនា ហើយក៏មានជាប់ឥទ្ធិពលព្រាហ្មណ៍សាសនាក្នុងការប្រតិបត្តិវិធីអគ្គិហោត្រ ឬ ហោមពិធី ដែលគេអុជទៀនធូបប្រទីបជ្វាលា ដើម្បីបូជាដល់អាទិទេព ។ ពីព្រោះតាមគម្ពីរទាសវង្សភាសាបាលី មានចែងថា ព្រះចង្កូមកែវទាំងបួន នៃព្រះសម្មាសម្ពុទ្ធ ប្រតិស្ថាននៅទីទាំងបួនគឺ :

- នៅត្រៃត្រឹង សួគ៌ (១)
- នៅពិភពនាគ (១)
- នៅស្រុកគន្ធារ (១) និងនៅទន្តបុរៈ (កលិង្គរដ្ឋ) ១

អត្ថន័យនិងខ្លឹមសារពិធីបណ្តែតប្រទីប

-ពិធីបណ្តែតប្រទីបជាពិធីបុណ្យ ទាក់ទងទៅនឹងសាសនាជាបុណ្យប្រពៃណីរបស់ខ្មែរបញ្ជាក់នូវទឹកសញ្ចេតនាស្នេហានិងគោរពដឹងគុណដល់សម្មាសម្ពុទ្ធគឺ ព្រះចង្កូមកែវ ប្រតិស្ថាននៅពិភពនាគ ព្រមទាំងស្នាមព្រះបាទ របស់ព្រះអង្គប្រតិស្ថាន នៅស្ទឹងនម្មទា និងកន្លែងដទៃទៀត ។

-ដឹងគុណដល់ព្រះគង្គារ និងព្រះធរណី ដែលបានផ្តល់នូវជីវភាពរស់នៅរបស់ប្រជាជាតិកម្ពុជាយ៉ាងរុងរឿងប្រកបដោយសុខុមាលភាព ។

-ដើម្បីសម្ដែងមនោសញ្ចេតនា ដឹងគុណចំពោះទន្លេមេគង្គនិងទន្លេសាប ដែលផ្ដល់ជីជាតិយ៉ាងសំខាន់ សម្រាប់បម្រើវិស័យកសិកម្ម ។

## ២៧. បុណ្យភេសជ្ជទាន

( សូមមើល ចាប ពិន ១៩៦៤ ទំព័រ ៤០-៤១ )

ការកុសលដែលធ្វើដោយវេរថ្នាំកែរោគ ប្រគេនព្រះសង្ឃហៅថា "បុណ្យភេជ្ជសទាន" ។

ក្នុងវិន័យបិដក មហាវគ្គត្រង់ភេសជ្ជកូន្ទកៈចែងថា : កាលព្រះដ៏មានព្រះភាគទ្រង់គង់នៅវត្តជេតពន ទ្រង់ជ្រាបថា ពួកភិក្ខុមានអាពាធ គ្រុនស្រៀវស្រាញក្នុងសរទកាល ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុ ទទួលភេសជ្ជៈ ៥យ៉ាងគឺ ទឹកដោះខាប់ ទឹកដោះរាវ ប្រេង ទឹកឃ្មុំ ទឹកអំពៅ របស់ទាំងអស់នេះជាភេសជ្ជៈផង គេសន្មតថាជាភេសជ្ជៈជាអាហាររបស់មនុស្សលោកផង ឱ្យភិក្ខុទទួលភេសជ្ជៈ ទាំង៥នេះ ក្នុងកាលគួរបរិភោគក្នុងកាលគួរ (តាំងពីពេលអរុណរះទៅទល់និងថ្ងៃត្រង់ ) ក៏បាន ក្នុងកាលមិនគួរ (តាំងពីពេលថ្ងៃជ្រេរពីត្រង់ទៅទល់នឹងអរុណរះ) ក៏បាន ។

លំដាប់តៗមក ទ្រង់អនុញ្ញាតវត្ថុជាភេសជ្ជៈច្រើនប្រការ ជាអាទិ៍គឺ

+ ពួកខ្លាញ់ មានខ្លាញ់ ខ្លាញ់ឃ្មុំ ខ្លាញ់ត្រីជាដើម
+ ពួកឫស មើម មានមើមរមៀត មើមខ្ញីជាដើម
+ ពួកទឹកចត់ មានទឹកចត់កើតពីដើមស្ដៅជាដើម
+ ពួកស្លឹក មានស្លឹកស្ដៅជាដើម
+ ពួកផ្លែ មានផ្លែ ជី ថ្មី ម្រេច ជាដើម
+ ពួកជ័រ មានជ័រហិង្គុ ជាដើម

- ទ្រង់អនុញ្ញាតកោស៤យ៉ាងគឺ ទឹកដោះស្រស់ ទឹកដោះជូរ ប្រេង ទឹកដោះខាប់ ទឹកដោះថ្លា ។
- ទ្រង់អនុញ្ញាតទឹកបាន ៨យ៉ាងគឺ ទឹកផ្លែស្វាយ ព្រីង ចេកមានគ្រាប់ ចេកឥតគ្រាប់ ស្រគំ ច័ន្ទនី ក្រអៅឈូក ម៉ាក់ប្រាង ។ ទឹកបាន៨យ៉ាងនេះត្រូវចំអិនដោយកំដៅថ្ងៃ

នឹងចំអិនដោយភ្លើងមិនគួរ ។ ឯរបៀបធ្វើ បើផ្លែស្វាយទុំ គប្បីចិតយកសាច់កិនឱ្យល្អិត លាយទឹកឆៅ ច្រោះដោយសំពត់យកទៅហាលថ្ងៃ ។ ៧យ៉ាងក្រៅពីនេះក៏គប្បីធ្វើរបៀបប្រហែលគ្នានេះដែរ ។

- ទ្រង់បញ្ញត្តិមិនឱ្យឆាន់ក្នុងវេលាវិកាល នូវមហាផល(ផ្លែឈើ) ៩យ៉ាងគឺ ផ្លែត្នោត ដូង ខ្នុរ សាកេ ឃ្លោក ត្រឡាច ត្រសក់ ឪឡឹក ល្ពៅ ។
- ទ្រង់អនុញ្ញាតឱ្យឆាន់ក្នុងវេលាវិកាល នូវទឹកឧទុកផល (ផ្លែឈើតូច) គ្រប់យ៉ាងមាន ផ្លែផ្តៅ អម្ពិល ក្រូច ពង្រ សង្ឃរ័ ជាដើម លើកលែងតែផ្លែដែលអនុឡោមតាមធញ្ញជាតិ គឺស្រូវ និងសណ្តែក ល្ង ចេញ ។
- ទ្រង់អនុញ្ញាតឱ្យឆាន់ទឹកស្លឹកឈើគ្រប់យ៉ាង វៀរលែងតែទឹកបន្លែឆ្អិនចេញ
- ទ្រង់អនុញ្ញាតឱ្យឆាន់ទឹកផ្កាឈើគ្រប់យ៉ាង វៀរលែងតែទឹកផ្កាស្រគំចេញ
- ទ្រង់អនុញ្ញាតឱ្យឆាន់ទឹកអំពៅ និងទឹកត្នោត

ឯស្លា បារី ទឹកតែ កាហ្វេ ទឹកកក ទឹកក្រូច ទឹកម៉ូណាត់ ស្ករស ស្ករត្នោត ស្ករក្រាម ស្ករតាំងស៊ិន លោកសង្គ្រោះចូលជាភេសជ្ជៈ ដែលទ្រង់អនុញ្ញាតដែរហៅថា អនុលោមភេសជ្ជៈ ។

បើទាយកត្រូវការធ្វើភេសជ្ជៈ ដូចពោលហើយនោះ ប្រគេនព្រះសង្ឃហៅថា ភេសជ្ជទាន ។ ពិធីភេសជ្ជៈទានមិនមានបែបបទច្រើនទេ បើទាយកចូលចិត្តធ្វើភេសជ្ជៈបែបណា ហើយបានចាត់ចែងធ្វើបែបនោះចង់យកទៅប្រគេនព្រះសង្ឃឯវត្តក៏បាន ចង់និមន្តព្រះសង្ឃមកផ្ទះរបស់ខ្លួនក៏បាន បើត្រូវការទៅធ្វើនៅឯវត្ត ត្រូវនាំភេសជ្ជៈទៅរៀបចំប្រគេនព្រះសង្ឃឯវត្ត បើត្រូវការធ្វើឯផ្ទះ ត្រូវរៀបចំទីសេនាសនៈ និងគ្រឿងដាក់ភេសជ្ជៈមានកែវជាដើមឯផ្ទះ ។ ហើយនិមន្តព្រះសង្ឃពីវត្តមកវេរប្រគេនឯផ្ទះ , កាលណាព្រះសង្ឃនិមន្តមកដល់ផ្ទះ ត្រូវទទួល បដិសណ្ឋារៈលោកដោយគោរព និមន្តលោកគង់លើអាសនៈ ដែលបានរៀបចំដោយប្រពៃ ហើយត្រូវនាំគ្នាវេរភេសជ្ជៈ ដែលខ្លួនត្រូវធ្វើគឺ ប្រើធ្វើទឹកអំពៅ ត្រូវវេរចេញទឹកអំពៅបើធ្វើ ទឹកឃ្មុំ ត្រូវវេរចេញឈ្មោះទឹកឃ្មុំ ។

# ២៨. បុណ្យសលាកភត្ត

( សូមមើល ចាប ពិន ប្រជុំបុណ្យ ១៩៦៤ ទំព័រ ៣៣)

ចង្ហាន់ដែលទាយកត្រូវធ្វើដោយពិធីចាប់ស្លាក ហៅថា " សលាកភត្ត " ។ បុណ្យនេះសម័យបច្ចុប្បន្ន ទាយកតែងធ្វើរៀងរាល់ឆ្នាំនៅខែពិសាខ-ជេស្ឋ ឬ អាសាធដែលជារដូវសម្បូរណ៍ផ្លែ ឈើផ្សេងៗ ។ សម័យពុទ្ធកាលទាយកធ្វើដោយឥតកំណត់កាល ស្រេចតែមានសទ្ធាកាលណាគេនាំគ្នាធ្វើកាលនោះ ។

## សលាកភត្តមានអង្គពីរគឺ

១- ការចាប់ស្លាកចំពោះលោកដែលសង្ឃចាត់មក

២- ទោះបានភិក្ខុចាស់ក្តី ក្មេងក្តី មិនសោមនស្ស មិនទោមនស្ស ។ លុះតែប្រកបដោយអង្គ២នេះ ទើបបានផលបរិបូរណ៍ ។

## ភាគពួកិច្ចនៃសលាកភត្តមាន៦ថ្នាក់គឺ :

១- កិច្ចផ្សាយដំណឹងសលាកភត្ត

២- កិច្ចចាត់ចែងភត្តាហារ និងទេយ្យទាន

៣- កិច្ចចាប់ស្លាក

៤- កិច្ចនមស្សការព្រះរតនត្រ័យ និងសមាទានសីល

៥- កិច្ចវេរសលាកភត្ត

៦- កិច្ចឧទ្ទិសផល

# ២៩. បុណ្យសង្ឃភត្ត

( សូមមើល ចាប ពិន ប្រជុំពិធីបុណ្យ ព.ស ២៥០៧ ទំព័រ ២៦-២៨)

បុណ្យសង្ឃភត្តគឺ ជាពិធីបុណ្យមួយនៃកុសលកិច្ច ដែលធ្វើឡើងដោយវេរចង្ហាន់ប្រគេនភិក្ខុតាំងពី ៤ អង្គឡើងទៅ ហៅថា " បុណ្យវេរសង្ឃភត្ត " ឬហៅថា " បុណ្យវេរចង្ហាន់សង្ឃ " ឬ ក៏អាចហៅថា " បុណ្យនិមន្តលោកឆាន់ " ក៏បាន ។

## ភាគតពុកិច្ចនៃសង្ឃភត្ត

បុណ្យវេរសង្ឃភត្ត និងធ្វើនៅទីវត្តក៏បាន នៅផ្ទះរបស់ទាយកក៏បាន ។ បុណ្យនេះទោះធ្វើនៅវត្តក្តី នៅផ្ទះក្តី មានកាតព្វកិច្ច ត្រូវចាត់ចែងជា ៦ ថ្នាក់ដូចតទៅគឺ

១-កិច្ចសុំនិមន្តលោកបដិគ្គាហកៈអំពីសង្ឃ

ទាយកត្រូវសុំនិមន្តលោកបដិគ្គាហកៈ ចំនួន ៤ អង្គឡើងទៅ អំពីលោកជាចៅអធិការវត្ត ឬ ជាភត្តុទ្ទេសក៍ ( អ្នកសម្តែងភត្ត) តម្រូវតាមពាក្យថា សង្ឃភត្ត ។

២-កិច្ចរៀបចំទីសេនាសនៈ និង ទេយ្យទាន

៣-កិច្ចទទួលលោកបដិគ្គាហកៈ ដែលសង្ឃចាត់មក

៤-កិច្ចនមស្សការព្រះរតនត្រ័យ និងសមាទានសីល

៥-កិច្ចវេរសង្ឃភត្ត និង ប្រគេនទេយ្យទាន ដល់ពេលវេរ គប្បីវេរ ៣ លើក

៦-កិច្ចឧទ្ទិសផល

សូមឧទ្ទិស ចំពោះដល់លោកអ្នកមានគុណទាំងឡាយ , មានមាតាបិតាជាដើម យើងខ្ញុំទាំងឡាយវេរ (នូវសង្ឃភត្ត) នេះ , ព្រមទាំងបរិក្ខារ , ប្រគេនដល់ព្រះសង្ឃ ,មានព្រះពុទ្ធជាប្រធាន សូមលោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមនោះ សំគាល់ (នូវសង្ឃភត្ត) នេះ ថា ដូចជារបស់នៃខ្លួន ហើយ សូមអនុមោទនាយកចុះ លុះអនុមោទនារួចហើយ សូមឱ្យរួចរំដោះ ចាកទុក្ខទាំងពួង ឱ្យបានសម្រេចដោយសម្បត្តិទាំងឡាយបីប្រការគឺ សម្បត្តិមនុស្សមួយ. សម្បត្តិ ទេវតាមួយ , សម្បត្តិព្រះនិព្វានមួយ , ដោយសមគួរតាមសេចក្តីប្រាថ្នារបស់លោកអ្នកដ៏មានគុណទាំងឡាយនោះ ដោយអំណាចផលានិសង្សដែលហួរជូនមកមិនដាច់នេះហោង។ ជាកិច្ចបញ្ចប់ពិធីបុណ្យ ។

## ៣០. បុណ្យឆ្លង

(សូមមើល ឃិន វ៉ន ប្រជុំបុញ្ញប្បវត្តិ គ.ស ១៩៦៧ ទំព័រ ៦១-៦៤)

ពិធីធ្វើបុណ្យឆ្លងនេះ គឺមានតាំងពីយូរយាណាស់មកហើយ ក្នុងព្រះពុទ្ធសាសនា ។ ពិធីធ្វើបុណ្យឆ្លងនេះ ពួកពុទ្ធបរិស័ទទាំងឡាយ បានធ្វើតៗមកគ្រប់បុណ្យមិនដែលឈប់ខានទេ សឹងតែរាល់ខែឆ្នាំ បើមិនអ្នកនេះ អ្នកនោះ ឱ្យតែមានសទ្ធាកសាងកិច្ចបុណ្យអ្វីមួយ ការធ្វើនោះ

បើតាមទម្លាប់របស់អ្នកប្រាជ្ញ ដែលធ្លាប់បានធ្វើត១ៗគ្នាមក មានពិធីដូច្នេះគឺយកផ្ដិលមួយយ៉ាង ធំមកបិទទៀន ៤ ភ្ជាប់នឹងមាត់ជាបញ្ញាកម្មដូចខាងក្រោមនេះ ។

អាចារ្យជាប្រធានក្នុងពិធីបុណ្យនោះ ត្រូវនិយាយពន្យល់ឱ្យអ្នកធ្វើបុណ្យទាំងឡាយ ស្ដាប់ថា ទៀន៤គឺជា អន្លង់ទាំង៤ មានកាមោឃៈ ជាដើម ឯភ្លើងដែលឆេះទៀននោះគឺ ភ្លើងទុក្ខ ភ្លើងកិលេស ទឹកក្នុងផ្ដិលនោះគឺ ទឹកអមតៈ មហានិព្វាន ដោយអំណាចផលបុណ្យដែលបាន ធ្វើនេះ សូមឱ្យបានសម្រេចដល់អមតៈ មហានិព្វាន ដើម្បីរំលត់នូវភ្លើងទុក្ខ ភ្លើងកិលេស លុះ ពន្យល់ចប់ហើយ លោកតាអាចារ្យបេះទៀនទាំង៤ ជ្រលក់ទៅក្នុងទឹកផ្ដិលឱ្យឃើញច្បាស់ថា មានតែទឹកអមតៈមហានិព្វានទេ ដែល អាចលត់ភ្លើងទុក្ខ ភ្លើងកិលេសបាន ។

ការដែលធ្វើបុណ្យអ្វីមួយ ហើយមានឆ្លងដូច្នេះ ដើម្បីបំពេញនូវអបរាបរចេតនាជាអង្គ ទី៣ របស់បុណ្យ មិនមែនខ្លាចទៅកើតជាសត្វតិរិច្ឆាន កង្កែប និងសីហៈនោះទេ។ ចំណែកក្បួនថា មិនបានឆ្លងទៅកើតជាសត្វ តិរិច្ឆាននោះជាក្បួនផ្ទុយហេតុផល យកជាប្រមាណមិនបាន ។ តាម ពិតព្រះសម្ពុទ្ធបរមគ្រូ ព្រះអង្គ ទ្រង់ប្រទានសិទ្ធិទុកមកដោយអធ្យាស្រ័យដ៏ពិសេសថា : ការ បំពេញកុសលទាំងអស់ក្នុងព្រះពុទ្ធសាសនា មានទេយ្យធម៌ដែលយើងរកបានមកដោយកម្លាំងហើយ ហើយនឹងត្រូវការឱ្យទៅជាទានក្នុងពេលណាមួយ , លោកកំណត់ត្រឹមតែការលះវត្ថុឱ្យផុតអំពី សេចក្ដីកំណាញ់ ហើយឱ្យទៅជាទាន ដរាបណា ដរាបនោះក៏បានឈ្មោះថា ធ្វើបុណ្យបានឆ្លង ហើយដែរ មិនចាំបាច់ធ្វើកិច្ចអ្វីឱ្យច្រើនហួសពីនោះទៅទៀតបាន ។

ហើយព្រះអង្គក៏ទ្រង់ពន្យល់អំពីអន្លង់ទាំង៤ទៀតគឺ កាមោឃៈ ១ , ភវោឃៈ ១ , អវិជ្ជោឃៈ ១ , ទិដ្ឋោឃៈ ១ ជាអន្លង់យ៉ាងធំ ដែលសត្វឆ្លងបានដោយកម្រ , ព្រោះអន្លង់ទាំង៤ នេះ បើទុកជាសត្វឆ្លងដោយសាឡាង កាណូត កុប៉ាល់ ទូកក្ដារជាដើម ក៏មិនអាចឆ្លងបានសោះ ឡើយ ព្រោះហេតុដូច្នេះបានជាព្រះអង្គទ្រង់ប្រទានឱ្យនូវយានជំនិះ ៤ យ៉ាងសម្រាប់ឆ្លងឱ្យផុត អំពីអន្លង់ ៤ នេះគឺ ÷

១- **សទ្ធាយតរតិឱឃំ** : សត្វឆ្លងអន្លង់ទៅបាន ដោយសារសទ្ធា

២- **អប្បមាទេន អណ្ណវំ** : សត្វឆ្លងសមុទ្រទៅបាន ដោយសារសេចក្ដីមិនធ្វេសប្រហែស

៣- **វិរិយេន ទុក្ខមច្ចេតិ** : សត្វឆ្លងសេចក្ដីទុក្ខទៅបាន ដោយសារសេចក្ដីព្យាយាម

៤- **បញ្ញាយ បរិសុជ្ឈតិ** : សត្វឆ្លងសេចក្តីមិនបរិសុទ្ធឱ្យបរិសុទ្ធបាន ដោយបញ្ញា

បើប្រសិនជាគ្រាន់តែធ្វើបុណ្យអ្វីមួយហើយមិនបានឆ្លង តើបានបុណ្យឬទេ ? មិនមែនទេការធ្វើដោយបរិសុទ្ធចិត្ត បានបុណ្យជានិច្ច ឱ្យតែធ្វើបុណ្យ ។ ឯបុណ្យដែលធ្វើហើយគ្មានពិធីឆ្លងនោះមានជាច្រើន ដូចជា ដាក់បាត្រមុខផ្ទះរាល់ថ្ងៃ និមន្តធម្មកថិកសំដែងធម៌ទេសនា ប្រគេនភេសជ្ជៈមានតែ ស្ក ជាដើម ។

## ៣១. ព្រះរាជពិធីច្រត់ព្រះនង្គ័ល

(សូមមើល ពិធីប្រចាំ១២ខែ របស់ ពេជ្រ សល់ ឆ្នាំ ១៩៦៦ ទំព័រ៣១-៣៥)

ថ្ងៃ ៤ រោច ខែ ពិសាខ ជាថ្ងៃដែលគេរៀបធ្វើព្រះរាជពិធីច្រត់ព្រះនង្គ័លជាឱឡាប្ញក ។ សម័យបុរាណ កាលណាបើព្រះមហាក្សត្រខ្មែរ ពុំទាន់ទ្រង់យាងចេញច្រត់ព្រះនង្គ័លទេ បណ្តារាស្ត្រស្រុកស្រែចំការពុំទាន់ហ៊ានចុះភ្ជួររាស់ទេ គេចាំស្តាប់ដំណឹងពីទីក្រុងសិន ។

ហេតុដែលនាំឱ្យព្រះរាជពិធីតម្រូវធ្វើនៅថ្ងៃ ៤ រោច ខែ ពិសាខ នោះនៅជាអាថ៌កំបាំងនៅឡើយ ប៉ុន្តែសព្វថ្ងៃនេះក៏ដោយ អ្នកស្រុកស្រែនៅតែនិយមរើសយកថ្ងៃល្អដើម្បីនឹងចុះភ្ជួរស្រែជាដំបូងដែ ។ តាមតម្រាខ្លះថា ថ្ងៃអាទិត្យចុះភ្ជួរស្រែលើកដំបូងល្អ ។ ចំណែកឯខាងព្រះរាជពិធីច្រត់ព្រះនង្គ័លវិញ ក៏ត្រូវរកថ្ងៃល្អ-អាក្រក់តាមក្បួនហោរាសាស្ត្រដែរ ។

ម្យ៉ាងទៀតគេច្រើនជឿថា នឹងចាប់ការអ្វីៗត្រូវរកថ្ងៃណាមួយខាងខ្នើត ដើម្បីឱ្យការនោះចេះតែចំរើនឡើង បីដូចជាព្រះច័ន្ទនៅលើអាកាសដែរ ។ ប៉ុន្តែការដែលព្រះរាជាទ្រង់ច្រត់ព្រះនង្គ័លនៅថ្ងៃ ៤ រោច ខែ ពិសាខនោះ នៅជាប្រស្នានៅឡើយ ។

ពីអតីតកាល ព្រះករុណាទ្រង់យាងភ្ជួរស្រែដោយព្រះអង្គឯង ក្នុងស្រែដ៏ពិសិដ្ឋមួយដូចជានៅក្នុងរឿងរាមកេរ្តិ៍ខ្មែរ និង សៀមនិយាយថា នៅពេលដែលព្រះបាទ **ជនក** ទ្រង់យាងច្រត់ព្រះនង្គ័លមាស ទ្រង់រើសបានទារិកាម្នាក់ ហើយទ្រង់ប្រទាននាមថា **សីតា** ដែលជាពាក្យសំស្ក្រឹតប្រែថា " អាចម៍បំណោះ " ក្រោយមកនាង **សីតា** ក៏បានព្រះ **រាម** ជាភស្តា ។ ក្នុងគម្ពីរព្រះពុទ្ធសាសនាបែបហីនយាននិយាយថា : កាលដែលព្រះពុទ្ធជាព្រះបរមគ្រូយើងនៅជារាជឱរសនៅឡើយ ពួកស្រីស្នំបានយកព្រះអង្គទៅជ្រកក្រោមម្លប់ដើមព្រីង នៅពេលដែលព្រះបិតា

ព្រះអង្គយាងច្រត់ព្រះនង្គ័ល ។ ពួកស្នំរវល់តែជក់ភ្នែកមើល ទំរាំតែនឹកឃើញព្រះ រាជកុមារព្រះអាទិត្យជ្រេទៅទិសបស្ចឹមទៅហើយ តែម្លប់ដើមព្រីងមិនជ្រេឃ្លាងឃ្លាតចោលស្រមោលទៅតាមដំណើរព្រះអាទិត្យទេ គឺនៅត្រង់គ្របពីលើព្រះរាជកុមារមិនឱ្យត្រូវកំដៅព្រះ អាទិត្យដដែល ។

អំណើះអំពីព្រះករុណាព្រះបាទ**អង្គឌួង**មក ព្រះរាជាខ្មែរទ្រង់ពុំច្រត់ព្រះនង្គ័លដោយព្រះអង្គឯងទេ ។ លោកមន្ត្រីក្រសួងកសិកម្មដែលមានងារជាឧកញ៉ាពលទេព ត្រូវចេញបំពេញភារកិច្ចជំនួសព្រះអង្គ។ ឯកតារបស់ឧកញ៉ាពលទេពនេះមានរូបទេព្តាកាន់កណ្តាប់ស្រូវជាសំគាល់ សព្វថ្ងៃភារៈនេះធ្លាក់ទៅលើមន្ត្រីខាងកសិកម្ម និងភរិយា ។ គេនិយម ហៅអ្នកដែលត្រូវបំពេញកិច្ចនោះថា " **ស្តេចមាឃ** "។ ឯប្រពន្ធស្តេចមាឃគេឱ្យឈ្មោះថា " **ម៉ែហូ** " (ម៉ែហូជាពាក្យសៀមដែលមានន័យថា មេលើត្បូង ) ។

ចាស់ៗបានដំណាលថា កាលជាន់ដើមកាលណាគេភ្ជួរស្រែមួយហើយ គេថែរក្សាស្រែនោះដោយផ្ចិតផ្ចង់រហូតដល់បានផលមែនទែន អ្នកផងនៅចាំថា ស្រែហ្លួងពីដើមស្ថិតនៅខាងលិចវត្តប្រយូរវង្ស ។ ក្នុងរជ្ជកាលព្រះករុណា**ព្រះស៊ីសុវត្ថិ** ពិធីច្រត់ព្រះនង្គ័លក៏ធ្វើនៅកន្លែងនោះដែរ ប៉ុន្តែពេលរហូតមក ដីផ្នែកខ្លះត្រង់កន្លែងនោះ ក៏ក្លាយទៅជាចំការច្បារដំណាំអស់ទៅ ។

នៅកន្លែងធ្វើពិធី គេសង់រោងមណ្ឌល ៥ សម្រាប់តម្កល់ទេវរូបនៅជុំវិញធ្លាដីដែលទុកសម្រាប់ភ្ជួរ ។ នៅថ្ងៃមួយរោច ខែពិសាខ ពេលជិតព្រលប់ក្រុមបារគូរៀបធ្វើពិធីសែនក្រុងពាលីដែលជាម្ចាស់ទឹកដី ដើម្បីសុំកន្លែងធ្វើពិធី ។ ថ្ងៃជាបន្ទាប់មកទៀតចំនួន២ថ្ងៃ នៅពេលព្រលប់ដូចគ្នា ពួកបារគូធ្វើហោមពិធី ។

ពាក្យថាពិធីក្នុងទីនេះមានន័យថា " ការរៀបចំ " ឬថា " កិច្ចធ្វើបុណ្យ " ។ ឯពាក្យថា ហោមបានសេចក្តីថា " ពលីការក្នុងរណ្តៅភ្លើង " ឬ " ការបូជាទេវតាដោយសាចទឹកដោះថ្លាក្នុងរណ្តៅភ្លើង " បើប្រែឱ្យខ្លីថា " ពិធីបូជាភ្លើង " ព្រោះទំនៀមនេះជាប្រពៃណីនៅប្រទេសឥណ្ឌាដែលធ្លាប់ធ្វើតាំងពីយូរអង្វែងណាស់មកហើយ ។ ប៉ុន្តែសព្វថ្ងៃនេះ ពួកព្រាហ្មណ៍ក្នុងកម្ពុជរដ្ឋយើងសង្ខេបពិធីត្រឹមតែធ្វើពលីការទេវរូប និងសូត្រប្រកាសទេវតា នៅរោងមណ្ឌលប៉ុណ្ណោះជាការស្រេច រីឯក្បួនច្បាប់សម្រាប់ធ្វើហោមពិធីមាននៅសល់ដល់សព្វថ្ងៃនេះ ។ នៅមុខរោងមណ្ឌលនីមួយៗមានពំនូកដីធ្វើជាបីថ្នាក់ នៅថ្នាក់លើបំផុតគេជីករណ្តៅដែលមានទំហំទទឹងមាត់

ប្រមាណជាមួយចំអាម និងមានជំរៅមួយចំអាមដែររួចគេយកអាចមិគោស្រស់ទៅបូករណ្ដៅនោះឱ្យស្អាត ។ គេយកសំពត់ស រុំស្រោបពំនូកដីទាំងពថ្នាក់ឱ្យជិត កុំឱ្យមើលឃើញដី រួចយកក្លស់មួយបាំងពីលើ ។ នៅក្នុងរណ្ដៅនោះ គេដុតភ្លើងបណ្ដើរ សូត្រគាថាបណ្ដើរ ។ អុសដែលប្រើដុតក្នុងពិធីត្រូវកាត់ជាកំណាត់ៗ ប្រវែង ៩ ធ្នាប់ចងជាបាច់ក្នុង១ បាច់មាន ៩ កំណាត់ ។ គេយកស្លឹកឈើផ្សេងៗ ដែលមានឈ្មោះជាសិរីមង្គលទៅជ្រលក់ក្នុងទឹកឃ្មុំ ក្នុងប្រេង រួចបង់ចូលទៅក្នុងរណ្ដៅភ្លើង ។ ឯទឹកដោះ ឬសប្បិគេប្រស់ឬចាក់បន្តិចម្ដងៗចូល ទៅក្នុងភ្លើងដែរ ។ សប្បិនិងទឹកដោះគោអាចប្រើផ្លាស់ប្ដូរគ្នាបាន ។ ភ្លើងហោមនោះត្រូវរំលត់ ដោយទឹកសង្ខ ។ នៅពេលដែលក្រុមបរោហិតធ្វើហោមពិធី គេត្រៀមនង្គ័ល និងគោឧសភរាជនៅទីដែលបម្រុងនិងភ្ជួរដើម្បីនឹងទទួលផលដ៏បរិសុទ្ធអំពីការបូជានោះ។ ម្យ៉ាងទៀតគួរកត់សំគាល់ថា នង្គ័លដែលប្រើក្នុងព្រះរាជពិធីនោះមានយាមដល់ទៅពីរ ចំណែកឯនង្គ័លរបស់ប្រជារាស្ត្រធម្មតា យាមតែមួយទេ ។

ដល់ថ្ងៃ ៤ រោច ខែពិសាខ ស្ដេចមាឃនិងព្រះម៉ែហួ ចូលទៅទីព្រះមេរុ ដោយក្បួនហែហើយចូលថ្វាយបង្គំរូបព្រះឥសូរក្នុងរោងពិធីទិសពាយ័ព្យ ក្រុមបារគូផ្លុំស័ង្ខ ៣ បទរួចស្ដេចមាឃចេញច្រត់ព្រះនង្គ័ល ក្បួនព្រះនង្គ័លចេញច្រត់ជាទក្ខិណាព័ត៌ ៣ជុំ ។ នង្គ័លកណ្ដាលជានង្គ័លស្ដេចមាឃ មាននង្គ័លមួយច្រត់ខាងមុខ នង្គ័លមួយទៀតច្រត់តាមពីក្រោយ ។ នង្គ័ល២នេះមានភ្នាក់ងាររាជការ ២នាក់ទៀតជាអ្នកកាន់ ។ ក្នុងខណៈកំពុងភ្ជួរនោះ ព្រះម៉ែហួចាប់ស្រូវពូជម្យ៉ាង ដែលល្អពិសេសជាងគេ ហៅថាស្រូវក្រយាសំពាន់ បាចព្រោចទៅឆ្វេងទៅស្ដាំដរាបដល់ឈប់ពិធីច្រត់ ។ តែក្នុង១ជុំៗពួកបាគូរផ្លុំស័ង្ខម្ដងជាសញ្ញា ។

លុះដល់ភ្ជួរគ្រប់៣ជុំហើយ ក្បួនព្រះនង្គ័លហែទៅឈប់នៅមុខរោងពិធីទិសបូព៌ ដែលមានតម្កល់រូបវិស្ណុ ហើយគេស្រាយគោចេញពីនឹម ។ នៅពេលនោះព្រាហ្មណ៍ ព្រះរាជគ្រូ ( ចាងហ្វាងក្រុមបាគូ ) សូត្រពាក្យអធិដ្ឋានផ្សងឱ្យគោនាំប្រផ្នូលល្អ ។ ព្រះរាជគ្រូយកទឹកមន្តទៅប្រោះក្បាលគោទាំង២ នៃព្រះនង្គ័ល ហើយលែងវាឱ្យទៅស៊ីរបស់ទាំង ៧ មុខ ដែលតម្កល់នៅលើតុប្រាក់តម្រៀបនៅមុខព្រះពន្លានៃព្រះករុណាមាន : ស្រូវ ពោត សណ្ដែក ល្ង ស្មៅស្រស់ ទឹក និងស្រា ។ ព្រាហ្មណ៍ទាយស្រុកទេសតាមរបស់ដែលគោនោះបរិភោគគឺថា បើគោស៊ីគ្រាប់អ្វីៗក្នុង

បណ្ដាគ្រាប់ដែលដាក់នៅទីនោះ ទាយថានឹងសម្បូណ៌ផលនោះ បើស៊ីស្មៅទាយថា នឹងមានកើតជំងឺរាតត្បាតសត្វពាហនៈ ។ បើផឹកទឹកទាយថា នឹងមានភ្លៀងច្រើន ហើយស្រុកទេសនឹងបានសុខសប្បាយ ។ ប៉ុន្តែបើគោបែរជាផឹកសុរាវិញ ទាយថានិងកើតមានមនុស្សពាលចោរលួច ចោរប្លន់ជាច្រើនក្នុងព្រះនគរ ។

## ៣២. បុណ្យអ្នកតា

(សូមមើលសៀវភៅ ពិធីប្រចាំ១២ខែ របស់ ពេជ្រ សល់ គ.ស ១៩៦៦ ទំព័រ ២៤-៣០)

នៅព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានៅស្រុកទៀតជាច្រើនដែរ គ្រប់ទីតំបន់ផ្សេងៗ ទោះបីស្រុកតូចក្តីធំក្តី តែងមានទេវភូតជាអ្នកចាំបាច់ថែរក្សាជាធម្មតា ។ ទេវភូតទាំងនោះអ្នកស្រុកហៅថា " **អ្នកតា** " ។ អ្នកតាខ្លះមានការត្រួតត្រាលើដីមួយដុំតូច មានស្រែ ឬ ភូមិមួយជាដើម ។ អ្នកតាខ្លះពូកែ ហើយមានមហិទ្ធិរិទ្ធគ្របដណ្តប់លើខេត្តមួយទាំងមូលក៏មាន ។ អ្នកតាខ្លះមានឈ្មោះថា " **ចាស់ស្រុក** " គឺថា ជាចាស់ទុំក្នុងស្រុក ឬជា " **ឃ្លាំងមឿង** " ប្រែថា " **កណ្តាលស្រុក** " ។ អ្នកតាខ្លះទៀតមានឈ្មោះហៅតាមដើមឈើ តាមស្រះ តាមបឹងបួរ ជាទីលំនៅដ្ឋានដែលខ្លួនតាំងនៅ ដូចជា អ្នកតា**ដំបងក្រញូង** អ្នកតា **ទ្វារ** ។ល។ ប៉ុន្តែមានអ្នកតាខ្លះយកឈ្មោះតាមទេវតាខាងព្រាហ្មណ៍សាសនាដែរ ហើយគេអាចសន្និដ្ឋានបានថា កន្លែងណាដែលមានអ្នកតា កន្លែងនោះកាលពីដើមមកប្រាកដជាមានព្រះវិហារតម្កល់ទេវរូប ដែលមានឈ្មោះដូចអ្នកតានោះដូចជា អ្នកតា **គគណេស** អ្នកតា **នរាយណ៍** ។ល។ ម្យ៉ាងទៀតនៅក្នុងអាស្រមអ្នកតានីមួយៗ គេតែងតែឃើញមានបំណែករូបបដិមាករបុរាណ ដែលអាចឱ្យគេសន្និដ្ឋានបានថា នៅកន្លែងនោះមានវិហារ ហើយដែលបានបាត់បង់អស់ទៅ ។

បុណ្យចំពោះអ្នកតា ជាបុណ្យរក្សាទុកនៅលំអានសាសនា ដែលមានចលនាវិវឌ្ឍន៍នៅប្រទេសកម្ពុជា ការគោរពចំពោះកម្លាំងធម្មជាតិ ជាលទ្ធិមួយដ៏ចាស់ផុតមុនដែលអារ្យធម៌ហិណ្ឌូ និង លទ្ធិព្រាហ្មញ្ញសាសនាបានចូលមក ហើយគេថែមទាំងបានសំគាល់ឃើញថា បច្ចុប្បន្នវិវត្តន៍នេះបណ្តាលឱ្យការគោរពសម័យបូរាណផ្លាស់សភាពទៅជាពិធីខាងព្រះពុទ្ធសាសនាសុទ្ធសាធវិញ ។

ភារៈសំខាន់របស់អ្នកតាក៏ត្រូវរាការពារសុខទុក្ខក្នុងអាណាខេត្តរបស់ខ្លួន ហេតុនេះ ហើយបានជានៅពេលមានជម្ងឺរាតត្បាត សត្វ ឬមនុស្ស ឬ នៅពេលរាំងភ្លៀង ម្តងៗអ្នកស្រុក តែងនាំគ្នាធ្វើពិធីឡើងអ្នកតា ហើយប្រហែលជាមកអំពីរឿងខាងលើនេះដែរ មើលទៅបានជាគេ ធ្វើពិធីឡើងអ្នកតា ក្នុងមួយឆ្នាំម្តងៗ នៅខែពិសាខ (មេសា-ឧសភា) ដែលជាខែដើមនៃរដូវធ្វើ ស្រែ ។ ប៉ុន្តែមានអ្នកស្រុកច្រើនដែរ ដែលនិយមឡើងនូវខែចែត្រ (មិនា-មេសា) ឬខែ ជេស្ឋ (ឧសភា-មិថុនា) ។

នៅក្នុងចំណោមអ្នកតារក្សាស្រុកចាស់ៗ មានអ្នកតាមួយនៅស្រុកបាភ្នំ ខេត្តព្រៃវែង ឈ្មោះ **អ្នកតាមេស** ។ គេយល់ថា បាភ្នំជាភ្នំ **វ្យាធបុរៈ** ដែលអ្នកប្រវត្តិសាស្ត្រជាតិចិនតែងនិយាយថា ក្នុងសតវត្សទី ៥ ព្រះឥសូរបានចុះមកផ្សាយតេជានុភាពដ៏អស្ចារ្យរបស់លោកមក លើភ្នំនេះ ។ សព្វថ្ងៃនេះមានរូបសំណាកបាក់បែកមួយជាតំណាងអ្នកតាដែលមានក្បាច់ចម្លាក់ បែបសម័យមុន អង្គគឺជា រូបរាង **ខ្មោ** ផ្តាញ់មារ **មហិង្សាសុរ** ។

ចាស់ៗតែងតំណាលថា បានឮឪពុកម្តាយ និយាយប្រាប់ថា : កាលជំនាន់ដើមគេធ្លាប់ សម្លាប់មនុស្សបូជាអ្នកតានោះ។ ប៉ុន្តែក្រោយមកគេពិឃាដក្របីឡើងកថ្វាយអ្នកតាជំនួសវិញ។ នៅពេលដែលគេយកដាវទៅវាត់ផ្តាច់កក្របី គេកំណត់យកអាការៈឈាមបាញ់ចេញជាទំនាយ ទឹកភ្លៀងក្នុងស្រុក គឺថាបើឈាមបាញ់ទៅទិសខាងណាច្រើន ទៅទិសខាងណាតិច គេអាច សំគាល់បានថា តំបន់ណាមានភ្លៀងច្រើន បានផលច្រើន តំបន់ណាមានភ្លៀងតិច បានផលតិច ។

សព្វថ្ងៃនេះគេឈប់សម្លាប់ក្របីទៀតហើយ គេយកជ្រូកដែលចិនសម្លាប់ស្រាប់យក ទៅថ្វាយ ហើយពិធីឡើងអ្នកតាត្រូវធ្វើនៅខែ ជេស្ឋរាល់ៗឆ្នាំ ។ ក្នុងតំបន់ជាមួយគ្នានោះ អ្នក តាឯទៀតក៏ត្រូវរៀបចំពិធីឡើងជាមួយគ្នាដែរ ។ អ្នកស្រុកថ្វាយព្រលឹងរៀបដាក់ចាន មានគ្រប សាជីពណិ តម្រូវតាមចិត្តអ្នកតានោះ ។ លើកំពូលសាជីមានដាក់អំបោះឆៅមួយប៉ោយសម្រាប់ ចងដៃពួកភ្នាក់ងាររាជការខេត្តនោះ ដើម្បីឱ្យមានការទាក់ទងយ៉ាងជិតស្និទ្ធ ជាមួយនឹងអ្នកតា រក្សាស្រុក ។ អ្នកតា **ឃ្លាំងមឿង** នៅខេត្តពោធិសាត់គឺ ជាអ្នកតាមួយដែលខ្មែរទូទាំងប្រទេស ស្គាល់ជាងគេ ។ ចំពោះអ្នកតានេះមានដំណាលថា កាលចុងសតវត្សទី ១៦ ព្រះបាទ **ជ័យជេដ្ឋា** កាលទ្រង់គង់នៅឯបន្ទាយជ័យ កាលនោះសៀមនិងខ្មែរកើតចម្បាំងនិងគ្នា កងទ័ពខ្មែរត្រូវ

បរាជ័យ ព្រះករុណាព្រួយព្រះហឫទ័យយ៉ាងខ្លាំង ឃើញដូច្នោះ លោក **សួគ៌ា** លោកចៅហ្វាយខេត្តពោធិសាត់ ចូលខ្លួនបូជាខ្លួនទៅកេណ្ឌទ័ពខ្មោចមកជាជំនួយព្រះមហាក្សត្រ ។ ថាហើយលោកចៅហ្វាយខេត្តនោះ បង្គាប់ឱ្យគេជីករណ្ដៅ១ ហើយឱ្យគេយកគ្រឿងសាស្ត្រាវុធគ្រប់បែបយ៉ាងមកដាក់ក្នុងរណ្ដៅចម្រុះគ្នា ។ លុះរៀបស្រេចកាលណាគេធ្វើពិធីបួងសួងរួចលោក **សួគ៌ា** លោកក៏លោតចុះទៅក្នុងរណ្ដៅនោះភ្លាម ប្រពន្ធក៏លោតសម្លាប់ខ្លួនតាមប្ដីដែរ ។ អ្នកផងក៏លុបដីគ្របខ្មោចនោះភ្លាមទៅ ។ ក្រោយមកទ័ពសៀមក៏ចូលមកឡោមព័ទ្ធបន្ទាយខ្មែរស្រាប់តែឮសូរសន្ធឹកអ៊ឹមឡាំងសម្បើមក្នុងរាត្រីនោះ ។ ហើយទ័ពសៀមដួលស្លាប់រណោករណូកបីដូចគេបាលរៀត ។ នេះហើយជាពលខ្មោចដែលចៅហ្វាយខេត្តសុំខ្លួនទៅកេណ្ឌមកជួយប្រទេសកម្ពុជា ឱ្យរួចពីភយន្តរាយ ។

ចាប់តាំងពីពេលនោះមក តែដល់ពេលខែពិសាខរៀងរាល់ឆ្នាំ គេតែងតែធ្វើបុណ្យរំលឹកចំពោះការបូជាជីវិតរបស់លោកចៅហ្វាយខេត្តនៅកន្លែងខ្មោចរបស់លោក។ ឯរបៀបបញ្ជាន់រូបអ្នកតា បើកាលណារូបអ្នកស្រុកសុំឱ្យមានភ្លៀងធ្លាក់ច្រើន ។ រូបស្នឹងដែលគេហៅនោះ ចេះតែរាំលុះត្រាតែញើសចេញហៀរពេញទាំងខ្លួនដូចគេងូតទឹកទើបឈប់ ។ ប៉ុន្តែបើគេត្រូវការសុំសេចក្ដីសុខវិញ ត្រូវផ្ទុកសំណែនទាំងឡាយលើសង្កឹក ហើយនាំយកទៅបញ្ជោរចោលនៅទីមួយឆ្ងាយអំពីភូមិស្រុក ដើម្បីបញ្ចៀសខ្មោចព្រាយបិសាច កុំឱ្យមកយាយីអ្នកស្រុក អ្នកភូមិ ។

នៅខេត្តកំពង់ធំ អ្នកស្រុកធ្វើពិធីឡើងអ្នកតានៅខែ ជេស្ឋដែរ ខេត្តនោះមានអ្នកតាមួយក្រុមនៅក្នុងព្រៃក្នុងឃុំនិលពេជ្រ ។ អ្នកតាសំខាន់ជាងគេគឺ អ្នកតាស្រីដែលមានរូបបដិមាស្រីជំទង់ រាងស្គមមួយជាតំណាង ហើយមានអ្នកតាបរិវា ៦ នាក់ទៀតជាជំនួយមើលការខុសត្រូវក្នុងតំបន់នោះ ។ នៅពេលធ្វើពិធី គេរៀបសែនបួងសួងចំពោះអ្នកតាស្រីធំដំបូងដើម្បីសុំចូលព្រៃកាប់ឈើកុំឱ្យមានគ្រោះថ្នាក់អ្វី ។ រួចគេឱ្យភ្លេងប្រគុំឡើង ដើម្បីនឹងនាំគ្នាពូនភ្នំខ្សាច់ ។ ដល់ពេលរសៀលគេរៀបបញ្ជាន់រូបសំណើង ហើយអ្នកតាទាំងអម្បាលម៉ាននោះចូលទៅជាន់រូប គេមានរៀបរណ្ដាប់សម្រាប់រូបដូចជាសំពត់អាវឆ្នៀងស្ពាយ គ្រឿងអលង្ការ ប្រេង ម្សៅ ក្រាស់ កញ្ចក់ ។ល។ ដែលជាប្រដាប់ខ្លួន ព្រោះអ្នកតាធំជាស្រី ។ លុះអ្នកតាចូលរូបកាលណា អ្នកស្រុកបែរបន់សុំសុខសប្បាយ រូបដែលជាន់នោះក៏ឆ្លើយតបទៅអ្នកស្រុកវិញ ដូចមនុស្សធម្មតាប្រាស្រ័យគ្នា ។

មានអ្នកតាខ្លះតម្រូវឱ្យធ្វើពិធីយ៉ាងអធិកអធមនៅពេលឡើងម្តងៗ ដូចជាអ្នកតាមួយនៅខាងដែនខ្មែរក្រោម (**ភូសាំងស៊ីន**) ។ អ្នកតានោះឈ្មោះអ្នកតា **សំពៅធ្លាយ** ។ នៅពេលឡើងអ្នកតា គេអុជទៀនបិទនៅថ្ងអ្នកតា រួចគេវាយស្គរធំបីបទ គេចាក់ស្រាសែនចំពោះមុខអ្នកតា ៣ ដង រួចហើយគេយកស្រាស្រោចលើថ្មអ្នកតានោះទៀត ។ គេចាប់យកម្ហូបក្បាលជ្រូក ទានំគ្រប់មុខ ដាក់ក្នុងសំពៅស្រទបចេក បញ្ជូរបញ្ជូនខ្មោច បិសាចចង្រៃ ឱ្យទៅផុតអំពីស្រុកភូមិ។ បន្ទាប់ពីនោះគេយកអំបោះទៅចងដៃកូនចៅ ចងកគោក្របី ដើម្បីឱ្យបានសេចក្តីសុខ ។ ភ្លេងក៏ចេះតែលេងកំដរ រហូតដល់ចប់ពិធីនោះទៅ ។

**<u>កំណត់:</u> តាមរឿងរ៉ាវដែលយើងបានអធិប្បាយមកខាងលើនេះ ជនជាតិខ្មែរជាអ្នកប្រពៃណីនិយម ហើយនៅចេះចាំរក្សាទំនៀមទម្លាប់ ព្រមទាំងរឿងរ៉ាវបរមបូរាណផង ។ នេះជារបបជំនឿម្ចាស់ស្រុករបស់ខ្មែរយើងកើតមានតាំងពីមុន គ.ស មកម្ល៉េះគឺសម័យមុនលាយឡំសាសនាបរទេស ហើយ ជំនឿនេះរស់មានជីវិតរហូតបច្ចុប្បន្ន ។**

## ៣៣. បុណ្យសង្ឃទាន

(សូមមើល ចាប ពិន ប្រជុំពិធីបុណ្យ ព.ស ២៥០៧ ទំព័រ ១៨-២៤)

ការធ្វើសង្ឃទានលុះតែប្រកបដោយអង្គទាំង២ នោះទើបឈ្មោះថា ជាសង្ឃទានពេញលក្ខណៈ ។ បណ្តាអង្គទាំង២នេះ អង្គទី១ ទាយកងាយធ្វើបាន ។ ឯអង្គទី២ ទាយកមិនងាយធ្វើបានទេ ព្រោះការធ្វើសង្ឃទាន ទាយកត្រូវចូលទៅវត្តទូលសុំសង្ឃអំពីភិក្ខុថា ជាចៅអធិការ ឬជាភត្តុទ្ទេសក៏ថា " សូមលោកម្ចាស់មេត្តាចាត់ព្រះថេរៈ១អង្គ អំពីសង្ឃទានឯផ្ទះខ្ញុំករុណា " ។ កាលទាយកសុំព្រះថេរៈហើយ បើបែរជាបានសាមណេរមកវិញ ក៏អាក់អន់ចិត្តដោយគ្រាន់តែនឹកអន់ចិត្តថា " ឱ អញបានតាមណេរ " តែប៉ុណ្ណេះក៏ទានរបស់ទាយកនោះមិនឈ្មោះថា សង្ឃទានទេ ។ មួយទៀតបើសុំ ព្រះថេរៈ តែបែរជាបានមហាថេរ ហើយគ្រាន់តែនឹកត្រេកអរថា " ឱ អញបានមហាថេរ " ប៉ុណ្ណេះក៏មិនឈ្មោះថា សង្ឃទានបរិសុទ្ធដែរ , លុះតែទាយកណាបានបដិគ្គាហកៈណាមួយ ទោះបីជាសាមណេរក្តី ភិក្ខុក្តី ក្មេងក្តី ចាស់ក្តី ល្ងង់ក្តី ចេះដឹងអំពីសង្ឃទាន ហើយមិន

អាក់អន់ចិត្ត មិនរង្កៀសចិត្ត អាចតាំងចិត្តគោរពកោតខ្លាចឧទ្ទិសចំពោះសង្ឃបាននោះទើបឈ្មោះសង្ឃទានពេញលក្ខណៈពិតប្រាដក ។

## សង្ឃទានមាន ៧ ប្រភេទ

សម័យពុទ្ធកាលទាយកធ្វើសង្ឃទានមាន ៧ ប្រភេទគឺ ÷

១- ទានប្រគេនចំពោះ ភិក្ខុសង្ឃ និងភិក្ខុនីសង្ឃមានព្រះពុទ្ធជាប្រធាន

២- ទានប្រគេនចំពោះ ឧភតោសង្ឃ ក្នុងកាលដែលព្រះតថាគតបរិនិព្វានហើយ

៣- ទានប្រគេនចំពោះ ភិក្ខុសង្ឃ

៤- ទានប្រគេនចំពោះ ភិក្ខុនីសង្ឃ

៥- ទានប្រគេនចំពោះ ភិក្ខុដែលគេនិមន្តយកអំពីសំណាក់ ឧភតោសង្ឃ

៦- ទានប្រគេនចំពោះ ភិក្ខុដែលនិមន្តយកអំពីសំណាក់ ភិក្ខុសង្ឃ

៧- ទានធ្វើដោយសុំសង្ឃឱ្យបញ្ជូនភិក្ខុ ឬ សាមណេរណាមួយនៅឯផ្ទះរបស់ខ្លួន ហើយប្រគេនទេយ្យទានចំពោះភិក្ខុ ឬ សាមណេររូបនោះដោយឧទ្ទិសចំពោះសង្ឃ ។

សម័យបច្ចុប្បន្ន ទាយកធ្វើសង្ឃទានមិនបានគ្រប់ទាំង ៧ ប្រភេទទេ បានតែចំពោះភិក្ខុសង្ឃ១ប្រភេទ ព្រោះពេលនេះគ្មានភិក្ខុនីគឺ ទាយកធ្វើបានតែចំពោះភិក្ខុ ឬ សាមណេរដែលសង្ឃចាត់មកតាមពាក្យសុំរបស់ខ្លួន និងចំពោះព្រះភក្ត្រព្រះពុទ្ធបដិមាករស្នងព្រះពុទ្ធអង្គប៉ុណ្ណោះ តែការធ្វើសង្ឃទានដល់ភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន ដូច្នេះក៏អនុលោមចូលក្នុងការធ្វើសង្ឃទានមានព្រះពុទ្ធផ្ទាល់ព្រះអង្គជាប្រធានដែរ ព្រោះត្រូវតាមប្រភេទទី២នៃសង្ឃទានដូចបានចែងក្នុងមាតិកាខាងដើម ។

## + អង្គនៃសង្ឃទាន

អដ្ឋកថាទក្ខិណាវិភង្គសូត្រមានចែងថា អង្គនៃសង្ឃទានមាន២គឺ :

១-ទាយកបានសុំនិមន្តលោកបដិគ្គាហកៈ អំពីសង្ឃ

២-កាលលោកបដិគ្គាហកៈ និមន្តមក បានតាំងចិត្តចំពោះសង្ឃ

ទានក្នុងព្រះពុទ្ធសាសនាមាន២ចំពូកគឺ :

១-ទានដែលប្រគេនចំពោះភិក្ខុ ឬ សាមណេរ ១រូប១តាមចិត្តស្រឡាញ់ហៅថា បាដិបុគ្គ លិកទាន ។

២-ទានប្រគេនចំពោះព្រះសង្ឃគឺ ភិក្ខុតាំងពី ៤ រូបឡើងទៅ ហៅថា សង្ឃទាន។ បណ្តាទានទាំង២ចំពូក សង្ឃទាន មានផលានិសង្សច្រើនលើសលុបជាងបាដិបុគ្គលិកទាន ព្រោះជាទានដ៏ឧត្តម នាំឱ្យសង្ឃក្នុងព្រះពុទ្ធសាសនាមានសាមគ្គីគ្នា ជាហេតុនាំឱ្យព្រះពុទ្ធសាសនាមានសេចក្តីរុងរឿង ។

+ **ភាគពូកិច្ចនៃសង្ឃទាន**

តាមប្រពៃណីពីបុរាណកាលមក ទាយកតែងធ្វើសង្ឃទានដោយរបៀបរៀបចំដែលចាត់ជាកិច្ចមាន ៦ ថ្នាក់គឺ ÷

១- **កិច្ចសុំនិមន្តលោកបដិគ្គាហកៈអំពីសង្ឃ** :

កាលបើទាយកត្រូវការធ្វើសង្ឃទានគប្បីទៅសុំនិមន្តបដិគ្គាហកៈអំពីសង្ឃឱ្យត្រឹមត្រូវតាមរបៀបសង្ឃទាន ទើបបានជាសង្ឃទាន ពេញលក្ខណៈ ។ ការសុំនិមន្តបដិគ្គាហកៈអំពីសង្ឃនោះ ទោះបីសុំនិមន្តប៉ុន្មានអង្គក៏បានតាមត្រូវការ ហើយទូលសុំនិមន្តចំពោះតែថ្ងៃត្រូវការធ្វើក៏បាន ទូលសុំនិមន្តម្តង ទុកធ្វើរាល់ថ្ងៃសីលជាយូរថ្ងៃខែឆ្នាំតទៅ គឺថា ដល់ថ្ងៃសីល កាលណាឱ្យនិមន្តទៅមិនបាច់យកទៅនិមន្តទៀតក៏បាន ហើយការសុំនិមន្តនោះ ត្រូវទូលសុំអំពីលោកគ្រូចៅអធិការវត្ត ឬអំពីភិក្ខុជាភត្តុទ្ទេសក៏ (លោកអ្នកចាត់ការរឿងភត្ត ដែលជំនុំសង្ឃតាំងឱ្យជាអ្នកចាត់)ឱ្យលោកចាត់ឱ្យក៏បាន។ ម្ចាស់ទានមិនត្រូវនិមន្តផ្ទាល់ខ្លួនចំពោះភិក្ខុ ឬសាមណេរណាមួយដែលខ្លួនស្គាល់ ឬ ស្រឡាញ់ទេ បើនិមន្តដូច្នេះទាននឹងទៅជា បាដិបុគ្គលិកទាន ។ ឯពាក្យទូលសុំនិមន្តបដិគ្គាហកៈអំពីសង្ឃនោះទាយកត្រូវទូលសុំ និមន្តថា " សូមលោកម្ចាស់ មេត្តាចាត់ភិក្ខុ (ឬសាមណេរ) ១ រូប (ឬ ២ រូប)ណាមួយទៅទទួលសង្ឃទានផ្ទះខ្ញុំព្រះករុណាក្នុងថ្ងៃនេះវេលា ព្រឹកម៉ោង" ។

**២- កិច្ចរៀបចំទីសេនាសនៈនិងទេយ្យទាន :**

ក្រោយពីសុំនិមន្តលោកបដិគ្គាហកៈអំពីសង្ឃហើយ ក្នុងពេលដែលត្រូវការ ត្រូវរៀបទីសេនាសនៈជាកន្លែង ដែលត្រូវធ្វើសង្ឃទានគឺរៀបចំតាំងអាសនៈព្រះពុទ្ធរូប មានគ្រឿងសក្ការៈបូជា រៀបក្រាលកន្ទេល កម្រាល ខ្នើយ កន្តោរ ផ្តិលទឹក ថូផ្កា ហើយនឹង គ្រឿងភេសជ្ជៈ មានទឹកតែ ស្ករ ស្លា ម្លូ បារី ជាដើម ដាក់រៀបរយតាម ជួរ កន្ទេល ដែលក្រាលកម្រាលយ៉ាងស្អាតសម្រាប់ប្រគេនលោកឆាន់ ។

**៣- កិច្ចទទួលលោកបដិគ្គាហកៈដែលសង្ឃចាត់ឱ្យមក :**

កាលភិក្ខុ ឬ សាមណេរ ជាបដិគ្គាហកៈដែលសង្ឃចាត់និមន្តដល់គ្រឹះស្ថានរបស់ខ្លួនហើយទាយកជាម្ចាស់ទាន ឬ អ្នកតំណាងម្នាក់ គប្បីក្រោកចេញទៅទទួលលោកនៅត្រង់មុខផ្ទះ ឬ ទ្វាររបងភូមិ និមន្តលោកចូលផ្ទះ លុះលោកនិមន្តដល់ ជណ្តើរផ្ទះ ត្រូវយកទឹកលាងព្រះបាទលោក ហើយជូតដោយសំពត់ស្ងួតស្អាត ឬ គ្រាន់តែយកសំពត់ស្អាតជូតព្រះបាទលោក ឱ្យជ្រះធូលីក៏បាន ហើយនិមន្តលោកចូលទៅគង់លើអាសនៈដែលរៀបចំហើយដោយប្រពៃនោះ ។

**៤- កិច្ចនមស្សការព្រះរតនត្រ័យ និងសមាទានសីល :**

លុះលោកជាបដិគ្គាហកៈ គង់លើអាសនៈស្រួលបួលហើយ ត្រូវនាំគ្នាថ្វាយបង្គំលោកដោយគោរព ហើយចូលប្រគេនភេសជ្ជៈដល់លោក រួចត្រូវឱ្យជួសដោះចង្ហាន់ដាក់ចានធំៗសម្រាប់រាប់បាត្រ ព្រមទាំងជួសបង្អែម ចំអាប ដាក់ក្នុងចានស្រាក់សម្រាប់ប្រគេនលោកក្នុងពេលវេរបាលីហើយ ។ វត្ថុទាំងនោះត្រូវយកមកតម្កល់ចំពោះព្រះភក្ត្រ លោកជាបដិគ្គាហកៈ ដែលមានព្រះពុទ្ធរូបស្ដែងព្រះអង្គជាប្រមុខក្នុងទីនោះ ហើយនាំគ្នាអុជទៀនធូប រួចសូត្រថ្វាយបង្គំព្រះ តាមបែបសង្ខេបក៏បាន ពិស្តាក៏បាន ចប់ហើយអារាធនានិច្ចសីល ឬ ឧបោសថសីលតាមថ្ងៃ ដែលធ្វើ គឺបើធ្វើក្រៅពីថ្ងៃសីលត្រូវអារាធនានិច្ចសីល បើធ្វើត្រូវលើថ្ងៃសីលគប្បីអារាធនាឧបោសថសីល ។

**៥- កិច្ចវេរសង្ឃទាន និងប្រគេនទេយ្យទាន**

**៦- កិច្ចឧទ្ទិសផល** : ជាបញ្ចប់បុណ្យ ។

# ៣៤. បុណ្យបច្ច័យ៤

(សូមមើល ចាប ពិន ប្រជុំពិធីបុណ្យ ព.ស ២៥០៧ ទំព័រ ៧១-៧៤)

ការធ្វើបុណ្យដែលធ្វើដោយវេរបច្ច័យ (គ្រឿងអាស្រ័យរបស់បព្វជិត) គ្រប់ទាំង៤មុខ ប្រគេន ព្រះសង្ឃហៅថា បុណ្យបច្ច័យ ៤ ។

បច្ច័យ៤គឺអ្វីខ្លះ ? បច្ច័យ៤ គឺ :

១-គ្រឿងស្លៀកដណ្តប់ គឺស្បង់ចីពរ សង្ឃាដី អង្សក វត្តពន្ធ កាយពន្ធ កន្សែងដណ្តប់ កន្សែងជូតមុខ កន្សែងជូតដៃជាដើម រហូតដល់សំពត់បិទបូសរុំដំបៅ ទទឹង ៤ធ្នាប់ បណ្តោយ ៨ ធ្នាប់ ជាទីបំផុតហៅថា ចីវរប្បច្ច័យ ។

២-គ្រឿងឆាន់គឺ បាយ សម្ល ម្ហូបគ្រឿម ម្ហូមស្រស់ ប្រហុក ផ្អក អំបិល ត្រីងៀត ត្រីឆ្អើរ ជាដើម ព្រមទាំងគ្រឿងប្រដាប់សម្រាប់ដាក់ចង្ហាន់ មានស្លាបព្រា ចានថ្ម ចានស្រោក់ តុ ចាស ជាដើមហៅថា បិណ្ឌបាតប្បច្ច័យ ។

៣-គ្រឿងដេកអង្គុយមាន កន្ទេល ខ្នើយ មុង ឆ័ត្រ ស្បែកជើង កុដិ សាលា វិហារ តុ កៅអីជាដើមហៅថា សេនាសនប្បច្ច័យ ។

៤-គ្រឿងថ្នាំព្យាបាលជំងឺ មានថ្នាំបុក គល្លិកា ក្រមួន កុឡា ប្រេងខ្យល់ ថ្នាំជក់ ថ្នាំឬត ថ្នាំលាប ថ្នាំចាក់ តែ ស្ករ ស្លា បារី ជាដើម ហៅថា គិលានភេសជ្ជប្បច្ច័យ ។

ទាយកដែលត្រូវការធ្វើបុណ្យបច្ច័យ៤ ត្រូវធ្វើគ្រប់ទាំង៤មុខ គឺគប្បីលៃធ្វើតាមសមត្ថភាព របស់ខ្លួនបើអាចធ្វើប៉ុណ្ណាបានក៏ធ្វើប៉ុណ្ណោះ ទោះបីតិចតួចឱ្យតែគ្រប់ទាំង៤មុខដូចរៀបរាប់តទៅ នេះ ÷

- មុខគ្រឿងចីវរ សូម្បីតែសាដក ១ ឬ ស្បង់ ១ ក៏បាន
- មុខគ្រឿងឆាន់ សូម្បីតែចង្ហាន់ ១ ឆ្នែត ក៏បាន
- មុខគ្រឿងសេនាសនៈ សូម្បីតែកន្ទេល ១ ឬ ខ្នើយ ១ ក៏បាន
- មុខគ្រឿងភេសជ្ជៈ សូម្បីតែប្រេងខ្យល់ ១ ដប ក៏បាន

សូមជ្រាបថាបើធ្វើតូច ក្នុងបច្ច័យមួយៗក៏តិច តែទោះបីតិចក៏គប្បីឱ្យគ្រប់៤មុខដូចពោលមកហើយបើអាចធ្វើធំហើយក្នុង១មុខៗ ច្រើនបាន ក៏រិតតែបានផលច្រើនតាមចំនួន ។

ដើម្បីឱ្យងាយកងាយយល់ ក្នុងកិច្ចធ្វើពិធីបុណ្យបច្ច័យ៤សូមពន្យល់របៀបធ្វើដូចតទៅនេះ :

## + ភាគពួកិច្ចនៃបុណ្យបច្ច័យ ៤

ពិធីបុណ្យបច្ច័យ ៤ មានកិច្ចត្រូវចាត់ចែងធ្វើជា ៦ ថ្នាក់គឺ :

១- កិច្ចសុំនិមន្តលោកបដិគ្គាហកៈអំពីសង្ឃ

២- កិច្ចរៀបចំទីសេនាសនៈ និងទេយ្យទាន : ការរៀបចំទីសេនាសនៈក្នុងពិធីបុណ្យ បច្ច័យ ៤ ដ៏ដូចក្នុងពិធីបុណ្យសង្ឃទានដែរ ប្លែកតែទេយ្យទានគឺ ពិធីបុណ្យបច្ច័យ៤នេះ ត្រូវរៀបចំបច្ច័យ៤គឺ ÷

បើចង់ធ្វើបច្ច័យធុនកណ្តាល ហើយនិមន្តលោក៤អង្គ ត្រូវរៀបបច្ច័យនីមួយ១៤ ប្រដាប់សម្រាប់ប្រគេនលោក១ ប្រដាប់១អង្គគឺ :

ក-មុខចីវរប្បច្ច័យ ឱ្យមានចីវរ ១ ត្រៃគឺស្បង់ចីពរសង្ឃាដីក៏បានតែ១ លៀងគឺស្បង់១ ចីពរ១ ក៏បានតែស្បង់១ ឬសាដក ១ក៏បាន ។

ខ-មុខបិណ្ឌបាតប្បច្ច័យឱ្យមានបាយ និងម្ហូប បង្អែម ព្រមទាំងអាហារូបករណ៍ មានចានថ្ម ចានស្រាក់ ស្លាបព្រា កំសៀវទឹក កែវទឹក ថូទឹក ជាដើម ។

គ-មុខសេនាសនប្បច្ច័យ ឱ្យមានកន្ទេល ខ្នើយ មុង ឆ័ត្រ ស្បែកជើង ជាដើម ។

ឃ-មុខគិលានភេសជ្ជប្បច្ច័យ ឱ្យមានប្រេងខ្យល់ ប្រេងកូឡា តែ ស្ករ បារីជាដើម ។

*ទាំង៤មុខនេះរៀបជា ១ ប្រដាប់ ក្នុងប្រដាប់នីមួយៗឱ្យមានសៀវភៅធម៌ សៀវភៅសរសេរ ទឹកខ្មៅ ខ្មៅដៃ ដងប៉ាកកាព្រមទាំងស្លាប បន្ទាត់ ជ័រលុប ច្រាស់ដុសធ្មេញ ថ្នាំដុសធ្មេញ ជាដើម ។ រៀបហើយត្រូវខ្ចប់ដោយក្រដាស់ភ្លឺៗ ចងបូរជាក្បាច់រំលេចពណ៌ឱ្យល្អស្អាត ហើយយកទាំង៤ ប្រដាប់នោះទៅដម្កល់ចំពោះព្រះភក្ត្រព្រះសង្ឃទាំង៤អង្គ នៅវេលា ចម្រើនព្រះបរិត្តទេសនាពី ល្ងាចផង ព្រឹកឡើងពេលវេរផង ។

៣- កិច្ចទទួលលោកបដិគ្គាហកៈដែលសង្ឃចាត់មក

៤- កិច្ចនមស្សការព្រះរតនត្រ័យ សមាទានសីល សូត្រមន្ត ទេសនា

៥- កិច្ចវេរបច្ច័យ ៤ នឹង ប្រគេនទេយ្យទាន : ព្រឹកឡើងពេលម៉ោង ៨ ឬ ៩ដែលព្រះសង្ឃ

និមន្តមកដល់ ហើយ ក្រោយពីនមស្សការព្រះរតនត្រ័យ សមាទានសីល អ្នកដើមការបុណ្យព្រម ទាំងញាតិមិត្តត្រូវនាំគ្នាកាន់គ្រឿងប្រដាប់បុណ្យឡើង ហើយអ្នកដើមបុណ្យឬអាចារ្យ តាំងនមោ ៣បទ រួចវេរបច្ច័យទាំង៤នេះទៅ ។

៦- កិច្ចឧទ្ទិសផល

## ៣៥. ពិធីត្រស្តិសង្ក្រាន

(សូមមើលសៀវភៅ ពិធីប្រចាំ១២ខែរបស់ ពេជ្រ សល់ គ.ស ១៩៦៦ ទំព័រ ៨៩-៩១)

នៅចុងខែផល្គុណ គឺនៅពេលជិតចូលឆ្នាំថ្មី នៅក្នុងព្រះបរមរាជវាំងមានធ្វើពិធីត្រស្តិសង្ក្រាន្ត ពិធីនេះខាងទំនៀមរាស្ត្រពុំមានធ្វើអ្វីទេ ។

ដើម្បីធ្វើពិធីនេះ គេសង់រោងមណ្ឌលស្លឹកប្រាំគី រោង ៤ខ្នងនៅក្រៅកំពែងព្រះបរមរាជវាំង ប្រចាំទិសធំទាំង ៤ និងរោងមួយខ្នងទៀតនៅមុខព្រះទីនាំងទេវាវិនិច្ឆ័យ សម្រាប់ឱ្យបារគូសូត្រមន្តអាគមបណ្តេញខ្មោចបិសាច និងកំចាត់ចង្រៃផ្សេងៗ ក្នុងឆ្នាំចាស់ឱ្យអស់ចេញ ។ មានខ្សែសីមាធ្វើដោយអំបោះ និង ស្បូវភ្លាំងព័ទ្ធជុំវិញកំពែងព្រះបរមរាជវាំង ។ ទំនៀមអ្នកស្រុកយើងតែងប្រើស្បូវភ្លាំងជាជំនួសស្បូវ " ទភិ " ដែលពួកព្រាហ្មណ៍ច្រើនប្រើក្នុងពិធីផ្សេងៗ ។ អំបោះសីមានោះព័ទ្ធតាំងពីទ្វារខាងកើតនៃព្រះបរមរាជវាំងមកដល់រោងមណ្ឌលទាំង៤ ហើយទើបបង្ហូតចូលទៅក្នុងព្រះបរមរាជវាំងតាមទ្វារខាងត្បូង រួចបញ្ចូលទៅព័ទ្ធមួយជុំព្រះទីនាំងទេវាវិនិច្ឆ័យ ទើបទៅព័ទ្ធស៊ុមទៀន ៧ ជុំកំពូលស៊ុមគ្រែ ព្រះរាជពិធី ៧ ជុំទៀតទើបបង្ហូតចុងអំបោះសីមាទៅប្រគេនព្រះសង្ឃកាន់សូត្រព្រះបរិត្តនៅវេលា យប់ ។

ព្រះករុណាទ្រង់យាងអុជទៀនជ័យ នៅចំពោះព្រះភ័ក្ត្រសម្តេចព្រះសង្ឃរាជ ទៀននោះត្រូវរក្សាឱ្យឆេះដរាបរហូតដល់ចប់ពិធី ។ ចំណែកឯព្រះបញ្ចក្សេត្រ ព្រះខ័ន្ធរាជ្យ លំពែងតាត្រសក់ផ្អែម* គ្រឿងអាវុធ រងដទៃៗ និងសន្លឹកមាសដែលមានចាឬកប្រវត្តិព្រះករុណាដោយសង្ខេប ក៏ត្រូវអញ្ជើញមកតាំងក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ក្នុងឱកាសនោះរហូតដល់ចប់ពិធីដែរ ។

---

* មានដំណាលថា : តាត្រសក់ផ្អែម ជាត្រសក់ផ្អែមណាស់ ទើបព្រះរាជាទ្រង់ព្រះរាជទាន លំពែងមួយ ដើម្បីការពារចោរលួចត្រសក ។ ដោយព្រះរាជាចង់ជ្រាបថា : តើនេះមើលថែទាំត្រសក់មែន ឬទេ ? ទ្រង់ក៏លបចូលទៅលួចត្រសក់គាត់សាល្បងមើល ពេលនោះតា

ប៉ុន្តែរបស់ដែលមានលក្ខណៈប្លែកក្នុងបុណ្យនេះគឺ " ដំបងពេជ្រ " សម្រាប់បណ្តេញខ្មោច បិសាច ឱ្យបវវៀសចៀសឆ្ងាយទៅ ។ " ដំបងពេជ្រ " នេះធ្វើដោយស្លឹកកំពូលត្នោតក្ងួចចុងម្ខាង និងមានសរសេរមន្តអាគមលើស្លឹកនោះផង ។ គេធ្វើ " ដំបងពេជ្រ " បែបនេះរាប់រយដើមសម្រាប់ ចែកជូនពួកនាម៉ឺន សព្វមុខមន្ត្រី និងភ្ញៀវម្នាក់ៗម្នាក់ ។ មិនតែប៉ុណ្ណោះ ភ្ញៀវត្រូវបានទទួលខ្សែ អភិសមរ១ ខ្សែម្នាក់ៗ មកពាក់ឈាងលើស្មាទៀត។ ខ្សែនោះធ្វើដោយអំបោះឆៅមានចងស្លឹកត្នោតបត់ជា៤ជ្រុង ចងជា៩អន្លើ ថែមទាំងមានសរសេរអក្សរមន្តផង ។

របស់ទាំងពីរបែបខាងលើនេះ មានប្រើតែក្នុងពិធីត្រស្តិសង្ក្រាន្តទេ ។ ឯអំបោះភ្លុកមានរាងជារង្វេលសម្រាប់ពាក់នៅក្បាល ដែលគេចែកក្នុងពិធីនោះដែរ មិនមែនប្រើតែក្នុងពិធីត្រស្តិសង្ក្រាន្តទេ នៅពិធីដទៃទៀត ដូចជាពិធីកំចាត់ចង្រៃ ឬ ពិធីកោរជុកក៏មានប្រើដែរ ។

របស់ទាំងបីមុខគឺ អំបោះភ្លុក ដំបងពេជ្រ និងខ្សែអភិសមរ គេត្រូវចែកយប់ទី២ ។ យប់នោះពួកភ្ញៀវ ដែលចូលទៅជួបជុំទាំងប៉ុន្មាន ពាក់អំបោះភ្លុក ពាក់ខ្សែអភិសមរ និងកាន់ដំបងពេជ្រគ្រប់គ្នា អង្គុយស្តាប់ព្រះសង្ឃចំរើនព្រះបរិត្តបណ្តេញខ្មោចបិសាច ។

តាំងពីដើមរៀងមក រហូតមកដល់ឆ្នាំ១៨៨៩ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់បាញ់មួយកាំភ្លើងដំបូងជាសញ្ញាដល់ពួកអ្នកបាញ់កាំភ្លើងធំ ដែលត្រៀមចាំនៅខាងក្រៅព្រះបរមរាជវាំង ដែលត្រូវបាញ់តទៅទៀតទាល់ព្រឹក ។

ព្រឹកថ្ងៃបង្ហើយ ព្រះករុណាជាម្ចាស់ជីវិតលើត្បូង ទ្រង់យាងស្រង់ព្រះសុគន្ធវារី ព្រះពុទ្ធមន្តយ៉ាងមហាឡាឬក មានបារគូថ្វាយស័ង្ខផង ។ បន្ទាប់ពីនោះមក ទ្រង់ស្តេចយាងលត់ទៀនជ័យជាមួយសម្តេចព្រះសង្ឃរាជ ។

ដល់ល្ងាច ព្រះថេរៈដែលចាស់វស្សាជាងគេ ត្រូវនិមន្តបាចសាចទឹកព្រះពុទ្ធមន្តពេញក្នុងព្រះបរមរាជវាំង ដើម្បីកំចាត់ឧបទ្រព្យចង្រៃនៃឆ្នាំចាស់ចេញ ឱ្យអស់អំពីផ្ទៃព្រះបរមរាជវាំង ។ សព្វថ្ងៃពិធីនេះហៅថា ពិធី ភាណយក្ខ ឬ ពិធីសូត្រភាណយក្ខ ។

---

ត្រសក់ក៏ស្មានថាចោរ ក៏ពួយលំពែងត្រូវព្រះរាជា ទ្រង់ទទួលទិវង្គតមួយរំពេច ។ ទើបគេនាំគ្នាលើកតាត្រសក់ផ្អែមឱ្យសោយរាជ្យស្នងព្រះអង្គទៅ ។

# ៣៦. បុណ្យផ្កា

(សូមមើល ចាប ពិន ប្រជុំពិធីបុណ្យ ព.ស ២៥០៧ ទំព័រ ៦០-៦៣)

បុណ្យផ្កាគឺជាពិធីមួយដែលធ្វើឡើងដោយមានផ្កាជាសម្ភារៈ ។ បុណ្យផ្កាមានពីរបែបគឺៈ

១- បុណ្យផ្ការុក្ខជាតិ និង ផ្កាវារីជាតិ គឺគេបេះផ្កាឈើ និង ផ្កាឈូកមកថ្វាយព្រះពុទ្ធរូប

២- បុណ្យផ្កាប្រាក់ គឺគេសន្មតប្រាក់ជាផ្កាបវារណាចំពោះព្រះសង្ឃដើម្បីសាងអ្វីមួយ ។

ប្រទេសខ្មែរសម័យបុរាណ ពុទ្ធបរិស័ទ ទាំងព្រះរាជា ទាំងប្រជារាស្ត្រ តែងទ្រង់ធ្វើ តែងធ្វើបុណ្យផ្ការុក្ខជាតិ និង ផ្កាវារីជាតិយ៉ាងឧឡារិក គឺប្រជារាស្ត្រតែងធ្វើនៅខែប្រាំង រវាងខែ មាឃ ផល្គុន ចេត្រ គេនាំគ្នាបេះផ្ការុក្ខជាតិ និង វារីជាតិ មានផ្កាម្លិះ និង ផ្កាឈូកជាដើម យក មកចងក្រងហែរទៅថ្វាយព្រះពុទ្ធរូបនៅព្រះវិហារវត្តជិតគ្នា ព្រះរាជាតែងទ្រង់ធ្វើនៅខែវស្សា គឺក្នុងថ្ងៃ១៥កើត ខែស្រាពណ៍ ដោយទ្រង់ស្តេចយាងទៅក្រសាលបឹងតាមព្រះទីនាំងនាវា ទ្រង់ ព្រះរាជបញ្ជាឱ្យបេះផ្កាឈូកស ក្រហម ផ្កាព្រលិត រំចង់ ស៊ប្បង្គជ យកមកថ្វាយព្រះក្នុងព្រះរាជ មន្ទីរ ហើយនឹងទ្រង់ចាត់ឱ្យ ហែដោយក្បួនហែមហោឡារិកទៅថ្វាយព្រះពុទ្ធបដិមាករ គ្រប់ អារាមហ្លួងហៅថាព្រះរាជពីធីបេះផ្កាឈូកថ្វាយព្រះ ។

ចំណែកពិធីរាស្ត្រ តាមដែលធ្លាប់បានឃើញមក អ្នកស្រុកខ្លះគេបេះផ្ការុក្ខជាតិមានម្លិះ រួត ម្លិះលា ជាដើម និងផ្កាវារីជាតិមាន ផ្កាឈូកស ក្រហម ព្រលិត រំចង់ជាដើមមកចងជា កម្រង ជាភ្នួង ព្រមទាំងអាហារូបករណ៍ជាអាទិ៍គឺ ចេក អំបុក និងគ្រឿងសម្ភារៈផ្សេងៗដង្ហែ ទៅចូល ក្នុងវត្តនៅជិតគ្នា ដែលធ្លាប់ទាក់ទងគ្នា ហើយយកផ្កាទាំងនោះទៅថ្វាយព្រះពុទ្ធរូបក្នុង ព្រះវិហារវត្តនោះ ក្រៅពីថ្វាយបង្គំព្រះហើយ គេនិមន្តសាមណេរមួយ ឬ ២ អង្គ សូត្រថ្វាយផ្កាថា " បូទម ក្រពុំរីក មានចិត្តត្រេកអរកាច់មក ថ្វាយ បូទមក្រពុំថ្វាយ បន្ទន់កាយកប់កេសរ ។ល។ " ដូច្នេះជាដើម ចប់ហើយអ្នកស្រុកជើង វត្ត គេរៀបចំភោជនីយអាហារទទួលភ្ញៀវ ។ បន្ទាប់ពី នោះគេឈប់សម្រាក ហើយនៅពេលត្រជាក់មុននិងលាគ្នាទៅវិញ ទាំងអ្នកស្រុកជើងវត្ត ទាំង អ្នកភ្ញៀវគេ នាំគ្នាលេងល្បែងប្រជាប្រិយផ្សេងៗ មានល្បែង ឈូង បុកកញ្ជ្រោ និង ប្របកៃ ជា ដើមយ៉ាង សប្បាយទាំងអស់គ្នា ហើយអ្នកហែផ្កាមកគេថ្វាយបង្គំលាព្រះសង្ឃ សំពះលាអ្នក ស្រុកជើងវត្ត នោះត្រឡប់ទៅស្រុកវិញ ដោយនាំយកសេចក្តីសប្បាយទៅផង ។

តាមការស្រាវជ្រាវ ពិធីបុណ្យផ្ការុក្ខជាតិនេះ មិនច្បាស់ជាថាកើតមានសតវត្សទីប៉ុន្មាន ឬ រជ្ជកាលណាទេ ឃើញតែក្នុងព្រះរាជពង្សាវតាកម្ពុជាថា " នៅរជ្ជកាលព្រះករុណាបរមកោដ្ឋ មានព្រះរាជពិធីបេះផ្កាឈូកថ្វាយព្រះក្នុងព្រះអារាមហ្លួង " ហើយនិងក្នុងសាស្ត្រស្លឹករឿងស្តេចក្មេងថា សម័យព្រេងនាយ មានក្មេងឃ្វាលគោមួយក្រុមបាននាំគ្នាបេះផ្កាឈើផ្សេងៗដង្ហែទៅថ្វាយព្រះពុទ្ធរូប នៅព្រះវិហារវត្តមួយ ក្រោយពីនោះក្មេងជាមេបានជាស្តេច ។ល។

តាមរឿងនេះឃើញថា នៅប្រទេសខ្មែរយើង សម័យបុរាណមានធ្វើពិធីបុណ្យផ្ការុក្ខជាតិ ធំដុំដាច់ដោយឡែក តែក្នុងសម័យបច្ចុប្បន្នឃើញធ្វើតែបន្តិចបន្តួចជាមួយផ្កាប្រាក់ ជាបុណ្យធំដុំ ព្រោះរួបរួមបច្ច័យកសាង ថាវរវត្តផ្សេងៗ ទាំងខាងពុទ្ធចក្រ ទាំងខាងអាណាចក្រ ជាការកសាងសាសនា និងប្រទេសជាតិឱ្យរុងរឿង ។

គម្ពីរបាលី មុត្តកវិនិច្ឆ័យ ត្រង់ភេសជ្ជៈ ករណាទិវិនិច្ឆ័យកថា មានចែងថា បានឮថាព្រះបុទុមត្ថេរ កាលណារោគកើតឡើងដល់ព្រះរាជទេពីនៃព្រះមហាក្សត្រីជាដើមជាទីស្និទ្ធស្នាល និងលោក ហើយព្រះរាជាបានចាត់ស្ត្រីបំរើម្នាក់ឱ្យមកសួរថ្នាំ លោកមិនប្រាប់ថា ចេះមិនចេះទេ ត្រឡប់ជាចរចារ និងពួកភិក្ខុថា ម្នាលអនុសោ បើរោគដូចនេះកើតឡើងដល់ភិក្ខុ តើគេតែងប្រើថ្នាំអ្វី ? ពួកភិក្ខុបានតបវិញថា " តែងយកថ្នាំនេះមួយៗ " ។ ស្ត្រីបំរើបានឮ ក៏យកដំណឹងនោះទៅក្រាបទូលព្រះរាជា ។ ព្រះរាជាដឹងពួក សេវកាមាត្យ បានជ្រាបសេចក្តីនោះ ក៏ចាត់ចែងថ្នាំនោះព្យាបាលរោគព្រះរាជទេពី ។ កាលរោគនោះជាសះស្បើយ ព្រះរាជានិង សេវកាមាត្យ បានយកចីវរមួយត្រៃ និងប្រាក់ ៣០០ គហាបណៈ ដាក់ក្នុងប្រអប់មួយនាំទៅតម្កល់ទុកទៀបបាទមូលនៃព្រះមហាបទុមត្ថេរ ហើយបវារណាថា " បពិត្រព្រះករុណាម្ចាស់ដ៏ ចំរើន សូមព្រះករុណាម្ចាស់ ចាត់ចែងផ្កាបូជា ( ព្រះពុទ្ធរូប ) ចុះ " ។ ព្រះមហាបទុមត្ថេរបាន ទទួលដោយ តុញ្ហីភាព រួចគិតថា " រូបិយវត្ថុ១ចំណែកនេះជាចំណែកអាចារ្យ " ។ លុះគិតហើយ ទើបញ៉ាំងអាចារ្យនោះឱ្យទទួលយកនូវចំណែកនោះដោយកប្បិយវោហារ សល់ពីនោះលោក ចាត់ចែងផ្កាបូជាព្រះពុទ្ធរូប ។

ប្រហែលជាពុទ្ធសាសនិកជន យកតម្រាប់តាមរឿងនេះបានជាគេធ្វើបុណ្យផ្ការុក្ខជាតិ និងផ្កាប្រាក់ ជាពុទ្ធបូជាជាប់ប្រពៃណីរៀងមក ហើយអ្នកមានសទ្ធាចង់សាង ថាវរវត្ថុមានកុដិ វិហារ សាលាបុណ្យ សាលារៀន ស្ពាន ស្រះជាដើម ដែលជារបស់ត្រូវចាយ ប្រាក់រាប់ពាន់រាប់

ម៉ឺន តែធនធានខ្លួនមានតិច មិនអាចសាងម្នាក់ឯងកើត ក៏ផ្ដើមជាបុណ្យផ្កាឡើង ដើម្បីអង្គាសប្រាក់ញាតិមិត្ត ឱ្យចូលជួយកសាងវត្ថុនោះ ៗ តាមកម្លាំងសទ្ធាផង , តែតាមទម្លាប់ស្រុកយើងទោះបីអ្នកមានធនធានច្រើនដែលអាចកសាងតែម្នាក់ឯងបាន ក៏តែងផ្សាយដំណឹងបុណ្យនោះដល់ញាតិមិត្តជិតឆ្ងាយ ឱ្យជួយឧបត្ថម្ភផង ។

## ៣៧. បុណ្យមតកភត្ត

( សូមមើល ចាប ពិន ប្រជុំពិធីបុណ្យ ព.ស. ២៥០៧ ទំព័រ ២៨-២៩ )

បុណ្យមតកភត្តគឺ ជាកិច្ចបុណ្យដែលទាយកធ្វើដោយវេរចង្ហាន់ប្រគេនព្រះសង្ឃ ឧទ្ទិសផលបញ្ជូនទៅបុគ្គលិកដែលស្លាប់ ហៅថា " បុណ្យវេរមតកភត្ត " តែតាមទម្លាប់អ្នកស្រុកហៅថា " បុណ្យដារ " ព្រោះសម័យបុរាណ ព្រះសង្ឃដែលនិមន្តមកសូត្រក្នុងពេលនោះ តែងសូត្រធម៌ពិស្ដារ ពីបាលីព្រះអភិធម្ម ៧ គម្ពីរបែបវែង ដែលចាស់ៗតែងហៅកាត់យកតែអក្សរ១តួខាងចុងថា " ធមិដារ " គឺបុណ្យដារបញ្ជូនផលទៅឱ្យខ្មោច ។

បុណ្យនេះគេតែងធ្វើនៅពេលដែលមានបុគ្គលជាញាតិ មានមាតាបិតាជាដើម ស្លាប់រវាង១ថ្ងៃ ឬ ២ថ្ងៃម្ដង ៣ថ្ងៃម្ដង ៧ថ្ងៃម្ដង ១០០ថ្ងៃម្ដង ហើយនិងតពីនោះរាល់ឆ្នាំទៅទៀតគឺធ្វើ១ខួបម្ដង ចំលើថ្ងៃខែដែលបុគ្គលនោះស្លាប់ ។

### I- ភាគពុកិច្ចនៃមតកភត្ត

កិច្ចដែលត្រូវធ្វើបុណ្យនេះចាត់ជា ៦ ថ្នាក់គឺ

១- កិច្ចសុំនិមន្តលោកបដិគ្គាហកៈអំពីសង្ឃ

២- កិច្ចរៀបចំទីសេនាសនៈនិងទេយ្យទាន

៣- កិច្ចទទួលលោកបដិគ្គាហកៈ ដែលសង្ឃចាត់មក

៤- កិច្ចនមស្សការព្រះរតនត្រ័យ និងសមាទានសីល

៥- កិច្ចវេរសង្ឃភត និងប្រគេនទេយ្យទាន

៦- កិច្ចឧទ្ទិសផល

បណ្ដាកិច្ចទាំង៦ថ្នាក់នេះ ថ្នាក់ទី១ . ៣ . ៤ និង ៦ ដូចកិច្ចក្នុងពិធីបុណ្យសង្ឃទាន ប្លែកតែត្រង់ថ្នាក់ទី ២ និង ថ្នាក់ទី ៥ ។

+ ថ្នាក់ទី២ កិច្ចរៀបចំទីសេនាសនៈ និងទេយ្យទាន

+ ថ្នាក់ទី៥ កិច្ចវេរមតកភត្តបង្សុកូល និង ប្រគេនទេយ្យទាន

+ ថ្នាក់ទី៦ កិច្ចឧទ្ទិសផលជាកិច្ចបញ្ចប់ពិធីបុណ្យ

## ៣៨. បុណ្យវេរសាដកនៅរដូវចូលឆ្នាំ

( សូមមើល ចាប ពិន ១៩៦៤ ទំព័រ ៧៧-៧៨)

ការបុណ្យដែលទាយកធ្វើដោយប្រគេនសំពត់ងូតទឹកចំពោះព្រះសង្ឃហៅថា " បុណ្យវេរសាដក " ឬ អ្នកខ្លះហៅថា " បុណ្យនិមន្តលោកឆាន់ប្រគេនសាដក " ព្រោះតាំងពីបូរាណកាលមក ពុទ្ធបរិស័ទជាតិខ្មែរតែងនិមន្តព្រះសង្ឃឆាន់ ប្រគេនសាដក ស្រង់ទឹកព្រះសង្ឃស្រង់ព្រះផ្នូតមាតាបិតា ជីដូនជីតានៅរដូវចូលឆ្នាំគឺ រវាងខែ ចេត្រ និងពិសាខ ឬ ចំលើថ្ងៃចូលឆ្នាំទាំងបីថ្ងៃ ឬថ្ងៃណាមួយ ។

បុណ្យនេះអ្នកខ្លះគេទៅរួមធ្វើនៅវត្ត អ្នកខ្លះធ្វើនៅផ្ទះ ទោះបីធ្វើនៅវត្តក្ដី នៅផ្ទះក្ដី ក៏មានពិធីត្រូវគ្នា ខុសតែទីកន្លែងប៉ុណ្ណោះ ។ ទីនេះសូមពណ៌នាតែពីរបៀបធ្វើនៅផ្ទះដូចតទៅ :

### ភាគពូកិច្ចនៃបុណ្យវេរសាដក

បើធ្វើនៅផ្ទះ គេចាត់ការដោយកិច្ចមាន៧ថ្នាក់គឺ

១- កិច្ចធ្វើសាដក

២- កិច្ចនិមន្តលោកបដិគ្គាហកៈអំពីសង្ឃ

៣- កិច្ចរៀបចំទីសេនាសនៈ និងទេយ្យទាន

៤- កិច្ចទទួលលោកបដិគ្គាហកៈ ដែលសង្ឃចាត់មក

៥- កិច្ចនមស្សការព្រះរតនត្រ័យ សមាទានសីលសូត្រមន្ត-ទេសនា

៦- កិច្ចវេរសាដក . ស្រង់ទឹក . វេរចង្ហាន់ .

៧- កិច្ចឧទ្ទិសផល

# ៣៩. អំពីសង្ឃកម្ម

( សូមមើល ញ៉ាន ភឿន - លោក ម៉ម ឆៃ លំអានទំនៀមខ្មែរបូរាណ

ព.ស ២៥៤៦ គ.ស ២០០២ ទំព័រ ១៦៩ -១៧៣ )

សង្ឃកម្ម គឺការងាររបស់សង្ឃ ដែលក្រុមភិក្ខុរួមគ្នាអនុមតិធ្វើដោយការព្រមព្រៀង។ សង្ឃដែលត្រូវធ្វើសង្ឃកម្ម នីមួយៗនោះលោកបញ្ញត្តិចំនួនភិក្ខុជាក្រុមជាវគ្គចំនួន ៥ វគ្គ ឬ ៥ ពួកគឺ :

១- **សង្ឃចតុវគ្គ** ប្រជុំភិក្ខុ៤ អង្គឬ ការកសង្ឃចំនួន ៤ រូង អាចធ្វើសង្ឃកម្មគ្រប់យ៉ាងបាន លើកលែងតែ **បវារណាកម្ម១ កឋិនកម្ម១ ឧបសម្បទានកម្ម១ អព្ភានកម្ម១** ។ ( សង្ឃកម្មទាំងបួននេះសម្រេចដោយភិក្ខុ ៤ អង្គមិនបាន ) ។

២- **សង្ឃបញ្ចវគ្គ** ប្រជុំភិក្ខុ ៥ អង្គ ឬ ការកសង្ឃចំនួន ៥ រូបអាចធ្វើសង្ឃកម្មបានគ្រប់យ៉ាង លើកលែងតែ **ឧបសម្បទាកម្ម** ក្នុងមជ្ឈិមប្រទេស និង **អព្ភានកម្ម១** ចេញគឺពួកភិក្ខុ ៥ រូប ប្រជុំធ្វើកម្ម ពីរយ៉ាងនេះមិនបាន ។

៣- **សង្ឃទសវគ្គ** ប្រជុំភិក្ខុ ១០អង្គ អាចធ្វើសង្ឃកម្មគ្រប់យ៉ាងបានលើកលែងតែ **អព្ភានកម្ម១** មិនអាចធ្វើបានឡើយ ។

៤- **សង្ឃវីសតិវគ្គ** ប្រជុំភិក្ខុ ២០ អង្គ អាចធ្វើសង្ឃកម្មគ្រប់ប្រការបានមិនមានទាស់ ។

៥- **សង្ឃអតិរេកវីសតិវគ្គ** ប្រជុំភិក្ខុលើសអំពី ២០ អង្គឡើងទៅ ធ្វើសង្ឃកម្មគ្រប់យ៉ាងបានដ៏ប្រពៃ ។

**សង្ឃកម្ម** ទាំងអស់នេះ បើពោលអំពីពិធីដែលសង្ឃត្រូវធ្វើ ( សូត្រ ) មាន៤យ៉ាងគឺ :

១. **អបលោកនកម្ម** សង្ឃកម្មដែលភិក្ខុសង្ឃធ្វើដោយគ្រាន់តែ សូត្រប្រកាស ( អបលោកន៍ ) មិនមានសូត្រកម្មវាចាឡើយ ។

២. **ញត្តិកម្ម** សង្ឃកម្មដែលសង្ឃធ្វើ គ្រាន់តែសូត្រតាំងញត្តិជាការស្រេច មិនមានសូត្រអនុស្សាវនា១ផង ។

៣. **ញត្តិទុតិយកម្ម** សង្ឃកម្មដែលសង្ឃធ្វើ ដោយសូត្រកម្មវាចាពីរគឺ តាំងញត្តិ១ និង អនុស្សាវនា ១ផង ។

៤. **ញត្តិចតុត្ថកម្ម** សង្ឃកម្មដែលសង្ឃធ្វើដោយកម្មវាចា ៤ គឺការតាំងញត្តិ ១ និង អនុស្សាវនា ៣ ទៀត ។

**បញ្ជាក់ :** គ្រប់សង្ឃកម្មទាំងអស់នោះធ្វើដោយអបលោកនកម្មក្តី ដោយញត្តិកម្ម ឬ ញត្តិទុតិយកម្ម ឬក៏ដោយញត្តិចតុត្ថកម្មក្តី ត្រូវតែធ្វើដោយអនុមតិរបស់សង្ឃ ដែលព្រមព្រៀងគ្នា ។ម្យ៉ាងទៀត កម្មដែលធ្វើដោយអបលោកនកម្ម មិនអាចយកធ្វើដោយញត្តិកម្មទេ ធ្វើដោយញត្តិកម្មមិនអាចធ្វើដោយញត្តិទុតិយកម្ម ឬ ដោយញត្តិចតុកម្មឡើយ គឺថា សង្ឃកម្មគ្រប់ប្រភេទ ដែលត្រូវធ្វើកម្មណា ធ្វើបានតែតាមវិធីកម្មនោះធ្វើជំនួសគ្នាមិនបាន ។

សង្ឃកម្មគ្រប់យ៉ាង ទោះធ្វើដោយអបលោកនកម្មទាំងប៉ុន្មានក្តី ធ្វើដោយញត្តិកម្មចំនួនប៉ុន្មានក្តី ធ្វើដោយញត្តិទុតិយកម្មចំនួនប៉ុន្មានក្តី ធ្វើដោយញត្តិចតុត្ថកម្មចំនួនប៉ុន្មានក្តី ការធ្វើសង្ឃកម្មទាំងអស់នោះ ត្រូវតែធ្វើឱ្យត្រឹមត្រូវតាមពុទ្ធានុញ្ញាត គឺធ្វើឱ្យបានជា **ធម្មសមគ្គ** ( ព្រមព្រៀងគ្នាប្រកបដោយធមិ ) ទើបបានឈ្មោះថា **ជាធម្មកម្ម វិនយកម្ម** ( ត្រូវតាមធមិ ត្រូវតាមវិន័យ ) បានឈ្មោះថា **អកុប្បកម្ម** (ជាកម្មមិនកម្រើក ប្រកបដោយហេតុ ទើបការធ្វើនោះសម្រេច ត្រឹមត្រូវ និងទទួលផលបាន ។ ព្រះពុទ្ធអង្គហាមផ្តាច់មិនឱ្យធ្វើជា :

- **អធម្មវគ្គ** : កម្មជាពួក មិនប្រកបដោយធមិ
- **ធម្មវគ្គ** : កម្មជាពួក ប្រកបដោយធមិ
- **អធម្មសមគ្គ** : កម្មព្រមព្រៀងគ្នាដែរ តែមិនប្រកបដោយ ធមិកម្មទាំង៣នេះ ទ្រង់ហាមមិនឱ្យធ្វើព្រោះជាកុប្បកម្ម (កម្មកម្រើក មិនប្រកបហេតុ) **ជាអធម្មកម្ម អវិនយកម្ម** ( កម្មមិនត្រូវតាមធមិ មិនតាមវិន័យ ) បើទុកជាខំប្រឹងធ្វើ ក៏ឈ្មោះថាមិនបានធ្វើដែរ ហើយមានទោស ( អាបត្តិ ) ផង ។

ពាក្យថា **កម្មជាពួក** គឺការកសង្ឃមិនគ្រប់ចំនួនក្នុងសង្ឃកម្មនោះ ឬ ភិក្ខុដែលគួរដល់ឆន្ទៈ មិននាំឆន្ទៈមក ។ សូម្បីក្នុងអារាមដែលត្រូវធ្វើសង្ឃកម្មនោះ ៗ មានភិក្ខុដល់ ទៅជាង ២០ ឬ ៣០-៤០ អង្គ តែពេលត្រូវធ្វើសង្ឃកម្មមានភិក្ខុសូម្បីតែមួយរូប មិនព្រមចូលរួមធ្វើ ហើយ

ទាំងមិនឱ្យឆន្ទៈដល់សង្ឃទៀតផង ។ ភិក្ខុសង្ឃនៅសល់ក្រៅពីនេះមានចំនួនលើស កំណត់ការក សង្ឃក្នុងសង្ឃកម្មក៏ដោយ ធ្វើសង្ឃកម្មនេះគឺ ធ្វើមិនបាន បើធ្វើ ហៅថា កម្មជាពួកគឺមិនព្រមព្រៀងគ្នា ។

ពាក្យថា : **មិនប្រកបដោយធម៌** សំដៅយកការធ្វើជា អបលោកនកម្មបែរជាធ្វើដោយតាំងញត្តិ ( ញត្តិកម្ម) កម្មធ្វើត្រឹមញត្តិកម្ម បែរជាធ្វើមានតាំងញត្តិផង មានអនុស្សាវនាផង គឺធ្វើដោយកម្មវាចាពីរ ( ញត្តិទុតិយកម្ម) ឬ ត្រូវធ្វើដោយកម្មវាចាពីរ បែរជាធ្វើដោយកម្មវាចា៤ (ញត្តិចតុត្ថកម្មទៅវិញ) ឬ ក៏តាំងញត្តិក្រោយអនុស្សាវនា គឺសូត្រអនុស្សាវនា មុនតាំងញត្តិ ។ ម្យ៉ាងទៀត ការសូត្រកម្មវាចា ឬការសូត្រញត្តិ ឬក៏ការសូត្រប្រកាស ( អបលោកន៍) អ្នកសូត្រមិនត្រឹមត្រូវតាមអក្ខរប្បភេទ (**សិថិលធានិត គរុលហុ...**។ល។ មិនត្រឹមត្រូវតាមឋានករណៈ ( មើលក្នុងកច្ចាយនូបត្ថម្ភក ភាគ១ផង ) ។ ការដែលភិក្ខុសង្ឃសូត្រសង្ឃកម្មខុស-ភ្លាត់ តាមប្រការណាមួយ ដូចរៀបរាប់ខាងលើនេះឈ្មោះថា **អធម្មកម្ម** កម្មមិនប្រកបដោយធម៌ ។

ពាក្យថា **ប្រកបដោយធម៌** គឺផ្ទុយពីខាងលើ ដោយធ្វើត្រឹមត្រូវតាមកម្មអានត្រឹមត្រូវ។

ពាក្យថា **ពមព្រៀងគ្នា** គឺការកសង្ឃជាភិក្ខុបកតត្ត (ភិក្ខុប្រក្រតីមិនត្រូវ អាបត្តិ) មានគ្រប់ចំនួនក្នុងសង្ឃកម្មនីមួយៗ ឬ ការកសង្ឃ មានចំនួនលើសក៏ដោយ បើ មានភិក្ខុ១រូបណាឈឺ មិនអាចចូលរួមបានក្តី ភិក្ខុជាប់នៅថែទាំគិលានភិក្ខុក្តី ឬ ភិក្ខុមានជាប់រវល់ក្នុងសង្ឃករណីកិច្ចក្តី សុទ្ធតែបាននាំឆន្ទៈមកដល់សង្ឃ ទោះបីភិក្ខុនៅគ្រប់ចំនួនការកសង្ឃក្នុងសង្ឃកម្មនោះ ៗ អាចធ្វើសង្ឃកម្មបាន ហៅថា ព្រមព្រៀងគ្នាទាំងអស់ ។

**សង្ឃករណីយកិច្ច** គឺកិច្ចការទាំងឡាយជារបស់សង្ឃពិតៗ ត្រូវភិក្ខុតំណាងសង្ឃជាអ្នកអនុវត្ត ។ ក្នុងអាវាសនីមួយៗ ក្រៅពីចៅអធិការ និងគ្រូសូត្រឆ្វេងស្តាំ នៅមានការចាត់តាំងភិក្ខុតំណាងសង្ឃ ដែលហៅថា **សង្ឃធ្វើសម្មតិកម្ម** សន្មតភិក្ខុនេះជា **ភត្តុទ្ទេសកៈ** ភិក្ខុនោះជា **សេនាសនប្បញ្ញាបកៈ** " អ្នករៀបចំចាត់ចែងទីសេនាសនៈ ឱ្យភិក្ខុសាមណេរក្នុងវត្ត " ជាដើម ។ ប៉ុន្តែវត្តអារាមខ្លះមិនមានសន្មត **ឧទ្ទេសកភិក្ខុ** ទេ គឺលោកគ្រូចៅអធិការផ្ទាល់ ដែលលោក

បំពេញសង្ឃករណីយកិច្ច តែម្តង ព្រោះបច្ចុប្បន្ន ព្រះសង្ឃ ភិក្ខុ សាមណេរតិចតួចក្នុងអាវាសវត្ត ភាគច្រើន ។

( សូមមើលសៀវភៅ " សង្ឃករណីយកិច្ច " បន្ថែម )

## **កម្មវិបត្តិ**

( សំដៅយកសង្ឃកម្មខុស ឬ ខូចសង្ឃកម្ម )

ដើម្បីធ្វើសង្ឃកម្ម ឱ្យបានត្រឹមត្រូវតាមធម៌វិន័យជាពុទ្ធានុញ្ញាត និង ពុទ្ធប្បញ្ញត្តិ គប្បីស្គាល់ឱ្យច្បាស់ វិបត្តិរបស់សង្ឃកម្មគ្រប់យ៉ាង ។

វិបត្តិសង្ឃកម្មដែលហៅថា កម្មវិបត្តិនោះមាន ៤ យ៉ាងគឺ :

១. **វត្ថុវិបត្តិ** វិបត្តិដោយវត្ថុ គឺខូច ឬ ខុសពី **ពុទ្ធប្បញ្ញត្តិ** ដូចជា បំបួសកុលបុត្រឱ្យជា ភិក្ខុដែលមានអាយុ មិនគ្រប់ ២០ ឆ្នាំជាដើម ។

២. **សីមាវិបត្តិ** វិបត្តិដោយសីមា គឺខូច ឬសីមាខុស បានដល់សីមាវិបត្តិ ១១ យ៉ាងណាមួយ ។

៣. **បរិសវិបត្តិ** វិបត្តិដោយបរិស័ទ គឺប្រជុំសង្ឃមិនគ្រប់អង្គតាមកំណត់ ឬ ភិក្ខុណាមួយក្នុងអាវាសនោះ មិនចូលរួម មិននាំឆន្ទៈ ។

៤. **កម្មវាចាវិបត្តិ** វិបត្តិដោយកម្មវាចា គឺសូត្រភ្លាំងភ្លាត់ខ្វះខាតមិន ត្រូវតាមរបៀប **អក្ខរៈ** គួរតាំងញត្តិ ឬ សូត្រអនុស្សាវនា តែមិនតាំងញត្តិ ឬ មិនសូត្រអនុស្សាវនា។

## ៤០. **ឧបោសថកម្ម**

( សូមមើល យិន វន ប្រជុំបុញ្ញប្រវត្តិ ភ្នំពេញ ឆ្នាំ ១៩៦៧ ទំព័រ ១៧៤)

**ឧបោសថកម្ម** ដែលជា ការងាររបស់ភិក្ខុសង្ឃគ្រប់រូប ត្រូវតែប្រតិបត្តិឧបោសថរាល់ថ្ងៃ ព្រោះជាចំណី ឬ ថ្នាំឱសថកែបំប៉នសីល ជម្រះសីលរបស់ផងភិក្ខុ ឱ្យស្អាតបរិសុទ្ធសមតាម **លោកស្សបុញ្ញក្ខេត្ត** គឺជាស្រែ បុណ្យដ៏ល្អ របស់ទាយកទាយិកាផង បានជាអរិយធន

ផ្ទាល់ព្រះអង្គផង ។ ពិសេសដើម្បីសាមគ្គី ដល់ភិក្ខុសង្ឃ ការពារបាននូវវិវាទាធិករណ៍របស់បព្វជិតក្នុងព្រះពុទ្ធសាសនាផង ។ **ឧបោសថកម្ម** ជា **ញត្តិកម្ម** ។

ឧបោសថកម្មក្នុងឱកាសនេះ សូមលើកតែ សង្ឃុបោសថ គឺឧបោសថដែលធ្វើដោយសង្ឃចតុវគ្គ ( ភិក្ខុ ៤ អង្គឡើងទៅ) ។ មិនបាននិយាយដល់គណុបោសថ ( ឧបោសថធ្វើដោយភិក្ខុ ២ ឬ ៣ អង្គ ) និងអធិដ្ឋានុបោសថ( ឧបោសថដែលធ្វើដោយភិក្ខុតែ ១អង្គ ) នោះទេ ។ **សង្ឃឧបោសថ**ដែលសង្ឃត្រូវធ្វើនោះគឺ ធ្វើឧបោសថ សម្តែងបាតិមោក្ខ ហៅថា **សុត្តុទ្ទេសុបោសថ** ( ឧបោសថដោយសូត្របាតិមោក្ខគ្រប់ឧទ្ទេស) ។

ឧបោសថកម្មនេះ **បកតត្តភិក្ខុ** ត្រូវធ្វើក្នុង១បក្ខម្តង គឺកន្លះខែធ្វើម្តង ហើយធ្វើចំខែពេញបូរមី ( ១៥កើត) និងថ្ងៃខែដាច់ ។ ហេតុនេះ ទើបលោកសម្តែងថា ឧបោសថ បើពោលតាមថ្ងៃត្រូវធ្វើ២យ៉ាងគឺ :

**១-ចាតុទ្ទសិកុបោសថ** ឧបោសថថ្ងៃទី ១៤ ( ថ្ងៃខែដាច់សម្រាប់ខែណាដែលខាងរនោចលោកថា កោរ៣ ខែនោះដាច់ខែថ្ងៃ ១៤ រោច )

**២-បណ្ណរសិកុបោសថ** ឧបោសថថ្ងៃ ១៥ ( បានដល់ថ្ងៃ ១៥ កើត ឬ ១៥ រោជ ) ប៉ុន្តែប្រសិនបើមានអធិករណ៍ដោយភិក្ខុបែកបាក់គ្នា នៅពេលស្រុះស្រួលគ្នាវិញ ទ្រង់អនុញ្ញាតឱ្យធ្វើឧបោសថមួយទៀត ទោះចំថ្ងៃណាដ៏ដោយ ។ ឈ្មោះថា **សាមគ្គីឧបោសថ** ឧបោសថថ្ងៃសាមគ្គីគ្នារបស់ភិក្ខុសង្ឃ ។

## ឧបោសថវិធី

របៀបធ្វើឧបោសថវិធីរបស់សង្ឃ (សម្តែងបាតិមោក្ខ)

ពេលនេះ ខ្ញុំលើកយកតែរបៀបរបបធ្វើឧបោសថ តាមលំដាប់លំដោយតាំងពីថ្ងៃឧបោសថចូលមកដល់ រហូតបានសម្តែងបាតិមោក្ខចប់សព្វគ្រប់តែប៉ុណ្ណោះ ។មិនលើកអំពី **ទោស-ប្បញ្ញត្តិ** (អាបត្តិ) ចំពោះភិក្ខុជាថេរៈ ឬនវភិក្ខុ ដែលមិនអើពើមិនរវល់ មិនខ្វល់ខ្វាយ ឬ ថាមិនចាប់អារម្មណ៍ដល់ថ្ងៃឧបោសថនោះទេ ទាំងមិនលើកឡើងអំពីអានិសង្ស របស់ភិក្ខុ ដែលខ្វល់ខ្វាយចាត់ចែងធ្វើឧបោសថ ឬ ថា មានឆន្ទៈពិត១ ក្នុងការបំពេញឧបោសថកម្ម នោះដែរ ព្រោះថា បើនឹងអធិប្បាយឱ្យសព្វគ្រប់ លើរឿងឧបោសថនេះ អាចធ្វើជាសៀវភៅមួយក្បាល

ដោយឡែកទៀត ទើបចូនល្មម ឬ សមគួរដល់អត្ថន័យទូលំទូលាយបាន ។ កាលបើថ្ងៃឧបោសថមកដល់ហើយ ភិក្ខុត្រូវអនុវត្តកិច្ចការដូចតទៅគឺៈ ដំបូងធ្វើបុព្វករណ៍ ៤ យ៉ាង បើព្រះថេរៈ មិនបានធ្វើត្រូវប្រើភិក្ខុដទៃឱ្យធ្វើ :

១. **សម្មជ្ជនី** : បោសសំអាតឧបោសថាគារ

២. **បទីបោ** : រៀបចំ ចង្កៀង ទៀន ភ្លើង ទុកក្រែងធ្វើពេលយប់

៣. **ឧទកំ** : រៀបចំទឹក សម្រាប់ឆាន់និង ប្រើប្រាស់ទុកឱ្យហើយ ។

៤. **អាសនេន** : រៀបចំក្រាលអាសនៈសម្រាប់សង្ឃ និង ធម្មាសនៈសម្រាប់អ្នកសម្តែងបាតិមោក្ខ ។ កិច្ចការ ៤ យ៉ាងនេះ ភិក្ខុត្រូវធ្វើទុកជាស្រេចមុនពេលភិក្ខុសង្ឃទៅជួបជុំគ្នា ។

ភិក្ខុសង្ឃស្លៀកស្បង់ គ្រងចីពរ ដាក់សង្ឃាដីក្រវាត់វត្តពន្ធ ឱ្យជាបរិមណ្ឌលនិមន្តចូលទៅជួបជុំគ្នា ក្នុងរោងឧបោសថ ។ ជួបជុំហើយ ត្រូវសម្តែងអាបត្តិគ្រប់អង្គ ។

ភិក្ខុថេរៈនាំភិក្ខុសង្ឃ នមស្ការព្រះរតនត្រៃ( ត្រៃបណាមគាថា) ជាសង្ខេប ។ នមស្ការចប់ហើយ ភិក្ខុសង្ឃបែរមកប្រជុំគ្នា ធ្វើបុព្វកិច្ច ៥ មុនពេលសម្តែងបាតិមោក្ខ គឺពិភាក្សាគ្នាជាមុនអំពី :

- ឆន្ទៈ និងបារិសុទ្ធ ដែលភិក្ខុអង្គណាត្រូវនាំមកក៏ប្រតិបត្តិចំពោះសង្ឃចុះបើមាន ។
- ឧតុក្ខានំ ការពិភាក្សាអំពីរដូវកាល ពេលនេះមានឧបោសថកន្លងទៅប៉ុន្មានហើយនៅសល់ប៉ុន្មាន ? ។
- ឱវាទោ បញ្ជាក់ថា បច្ចុប្បន្នគ្មានភិក្ខុនី ដើម្បីឱ្យឱវាទទេ ។ កាលបើចប់កិច្ចពិភាក្សាបុព្វកិច្ចហើយ គប្បីកំណត់ភិក្ខុពីរអង្គ សម្រាប់សួរឆ្លើយវិន័យ ។ ដោយភិក្ខុអ្នកឆ្លើយ ត្រូវបានភិក្ខុអ្នកសួរ អារាធនាឱ្យសម្តែងបាតិមោក្ខតែម្តងក្នុងពេលចុងបញ្ចប់សំនួរចម្លើយនោះ ។ បន្តពីធ្វើបុព្វកិច្ចហើយ ភិក្ខុសង្ឃត្រូវគង់ឱ្យជាប់ហត្ថបាសគ្រប់អង្គ ព័ទ្ធជុំវិញគ្រែ ធម្មាសនៈ ហើយភិក្ខុអង្គុយច្រហោងផ្គងអញ្ជលីរកគ្នា ផ្តើម **នមោ** ៣បទ ដោយភិក្ខុអ្នកសួរ សន្មតខ្លួនជាអ្នកសួរវិន័យ រួចភិក្ខុអ្នកឆ្លើយផ្តើម **នមោ** បីបទ ហើយសន្មតខ្លួនជាអ្នកឆ្លើយវិន័យ ។ **សម្មតិកម្ម** (ការសន្មត) នេះជា **ញត្តិកម្ម** ។ សន្មតរួចហើយ ចាប់បន្ត សួរ-ឆ្លើយ ជាបាលិសុទ្ធ អំពី

បុព្វករណ៍ ៤ បុព្វកិច្ច ៥ និង អពិ **មត្តកល្ល ខ្ញទោសថ** តទៅ រហូតចប់ ។ ចុងក្រោយភិក្ខុអ្នកសួរ អារាធនាភិក្ខុអ្នកឆ្លើយ ដើម្បីឱ្យជាអ្នកសម្តែងបាតិមោក្ខតទៅ ។ ( កិច្ចវិន័យ សន្មតខ្លួន សួរឆ្លើយវិន័យជាដើម នេះមាននៅក្នុងសៀវភៅ ភិក្ខុបាតិមោក្ខ បាលីប្រែរបស់ព្រះភិក្ខុធម្មារាមោ ប៊ុណ្ណ សម្ភាជន៍ ) ។

ពេលនោះភិក្ខុអ្នកត្រូវសម្តែងបាតិមោក្ខ ត្រូវថ្វាយបង្គំព្រះពុទ្ធបដិមា និងថ្វាយបង្គំព្រះមហាថេរនៅក្នុងទីចំពោះមុខនោះ (បើមាន) ហើយឡើងគង់លើធម្មាសនៈ ដែលរៀបចំទុកស្រេចជាប់ហត្ថបាសនឹងភិក្ខុសង្ឃ ហើយចាប់ផ្តើមសូត្របាតិមោក្ខ ដែលមានក្នុងសៀវភៅបាតិមោក្ខ តាំងពីដើមដល់ចប់ ។

កិច្ចឧបោសថកម្ម ឈ្មោះថា ចប់ ឬ សម្រេចជាស្ថាពរ នៅពេលសម្តែងបាតិមោក្ខចប់ដោយបរិបូរណ៍ ។

កំណត់: ១.តាំងពីបុរម្យបុរាណមក នៅស្រុកខ្មែរយើងមានប្រពៃណីធ្វើបុណ្យច្រើនបែបច្រើនយ៉ាងណាស់ បុណ្យព្រះពុទ្ធសាសនា បុណ្យសំយោគព្រះពុទ្ធសាសនា ព្រហ្មញ្ញសាសនា សាសនាម្ចាស់ស្រុក ទៅតាមទំនៀមរាស្ត្រ តាមតំបន់ស្រុកទេស ផ្សេងៗគ្នា ។ ព្រោះអ្វី ? ព្រោះខ្មែរក៏ជាមនុស្ស ១ ត្រូវការសេចក្តីសុខ សេចក្តីសុខកើតឡើងដោយសារចិត្តបុណ្យ ( សន្តិភាព ផ្លូវចិត្ត ) ។

២.យើងអាចកត់សម្គាល់ថា ខ្មែរចូលចិត្តធ្វើបុណ្យណាស់ ពាក្យទំនៀមខ្មែរពោលថា " ខ្វះអ្វីខ្វះចុះ កុំឱ្យតែខ្វះអរិយទ្រព្យ គឺបុណ្យ " អរិយទ្រព្យ៧ ប្រការគឺ ស. សី. ហិ. ឱ សុ. ចា. ប. អរិយទ្រព្យ ៧ ប្រការ គឺសទ្ធា សេចក្តីជឿកម្ម និង ផលនៃកម្មក្នុងព្រះពុទ្ធសាសនា ១ សីល៥ សីល៨ សីល១០ សីល២២៧ ដ៏បរិសុទ្ធ ១ អៀនខ្មាសអំពើអាក្រក់ ១ សេចក្តីភ័យខ្លាច បាប ១ កិរិយាត្រាប់ត្រង់នូវធម៌១ សេចក្តី បរិច្ចាទាន ឬលះបង់ចោលនូវអំពើអាក្រក់ ១ បញ្ញាជាសម្មាទិដ្ឋិ១ ធម៌៧ ប្រការនេះ មាននៅលើបុថុជ្ជនណា បុថុជ្ជននោះឯងហៅថា កល្យាណបុថុជ្ជន គឺរាប់ថាជាអ្នកប្រាជ្ញ បាន [1] ។

---

[1] សុត្តន្តប្រីជា **៥៦** គតិលោក ភាគទី២ ពុទ្ធសាសនបណ្ឌិត្យ ព.ស ២៥៣៩ ទំព័រ ៦៤

ម្យ៉ាងវិញទៀត ការគោរព ការជឿព្រះសម្មាសម្ពុទ្ធនៃយើងព្រះអង្គបានទូន្មាន នៅក្នុងកាលាមសូត្រ ជាពុទ្ធភាសិត ១០ ប្រការ ។ ប្រការនិមួយៗ សុទ្ធតែផ្តល់តម្លៃទៅលើខ្លួនឯង គឺៈ

១.កុំជឿដោយបានឮតៗ គ្នាមក

២.កុំជឿតាមល្បីល្បាញ

៣.កុំជឿ តាមដំណឹងដែលចេញពីមាត់មួយទៅមាត់មួយ

៤.កុំជឿ ដោយផ្អែកអាងទៅលើតម្រាក្បួនខ្នាត

៥.កុំជឿ ដោយគួសដោយកខ្លួនឯង

៦.កុំជឿ ដោយគ្មាន់គ្នេគិតប៉ានស្មាន

៧.កុំជឿ ដោយត្រិះរិះដោយគយគន់តាមអាការៈប្រហាក់ប្រហែល

៨.កុំជឿ ដោយសំអាងថាស្របគំនិត ឬ សមតាមគំហើញរបស់ខ្លួន

៩.កុំជឿ ដោយអាងឬ ឃើញថាអ្នកឱ្យជឿបាន

១០.កុំជឿ ដោយរាប់អានថាអ្នកនេះ ជាគ្រូរបស់ខ្លួន។

ពុទ្ធឱវាទនេះ បស្ទឹមជនគេមានការចាប់អារម្មណ៍ ច្រើនហើយគេប្រកាន់យកជាគំនិតស្រាវជ្រាវ រកសេចក្តីពិតដែលគេយល់ថា ត្រូវតាមគោលការណ៍នៃវិទ្យាសាស្ត្រយ៉ាងច្បាស់លាស់ផង ។

៣.យើងអាចកត់ត្រាបានថា ការធ្វើបុណ្យរបស់ខ្មែរ ច្រើននិយមធ្វើតៗគ្នា តាមទម្លាប់គ្រួសារ វង្សត្រកូល តំបន់ ភូមិស្រុករបស់គេ ដោយគេពុំសូវបានគិតដល់ខ្លឹមសារ និងតម្រូវតាមស្ថានភាពសង្គមទេ ។

៤.បុណ្យខ្លះមានឈ្មោះដូចគ្នា ខ្លឹមសារដូចគ្នា ប៉ុន្តែទម្រង់នៃការធ្វើផ្សេងគ្នា (ខុសទីកន្លែង អ្នកមាន អ្នកក្រ) ។

៥.បើតាម យោបល់របស់ព្រះរាជ **តាន់** ដែលជាមេដឹកនាំដ៏ល្អម្នាក់ និងមានចិត្តសប្បុរស នៅសម័យសន្តិវង្សស៊ីន នាសម័យចិនបុរាណ ដែលបានគ្រប់គ្រងនយោ

ចាយប្រទេសបានល្អ ។ ព្រះរាជា **តាន់** បានផ្លាក់ពាក្យនៅលើថាសថា "បើថ្ងៃនៅ តែរះនិងលិច កិច្ចការអ្វីក៏ត្រូវតែថ្មី ដូច្នេះយើងក៏ផ្លាស់ប្តូរថ្មីដែរ "[២]។

តាំងពីជាង២៥០០ មុនមកព្រះពុទ្ធទ្រង់បានពន្យល់ណែនាំថា" អ្វីៗ សុទ្ធតែមានការផ្លាស់ប្តូរទាំងអស់ ព្រះអាទិត្យ ក៏តែងតែថ្មីរាល់ថ្ងៃដែរ ព្រះអាទិត្យរះថ្ងៃនេះ និងព្រះអាទិត្យម្សិលមិញមិនដូចគ្នាទេ "[៣]។

ការបកស្រាយខាងលើនេះ បណ្ឌិតនិងអ្នកប្រាជ្ញទាំងអស់នៃសម័យបុរាណទាំងលោកខាងលិច និងអ៊ឺរ៉ុប ខាងកើត តែងមានការផ្លាស់ប្តូរ ដើម្បីឱ្យមានការជឿនលឿនរាល់ថ្ងៃ ។

នៅសម័យរីកចម្រើន អភិវឌ្ឍយ៉ាងឆាប់រហ័សដូចបច្ចុប្បន្ននេះ គេមិនអាចទទួលយកនូវមេដឹកនាំណា ដែលមានគំនិតបុរាណសុទ្ធសាធទេ ។ ព្រះពុទ្ធ ព្រះអង្គមានជំនឿថា " សត្វរាល់រូបត្រូវប្រព្រឹត្តក្នុងគន្លងបែបណា ដែលវាមិនបណ្តាលឱ្យកើតអំពើអាក្រក់ផ្ទាល់ខ្លួន ឬអ្នកដទៃផងឡើយ ។

ចក្កវត្តិសីហនាទសូត្រ បានបំភ្លឺថា "ការត្រិបត្តិដែលល្អប្រសើរនោះ មានបីយ៉ាងគឺ ទាន សីល និង ភាវនា ដែលជាកត្តាសំខាន់បំផុត សម្រាប់មនុស្សគ្រប់រូប ធ្វើឱ្យជីវិតរស់នៅរបស់ខ្លួនមានតម្លៃ [៤]។

ប្រសិន បើគេប្រព្រឹត្តសប្បុរសធម៌ ប្រកបដោយវិចារណញ្ញាណ គេបង្កើតបាននូវសេចក្តីស្រឡាញ់រាប់អាន និងសមភាព (បុណ្យ) ហើយគេក្លាយជាមនុស្សចិត្តទូលាយអាចចែកអ្វីដែលគេមានតាមការគួរដល់អ្នកដទៃ ។ គោលការណ៍ទាំងឡាយនេះ នឹងជួយយើងឱ្យផ្តល់វិភាគទានមួយចំណែកធំដល់ការកសាងសង្គមមួយស្អាតស្អំ និងរីកចម្រើនទាំងសំភារៈទាំងខាងផ្លូវចិត្ត ។ ប្រសិនបើយើងព្យាយាមដឹកនាំ ជីវភាពបែបនេះ យើងនឹងបានក្លាយជាអ្នកប្រតិបត្តិតាមមាគ៌ាពិតរបស់ព្រះពុទ្ធដែលអាចនាំឱ្យយើងសម្រេច

---

[២] [៣] ម៉ាស៊ីស៊ីតា សូណូសឹកេ ល័ក្ខណៈ មេដឹកនាំ ភ្នំពេញ ២០០១ ទំព័រ ១១៤-១១៥

[៤] ឈន អៀម ពុទ្ធសាសនានិងសង្គម កម្ពុជសុរិយា លេខ២ ១៩៩៥ ទំព័រ ៧-៨

បានសុភមង្គលដ៏ឧត្តុង្គឧត្តម ។ នេះជាហេតុការណ៍ ដ៏មានសារសំខាន់ណាស់ក្នុងការព្យាយាមរក្សាគុណភាពក្នុងសន្តានចិត្តបុគ្គល និងក្នុងពិភពលោក ។

យ៉ាងណាមិញ ដូចជាអត្ថន័យវាក្យស័ព្ទព្រះពុទ្ធសាសនាមួយចំនួន ខាងក្រោមនេះ ៈ

" ធម៌ៈ កម៌ៈ និវ៌ាណៈ មោក្សៈ និរយៈ សង្សារៈ អាត្មា " គឺជាពាក្យមួយចំនួនដែលជាពាក្យរួមសម្រាប់ប្រើក្នុងក្រុមសាសនាទាំងអស់ ក្នុងអម្លុងសម័យកាលរបស់ព្រះអង្គ ព្រះពុទ្ធបាន ផ្តល់អត្ថន័យ និងការបកស្រាយដ៏ពិសេសតែមួយគត់ ហើយប្រកបដោយបិចារណកម្មបំផុត ចំពោះពាក្យសាសនាជាធរមានស្រាប់ហើយទាំងនោះ។

**ធម្មៈ (ធម៌)**

ចូរយើងក្រឡេកមើលពាក្យ ធម៌ៈ ឬ (ធម្មៈ)ជាឧទាហរណ៍ ។ ការបកស្រាយសម័យបុរាណ ផ្តល់ឱ្យដល់ពាក្យធម៌នេះ ដូច្នេះថា ធម៌ជាច្បាប់មួយ ដែលអាទិទេពប្រទានឱ្យ ។ យោងតាមជំនឿបុរាណ អាទិទេពបានសន្យាចុះមកបង្ហាញខ្លួនម្តងម្កាលដើម្បីការពារធម៌នេះ តាមការអវតារមកកើតក្នុងតួអង្គផ្សេងៗ ។ ព្រះពុទ្ធមិនបានទទួលស្គាល់ថា មានអាទិទេពណាមួយអាចផ្តល់លទ្ធិ បទបញ្ញត្តិ និងច្បាប់សាសនាឱ្យទេ ។ ព្រះអង្គបានប្រើពាក្យធម៌ (ធម្ម) សម្រាប់ពណ៌នាពាក្យប្រៀនប្រដៅរបស់ព្រះអង្គទាំងមូល ។ ធម៌ មានន័យថា អ្វីៗ ដែលទ្រទ្រង់ ធ្វើឱ្យឋិតថេរ គាំទ្រ ។ ពួកទស្សនវិទូលោកខាងលិច ពិពណ៌នាពុទ្ធសាសនាថា ជាមាគ៌ានៃជីវិតដ៏ប្រសើរឬថាជា" សាសនាមានសេរីភាព និងវិចារណញ្ញាណ" [៥] ។

ធម៌ មិនមែនជាច្បាប់ដ៏អស្ចារ្យ ដែលនរណាម្នាក់បានបង្កើតឡើង ឬបានផ្តល់ឱ្យនោះទេ ។ តួខ្លួនរបស់យើងផ្ទាល់ គឺជាធម៌ ។ ចិត្តរបស់យើងផ្ទាល់គឺ ធម៌ សកលលោកធាតុទាំងស្រុង គឺធម៌ ។ ដោយការយល់ដឹងនូវធម្មជាតិ (ចរិត) នៃរូបកាយ និងធម្មជាតិនៃចិត្ត ហើយនិងលក្ខខណ្ឌលោកិយ យើងដឹងច្បាស់ ធម៌។ ព្រះពុទ្ធបានបង្រៀនយើងឱ្យស្វែងយល់នូវធម្មជាតិ (ចរិត) នៃជីវិតរបស់យើងប្រកបដោយ ហេតុផលក្នុងបែបបទ

---

[៥] ស្រី ធម្មានន្ទ ប្រែដោយ ឈន អៀម ពុទ្ធសាសនាក្នុងឋានៈជា សាសនាមួយ ភ្នំពេញ ឆ្នាំ ២០០១ ទំព័រ ១៣

ជាកស្តែង។ ជីវិតរបស់យើងទាក់ទងនឹងជីវិតរបស់សត្វលោកនិមួយៗ នៅក្នុងលោកនេះ នាពេលឥឡូវនេះ ហើយដោយហេតុនេះ ជីវិតរបស់យើងមាន អន្តរសម្ព័ន្ធជាមួយជីវិតទាំងអស់ ។ តាមធម្មតា កាលណាគេនិយាយពីសាសនា គេតែងសួរថា " **អ្វីជាសទ្ធារបស់អ្នក** ? " ។ ( What is your faith ? )។ គេបានប្រើពាក្យ " **សទ្ធា** "(faith) ។ ព្រះពុទ្ធមិនបានជាប់ព្រះទ័យក្នុងការអភិវឌ្ឍន៍ " **សទ្ធា** " ក្នុងន័យដាច់ខាតនោះទេ ទោះបី **សទ្ធា** នេះ អាចមានប្រយោជន៍នៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍន៍សាសនារបស់បុគ្គលក៏ដោយ។ គ្រោះថ្នាក់នៃការជឿទុកចិត្តលើសទ្ធាតែម្យ៉ាង ដោយគ្មានចំណេះដឹងវិភាគច្បាស់លាស់ គឺជាគ្រោះថ្នាក់ ដែលអាចនាំយើងឱ្យធ្លាក់ក្នុងជំនឿងប់ងុលក្នុងសាសនា (ទិដ្ឋុម្មាទ) ( Religious fanatics)[៦] ។

ជនទាំងឡាយណាដែលបាន ធ្វើឱ្យ **សទ្ធា** ចាក់ឫសរឹងមាំ នៅក្នុងដួងចិត្តរបស់ខ្លួន ហើយជនទាំងឡាយនោះមិន អាចមើលឃើញទស្សនៈវិស័យរបស់មនុស្សឯទៀតបានទេ ពីព្រោះ គេបានស្ថាបនានៅ ក្នុងដួងចិត្តរបស់គេរួចស្រេចទៅហើយ ថាអ្វីដែលគេជឿ គឺជា សច្ចៈតែមួយគត់ ។ ព្រះពុទ្ធបានគ្រើនរំលឹកជាញឹកញាប់ថា បុគ្គលមិនត្រូវជឿ សូម្បីព្រះធម៌របស់ព្រះអង្គ ផ្ទាល់ក៏ដោយ លើមូលដ្ឋាន **សទ្ធា** តែឯងនោះទេ ។ បុគ្គលត្រូវមានចំណេះដឹង (ពុទ្ធិ) ហើយបន្ទាប់មក ធ្វើឱ្យរីកចម្រើនសេចក្តីយល់ដឹងតាមរយៈការសិក្សា ការពិភាក្សាភាវនា ហើយនៅទីបំផុត តាមរយៈឈាន (ឬបច្ចវេក្ខណៈ) ។ ចំណេះដឹង (ពុទ្ធិ) គឺជារឿងមួយ សេចក្តីយល់ដឹង គឺជារឿងមួយទៀត ។ ប្រសិនបើមានសេចក្តីយល់ដឹង បុគ្គលអាចកែតម្រូវជីវិតរបស់ខ្លួនបាន ឱ្យស្របទៅតាមកាលៈទេសៈកំពុងប្រែប្រួល ដោយផ្អែកលើចំណេះដឹងដែលខ្លួនមាន ។ យើងអាចមានឱកាសជួបមនុស្ស ចេះដឹង ជាពហុស្សូត្រដែលចេះដឹងអ្វីៗច្រើន ប៉ុន្តែ ជាមនុស្សមិនប្រាកដនិយម ពីព្រោះតែអាត្មា និយមរបស់គេ អត្តទត្ថភាពរបស់គេ បដិឃៈរបស់គេ និងគំនុំរបស់គេ មិននាំឱ្យគេចាប់ យកបាននូវឥរិយាបថផ្លូវចិត្ត ឥតលំអៀង និងសេចក្តីក្សេមក្សាន្តក្នុងចិត្តបានទេ។ កាលណាមានករណីចាំបាច់ត្រូវធ្វើសម្បទាន ហើយយើងក៏ត្រូវចេះដឹង

[៦] ដ. ទំព័រ ១៤

ធ្វើសម្បទានផងដែរ ។ កាលណាមានករណីចាំបាច់ ត្រូវសន្ដោស យើងក៏ត្រូវចេះដឹងសន្ដោសអធ្យាស្រ័យផងដែរ។ កាលណាមានករណីត្រូវពង្រឹង ជំហរម៉ឺងម៉ាត់ យើងក៏ត្រូវចេះដឹងពង្រឹងជំហរ ម៉ឺងម៉ាត់ដោយសេចក្ដីថ្លៃថ្នូរ ។

## កម៌ (កម្ម)

ចូរយើងលើកយកឧទាហរណ៍មួយទៀត គឺពាក្យ កម៌ (ឬកម្ម)។ ពាក្យនេះមានន័យយ៉ាងសាមញ្ញថា អំពើ ។ ប្រសិនបើ មនុស្សម្នាក់បានធ្វើកម្មអាក្រក់ សម្រាប់មនុស្សនោះ គេមិនងាយគេចផុតពីផលអាក្រក់របស់អំពើនោះឡើយ ។ ដោយប្រការនេះ ឬប្រការផ្សេង បុរស ឬស្ត្រីនោះ ត្រូវប្រឈមមុខចំពោះផលវិបាកទាំងឡាយ ដែលហូរចេញមកពីអំពើនោះ ។ យោងតាមជំនឿពីព្រេងនាយ គេបានយល់ថា មានទេពតាមួយអង្គចាំបែងចែកកម្មនេះ ។ ទេពតាផ្ដន្ទាទោស យោងតាមអំពើ (កម្ម) អាក្រក់របស់បុគ្គល ទេពតាផ្ដល់រង្វាន់ យោងតាមអំពើ (កម្ម) ល្អរបស់បុគ្គល ។ ព្រះពុទ្ធមិនបានទទួលស្គាល់ជំនឿនេះទេ ។ ព្រះអង្គមានបន្ទូលថា គ្មានតួអង្គអាទិទេព ឬអានុភាពណាមួយ ដែលជាអ្នកចាត់ចែងប្រតិបត្តិការចែកផលនៃកម្មទេ ។ កម្មផ្ទាល់ នឹងផ្ដល់លទ្ធផលក្នុងឋានៈជាប្រតិបត្តិការអព្យាក្រឹតនៃក្រឹត្យក្រម ហេតុ និងផល ។ ព្រះអង្គ បានមានបន្ទូលថា យើងអាចជៀសបាននៅក្នុងករណីខ្លះ រហូតដល់ជំនះលើផលនៃ កម្មបានទៀតផង ប្រសិនបើយើងប្រព្រឹត្តបានល្អ ។ ព្រះអង្គបានទូន្មានថា "យើងមិនត្រូវដាក់ខ្លួនយើងចុះចាញ់ឥទ្ធិពលព្រេងវាសនា ដោយគិតថា កាលណាយើងបានធ្វើអំពើអាក្រក់ហើយ គេគ្មានសេចក្ដីសង្ឃឹមផ្សេងទៀតទេ ។ សាសនាដទៃទៀត ប្រៀនប្រដៅថា ទេពតា ឬ (អាទិទេព) អាចធ្វើឱ្យទៅជាអហោសិកម្មបាននូវផលនៃកម្ម តាមរយៈការលើកលែងទោស ប្រសិនបើអ្នកជឿធ្វើពិធីបូជា បន់ស្រន់ និងថ្វាយពលិការ ។ ប៉ុន្តែព្រះពុទ្ធប្រៀនប្រដៅថា យើងត្រូវធ្វើឱ្យសម្រេចនូវការសង្គ្រោះ ដោយកម្លាំងខិតខំផ្ទាល់របស់យើង និងសំអាតចិត្តឱ្យល្អផូរផង់ "[៧]។

---

[៧] -ដ- ទំព័រ ១៦

"ព្រះពុទ្ធអាចចង្អុលប្រាប់អ្នកនូវអ្វីត្រូវធ្វើ ប៉ុន្តែ ព្រះអង្គមិនធ្វើកិច្ចការនោះជំនួសអ្នកទេ"។ អ្នកត្រូវធ្វើកិច្ចការសង្គ្រោះដោយខ្លួនឯង ។ ព្រះពុទ្ធបានបញ្ជាក់យ៉ាងច្បាស់លាស់ថា គ្មាននរណាអាចធ្វើអ្វីមួយជំនួសអ្នកឯទៀត សម្រាប់ការសង្គ្រោះបានទេ លើកលែងតែការបង្ហាញផ្លូវប៉ុណ្ណោះ ។ ហេតុនោះ យើងមិនត្រូវពឹងពាក់អាទិទេព ឬ (ទេពតា)ហើយក៏ មិនត្រូវពឹងពាក់ព្រះពុទ្ធផងដែរ ។ យើងត្រូវដឹងនូវអ្វីជាគុណសម្បត្តិជាករណីយកិច្ច និងជាការទទួលខុសត្រូវក្នុងឋានៈយើងជាតួអង្គមនុស្សម្នាក់ ។ ព្រះអង្គទូន្មានថា ប្រសិនបើយើង បានប្រព្រឹត្តធ្វើកម្មអកុសលខ្លះៗ យើងមិនគប្បីខ្វះខ្វាយថាមពលដ៏ថ្លៃថ្លា ដោយការខកចិត្ត ឬអស់សង្ឃឹម មិនខិតខំធ្វើសេចក្តីព្យាយាម ដើម្បីកែតម្រូវអំពើនោះឡើយ ។

កិច្ចតម្រូវបំពេញដំបូងបង្អស់ គឺត្រូវប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ បញ្ចប់ការប្រព្រឹត្តអំពើដដែលៗ ដូចជាបាបកម្ម ដោយសេចក្តីយល់ដឹងនូវសេចក្តីអន្តរាយ ដែលបាបកម្មនោះអាចបង្ករឡើយ ។

កិច្ចទីពីរគឺ : ត្រូវបណ្តុះកុសលកម្មឱ្យបានច្រើនឡើងៗ ។

កិច្ចទីបី យើងត្រូវខិតខំ បន្ថយគំនិតអាក្រក់ អត្តទត្តភាព គំនុំគុំគួន ទោសៈច្រណែន ឈ្នានីស និងព្យាបាទ ។ តាមគន្លងនេះ យើងអាចបន្ថយផលអាក្រក់នៃបាបកម្មដែលយើងបានប្រព្រឹត្តកន្លងមក ។ នេះគឺជាវិធីរបស់ព្រះពុទ្ធ សម្រាប់ជំនះផលអាក្រក់ ។ ព្រះអង្គមិនបានមានបន្ទូលប្រាប់ឱ្យយើងត្រូវតែបន់ស្រន់ និងគោរពបូជាព្រះអង្គ ដើម្បីព្រះអង្គ នឹងសណ្តោសទោសទាំងអស់របស់យើងនោះទេ ។

សេចក្តីបរិសុទ្ធនិងសេចក្តីមិនបរិសុទ្ធ នៃចិត្តរបស់យើង អាស្រ័យលើខ្លួនយើងផ្ទាល់ ។ គ្មានអាទិទេព គ្មានព្រះពុទ្ធអង្គ គ្មានតួអង្គមនុស្សណា អាចធ្វើឱ្យសៅហ្មង ឬធ្វើឱ្យបរិសុទ្ធនូវចិត្តរបស់បុគ្គលឡើយ។ ខ្ញុំមិនអាចបង្កើតសេចក្តីសៅហ្មងក្នុងចិត្តរបស់លោកអ្នកបានទេ គឺមិនអាចធ្វើចិត្តរបស់លោកអ្នកឱ្យបរិសុទ្ធបានទេ ។ព្រះពុទ្ធបានប្រៀបប្រដៅថា អ្វីដែលមនុស្សត្រូវការសម្រាប់សេចក្តីសុខរបស់គេ គឺមិនមែនសាសនា ឬគំនរទ្រឹស្តីទេ ប៉ុន្តែ គឺសេចក្តីយល់ដឹងអំពីធម្មជាតិ មាគ៌ាដែលព្រះ ពុទ្ធបានចង្អុលប្រាប់យើង

តាមជំនឿរបស់ខ្ញុំ គឺជាមាគ៌ាតែមួយគត់ដែល មនុស្សជាតិត្រូវ ដើរតាម ប្រសិនបើគេចង់ជៀសផុត ពីមហន្តរាយ[៨]។ Jawaharlal Nehru ។

## និព្វាន (និរ៉ាណា)

ព្រះពុទ្ធមិនធ្លាប់បានប្រកាសថា ព្រះអង្គបានបង្កើតព្រះធម៌សោះឡើយ ។ អ្វីដែលព្រះអង្គបានរកឃើញ គឺជាសច្ចៈសកលនៃធម្មជាតិពិតនៃជីវិត ។ តាមពិតពាក្យសាសនាមួយចំនួន ត្រូវបានគេស្គាល់ច្បាស់លាស់រួចហើយ នៅក្នុងប្រទេសឥណ្ឌានាសម័យនេះ។ ប៉ុន្តែ ភាពគ្មានពីររបស់ព្រះពុទ្ធ គឺព្រះអង្គបានរើសយកទស្សនៈ ឬគំនិតមានស្រាប់ទាំងនោះ មកប្រើ ហើយបានផ្តល់អត្ថន័យដ៏សុខុមបំផុត និងមានអត្ថរសយ៉ាងជ្រាលជ្រៅ ។ ជាឧទាហរណ៍ មុនសម័យកាលព្រះពុទ្ធ ពាក្យ " **និរ៉ាណា** ឬ (និព្វាន ) " មានន័យយ៉ាងសាមញ្ញថា សន្តិភាព ឬ សេចក្តីរលត់ ។ ប៉ុន្តែ ព្រះអង្គបានផ្តល់ឱ្យពាក្យនេះ នូវទំហំនៃអត្ថន័យថ្មីទាំងស្រុង ។ **និ** មានន័យថា " គ្មាន " ហើយ **វាណា** មានន័យថា " ចំណង់ " ឬ " តណ្ហា " គឺៈបានន័យថា គ្មានតណ្ហា គ្មានឧបាទាន (សេចក្តីជាប់ជំពាក់ចិត្ត) និងគ្មានអត្តទត្ថភាព ។ យើងមិនអាចសោយរសជាតិ និរ៉ាណា (និព្វាន) បាន ពីព្រោះយើងនៅមានតណ្ហា ឧបាទាន និងអត្តទត្ថភាព ។ កាលណា យើងអាចរំដោះខ្លួនផុតពីកិលេសទាំងនេះ យើងអាច ពិសោធន៍ ឬ (សោយ) បរមសុខនិព្វានបាន ។ ការពិសោធន៍ ឬការសោយបរមសុខពិត គឺជារឿងពិបាក ពីព្រោះយើងមានចិត្តវេគ ( Emotions ) ហើយយើងអន្ទះសារចង់បានសេចក្តីសោមនស្សតាមផ្លូវវិញ្ញាណ (កាមសុខ)។ ដរាបណា យើងរស់នៅជាប់ជំពាក់ក្នុងពិភពនៃ កាមសុខ យើងនឹងមិនបានពិសោធន៍ ឬ (ទទួលសោយ) សេចក្តីសុខដ៏ពិតឡើយ ។ មែនហើយ វាជារឿងពិតដែលថា យើងពិសោធន៍ ឬ (ទទួលសោយ) សេចក្តីសុខបែបណាមួយនៅក្នុងជីវិត ប៉ុន្តែ

---

[៨] -ដ- ទំព័រ ១៧-១៨

តាមជំនឿរបស់ខ្ញុំ គឺជាមាគ៌ាតែមួយគត់ដែល មនុស្សជាតិត្រូវ ដើរតាម ប្រសិនបើគេចង់ជៀសផុត ពីមហន្តរាយ [៨]។ Jawaharlal Nehru ។

## និព្វាន (និរ៍វាណ)

ព្រះពុទ្ធមិនធ្លាប់បានប្រកាសថា ព្រះអង្គបានបង្កើតព្រះធម៌សោះឡើយ ។ អ្វីដែលព្រះអង្គបានរកឃើញ គឺជាសច្ចៈសកលនៃធម្មជាតិពិតនៃជីវិត ។ តាមពិតពាក្យសាសនាមួយចំនួន ត្រូវបានគេស្គាល់ច្បាស់លាស់រួចហើយ នៅក្នុងប្រទេសឥណ្ឌានាសម័យនេះ។ ប៉ុន្តែ ភាពគ្មានពីររបស់ព្រះពុទ្ធ គឺព្រះអង្គបានរើសយកទស្សនៈ ឬគំនិតមានស្រាប់ទាំងនោះ មកប្រើ ហើយបានផ្តល់អត្ថន័យដ៏សុខុមបំផុត និងមានអត្ថរសយ៉ាងជ្រាលជ្រៅ ។ ជាឧទាហរណ៍ មុនសម័យកាលព្រះពុទ្ធ ពាក្យ " **និរ៍វាណ** ឬ (និព្វាន ) " មានន័យយ៉ាងសាមញ្ញថា សន្តិភាព ឬ សេចក្តីរលត់ ។ ប៉ុន្តែ ព្រះអង្គបានផ្តល់ឱ្យពាក្យនេះ នូវទំហំនៃអត្ថន័យថ្មីទាំងស្រុង ។ **និ** មានន័យថា " គ្មាន " ហើយ **វាណ** មានន័យថា " ចំណង់ " ឬ " តណ្ហា" គឺៈបានន័យថា គ្មានតណ្ហា គ្មានឧបាទាន (សេចក្តីជាប់ជំពាក់ចិត្ត) និងគ្មានអត្តទត្ថភាព ។ យើងមិនអាចសោយរសជាតិ និរ៍វាណ (និព្វាន) បាន ពីព្រោះយើងនៅមានតណ្ហា ឧបាទាន និងអត្តទត្ថភាព ។ កាលណា យើងអាចរំដោះខ្លួនផុតពីកិលេសទាំងនេះ យើងអាច ពិសោធន៍ ឬ (សោយ) បរមសុខនិព្វានបាន ។ ការពិសោធន៍ ឬការសោយបរមសុខពិត គឺជារឿងពិបាក ពីព្រោះយើងមានចិត្តវេគ ( Emotions ) ហើយយើងអន្ទះសារចង់បានសេចក្តីសោមនស្សតាមផ្លូវវិញ្ញាណ (កាមសុខ)។ ដរាបណា យើងរស់នៅជាប់ជំពាក់ក្នុងពិភពនៃ កាមសុខ យើងនឹងមិនបានពិសោធន៍ ឬ (ទទួលសោយ) សេចក្តីសុខដ៏ពិតឡើយ ។ មែនហើយ វាជារឿងពិតដែលថា យើងពិសោធន៍ ឬ (ទទួលសោយ) សេចក្តីសុខបែបណាមួយនៅក្នុងជីវិតប៉ុន្តែសេចក្តីសុខនេះ មិនអាចឱ្យឈ្មោះបានថា ជា "**សេចក្តីសុខ** " ដាច់ខាត នោះទេ ពីព្រោះសេចក្តីសុខនេះ មិនមានចរិតអចិន្ត្រៃយ៍ទេ [៩]។

---

[៨] -ដ- ទំព័រ ១៧-១៨

[៩] -ដ- ទំព័រ ១៨-១៩

## សីលធម៌

សីលធម៌ពុទ្ធសាសនា គឺផ្អែកលើសេរីភាព និងសេចក្តីយល់ដឹង ។ ពីព្រោះសីលធម៌ដុះចេញមកពីសេចក្តីត្រូវការរបស់សង្គម សម្រាប់ភាពគង់វង់ខ្លួនឯង សីលធម៌នេះត្រូវតែសម្របសម្រួលខ្លួនឯងយ៉ាងចាំបាច់ទៅនឹងពេលវេលានិងកាលៈទេសៈដែលកំពុងតែប្រែប្រួល ។`ដោយហេតុដូច្នេះ សីលធម៌ គឺជាសភាវៈប្រៀបធៀប ឬមានលក្ខណៈធៀប (មិនដាច់ខាត់)។ តាមពិត វាពុំ អាចមានសីលធម៌ ឬ ទស្សនៈអភិសមាចារណាមួយទេ ប្រសិនបើសីលធម៌នោះមានទី តាំងនៅក្នុងការដាក់បង្ខំឬអន្តរាគមន៍អំពីភ្នាក់ងារណាមួយ នៅខាងក្រៅបុគ្គលខ្លួនឯងផ្ទាល់។ ប៉ុន្តែបុគ្គលនោះ គប្បីយល់ព្រមដោយសេរីនូវការកំហិតណាមួយ ដែលដាក់បង្ខំមកលើខ្លួនសម្រាប់ឱ្យសីលធម៌អនុវត្តបានប្រសិទ្ធភាពពិតប្រាកដ។សីលធម៌ព្រះពុទ្ធសាសនាមានជម្រៅខ្លាំងណាស់ "សីលវិទ្យាសាកលលោក" ដែលបោះពុម្ព ឆ្នាំ ២០០២ ដោយបណ្ឌិត ខ្លូត ធីតា )។

មេត្តា ( Compassionate Love ) គឺជាគ្រឹះនៃចរិយាសីលធម៌ និងអភិសមាចារទាំងអស់នៅក្នុងពុទ្ធសាសនា ។ ចេញពីមេត្តាធម៌នេះទៅ ទើបកើតមានសិក្ខាបទអភិសមាចារ និង សីលៈ (សីលវិទ្យា) សេវកិច្ចសង្គម យុត្តិធម៌សង្គម សុខុមាលភាពសង្គមទាំងអស់នេះជាអាទិ៍ ។ សមភាព ភាតរភាព សន្ដោស សេចក្តីយោគយល់ ការគោរពចំពោះជីវិត ការគោរពទស្សនៈចំពោះអ្នកដទៃ ការគោរពសាសនាអ្នកដទៃទាំងអស់នេះមានឫសគល់របស់វានៅក្នុងមេត្តា ។ ផ្អែកលើគោលការណ៍ដ៏ប្រសើរខ្ពង់ខ្ពស់នេះ ពុទ្ធសាសនា ត្រូវបានគេចាត់ទុកជាសាសនាសន្តិភាពជានិច្ច ។ ប្រវត្តិដ៏យូរលង់របស់ពុទ្ធសាសនាបាន រួចផុតពីការលាបពណ៌នៃសង្គ្រាមសាសនា ការធ្វើទុក្ខបុកម្នេញសាសនា និងការស្រាវជ្រាវ លុបបំបាត់ជំនឿសាសនាដទៃ ( Religuous persecutions and inquisitions) ។ ពុទ្ធសាសនានៅក្នុងទិដ្ឋភាពនេះ ឈរនៅជាជើងឯកក្នុងប្រវត្តិសាស្ត្រនៃសាសនាទាំងឡាយ [១០] ។

ដោយសារឧទាហរណ៍ដ៏ប្រសើររបស់ព្រះពុទ្ធ នៅក្នុងរឿងនេះ លោក ស្វាមី វិវេក នន្ទ: និយាយនៅក្នុងឧទ្ទេសថា របស់លោកស្តីពី កម៌យោគៈ ថា" ពូជជាតិមនុស្សទាំងមូល ផលិតបានមនុស្សបែបនេះតែមួយគត់ ទស្សនវិជ្ជាដ៏ខ្ពស់បែបនេះតែមួយគត់ សមានចិត្តទូលំទូលាយបែបនេះតែមួយគត់ ។ មហាទស្សនវិទូដែលផ្សព្វផ្សាយទស្សនវិជ្ជាដ៏ខ្ពង់ខ្ពស់បំផុត មានសមានចិត្តដ៏ជ្រាលជ្រៅបំផុត ចំពោះសត្វដ៏ទាបបំផុត ហើយមិន

---

[១០] -ដ- ទំព័រ ៤៣

ដែលទាមទារអ្វីសម្រាប់ខ្លួនលោកសោះឡើយ ។ លោក គឺជាកម្មយោគីគំរូ ធ្វើសកម្មភាពទាំងស្រុងដោយមិនចាំបាច់មានហេតុជំរុញឱ្យធ្វើ ហើយប្រវត្តិសាស្ត្រមនុស្សជាតិបង្ហាញឱ្យឃើញលោកជាមហាបុរសកំពូល មិនធ្លាប់ដែលមាន គ្មានគូប្រៀបជាការផ្សំចូលគ្នាដ៏ចំបងបំផុតនៃហឫទ័យ និងពុទ្ធិដែលមិនធ្លាប់កើតមានសោះឡើយ[១១] ។

ទាក់ទងទៅនឹងក្រមសីលធម៌ និងសង្គម របស់ពុទ្ធសាសនា ទស្សនវិទូអាល្លឺម៉ង់ គឺលោកសាស្ត្រាចារ្យ ម៉ាក្ស មូល្ល័រ (Max Muller) បាននិយាយថា : "ក្រមសីលធម៌ពុទ្ធសាសនា បើពិចារណាដោយដិតដល់ទៅ គឺជាក្រមសីលធម៌មួយដ៏សុក្រឹតបំផុត ដែលពិភពលោកមិនធ្លាប់បានស្គាល់ "[១២] ។

ស្តីពីចំណុចនេះ សក្ខីភាពទាំងអស់ ទាំងមកពីក្រុមសត្រូវ ទាំងមកពីក្រុមមិត្តបានយល់ស្របគ្នា ទាំងទស្សនវិទូ ទាំងឡាយដែលអាចកើតមាន ទាំងអ្នកផ្សព្វផ្សាយសាសនាបរមត្ថវិទូជំនាញៗ វិវាទី (អ្នកចូលចិត្តឈ្លោះ) ទាំងឡាយ ដែលកើតមាន ។ ប៉ុន្តែតើនៅទីណា ទើបយើងនឹងរកឃើញអវតានៃសេចក្តីស្រឡាញ់មួយបែបនេះ ជាសេចក្តីស្រឡាញ់ ដែលគ្មានការបែងចែកវណ្ណៈ និងជំនឿសាសនា ឬពណ៌សម្បុរស្បែក ជាសេចក្តីស្រឡាញ់ ដែលហូរហៀរហួសព្រំដែនមនុស្សជាតិ ហើយឱបក្រសោបរហូតដល់ពពួកសត្វមានជីវិតទាំងអស់ នៅក្នុងរលោកហូរហៀរទៅរបស់ខ្លួនជាសេចក្តីស្រឡាញ់ដែលតាងសិក្ខាបទនៃមេត្តា សកល (Universal loving- Kindness ) និងអហិង្សា ។

លោក អាល់ប៊ែរ ស្វេតហ្សេ ( Albert Schweitger ) និយាយថា" នៅក្នុងវិស័យនេះព្រះពុទ្ធបានធ្វើសេចក្តីប្រកាសអំពីសច្ចភាពដែលមានតម្លៃស្ថិតស្ថេរចិរកាល ហើយបានផ្សាយចេញទៅនូវអភិសមាចារ មិនមែនជារបស់ប្រទេសឥណ្ឌាម្នាក់ឯងទេ ប៉ុន្តែជារបស់មនុស្សជាតិ ។ ព្រះពុទ្ធ គឺជាបុគ្គលមួយរូប ក្នុងចំណោមមនុស្សមានទេពកោសល្យប្រកបដោយអភិសមាចារដ៏ខ្ពង់ខ្ពស់បំផុត ដែលបានកើតឡើងក្នុងលោក "[១៣] ។

វែងឆ្ងាយជាងនេះទៅទៀត លោកសាស្ត្រាចារ្យ រីស ដាវិទ ( Rhys David ) បានធ្វើការសង្កេតថា ការសិក្សាពុទ្ធសាសនា គួរត្រូវបានចាត់ទុកជាផ្នែកមួយចាំបាច់នៃ

---

[១១] -ដ- ទំព័រ ៤៣-៤៤ [១២] -ដ- ទំព័រ ៤៤ [១៣] -ដ- ទំព័រ ៤៥

មុខវិជ្ជាអភិសមាចារ ហើយមិនគួរត្រូវបានគេបោះបង់ចោលឱ្យនៅត្រឹមតែមួយ ឬពីរទំព័រ ប៉ុន្តែ គេត្រូវទទួលស្គាល់អភិសមាចារនេះឱ្យបានត្រឹមត្រូវ នៅក្នុងទិដ្ឋភាពប្រវត្តិសាស្ត្រនៃការវិវត្តន៍អភិសមាចារ[១៤] ។

## សន្និដ្ឋាន

ដើម្បីជំនះបញ្ហានេះបាន អ្នកដឹកនាំជាពុទ្ធសាសនិក (ព្រះសង្ឃ និងគ្រហស្ថ) ត្រូវប្រើវិធីសម័យថ្មី ដែលពួកគេមាន ដើម្បីបញ្ចូលព្រះធម៌ ។ ការទេសនា ឬការនិយាយស្តី ត្រូវបង្កើនការទាក់ទាញចិត្តឱ្យខ្លាំង ហើយទាក់ទងនឹងសេចក្តីត្រូវការសម័យថ្មី ។ សង្ខេបមក ព្រះធម៌ គឺ អកាលិកធម៌ (ធម៌គ្មានកាលកំណត់) គ្រាន់តែបែបបទដែលយើងពន្យល់ធម៌ ត្រូវធ្វើឱ្យបានស្របស្រួលទៅនឹងរល្បឿននៃការប្រែប្រួលក្នុងសង្គមប៉ុណ្ណោះ ។ ព្រះពុទ្ធអង្គផ្ទាល់ទ្រង់បានសម្រួលការប្រតិបត្តិពីបុរាណជាច្រើន ឱ្យសមស្របទៅនឹងមនុស្សនាសម័យកាលរបស់ព្រះអង្គ ហើយព្រះអង្គក៏បានបញ្ជាក់យ៉ាងច្បាស់ផងដែរថា សិក្ខាបទបន្ទាប់បន្សំខ្លះ អាចនឹងកែប្រែបានដើម្បីឱ្យសមស្របទៅនឹងការប្រែប្រួលនៃពេលវេលា" ។ ព្រោះហេតុនោះ យើងត្រូវប្រើបច្ចេកវិជ្ជាសម័យថ្មីជាពិសេស ប្រព័ន្ធផ្សព្វផ្សាយពត៌មានអេឡិចត្រូនិច ដើម្បីផ្សព្វផ្សាយព្រះធម៌ឱ្យមានប្រសិទ្ធភាព និងកាន់តែសម្រេចផលបានល្អ ។ តាមគន្លងនេះ យើងអាចផ្សាយទៅដល់មនុស្សជាច្រើន ហើយទប់ស្កាត់ការឃោសនាមួលបង្កាច់ដ៏ច្រើនលើសលប់ ដែលកំពុងតែផ្សព្វផ្សាយទៅ ដោយសាសនាទាំងដទៃ ។ ភិក្ខុសង្ឃ ជាពិសេស ត្រូវរៀនប្រើប្រព័ន្ធផ្សាយពត៌មាននេះ ហើយត្រូវចំណាយពេល និងពលកម្មរបស់ខ្លួន អនុវត្តភារកិច្ចដ៏ឧត្តុងឧត្តមនៃការផ្សព្វផ្សាយព្រះសារដ៏វិសេស ដែលបានបន្ទុកបណ្តាក់មកលើខ្លួនដោយព្រះបរមគ្រូ ក្នុងបែបបទដែលសមស្របទៅនឹងយុគសម័យថ្មី ។ ជនជាគ្រហស្ថត្រូវធ្វើការជិតស្និទ្ធជាមួយភិក្ខុសង្ឃ ដើម្បីឧបត្ថមលោកក្នុងការងារនេះ ។ ប្រសិនបើយើងមានបំណងបញ្ចូលព្រះធម៌ឱ្យបានជោគជ័យ យើងត្រូវបង្វឹកវាគ្មិនដ៏ពូកែ និងមានឥទ្ធិពល ជាពិសេស ក្នុងចំណោមព្រះសង្ឃដែលមានក្រហត្ថនៅពីក្រោយ នេះរួមបញ្ចូលទាំងប្រព័ន្ធហ្វឹកហ្វឺនគ្រូប្រដៅសាសនាដ៏ល្អប្រសើរផង ។ ភិក្ខុទាំងឡាយ ត្រូវជាបុគ្គលមានលក្ខណសម្បត្តិល្អផ្តាច់គេក្នុងចរិយាផ្ទាល់ខ្លួន ក៏ដូចជា ភាពវៃឆ្លាតក្នុងការបកស្រាយ និងផ្សព្វផ្សាយព្រះធម៌ដល់សវនជនសម័យថ្មី ។ លោកទាំងនោះត្រូវមានចំណេះដឹងអំពីសេវកិច្ចចំពោះសង្គមផងដែរ ។ ព្រះសង្ឃមិនអាចពួនសំងំនៅក្រោមជញ្ជាំងវិហាររបស់ព្រះអង្គហើយធ្វើមិនដឹងមិនឮនូវបញ្ហាប្រឈមដ៏ធំធេង កំពុងមានវត្តមាននៅក្នុងពិភពលោកខាងក្រៅឡើយ ។ លោក

---

[១៤] -ដ- ទំព័រ ៤៥

ត្រូវប្រើសេចក្ដីព្យាយាម ថាមពល ញាណសត្តិ និងបញ្ញារបស់ខ្លួន ដើម្បីបម្រើមនុស្សជាតិក្នុងបែបបទដែលអាចធ្វើបាន ។ យើងត្រូវបញ្ឈប់ថ្កោលទោសលើភាពផ្សេងៗគ្នារបស់យើងក្នុងទ្រង់ទ្រាយនៃពុទ្ធសាសនា ដែលយើងប្រតិបត្តិ ស្ដីពីថាតើពិធីគោរពបូជា ធ្វើបានត្រឹមត្រូវ ឬមិនត្រឹមត្រូវ ។ ជាការប្រសើរ យើងត្រូវរួបរួមគ្នានៅពីក្រោយព្រះធម៌ហើយធ្វើការសម្រាប់សុខុមាលភាពមនុស្សគ្រប់រូប ទាំងខាងផ្លូវកាយ ទាំងខាងផ្លូវចិត្ត ។

ពុទ្ធសាសនា គឺជាស្នូលនៃជីវភាពរស់នៅរាល់ថ្ងៃរបស់យើង ។ ពុទ្ធសាសនា អាចដឹកនាំមនុស្សជាតិ-ជាក្រហស្ថក៏ដូចជា បព្វជិត ឱ្យផ្ដល់វិភាគទានដ៏ប្រសើររបស់យើង ដើម្បីបំពេញនាទីរៀងខ្លួននៅក្នុងសង្គមរបស់ពួកគេ ។ បើមនុស្សម្នាក់ៗយល់ដឹងថាតើបុរស ឬស្ត្រីនោះៗ អាចផ្ដល់វិភាគទានដ៏ប្រសើរយ៉ាងណាខ្លះ ដល់សុខុមាលភាពនៃពិភពលោក នោះជីវិតរស់នៅនឹងមានអត្ថន័យពេញលេញ ។ នេះមិនមែនជាការគិតគូរចង់បានដ៏សាមញ្ញទេ ។ ដោយអាងហេតុផលចំពោះការសង្ស័យថា ព្រះធម៌របស់ព្រះពុទ្ធអាចត្រូវបានគេសិក្សាយល់ដឹងនិងប្រតិបត្តិតាម ដើម្បីធ្វើឱ្យសតវត្សទី២១ ជាយុគដ៏សុក្រឹត ជាយុគនៃចិន្តាមនុស្ស បានឬទេ ។ ប៉ុន្តែនិយាយបែបនេះ មិនមែនមិនគាំទ្រវត្តអារាម បុណ្យទាននោះគេទេគាន់តែប្រតិបត្តិទាំងឡាយត្រូវបន្ថែមគំនិតឱ្យកាន់តែប្រសើរ ច្បាស់លាស់មិនធ្វើទាំងងងឹតងងល់ ។

# ឧបសម្ព័ន

## អ្នកប្រាជ្ញក្នុងពុទ្ធសាសនាពីឆ្នាំ ១០០ ដល់ឆ្នាំ ៧០០

ឆ្នាំ ១០០ — អស្វឃោស–វសុមិត្រទី ១

នាគាជុន – អារ្យទេវ

ឆ្នាំ២០០ ដល់ ៣០០ —

ធម៌ត្រាត

វសុពន្ធុ – អសង្គ – សំឃភទ្រ – ហរិវ៌្មន (២៨០.៣៦០)

ឆ្នាំ៥០០

សារមតិ– ពុទ្ធសិម្ហ–វិមលមិត្រ (៣៦០–៤០០)

ឆ្នាំ ៥០០ — ទិង្នាគ–វសុមិត្រ ទី ២

ធម៌បាល (៥១០–៥៩៥) ស្ថិរមតិ (៥២០–៥៦០) គុណមតិ (៥២០ – ៥៦០)

ឆ្នាំ ៦០០

សីលភទ្រ (៥២៧–៦៣៥) ជយសេន (៥៣៣–៥៣៥) – ប្រាជ្ញគុប្ត វសុមិត្រ ទី ៣

ភទ្ររុចិ – ភាវវិវេក (តាំងពីឆ្នាំ ៥៥០ មក)

ឆ្នាំ ៧០០ — ចន្ទ្រគោមិន៍ (ឆ្នាំ ៦២៥ ដល់ ៦៧៣)

ចន្ទ្រកីរ្តិ

# ឯកសារពិគ្រោះ


| | | | |
|---|---|---|---|
| ១.**ខ្លូត ធីតា** | មូលដ្ឋានគ្រឹះ នៃសីលវិទ្យាសាកលលោក | | ឆ្នាំ២០០២ |
| ២.**ខៀវ ជុំ** | សកលចិន្តា | ភ្នំពេញ | ព.ស២៥១៦ |
| ៣.**ចាន់ ពិន** | ប្រជុំពិធីបុណ្យ | ភ្នំពេញ | ឆ្នាំ១៩៦៤ |
| ៤.**ធីង ផាន់សុផុន** | ព្រះសមណគោតម ភាគទី ១ ទី២ | អាមេរិក | ឆ្នាំ១៩៩៥ |
| ៥.**ជួន ណាត** | ១-ទស្សនាវដ្តីពន្លឺពុទ្ធចក្រទី ៦ | ភ្នំពេញ | ឆ្នាំ១៩៦២ |
| | ២-ពុទ្ធិកសិក្សា | ភ្នំពេញ | ឆ្នាំ១៩៥៩ |
| ៦.**ឈុន អៀម** | ពុទ្ធសាសនា ក្នុងឋានៈសាសនាមួយ | ពុទ្ធសាសនបណ្ឌិត្យ | |
| ៧.**ញ៉ុក ថែម** | ពន្លឺអាស៊ីទ្វីប | ពុទ្ធសាសនបណ្ឌិត្យ | ឆ្នាំ១៩៦៧ |
| ៨. **ញាណ តឿន** | និង ម៉ម ឆៃ លំអានទំនៀមខ្មែរបុរាណ | ពុទ្ធសាសនបណ្ឌិត្យ | ឆ្នាំ២០០២ |
| ៩. **តាក ស៊ុនអ៊ី** | ទស្សនាវដ្តីប្រជាជន ឆ្នាំទី២ លេខ ១៩ ខែធ្នូ | ភ្នំពេញ | ឆ្នាំ២០០២ |
| ១០.**ត្រឹង ងា** | វប្បធម៌ អរិយធម៌ខ្មែរ | ភ្នំពេញ | ឆ្នាំ.......... |
| ១១.**តូច ឈួន** | សម័យលោកម្ចាស់ | បាត់ដំបង | ឆ្នាំ១៩៩៤ |
| ១២.**ឃ៉ីង ខាត់** | មហាវណ្ណកម្ម | ភ្នំពេញ | ឆ្នាំ១៩៧០ |
| ១៣.**ប៉ែន សារឿន** | សាសនាប្រៀបធៀប | ភ្នំពេញ | ឆ្នាំ១៩៦៩ |
| ១៤.**ប៊ុត សាវង្ស** | សិក្ខាបទមនុស្សល្អ | អន្លង់វិល | ព.ស២៥៥៤ |
| ១៥.**ពុទ្ធសាសនា** | ២៥០០ ពុទ្ធសាសនបណ្ឌិត្យ | ព្រៃវែង | ព.ស២៥៤៤ |
| ១៦.**ពេជ្រ សល់** | ពិធីប្រចាំដប់ពីរខែ | ពុទ្ធសាសនបណ្ឌិត្យ | ឆ្នាំ១៩៦៦ |
| ១៧.**យិន ទន** | ប្រជុំបុណ្យប្រពៃណី | ព្រៃវែង | ឆ្នាំ១៩៦៧ |
| ១៨.**លីឆាម តេង** | ជីវតាក្ខាន់ | ភ្នំពេញ | ឆ្នាំ១៩៧៣ |
| ១៩.**ម៉ា ស៊ីស៊ីតា** | ខូណូស៊ីកោ លក្ខណ្ឌមេដឹកនាំ | ភ្នំពេញ | ឆ្នាំ២០០១ |
| ២០.**សុត្តន្តប្រីជាឥន្ទ** | គតិលោក ភាគ២ | ពុទ្ធសាសនបណ្ឌិត្យ | ឆ្នាំ១៩៦៥ |
| ២១.**ហួត តាត** | កល្យាណមិត្ត | ពុទ្ធសាសនបណ្ឌិត្យ | ឆ្នាំ១៩៧៣ |
| ២២.**ហួត រេចសួ** | អត្ថាធិប្បាយទស្សនវិជ្ជា | ភ្នំពេញ | ឆ្នាំ១៩៧៣ |
| ២៣.**អ៊ុម ស៊ុម** | បំភ្លឺបុណ្យ | ភ្នំពេញ | ឆ្នាំ១៩៩០ |



## វណ្ណកម្ម

១៩៩៥ : ទស្សនៈអហិង្សារបស់ព្រះពុទ្ធសាសនា និងសិទ្ធិមនុស្ស

១៩៩៦ : អហិង្សាព្រះពុទ្ធសាសនា និងលទ្ធិប្រជាធិបតេយ្យ

១៩៩៦ : ព្រះពុទ្ធសាសនា និងការអភិវឌ្ឍសង្គមខ្មែរ

១៩៩៦-២០០១ : ទស្សនាវដ្ដីអក្សរសាស្ត្រ មនុស្សសាស្ត្រ "ព្រះពុទ្ធសាសនានៅកម្ពុជា"

១៩៩៧-១៩៩៨ : ពុទ្ធសាសនា និងជីវិតខ្មែរ

១៩៩៨-១៩៩៩ : ព្រះពុទ្ធសាសនា និងសង្គមខ្មែរ

១៩៩៩ : គួរយល់ដឹងជំនឿសាសនាលើសកលលោក

១៩៩៩ : ទិដ្ឋភាពទូទៅនៃគំនិតខ្មែរ

២០០០ : ព្រះសាមណគោតម

២០០០ : បកប្រែ ១០០សំណួរ ១០០ចម្លើយ ព្រះពុទ្ធសាសនានៅប្រទេសចិន

២០០០ : របូតបច្ចុប្បន្ន ទស្សនាវដ្ដីកម្ពុជសុរិយា (ស្មារតីខ្មែរ និងព្រះពុទ្ធសាសនា)

២០០២ : រៀបចំសិក្ខាសាលាស្ដីពី " ស្ថានភាពសាសនានៅកម្ពុជា បច្ចុប្បន្ន"

២០០២ : បោះពុម្ពសៀវភៅ" មូលដ្ឋានគ្រឹះនៃសីលវិទ្យាសកលលោក"

ធ្នូ / ២០០២ : បោះពុម្ពភាគទី១ "ការស្វែងយល់អំពីរបត់ព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរ"

២០០៣ : បោះពុម្ពភាគទី២ "ការស្វែងយល់អំពីរបត់ព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរ"

២០០៣ : ត្រៀមបោះពុម្ពលើកទី " មូលដ្ឋានគ្រឹះនៃសីលវិទ្យាសកលលោក "

- ភារកិច្ចបច្ចុប្បន្ន អនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម
- សមាជិកពេញសិទ្ធិនៃរាជបណ្ឌិតសភាកម្ពុជា
- សាស្ត្រាចារ្យទស្សនវិជ្ជានៃរាជបណ្ឌិតសភាកម្ពុជា

  *បង្រៀនបន្ថែមនៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

  *សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និង សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា

បណ្ឌិត ខួត ធីតា

គោលបំណងនៃសៀវភៅនេះរួមចំណែកផ្ដល់ឱ្យពុទ្ធសាសនិកម្ដុជានូវ មូលដ្ឋានពុទ្ធ ទ្រឹស្ដី និងការប្រតិបត្តិស្ដីអំពីបញ្ហាព្រះពុទ្ធសាសនា កាន់តែប្រសើរឡើង ។

១. លើកស្ទួយព្រះធម៌របស់ព្រះពុទ្ធ
២. ពង្រឹងឯកភាព ក្នុងចំណោមអ្នកដឹកនាំនិកាយព្រះពុទ្ធសាសនាទាំងអស់
៣. ធ្វើឱ្យប្រាកដនូវសាមគ្គីភាព និងភាតរភាពក្នុងចំណោមពុទ្ធសាសនិកជនទាំងឡាយ
៤. ផ្ដល់មូលនិធិជាអំណោយ និងរង្វាន់ សម្រាប់លើកស្ទួយពុទ្ធសាសនា
៥. ជ្រោងខ្ពស់សេរីភាព និងសន្តិភាពសម្រាប់មនុស្សទាំងអស់តាមរយៈពុទ្ធធម៌
៦. ជ្រោងខ្ពស់គុណសម្បត្តិមនុស្សនិង គោរព ករណីយកិច្ចមនុស្ស ។

បច្ចុប្បន្ននេះប្រទេសទាំងឡាយដែលមានប្រជាជន ជាពុទ្ធសាសនិកច្រើនរួមមាន : កម្ពុជា ៩៥% មីយ៉ាន់ម៉ារ ៩៥% ស្រីលង្កា ៧០% តៃវ៉ាន់ ៦០% ជប៉ុន ៦៥ % ថៃឡង់ ៩៥%

រោងពុម្ព វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ